ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

( គ.ជ.ប )

# បទបញ្ជា និងនីតិវិធី

## សម្រាប់

# ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខៈ ៥២១ គ.ជ.ប.ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យប្រើបទបញ្ជា និងនីតិវិធី
## សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៧ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១០ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៥៨១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជំនួសប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់ /.



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីមែល : info@nec.gov.kh

- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៤៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្តីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងការអនុម័តរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យប្រើជាផ្លូវការនូវបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (ប.ន.ព.ស) ដែលមាន ១០ ជំពូក ១៥៧ ប្រការ និងឧបសម្ព័ន្ធទាំង៨ សម្រាប់អនុវត្តក្នុងការរៀបចំការចាត់ចែង និងការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តាមការកំណត់នៃច្បាប់។

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ថ្ងៃអង្គារ ១១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៣

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ប្រាជ្ញ ចន្ទ

# មាតិកា


**ជំពូកទី១ បទប្បញ្ញត្តិទូទៅ.................................................................................១**

**ជំពូកទី២ ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា.....................................៤**

- សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត......................................................................................៤
- ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត......................................................................................៦
- សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប ..........................................៦
- លក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប ..........................................................៧
- សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ...............................................................៧
- បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំងសមាសភាព គ.ក.ប/គ.ក.រ ..........................................................................................៩
- បែបបទ និងនីតិវិធីនៃការជ្រើសរើសសមាសភាព គធ.ខប និងសមាសភាព គ.ក.ប/គ.ក.រ ..............................................................................................................១២
- ប្រាក់កម្រៃរបស់មន្ត្រីបោះឆ្នោត........................................................................................១២
- អាណត្តិរបស់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ............ ១២
- ការតែងតាំងក្នុងរយៈពេលមានកំណត់ ..................................................................................១៣
- គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខាររបស់ គ.ជ.ប...............................................១៣
- ប្រតិទិនសម្រាប់ការបោះឆ្នោត .......................................................................................... ១៤
- ការងារសន្តិសុខបោះឆ្នោត ................................................................................................ ១៤
- ការអនុវត្តវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់នានា ............២០

**ជំពូកទី៣ ចំនួនសមាជិកព្រឹទ្ធសភា ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ ..................................................................................... ២១**

- ចំនួនសមាជិកព្រឹទ្ធសភា......................................................................................................២១
- ប្រព័ន្ធបោះឆ្នោត ...............................................................................................................២១
- មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ.................................................................២២

**ជំពូកទី៤ អ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីបោះឆ្នោត និងការិយាល័យបោះឆ្នោត..២៣**

- អ្នកបោះឆ្នោត និងអង្គបោះឆ្នោត ....................................................................................... ២៣
- លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត........................................................................... ២៤

- ការិយាល័យចុះឈ្មោះបោះឆ្នោត ..... ២៤
- សង្ខេបដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ..... ២៥
- រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ..... ២៥
- ការទទួលខុសត្រូវរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា និង កបយ.ស ក្នុងការចុះឈ្មោះបោះឆ្នោត ..... ២៧
- សម្ភារ ឯកសារសម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការចុះឈ្មោះបោះឆ្នោត ..... ២៩
- ការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការបញ្ជូនបញ្ជីឈ្មោះតាមអង្គបោះឆ្នោតមក គ.ជ.ប ..... ២៩
- ការប្រគល់ និងការទទួលបញ្ជីឈ្មោះតាមអង្គបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតដំបូង ដោយប្រព័ន្ធកុំព្យូទ័រនៅ គ.ជ.ប ..... ៣៨
- ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ..... ៤០
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ..... ៤២
- គោលការណ៍ទូទៅ ..... ៤២
    - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប ..... ៤៤
        ការដាក់ ការទទួលពាក្យបណ្ដឹងនៅ គធ.ខប ..... ៤៤
        ការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប ..... ៤៥
    - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ..... ៤៧
        ការដាក់ ការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប ..... ៤៧
        ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប ..... ៤៨
    - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ..... ៥០
        ការដាក់ ការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ..... ៥០
        ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ..... ៥០
- ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ខប ឬសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប ឬសេចក្ដីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ..... ៥០
    - ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ខប ..... ៥០
    - ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប ..... ៥១
    - ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ..... ៥១

- លក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា................................ ៥៤
- ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត............................................ ៥៥
- ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ............................................ ៥៦
- ទីតាំងរដ្ឋបាល និងសន្តិសុខសម្រាប់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត...............................................................................................................៥៧
- វិធានការការពារសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់............................................... ៥៨
- វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ.......................................................................................................... ៦១

**ជំពូកទី៥ ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ................................................................................ ៦២**

- ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន ....................................................................... ៦២
- ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន ......................................................................៦៣
- ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស ........................................................................៦៣
- ការប្រកាសបេក្ខភាពបេក្ខជនគណបក្សនយោបាយ .................................................. ៦៤
- ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ......... ៦៥
- លក្ខខណ្ឌ និងបែបបទក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ................................................................................... ៦៥
- ការដាក់ឱ្យប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ.......................................................................៦៧
- ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ .........................................................................................៦៧
- ការពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ..... ៦៨
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ............... ៦៩
  - ការដាក់ ការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ........................................... ៦៩
  - ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ..............................................៧០
- ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ........................................................................................៧០
- សិទ្ធិទទួលបាននូវការការពារសុវត្ថិភាពរបស់បេក្ខជន..............................................៧០

- ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត ........................................................................................ ៧១

**ជំពូកទី៦ ការឃោសនាបោះឆ្នោត ........................................................................................ ៧៤**

- គោលការណ៍នៃការឃោសនាបោះឆ្នោត ........................................................................................ ៧៤
- សម្ភារអប់រំអ្នកបោះឆ្នោត ........................................................................................ ៨៦
- រូបភាព និងសម្ភារឃោសនាបោះឆ្នោត ........................................................................................ ៨៩
- កិច្ចសហការ និងភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និង គ.ជ.ប ............. ៩៦

**ជំពូកទី៧ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន .៩៧**

- ភ្នាក់ងារគណបក្សនយោបាយ........................................................................................ ៩៧
  - សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ........................................................ ១០៣
  - បម្រាមចំពោះគណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយ ................ ១០៤
- អ្នកសង្កេតការណ៍បោះឆ្នោត........................................................................................ ១០៩
- អ្នកសង្កេតការណ៍ជាតិ ........................................................................................ ១០៩
- អ្នកសង្កេតការណ៍អន្តរជាតិ........................................................................................ ១១៣
- សិទ្ធិរបស់អ្នកសង្កេតការណ៍ ........................................................................................ ១១៤
- ភារកិច្ចរបស់អ្នកសង្កេតការណ៍ ........................................................................................ ១១៥
- បម្រាមចំពោះអ្នកសង្កេតការណ៍ ........................................................................................ ១១៦
- អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ........................................................................................ ១១៨

**ជំពូកទី៨ ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ........................................................................................ ១២២**

- ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ........................................... ១២២
- ការផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតចាំបាច់សម្រាប់ការបោះឆ្នោត .១២៣
- ការទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ ................................................. ១២៤
- ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត . ១៣៣
- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត..១៣៨
- ការប្រព្រឹត្តទៅនៃការបោះឆ្នោត........................................................................................ ១៣៩
- ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត ........................... ១៥៩

- ការបិទការិយាល័យបោះឆ្នោត ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន....................១៦៣
- ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬ/និងត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន....................១៦៦
- ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត....................១៦៨
- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ....................១៨០
- ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ....................១៨៣
- កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការស្កែន និងបញ្ជូនរូបភាពកំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតទៅ គ.ជ.ប សម្រាប់ផ្សាយជាលទ្ធផលបឋមនៃការបោះឆ្នោត....................១៨៦
- ការបញ្ជូនស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ លគធ.ខប....................១៨៧
- ការរាប់សន្លឹកឆ្នោតនៅ លគធ.ខប ឬទីតាំងសុវត្ថិភាពណាមួយ....................១៨៩
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទៅ គធ.ខប....................១៩៣
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីនៅ ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត ទៅ គធ.ខប....................១៩៨
- ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត....................២០០
- កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត....................២០៣
  - ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់....................២១៤
- ការពិនិត្យ និងចុះហត្ថលេខាលើលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត....................២១៧
- ការវេចខ្ចប់ និងបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាល់សម្ភារ ឯកសារបោះឆ្នោត ទៅ គ.ជ.ប....................២២០
- ការដាក់ពាក្យបណ្តឹងតវ៉ានឹងការសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប....................២២៤

- ការបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិបម្រើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនីមួយៗ ........ ២២៦
- ការប្រគល់ និងការទទួលកញ្ចប់ “ឃ ពិសេស” និងស្បោង “ឃ ព្យួរលទ្ធផល” ឬ/និងស្បោង “ឃ” ឬ/និងស្បោង (“ឃ” មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព “ក”) និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្តីការ គ.ជ.ប ........ ២៣៣
- កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ........ ២៣៨
- ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើននៃរាជធានី ខេត្ត ចំណុះភូមិភាគ ដែល គធ.ខប បានសម្រេចព្យួរជាបណ្តោះអាសន្ន ........ ២៤០
- ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំណុះភូមិភាគ ដែលគ្មានពាក្យបណ្តឹងតវ៉ាត្រូវបានដាក់នៅ គធ.ខប ឬ/និង គ.ជ.ប ........ ២៤៧
- ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំណុះភូមិភាគ ដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ឬ/និង គ.ជ.ប ហើយដែលមានកញ្ចប់សុវត្ថិភាព “ក” មួយ ឬច្រើនត្រូវបានបើក ........ ២៤៩
- ការទាញទិន្នន័យ និងការផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគក្នុងប្រព័ន្ធកុំព្យូទ័រ និងការកំណត់បែងចែកអាសនៈតាមភូមិភាគនីមួយៗ ........ ២៥៥
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតទៅ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ ........ ២៥៧
    - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ........ ២៥៨
        ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប ........ ២៥៨
        ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ........ ២៥៩
    - ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ........ ២៦០
        ការដាក់ ការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ........ ២៦០
        ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ........ ២៦០

**ជំពូកទី៩ សមត្ថកិច្ចដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត ........ ២៦៣**

**ផ្នែកទី១ សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង ......................... ២៦៣**
- សមត្ថកិច្ចដោះស្រាយពាក្យបណ្តឹងក្នុងការបោះឆ្នោត ......................... ២៦៣
- សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ......................... ២៦៣
- ការប្តឹងតវ៉ា ឬការប្តឹងជំទាស់......................... ២៦៥
- ការដកពាក្យបណ្តឹង ......................... ២៦៦
- ការរួមបញ្ចូលរឿងក្តី ......................... ២៦៧
- សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ......................... ២៦៧
- សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី......................... ២៦៩
- នីតិវិធីប្រជុំផ្សះផ្សា ឬនីតិវិធីសវនាការ......................... ២៦៩
  - ប្រភេទសវនាការ......................... ២៧០
  - ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬសវនាការ ......................... ២៧០
  - ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ......................... ២៧១
  - ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ......................... ២៧២
  - ពេលវេលាដោះស្រាយពាក្យបណ្តឹង......................... ២៧៣
  - ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការ ......................... ២៧៣
    - ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ខប ......................... ២៧៣
    - ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប......................... ២៧៤
  - ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬសវនាការ ......................... ២៧៤
  - ការប្រកាសសេចក្តីសម្រេច......................... ២៧៥
  - ការបំពេញ និងប្រើប្រាស់ទម្រង់សម្រង់សេចក្តីសម្រេច (ទ.១២០៣)......................... ២៧៥
  - ការបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣)......................... ២៧៦
  - ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ឬសវនាការ......................... ២៧៧

**ផ្នែកទី២ នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ព.ស ......................... ២៧៨**

- ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ..២៧៨
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ........................២៧៨
ការដាក់ ការទទួលពាក្យបណ្តឹងនៅ គធ.ខប ..................................................២៧៨
ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ......................................................២៨០
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប.......................... ២៨២
ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប ................................................. ២៨២
ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប.........................................................២៨៤
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ..........២៨៦
ការដាក់ ការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ....................................២៨៦
ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ .........................................២៨៦
- ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត ............................................ ២៨៦
**ជំពូកទី១០ ការបាត់បង់អាសនៈនៃព្រឹទ្ធសភា និងការជ្រើសតាំងសមាជិកជំនួស**...២៩១
- ការបាត់បង់អាសនៈបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតផ្លូវការរួចហើយ........... ២៩១
- ការជ្រើសតាំងជំនួស ..................................................................................... ២៩៤
**ឧបសម្ព័ន្ធ**
១- ការបែងចែកអាសនៈ.......................................................................................២៩៥
២- ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត ................................................................ ៣១៦
៣- ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្ស
នយោបាយ ក្នុងដំណើរការបោះឆ្នោត ................................................................. ៣៣២
៤- ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត .......... ៣៤៩
៥- ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត............... ៣៦០
៦- ក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និង
ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដំណើរការបោះឆ្នោត ......................................... ៣៦៨
៧- សម្ភារ ឯកសារដែលត្រូវប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការ
បោះឆ្នោតទាំងមូល .......................................................................................... ៣៨១
៨- សម្ភារ ឯកសារដែលត្រូវប្រគល់ជូន គ.ក.ប/គ.ក.រ សម្រាប់ប្រើប្រាស់
ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល.............................................................. ៣៨៣

# អក្សរកាត់

| | | |
|---|---|---|
| ១- | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២- | គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត | គ.ស.អ |
| ៣- | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៤- | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ៥- | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៦- | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៧- | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៨- | ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ៩- | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ព.ស |
| ១០- | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ១១- | ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត | ច.វ.ច.ប |
| ១២- | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា | ប.ន.ព.ស |
| ១៣- | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១៤- | ទម្រង់បែបបទលេខ | ទ. |

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**ប្រការ១.១.-**

អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ច.គ.ជ.ប) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ព.ស) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ត.រ) និងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត (ច.វ.ច.ប) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានសិទ្ធិអំណាច និងភារកិច្ចរៀបចំបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (ប.ន.ព.ស) ដែលកំណត់អំពីការរៀបចំ ការចាត់ចែង ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

**ប្រការ១.២.-**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង ៦ (ប្រាំមួយ) ឆ្នាំម្តង លើកលែងតែក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត។ ក្នុងករណីនេះ ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំតាមសំណើរបស់ព្រះមហាក្សត្រ ហើយការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភាត្រូវសម្រេចដោយមតិយល់ព្រម ២/៣ (ពីរភាគបី) យ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

១.២.១ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើងនៅថ្ងៃអាទិត្យសប្តាហ៍ទី៤ យ៉ាងយូរ មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា។

១.២.២ កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

១.២.៣ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទនៃការបោះឆ្នោតនេះ នៅគ្រប់រាជធានី ខេត្ត។

**ប្រការ១.៣.-**

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាអាចនឹងធ្វើឡើងនៅក្រោយរយៈពេល ៦ (ប្រាំមួយ) ឆ្នាំបាន ប្រសិនបើព្រឹទ្ធសភាត្រូវបានបន្តនីតិកាលរបស់ខ្លួន ដោយមូលហេតុមានសង្គ្រាម ឬកាលៈទេសៈពិសេស ស្របតាមមាត្រា១០២ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ នៅពេលដែលសង្គ្រាម ឬកាលៈទេសៈពិសេសត្រូវបានបញ្ចប់ និងបន្ទាប់ពីកាលបរិច្ឆេទនៃការបោះឆ្នោតត្រូវបានប្រកាសជាផ្លូវការ គ.ជ.ប ត្រូវរៀបចំប្រតិទិនសម្រាប់ការបោះឆ្នោតស្របតាមបទប្បញ្ញត្តិនៃ ច.ប.ព.ស។

**ប្រការ១.៤.-**

នីតិកាលរបស់ព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។

**ប្រការ១.៥.-**

ព្រឹទ្ធសភាមានសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភា ២ (ពីរ) រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកព្រឹទ្ធសភា ២ (ពីរ) រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។ សមាជិកព្រឹទ្ធសភាងទៀត ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។

**ប្រការ១.៦.-**

សមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតជ្រើសតាំងដោយអ្នកបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ទាំងអស់ក្នុងតំណែងនៅក្នុងក្របខណ្ឌនៃភូមិភាគនោះ។

**ប្រការ១.៧.-**

មណ្ឌលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបានរៀបចំតាមភូមិភាគ។ ភូមិភាគនីមួយៗរួមបញ្ចូលគ្នានូវរាជធានី ខេត្តមួយ ឬច្រើន។ មណ្ឌលបោះឆ្នោតនីមួយៗត្រូវមានសមាជិកព្រឹទ្ធសភាស្មើនឹងចំនួនអាសនៈក្នុងភូមិភាគនោះ។

**ប្រការ១.៨.-**

ភូមិភាគ ឬរាជធានី ខេត្តណាដែលមិនអាចដំណើរការរៀបចំបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបាន ដោយសារករណីកាលៈទេសៈពិសេស គ.ជ.ប ត្រូវធ្វើសេចក្តីរាយការណ៍ទូលថ្វាយព្រះមហាក្សត្រ ជូនព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាធម្មនុញ្ញ។

១.៨.១ គ.ជ.ប មានសិទ្ធិសម្រេចមិនបើកការិយាល័យបោះឆ្នោត និងមានសិទ្ធិបិទការិយាល័យបោះឆ្នោតមួយ ឬច្រើននៅទីប្រជុំជនរាជធានី ខេត្តនៃភូមិភាគណាមួយក្នុងកាលៈទេសៈពិសេសដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត។

១.៨.២ គ.ជ.ប ត្រូវរាយការណ៍ជាបន្ទាន់ ទូលថ្វាយព្រះមហាក្សត្រ ជូនព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាធម្មនុញ្ញ អំពីការិយាល័យបោះឆ្នោតនៅទីប្រជុំជនរាជធានី ខេត្តនៃភូមិភាគណាដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបាន ដោយករណីកាលៈទេសៈពិសេស។

**ប្រការ១.៩.-**

កររណីការិយាល័យបោះឆ្នោតនៅទីប្រជុំជនរាជធានី ខេត្តនៃភូមិភាគណាដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតបានដូចមានចែងក្នុងប្រការ ១.៨ ខាងលើនេះ ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះនឹងត្រូវដំណើរការនៅពេលស្ថានការណ៍នៅទីប្រជុំជនរាជធានី ខេត្តនៃភូមិភាគនោះមានភាពប្រក្រតីឡើងវិញ។

**ប្រការ១.១០.-**

ការបោះឆ្នោតសាជាថ្មីត្រូវធ្វើឡើងក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែល គ.ជ.ប ប្រកាសមិនបើកការិយាល័យបោះឆ្នោតណាមួយ ឬបិទការិយាល័យបោះឆ្នោតណាមួយនៅថ្ងៃបោះឆ្នោត ឬបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយនៅទីប្រជុំជនរាជធានី ខេត្តនៃភូមិភាគណាមួយ។

# ជំពូកទី២
# ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

## សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត

### ប្រការ២.១.-

ការរៀបចំ ការចាត់ចែង និងការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺជាសមត្ថកិច្ចរបស់ គ.ជ.ប។

គ.ជ.ប ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួនដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ សមាសភាព គ.ជ.ប និងសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវមានជំហរអព្យាក្រឹត ឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត។

### ប្រការ២.២.-

គ.ជ.ប ត្រូវដាក់ចេញនូវបទបញ្ជា និងនីតិវិធីសម្រាប់ចាត់ចែង រៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុង ច.គ.ជ.ប ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

### ប្រការ២.៣.-

គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

២.៣.១ ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោតដោយសម្ងាត់។

២.៣.២ រៀបចំគម្រោងផែនការការងារ ថវិកា និងសម្ភារ បរិក្ខារបម្រើឱ្យការបោះឆ្នោត និងផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត។

២.៣.៣ តែងតាំងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និងគណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប)។

២.៣.៤ ធ្វើបទបញ្ជា នីតិវិធី និងសេចក្តីណែនាំនានាសម្រាប់ដំណើរការបោះឆ្នោតក្នុងក្របខណ្ឌនៃច្បាប់ជាធរមាន។

២.៣.៥ លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត។

២.៣.៦ ត្រួតពិនិត្យការងាររបស់គណៈកម្មការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

២.៣.៧ កំណត់ព្រំដែនការិយាល័យបោះឆ្នោត។

២.៣.៨ ចេញសេចក្តីសម្រេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត។

២.៣.៩ ផលិត និងបែងចែកសម្ភារ បរិក្ខារបម្រើឱ្យការងារបោះឆ្នោត។

២.៣.១០ លើកសំណើដាក់ជូនស្ថាប័នមានសមត្ថកិច្ចតាមអង្គបោះឆ្នោតនីមួយៗ ដើម្បីផ្ទេរសមត្ថកិច្ចជូនអគ្គលេខាធិការដ្ឋានរដ្ឋសភា និងធ្វើប្រតិភូកម្មអំណាចដល់ កបឃ.ស ទាំងនោះ ឱ្យជួយបំពេញការងារចុះឈ្មោះបោះឆ្នោត ស្របតាម ច.ប.ព.ស និង ប.ន.ព.ស នេះ។

២.៣.១១ រៀបចំបញ្ជីបោះឆ្នោតដំបូង និងបញ្ជីបោះឆ្នោត។

២.៣.១២ ពិនិត្យ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោត។

២.៣.១៣ ទទួល និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

២.៣.១៤ គ្រប់គ្រង និងត្រួតពិនិត្យការប្រព្រឹត្តទៅនៃការឃោសនាបោះឆ្នោត។

២.៣.១៥ រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។

២.៣.១៦ ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ។ ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ។ លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះបោះឆ្នោតឡើងវិញ។

២.៣.១៧ ត្រួតពិនិត្យចំណូល និងចំណាយក្នុងរយៈពេលឃោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ។

២.៣.១៨ ចាត់វិធានការ និងសម្របសម្រួល ដើម្បីឱ្យមានការប្រើប្រាស់ប្រព័ន្ធឃោសនាសាធារណៈតាមគោលការណ៍ស្មើភាព និងសមធម៌។

២.៣.១៩ ផ្តល់ព័ត៌មាន ទិន្នន័យ និងស្ថិតិអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការបោះឆ្នោត។ ធានាឱ្យការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំ អំពីកិច្ចដំណើរការបោះឆ្នោតរវាង គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែលពាក់ព័ន្ធនានា។

២.៣.២០ ផលិតឯកសារផ្សព្វផ្សាយ អំពីការងារបោះឆ្នោត។

២.៣.២១ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត។

២.៣.២២ រៀបចំឯកសារ កម្មវិធី និងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត។

២.៣.២៣ ពិនិត្យ សម្រេច និងចេញបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ។

២.៣.២៤ ត្រួតពិនិត្យ ដើម្បីធានាភាពត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

២.៣.២៥ សម្រេចដោយបើកសវនាការជាសាធារណៈលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត លើកលែងតែពាក្យបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

២.៣.២៦ បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត។

២.៣.២៧ អនុវត្តការងារដទៃទៀតតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

**ប្រការ២.៤.-**

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គ.ជ.ប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

## ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត

**ប្រការ២.៥.-**

អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គ.ជ.ប អាចចេញសេចក្តីសម្រេចប្រគល់សិទ្ធិរបស់ខ្លួនដល់ គធ.ខប គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) និងមន្ត្រី ឬភ្នាក់ងារបម្រើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត។

## សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប

**ប្រការ២.៦.-**

គធ.ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្ត ដែលត្រូវតែងតាំងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោត។ សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ព.ស នេះ។

## លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គជ.ខប

### ប្រការ២.៧.-

បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គជ.ខប ត្រូវអនុវត្តតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

២.៧.១ សមាសភាព គជ.ខប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និង មន្ត្រីរាជការក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត លើកលែងតែ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និង ជនដែលត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

២.៧.២ សមាសភាព គជ.ខប ត្រូវបានជ្រើសរើសដោយអនុលោមតាមបែបបទ និង នីតិវិធីនៃការជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិកដូចបាន កំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

## សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ

### ប្រការ២.៨.-

សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ ត្រូវអនុវត្តតាម ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុង របស់ គ.ជ.ប និង ប.ន.ព.ស នេះ។

២.៨.១ គ.ក.ប/គ.ក.រ ត្រូវមានសមាសភាព ៦ (ប្រាំមួយ) រូប ដែលរួមមាន ប្រធាន ១ (មួយ) រូប អនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងសមាជិក ៣ (បី) រូប។ ភារកិច្ច និងការទទួលខុសត្រូវរបស់សមាសភាព គ.ក.ប/គ.ក.រ ត្រូវបានកំណត់ដូចខាងក្រោម៖

២.៨.១.១ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចទទួលខុសត្រូវរួមក្នុងការ គ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់ សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់ សន្លឹកឆ្នោត។

២.៨.១.២ អនុប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចជាជំនួយការរបស់ ប្រធាន គ.ក.ប/គ.ក.រ ទទួលខុសត្រូវក្នុងការផ្តល់សន្លឹកឆ្នោត ជូនអ្នកបោះឆ្នោតនៅពេលបោះឆ្នោត និងកត់ត្រាសំឡេងឆ្នោត នៅពេលរាប់សន្លឹកឆ្នោត។

២.៨.១.៣ លេខាធិការ មានភារកិច្ចទទួលខុសត្រូវក្នុងការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត និងការបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

២.៨.១.៤ សមាជិកទី១មានភារកិច្ចទទួលខុសត្រូវពិនិត្យការស៊កសន្លឹកឆ្នោតទៅក្នុងហិបឆ្នោត និងជ្រលក់ម្រាមដៃអ្នកបោះឆ្នោតក្នុងទឹកខ្មៅលុបមិនជ្រះ និងទទួលគូសសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត។

២.៨.១.៥ សមាជិកទី២ មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- ជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត
- ចាត់ចែងសណ្តាប់ធ្នាប់ជូនអ្នកបោះឆ្នោត
- ចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើ ដើម្បីធ្វើមោឃភាព
- បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅមុខការិយាល័យបោះឆ្នោត
- បញ្ជូនស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ទៅ គឃ.ខប បន្ទាប់ពីបញ្ចប់ការធ្វើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២)។

២.៨.១.៦ សមាជិកទី៣ មានភារកិច្ចទទួលខុសត្រូវការងារសណ្តាប់ធ្នាប់ របៀបរៀបរយ និងថែរក្សាសម្ភារ ឯកសារបោះឆ្នោតនៅពេលបោះឆ្នោត និងនៅពេលរាប់សន្លឹកឆ្នោត។

២.៨.២ គ.ក.ប/គ.ក.រ ត្រូវអនុវត្តភារកិច្ច និងទទួលខុសត្រូវក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតពាក់ព័ន្ធដូចមានចែងក្នុងប្រការ ៨.៣ រហូតដល់ប្រការ ៨.៥ នៃ ប.ន.ព.ស នេះ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

២.៨.៣ គ.ក.ប/គ.ក.រ ត្រូវទទួលខុសត្រូវចំពោះមុខ គឃ.ខប។

២.៨.៤ គ.ក.ប/គ.ក.រ ទទួលសេចក្តីណែនាំពី គ.ជ.ប តាមរយៈ គឃ.ខប។

## បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំង សមាសភាព គ.ក.ប/គ.ក.រ

**ប្រការ២.៩.-**

បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គ.ក.ប/គ.ក.រ ត្រូវអនុវត្តតាម ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និងតាមសេចក្ដីសម្រេចរបស់ គ.ជ.ប។

២.៩.១ សមាសភាព គ.ក.ប/គ.ក.រ ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

២.៩.២ អ្នកដែលត្រូវបានជ្រើសរើសជាសមាសភាព គ.ក.ប/គ.ក.រ គឺជាបេក្ខជនដាក់ពាក្យសុំចូលបម្រើការងារណាដែលបានទទួលជោគជ័យក្នុងការជ្រើសរើស បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលពេញម៉ោង និងបានចុះហត្ថលេខាលើកិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២) នៅក្រោយពេលវគ្គបណ្ដុះបណ្ដាលត្រូវបានបញ្ចប់។ ក្នុងការជ្រើសរើសនេះ ត្រូវផ្ដល់អាទិភាពចំពោះបេក្ខជនដែលធ្លាប់មានបទពិសោធន៍ក្នុងការងារបោះឆ្នោតពីមុនមក ឬបទពិសោធន៍ការងារពាក់ព័ន្ធនឹងមុខតំណែង។

២.៩.២.១ បេក្ខជនណាដែលត្រូវបានជ្រើសរើសហើយ ប៉ុន្តែមិនបានចូលរួមវគ្គបណ្ដុះបណ្ដាល ត្រូវដាក់ជំនួសជាបន្ទាន់ដោយបេក្ខជនបម្រុង។

២.៩.២.២ ប្រសិនបើគ្មានបេក្ខជនបម្រុងសម្រាប់ជំនួស គធ.ខប ត្រូវចាត់ចែងស្នើសុំ គ.ជ.ប ជ្រើសរើសអ្នកជំនួសជាបន្ទាន់។

២.៩.៣ ដើម្បីទទួលបានការជ្រើសរើស និងបានបម្រើការងារក្នុងលក្ខណៈជាប់កិច្ចសន្យាជាសមាសភាព គ.ក.ប/គ.ក.រ បេក្ខជនដាក់ពាក្យសុំបម្រើការងារត្រូវ៖

២.៩.៣.១ ឆ្លងកាត់ដោយជោគជ័យនូវការជ្រើសរើសដែលគ្រប់គ្រង ពិនិត្យដោយអនុគណៈកម្មការសម្ភាសន៍ជ្រើសរើស។

២.៩.៣.២ គោរពរដ្ឋធម្មនុញ្ញ និងអនុវត្តតាម ច.គ.ជ.ប ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ព.ស នេះ។

២.៩.៣.៣ យល់ព្រមធ្វើសច្ចាប្រណិធានថា ប្រកាន់ជំហរអព្យាក្រឹត និងមិនលម្អៀង។

២.៩.៣.៤ យល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កម្រៃ។

២.៩.៣.៥ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង។

២.៩.៣.៦ ចុះហត្ថលេខាយល់ព្រមលើកិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២)។

២.៩.៤ ទម្រង់បែបបទសម្រាប់បំពេញកិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត(ទ.១០០២) ត្រូវបញ្ជាក់ព័ត៌មានអ្នកដែលត្រូវតែងតាំងដូចខាងក្រោម៖

២.៩.៤.១ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត។

២.៩.៤.២ ឈ្មោះ អាសយដ្ឋាន និងភស្តុតាងបញ្ជាក់ពីភាពមានសិទ្ធិបោះឆ្នោត។

២.៩.៤.៣ មុខតំណែងក្នុង គ.ក.ប/គ.ក.រ។

២.៩.៤.៤ លក្ខខណ្ឌការងារ ភារកិច្ច និងការទទួលខុសត្រូវ។

២.៩.៤.៥ ការសន្យាយល់ព្រមទទួលយកភារកិច្ច លក្ខខណ្ឌការងារ និងប្រាក់កម្រៃ។

២.៩.៤.៦ ការសន្យាថានឹងអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត និងមិនលម្អៀង។

២.៩.៤.៧ ការសន្យាថានឹងអនុវត្តតាម ច.គ.ជ.ប ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និង ប.ន.ព.ស នេះ ព្រមទាំងរាល់សេចក្តីណែនាំរបស់ គ.ជ.ប។

២.៩.៤.៨ ការសន្យាថានឹងគោរពតាមគោលការណ៍នៃការបោះឆ្នោត។

២.៩.៤.៩ ហត្ថលេខារបស់សាមីខ្លួន និងហត្ថលេខារបស់ប្រធាន គឃ.ឌប។

២.៩.៥ សមាសភាព គ.ក.ប/គ.ក.រ ត្រូវតែជ្រើសរើសដោយផ្អែកតាមបែបបទ និងនីតិវិធីនៃការជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិកដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

២.៩.៦ គធ.ខប ត្រូវប្រគល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងជាសមាសភាព គ.ក.ប/គ.ក.រ ទាំងអស់តាមរាជធានី ខេត្តរបស់ខ្លួន ដោយភ្ជាប់ជាមួយនូវកិច្ចសន្យាបម្រើការងារក្នុងគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១០០២) ដែលបានបំពេញ និងចុះហត្ថលេខារួចម្នាក់ៗ ១ (មួយ) ច្បាប់ ដើម្បីស្នើសុំសេចក្ដីសម្រេចតែងតាំងពី គ.ជ.ប។

២.៩.៧ នៅពេលទទួលបានសំណើសុំតែងតាំងដូចមានចែងក្នុងចំណុច ២.៩.៦ ខាងលើនេះ គ.ជ.ប ត្រូវពិនិត្យ និងចេញសេចក្ដីសម្រេចតែងតាំង គ.ក.ប ហើយត្រូវរក្សាទុកឯកសារនៃបញ្ជីឈ្មោះសមាសភាព គ.ក.ប/គ.ក.រ ទាំងនោះជាផ្លូវការ។

២.៩.៨ បន្ទាប់ពីទទួលបានសេចក្ដីសម្រេចរបស់ គ.ជ.ប គធ.ខប ត្រូវបំពេញ និងផ្ដល់បណ្ណសម្គាល់ខ្លួនជូនសមាសភាព គ.ក.ប/គ.ក.រ សម្រាប់ពាក់នៅពេលបំពេញភារកិច្ចក្នុងអាណត្តិការងាររបស់ខ្លួន។

២.៩.៩ សមាសភាព គ.ក.ប/គ.ក.រ ត្រូវស្ថិតនៅក្នុងមុខតំណែង រហូតដល់បញ្ចប់ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងក្រោយពីបានប្រគល់ស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតចប់សព្វគ្រប់ជូន គធ.ខប រួចរាល់ហើយ។ ផ្អែកតាមមុខតំណែងរបស់ខ្លួន សមាសភាព គ.ក.ប/គ.ក.រ ម្នាក់ៗនឹងទទួលបានប្រាក់កម្រៃជាប្រាក់រៀល សម្រាប់ការងាររបស់ខ្លួន ដោយគិតបញ្ចូលទាំងថ្លៃម្ហូបអាហារ និងថ្លៃធ្វើដំណើរផង។

២.៩.៩.១ ចំនួនទឹកប្រាក់ដែលត្រូវបានផ្ដល់ជាកម្រៃសម្រាប់ការបំពេញការងារនៃសមាសភាព គ.ក.ប/គ.ក.រ ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប។

២.៩.៩.២ ក្នុងករណីសមាសភាព គ.ក.ប/គ.ក.រ ណាដែលតម្រូវឱ្យស្ថិតក្នុងមុខតំណែងយូរជាងការកំណត់ដូចមានចែងក្នុងចំណុច ២.៩.៩.១ ខាងលើនេះ មន្ត្រីនោះនឹងត្រូវទទួលបានប្រាក់កម្រៃបន្ថែមតាមសេចក្ដីសម្រេចរបស់ គ.ជ.ប។

២.៩.១០ គធ.ខប ត្រូវអនុវត្តការវាយតម្លៃសមាសភាព គ.ក.ប/គ.ក.រ ទាំងអស់ចំណុះរាជធានី ខេត្ត ក្នុងរយៈពេល ២ (ពីរ) សប្ដាហ៍យ៉ាងយូរ បន្ទាប់ពីថ្ងៃបោះឆ្នោត។

២.៩.១០.១ នៅមុនបញ្ចប់ភារកិច្ចរបស់ខ្លួន គធ.ខប ត្រូវផ្ដល់កំណត់ហេតុវាយតម្លៃសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១១៣) ដែលបានបំពេញរួចហើយទៅ គ.ជ.ប។

២.៩.១០.២ គ.ជ.ប ត្រូវកត់ត្រាបន្ថែមទិន្នន័យនៃកំណត់ហេតុវាយតម្លៃសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១១៣) ទាំងអស់ទៅក្នុងបញ្ជីឈ្មោះនៃសមាជិក គ.ក.ប/គ.ក.រ ដែលត្រូវរក្សាទុក។

**បែបបទ និងនីតិវិធីនៃការជ្រើសរើសសមាសភាព គធ.ខប និងសមាសភាព គ.ក.ប/គ.ក.រ**

**ប្រការ២.១០.-**

បែបបទ និងនីតិវិធីនៃការជ្រើសរើសសមាសភាព គធ.ខប និងសមាសភាព គ.ក.ប/គ.ក.រ ត្រូវឈរលើគោលការណ៍ស្មើភាព ដោយត្រឹមត្រូវ តម្លាភាព អព្យាក្រឹត សមត្ថភាព មិនប្រកាន់និន្នាការនយោបាយ និងការងារពាក់ព័ន្ធ ដែលមានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប និងតាមសេចក្តីសម្រេចរបស់ គ.ជ.ប។ គ.ជ.ប លើកទឹកចិត្ត និងផ្តល់អាទិភាពដល់បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងការងារពាក់ព័ន្ធ។

**ប្រាក់កម្រៃរបស់មន្ត្រីបោះឆ្នោត**

**ប្រការ២.១១.-**

ប្រាក់កម្រៃរបស់សមាជិក និងមន្ត្រី បុគ្គលិកនៃ គ.ជ.ប និងសមាជិក និងមន្ត្រី បុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

២.១១.១ ប្រាក់កម្រៃត្រូវបើកជារៀងរាល់ខែចំពោះអ្នករាជការ គ.ជ.ប និងមន្ត្រី បុគ្គលិកជាប់កិច្ចសន្យា ហើយត្រូវបើកផ្តាច់ចំពោះមន្ត្រី បុគ្គលិកម៉ៅការក្រោយការបញ្ចប់ការងារ។

២.១១.២ ប្រាក់កម្រៃត្រូវបើកជូនជាប្រាក់រៀល បន្ទាប់ពី គ.ជ.ប ទទួលបានប្រាក់ពីអគ្គនាយកដ្ឋានរតនាគារជាតិ។

**អាណត្តិរបស់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់**

**ប្រការ២.១២.-**

អាណត្តិរបស់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់រួមមានៈ

២.១២.១ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់មានសមាសភាព គ.ជ.ប ថ្មីចូលកាន់តំណែង។

២.១២.២ គធ.ខប ត្រូវបំពេញភារកិច្ចរបស់ខ្លួន រហូតដល់ថ្ងៃប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាក្នុងរាជធានី ខេត្តរបស់ខ្លួន។

២.១២.៣ គ.ក.ប/គ.ក.រ ត្រូវបំពេញការងាររបស់ខ្លួន រហូតដល់បញ្ចប់ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត និងក្រោយពីបានប្រគល់ស្បោង "ខ" និងសម្ភារ បរិក្ខារ ឯកសារបោះឆ្នោតចប់សព្វគ្រប់ជូន គធ.ខប រួចរាល់ហើយ។

## ការតែងតាំងក្នុងរយៈពេលមានកំណត់

### ប្រការ២.១៣.-

គ.ជ.ប មានសិទ្ធិតែងតាំង គធ.ខប ឬ គ.ក.ប/គ.ក.រ ក្នុងរយៈពេលមានកំណត់ នៅពេលណាមួយ បន្ទាប់ពីការបោះឆ្នោតជាទូទៅត្រូវបានបញ្ចប់ ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតសាជាថ្មី (ប្រសិនបើមាន)។

២.១៣.១ ក្នុងការតែងតាំងក្នុងរយៈពេលមានកំណត់នេះ បែបបទ និងនីតិវិធីអំពីការជ្រើសរើស រចនាសម្ព័ន្ធ សមាសភាព លក្ខណវិនិច្ឆ័យ សិទ្ធិអំណាច ការទទួលខុសត្រូវ ប្រាក់កម្រៃត្រូវអនុលោមតាម ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប.ន.ព.ស នេះ និងតាមការសម្រេចរបស់ គ.ជ.ប។

២.១៣.២ អាណត្តិរបស់ គធ.ខប និង គ.ក.ប/គ.ក.រ ដែលត្រូវបានតែងតាំងក្នុងរយៈពេលមានកំណត់នេះ ត្រូវបញ្ចប់នៅពេលចប់ភារកិច្ចតាមការកំណត់របស់ គ.ជ.ប។

## គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខាររបស់ គ.ជ.ប

### ប្រការ២.១៤.-

សម្ភារ និងបរិក្ខាររបស់ គ.ជ.ប ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការងាររៀបចំការបោះឆ្នោត លើកលែងតែមានការសម្រេចផ្សេងពីនេះរបស់ គ.ជ.ប។

២.១៤.១ គ្មានសមាជិក និងមន្ត្រី បុគ្គលិកនៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយអាចប្រើប្រាស់សម្ភារ និងបរិក្ខាររបស់ គ.ជ.ប ក្រៅពីការរៀបចំការបោះឆ្នោតឡើយ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ គ.ជ.ប។ ត្រូវបានកំណត់ជាសម្ភារ និងបរិក្ខារ មានជាអាទិ៍រថយន្ត ម៉ូតូ សម្ភារការិយាល័យ សម្ភារចុះឈ្មោះបោះឆ្នោត សម្ភារបោះឆ្នោត និងសម្ភាររាប់សន្លឹកឆ្នោត ឬសម្ភារផ្គត់ផ្គង់ការបោះឆ្នោត និងប្រេងឥន្ធនៈ។

២.១៤.២ ប្រសិនបើសមាជិក ឬបុគ្គលិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយល្មើសនឹងចំណុច ២.១៤.១ ខាងលើនេះ ជននោះនឹងត្រូវដាក់វិន័យ។ វិធានការដាក់វិន័យ គឺគិតចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ។

២.១៤.៣ សមាជិក ឬបុគ្គលិកនៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយដែលល្មើសក្នុងការប្រើប្រាស់សម្ភារ និងបរិក្ខារទាំងនេះ ត្រូវទូទាត់សងតម្លៃទៅតាមការកំណត់របស់ គ.ជ.ប។

២.១៤.៤ ប្រសិនបើសមាជិក ឬបុគ្គលិកណាម្នាក់នៃ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ធ្វើឱ្យសម្ភារ បរិក្ខារបាត់បង់ ឬខូចខាតក្នុងពេលប្រើប្រាស់ខុសច្បាប់បុគ្គលនោះត្រូវទូទាត់សងតម្លៃនៃសម្ភារ បរិក្ខារដែលបានបាត់បង់ ឬខូចខាតនោះ។

២.១៤.៥ គ.ជ.ប ត្រូវចេញផ្សាយបទបញ្ជាជាមូលដ្ឋានសម្រាប់ការប្រើប្រាស់សម្ភារ បរិក្ខារទាំងនោះ។

## ប្រតិទិនសម្រាប់ការបោះឆ្នោត

### ប្រការ២.១៥.-

គ.ជ.ប ត្រូវចាត់ចែងធ្វើ និងផ្សព្វផ្សាយប្រតិទិនសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

២.១៥.១ បន្ទាប់ពីប្រកាសថ្ងៃបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គ.ជ.ប ត្រូវចាត់ចែងធ្វើប្រតិទិនសម្រាប់ការបោះឆ្នោត និងផ្សព្វផ្សាយជាបន្ទាន់។

២.១៥.២ ការផ្សព្វផ្សាយប្រតិទិនការងារបោះឆ្នោត ត្រូវធ្វើឡើងឱ្យបានមុនថ្ងៃចាប់ផ្តើមចុះឈ្មោះបោះឆ្នោត។

២.១៥.៣ ប្រតិទិនការងារបោះឆ្នោតត្រូវកំណត់ជាអាទិ៍៖

- ថ្ងៃចាប់ផ្តើមចុះឈ្មោះអ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន និងថ្ងៃបញ្ចប់
- ថ្ងៃចាប់ផ្តើមចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងថ្ងៃបញ្ចប់
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោត
- ថ្ងៃចាប់ផ្តើមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ និងថ្ងៃបញ្ចប់ការទទួលពាក្យ
- ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត
- ថ្ងៃបោះឆ្នោត និងថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ន និងលទ្ធផលផ្លូវការ
- ថ្ងៃទទួល និងដោះស្រាយពាក្យបណ្តឹងតាមដំណាក់កាលនីមួយៗ។

## ការខារសន្តិសុខបោះឆ្នោត

### ប្រការ២.១៦.-

គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវក្នុងការលើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈក្នុងដំណើរការបោះឆ្នោត ក្នុងនោះត្រូវណែនាំ គជ.ខប និង គ.ក.ប/គ.ក.រ ឱ្យសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចលើកវិធានការការពារ បង្ការ និងដោះស្រាយជាក់ស្តែង តាមពេលវេលា ទីកន្លែង ក្នុងភូមិសាស្ត្រ និងចាត់ចែងឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងធ្វើការផ្សព្វផ្សាយ ក្នុងករណីចាំបាច់។

**ប្រការ២.១៧.-**

ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់ គ.ជ.ប និង គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត តាមសំណើរបស់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

២.១៧.១ ផ្អែកតាមផែនការអន្តរស្ថាប័នលេខ ០១០ ផ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ រវាងក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០២២-២០២៤ នៅថ្នាក់ជាតិត្រូវមានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.អ) ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានតួនាទី ភារកិច្ចត្រូវសហការ និងរៀបចំចាត់វិធានការ ឬសេចក្តីណែនាំផ្សេងៗស្តីពីការការពារសន្តិសុខសុវត្ថិភាពនិងសណ្តាប់ធ្នាប់ និងតាមដាន ត្រួតពិនិត្យ គ្រប់គ្រងការប្រើប្រាស់កម្លាំងនគរបាល កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទ ដែលមានមូលដ្ឋានឈរជើងក្នុងរាជធានី ខេត្ត ឬនៅថ្នាក់ជាតិ ព្រមទាំងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោតផ្អែកតាមចំនួនដែលបានកំណត់ នៅក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានស្រាប់ ត្រូវបានកំណត់ជាគណៈបញ្ជាការសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ហើយគ្រប់យន្តការ-រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតទាំងអស់ ត្រូវអនុវត្តសកម្មភាពរបស់ខ្លួនផ្អែកតាមគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ផែនការអន្តរស្ថាប័នរវាងក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប និងសេចក្តីណែនាំរួមរវាង គ.ស.អ និង គ.ជ.ប ផែនការ និងសេចក្តីណែនាំដោយឡែកស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ការបោះឆ្នោត។

២.១៧.២ លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ដែលត្រូវបង្កើតឡើងតាមសេចក្តីសម្រេចរបស់ គ.ជ.ប ជាជំនួយការផ្នែកការងារសន្តិសុខបោះឆ្នោតឱ្យ គ.ជ.ប មានភារកិច្ចសម្របសម្រួល និងសហការជាមួយលេខាធិការដ្ឋានរបស់ គ.ស.អ ឬ/និងក្រសួង ស្ថាប័ន និងអង្គភាពជំនាញពាក់ព័ន្ធក្នុងការរៀបចំខ្លឹមសារនៃផែនការ ឬសេចក្តីណែនាំផ្សេងៗស្តីពីការការពារសន្តិសុខ សុវត្ថិភាព និង

សណ្ដាប់ធ្នាប់ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ អគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសដែលមាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ជាសេនាធិការឱ្យលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ត្រូវទទួលជួយការងារបច្ចេកទេស និងរដ្ឋបាល។

២.១៧.៣ យន្តការ និងរចនាសម្ព័ន្ធផ្នែកសន្តិសុខរបស់ គ.ជ.ប និង គ.ស.អ។




២.១៧.៤ គ.ជ.ប (លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប) គធ.ខប និង គ.ក.ប/គ.ក.រ ត្រូវសហការតាមឋានានុក្រមនៃរចនាសម្ព័ន្ធចាត់តាំងផ្នែកសន្តិសុខរបស់ គ.ស.អ ដែលរួមមានលេខាធិការដ្ឋានរបស់ គ.ស.អ អភិបាលនៃគណៈអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដូចបានកំណត់បង្ហាញក្នុងចំណុច ២.១៧.៣ ខាងលើនេះ។

២.១៧.៥ ភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ត្រូវស្ថិតក្នុងឯកសណ្ឋានតាមប្រភេទនៃកងកម្លាំងនីមួយៗឱ្យបានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមគោលការណ៍នៃ ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប ប.ន.ព.ស នេះ ផែនការអន្តរស្ថាប័ន និងក្រមសីលធម៌ ព្រមទាំងសេចក្ដីណែនាំផ្សេងៗ។ យន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតត្រូវចាត់ចែងភ្នាក់ងារសន្តិសុខបោះឆ្នោតតាមសំណូមពរ

របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីការពារមុខសញ្ញា ឬគោលដៅសំខាន់ៗដែលត្រូវការពារជារួម ឬការពារដោយប្រយោល ដោយយោងទៅលើលទ្ធភាពនៃការប្រើប្រាស់កម្លាំង មធ្យោបាយ សម្ភារក្នុងការការពារមុខសញ្ញា និងគោលដៅដែលបានកំណត់។ មុខសញ្ញា និងគោលដៅសំខាន់ៗរួមមាន៖

**ក- មុខសញ្ញាការពារជាអាទិភាព**

- សមាជិក គ.ជ.ប មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់របស់ គ.ជ.ប
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងអ្នកគាំទ្រ
- អ្នកមានសិទ្ធិបោះឆ្នោត
- ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោតនៃសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ
- តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬប្រទេសនានា និងតំណាងអង្គការអន្តរជាតិដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប ឱ្យចូលរួមជាអ្នកសង្កេតការណ៍។

**ខ- គោលដៅការពារជាអាទិភាព**

- ទីស្តីការ គ.ជ.ប លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) និងលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប)
- ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ទីតាំងបិទផ្សាយបញ្ជីបោះឆ្នោត បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ
- ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត
- កន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងសង្ហារិមបម្រើការងារបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅគោលដៅមួយ ដែលកំណត់ដោយ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- ទីស្នាក់ការ និងកន្លែងជួបប្រជុំ ឬក្បួនព្យុហយាត្រាឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជន។

២.១៧.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ដែលជាសេនាធិការឱ្យលេខាធិការដ្ឋានសន្តិសុខបោះឆ្នោត នៃ គ.ជ.ប មានភារកិច្ចពិនិត្យរៀបចំគម្រោងផលិតឯកសារ និងសម្ភារទាក់ទងការងារសន្តិសុខបោះឆ្នោតសំខាន់ៗ រួមមានសៀវភៅក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដំណើរការបោះឆ្នោត ខិត្តបណ្ណផ្សព្វផ្សាយផ្សេងៗទាក់ទងការងារសន្តិសុខបោះឆ្នោត និងប្រឡង់ដៃសន្តិសុខបោះឆ្នោត ដើម្បីសុំការសម្រេចពី គ.ជ.ប។

២.១៧.៧ គធ.ខប ត្រូវចាត់ចែងរៀបចំកិច្ចប្រជុំចម្រុះ ក្នុងគោលដៅជួបពិភាក្សាការងារចាត់វិធានការបង្ការ ទប់ស្កាត់ ឬក៏ការស្វែងរកដំណោះស្រាយសមស្រប ដើម្បីបង្ការ និងកាត់បន្ថយបញ្ហាទំនាស់ ឬបាតុភាពនានា ដែលអាចកើតមាននៅគ្រប់ដំណាក់កាលនៃការរៀបចំការបោះឆ្នោត។ គធ.ខប ត្រូវរៀបចំកិច្ចប្រជុំម្តងក្នុងមួយសប្តាហ៍ និងអាចកោះប្រជុំតាមការចាំបាច់។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ រួមមាន៖

- ប្រធាន គធ.ខប — ជាសហប្រធាន
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ឬតំណាង — ជាសហប្រធាន
- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង — ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង — ជាសមាជិក
- មេបញ្ជាការយោធភូមិភាគពិសេស ឬមេបញ្ជាការយោធភូមិភាគទី១ ដល់ទី៥ នៃរាជធានី ខេត្ត ដែលពាក់ព័ន្ធ — ជាសមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត ឬតំណាង — ជាសមាជិក
- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬតំណាង — ជាសមាជិក
- ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត — ជាសមាជិក
- តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត — ជាសមាជិក

- តំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធប្រចាំរាជធានី ខេត្ត ជាសមាជិក
- អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ (ប្រសិនបើមាន) ជាសមាជិក។

២.១៧.៨ នៅពេលឃោសនាបោះឆ្នោត យោធិននៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ឬភ្នាក់ងារសន្តិសុខបោះឆ្នោតដែលកំពុងបំពេញភារកិច្ចមិនត្រូវ៖

២.១៧.៨.១ ឈរក្បែរ ឬដើរកៀកពេកនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតនានា ដោយត្រូវធានាចំពោះគ្រប់គណបក្សនយោបាយឈរឈ្មោះ និងបេក្ខជនគ្រប់រូបនូវសិទ្ធិស្មើៗគ្នាក្នុងការធ្វើសកម្មភាព និងក្នុងការទទួលបានសេវាសន្តិសុខ សុវត្ថិភាព ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយពីអាជ្ញាធរមានសមត្ថកិច្ច។

២.១៧.៨.២ ចូលរួមគាំទ្រ ឬប្រឆាំងចំពោះសកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះណាមួយ ឬបេក្ខជនណាម្នាក់ដាច់ខាត។

២.១៧.៩ នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតមានចំនួនមិនលើសពី ៣ (បី) នាក់ ដែលការពារនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត តែមួយដាច់តែឯងត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងពាក់ប្រឡង់ដៃសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប រហូតដល់ចប់ភារកិច្ច។

២.១៧.១០ ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតច្រើនប្រមូលផ្តុំនៅក្នុងបរិវេណ ឬអគារតែមួយ ចំនួនភ្នាក់ងារសន្តិសុខបោះឆ្នោតសម្រាប់ការិយាល័យនីមួយៗ ត្រូវមានចំនួនសមស្របទៅនឹងស្ថានភាពភូមិសាស្ត្រ និងសន្តិសុខជាក់ស្តែង។

២.១៧.១១ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីចៀសវាងការរំខាន ការអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬក៏ហេតុការណ៍អសន្តិសុខផ្សេងៗ ដែលនឹងអាចកើតមានជាថៃដន្យ។

២.១៧.១២ ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ ឬ/និងក្រុមពន្លត់អគ្គិភ័យ...) អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានតែក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ.ខប ឬពីប្រធាន គ.ក.ប/គ.ក.រ។

## ការអនុវត្តវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់នានា

**ប្រការ២.១៨.-**

ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប្រសិនបើប្រទេសជាតិជួបគ្រោះអាសន្ន ឬស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់នានាត្រូវអនុវត្តដោយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

# ជំពូកទី៣
# ចំនួនសមាជិកព្រឹទ្ធសភា ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ

## ចំនួនសមាជិកព្រឹទ្ធសភា

### ប្រការ៣.១.-

ព្រឹទ្ធសភាមានសមាជិកចំនួន ៦២ (ហុកសិបពីរ) រូប។ សមាជិកព្រឹទ្ធសភា ២ (ពីរ) រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកព្រឹទ្ធសភា ២ (ពីរ) រូប ត្រូវបានជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដោយប្រៀប រីឯសមាជិកព្រឹទ្ធសភា ៥៨ (ហាសិបប្រាំបី) រូបទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ស្របតាមនីតិវិធីដូចមានចែងក្នុង ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប និង ប.ន.ព.ស នេះ។

## ប្រព័ន្ធបោះឆ្នោត

### ប្រការ៣.២.-

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមមណ្ឌលត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដោយកំណត់យកភូមិភាគធ្វើជាមណ្ឌលបោះឆ្នោត។

៣.២.១ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវធ្វើបញ្ជីរាយនាមបេក្ខជនដោយផ្អែកលើមូលដ្ឋានភូមិភាគ។

៣.២.២ សមាជិកព្រឹទ្ធសភាដែលមិនត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ឬជ្រើសតាំងដោយរដ្ឋសភា ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកល មិនចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។

៣.២.៣ សមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតជ្រើសតាំងតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌនៃភូមិភាគ។

៣.២.៣.១ តំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌនៃភូមិភាគត្រូវចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយនៅទីប្រជុំជនរាជធានី ខេត្តតែមួយគត់ចំណុះភូមិភាគ។

៣.២.៣.២ តំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌភូមិភាគដែលជាអ្នកបោះឆ្នោតម្នាក់ៗ មានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជ្រើសរើសឆ្នោតជាសម្ងាត់។

៣.២.៤ ការបែងចែកអាសនៈត្រូវផ្អែកលើលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាតាមភូមិភាគ និងគណនាតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដោយអនុវត្តតាមនីតិវិធីដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ ស្តីពីការបែងចែកអាសនៈ។

## មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ

### ប្រការ៣.៣._

មណ្ឌលបោះឆ្នោតត្រូវបានរៀបចំ និងបែងចែកជា ៨ (ប្រាំបី) ភូមិភាគ។ អាសនៈនៅក្នុងព្រឹទ្ធសភាដែលត្រូវបោះឆ្នោតជ្រើសតាំង ត្រូវកំណត់ត្រឹមចំនួន ៥៨ (ហាសិបប្រាំបី) ដោយបែងចែកតាមភូមិភាគដូចខាងក្រោម៖

៣.៣.១ ភូមិភាគទី១ រាជធានីភ្នំពេញ មាន ៦ (ប្រាំមួយ) អាសនៈ។

៣.៣.២ ភូមិភាគទី២ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ មាន ៨ (ប្រាំបី) អាសនៈ។

៣.៣.៣ ភូមិភាគទី៣ ខេត្តកណ្តាល មាន ៥ (ប្រាំ) អាសនៈ។

៣.៣.៤ ភូមិភាគទី៤ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន មាន ១០ (ដប់) អាសនៈ។

៣.៣.៥ ភូមិភាគទី៥ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប មាន ៧ (ប្រាំពីរ) អាសនៈ។

៣.៣.៦ ភូមិភាគទី៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង មាន ៧ (ប្រាំពីរ) អាសនៈ។

៣.៣.៧ ភូមិភាគទី៧ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ មាន ៩ (ប្រាំបួន) អាសនៈ។

៣.៣.៨ ភូមិភាគទី៨ ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី មាន ៦ (ប្រាំមួយ) អាសនៈ។

# ជំពូកទី៤

# អ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីបោះឆ្នោត និងការិយាល័យបោះឆ្នោត

## អ្នកបោះឆ្នោត និងអង្គបោះឆ្នោត

### ប្រការ៤.១.-

អ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌនៃភូមិភាគនីមួយៗ។ គ.ជ.ប ត្រូវណែនាំដល់អ្នកបោះឆ្នោត អង្គបោះឆ្នោត អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ អំពីបែបបទទាក់ទងនឹងការចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៤.១.១ តំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌរាជធានី ខេត្តចំណុះភូមិភាគនីមួយៗ ត្រូវបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៤.១.២ តំណាងរាស្ត្រក្នុងតំណែងម្នាក់ៗ និងសមាជិក កបឃ.ស ក្នុងតំណែងម្នាក់ៗ មានសិទ្ធិចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយនៅទីប្រជុំជនរាជធានី ខេត្តតែមួយគត់ចំណុះភូមិភាគពាក់ព័ន្ធ។

៤.១.៣ ការចុះឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមរបៀបស្រង់ឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតបញ្ចូលទៅក្នុងបញ្ជីឈ្មោះដោយឡែកពីគ្នាទៅតាមអង្គបោះឆ្នោតនីមួយៗ និងបញ្ជូនតាមលំដាប់ឋានានុក្រមមក គ.ជ.ប ឱ្យបានតាមកាលបរិច្ឆេទកំណត់។

៤.១.៤ អគ្គលេខាធិការដ្ឋានរដ្ឋសភាត្រូវរៀបចំបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង។ អគ្គលេខាធិការរដ្ឋសភាត្រូវចុះហត្ថលេខា និងបោះត្រាអគ្គលេខាធិការដ្ឋានរដ្ឋសភា ដែលមានការបញ្ជាក់ឯកភាពពីប្រធានរដ្ឋសភា រួចបញ្ជូនមក គ.ជ.ប ឱ្យបានតាមកាលបរិច្ឆេទកំណត់។ បញ្ជីឈ្មោះនេះត្រូវរៀបចំតាមគំរូដែល គ.ជ.ប ផ្តល់ជូន។

៤.១.៥ កបឃ.ស ត្រូវរៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង។ ប្រធាន កបឃ.ស និងជាមេឃុំ ចៅសង្កាត់ត្រូវចុះហត្ថលេខារួចបោះត្រារដ្ឋបាលឃុំ សង្កាត់ ដែលមានការបញ្ជាក់ឯកភាពពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ រួចបញ្ជូនមក គ.ជ.ប ឱ្យបានតាមកាលបរិច្ឆេទកំណត់។

៤.១.៦ ក្នុងករណី កបឃ.ស នៃឃុំ សង្កាត់ណាមួយមិនបានរៀបចំ និងបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងមក គ.ជ.ប ដូចមានចែងក្នុងចំណុច ៤.១.៥ ខាងលើនេះ គ.ជ.ប ត្រូវធ្វើប្រតិភូកម្មមុខងារដល់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ ដើម្បីរៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នោះ រួចចុះហត្ថលេខា បោះត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការបញ្ជាក់ឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ រួចបញ្ជូនមក គ.ជ.ប ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន។

## លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត

### ប្រការ៤.២.-

អ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយនៅទីប្រជុំជនរាជធានី ខេត្តណាមួយនៃភូមិភាគពាក់ព័ន្ធ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

៤.២.១ ជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិក កបឃ.ស ក្នុងតំណែង នៅក្នុងក្របខណ្ឌនៃភូមិភាគនីមួយៗ។

៤.២.២ មិនចាំបាច់បង្ហាញខ្លួន ឬអាចទៅបង្ហាញខ្លួនចំពោះមុខអគ្គលេខាធិការរដ្ឋសភា ឬប្រធាន កបឃ.ស នៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីទទួលព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីការិយាល័យបោះឆ្នោត និងអំពីតម្រូវការឯកសារនៅពេលបោះឆ្នោត។

## ការិយាល័យចុះឈ្មោះបោះឆ្នោត

### ប្រការ៤.៣.-

ការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយ ត្រូវបានកំណត់សម្រាប់អង្គបោះឆ្នោតតំណាងរាស្ត្រ និងការិយាល័យចុះឈ្មោះបោះឆ្នោតចំនួនមួយត្រូវបានកំណត់សម្រាប់អង្គបោះឆ្នោត កបឃ.ស នីមួយៗ។ ការិយាល័យចុះឈ្មោះបោះឆ្នោត គឺជាការិយាល័យស្ថិតនៅមួយកន្លែង។

៤.៣.១ ការិយាល័យចុះឈ្មោះបោះឆ្នោតសម្រាប់តំណាងរាស្ត្រក្នុងតំណែងត្រូវមានទីតាំងនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា។

៤.៣.២ ការិយាល័យចុះឈ្មោះបោះឆ្នោតសម្រាប់សមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ ឬទីតាំងណាមួយសមស្របក្នុងឃុំ សង្កាត់។

## សង្ខេបដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ

### ប្រការ៤.៤.-

ការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការផ្តល់សុពលភាពបញ្ជីបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ចែកជាដំណាក់កាលដូចខាងក្រោម៖

៤.៤.១ ការចុះឈ្មោះបោះឆ្នោតជូនតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងធ្វើឡើងដោយឡែកពីគ្នានៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌរាជធានី ខេត្តនៃភូមិភាគនីមួយៗ។

៤.៤.២ ការរៀបចំ និងបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង តាមលំដាប់ឋានានុក្រមមក គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស) ដើម្បីបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ និងរៀបចំជាបញ្ជីបោះឆ្នោតដំបូង។

៤.៤.៣ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងធ្វើឡើងនៅ លគច.ខប និងនៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនរាជធានី ខេត្តនៃភូមិភាគពាក់ព័ន្ធ។

៤.៤.៤ ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ដែលទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង។

៤.៤.៥ ការកែតម្រូវបញ្ជីបោះឆ្នោត ការបោះពុម្ព និងការផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៤.៤.៦ ការកែប្រែបញ្ជីបោះឆ្នោតផ្លូវការ ក្នុងករណីមានអ្នកបោះឆ្នោតទទួលមរណភាព។

## រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ

### ប្រការ៤.៥.-

គ.ជ.ប ត្រូវរៀបចំបញ្ជីបោះឆ្នោត និងផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ដើម្បីធានាឱ្យការចុះឈ្មោះបោះឆ្នោត ការរៀបចំបញ្ជីបោះឆ្នោតដំបូង ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងការផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការដំណើរការទៅយ៉ាងរលូន និងទាន់ពេលវេលាដែលកំណត់ដោយច្បាប់ គ.ជ.ប ត្រូវកំណត់រយៈពេល និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតសម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមអង្គបោះឆ្នោតនីមួយៗ។

៤.៥.១ ការចុះឈ្មោះបោះឆ្នោតរួមនឹងការរៀបចំ និងការបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក គបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌរាជធានី ខេត្តនៃភូមិភាគនីមួយៗ តាមលំដាប់ឋានានុក្រមមកដល់ គ.ជ.ប ត្រូវបានកំណត់រយៈពេលសរុបត្រឹម ២១ (ម្ភៃមួយ) ថ្ងៃ ដោយមិនគិតបញ្ចូលថ្ងៃបុណ្យផ្លូវការ។

៤.៥.១.១ រយៈពេលសម្រាប់ការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតនីមួយៗ ត្រូវបានកំណត់ស្មើនឹង ១៤ (ដប់បួន) ថ្ងៃ។

៤.៥.១.២ រយៈពេលសម្រាប់ការបញ្ជាក់ឯកភាព និងការបញ្ជូនបញ្ជីឈ្មោះនៃអង្គបោះឆ្នោតពាក់ព័ន្ធតាមលំដាប់ឋានានុក្រមមក គ.ជ.ប ត្រូវបានកំណត់រយៈពេល ៧ (ប្រាំពីរ) ថ្ងៃ។

៤.៥.១.៣ ក្នុងករណីការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយបានចុះឈ្មោះជូនតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក គបឃ.ស ទាំងអស់ក្នុងតំណែងរួចរាល់មុនរយៈពេលកំណត់ ការិយាល័យចុះឈ្មោះបោះឆ្នោតនោះ អាចបន្តអនុវត្តជំហានបញ្ជាក់ឯកភាព និងបញ្ជូនបញ្ជីឈ្មោះនៃអង្គបោះឆ្នោតពាក់ព័ន្ធតាមលំដាប់ឋានានុក្រមមក គ.ជ.ប ដោយពុំចាំបាច់រង់ចាំ។

៤.៥.២ ការចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមធ្វើនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា និងនៅគ្រប់សាលាឃុំ សង្កាត់ទូទាំងប្រទេស ក្នុងថ្ងៃតែមួយដូចបានកំណត់ក្នុងប្រតិទិនការងាររបស់ គ.ជ.ប។ ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា និងនៅសាលាឃុំ សង្កាត់ត្រូវបើកអនុវត្តការចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលម៉ោងធ្វើការ នៅរៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។

៤.៥.៣ គ.ជ.ប ត្រូវណែនាំអគ្គលេខាធិការដ្ឋានរដ្ឋសភា លធ.ខប និង គបឃ.ស ឱ្យផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេល និងកាលបរិច្ឆេទដូចមានចែងក្នុងចំណុច ៤.៥.១ ខាងលើនេះ ព្រមទាំងប្រតិទិនសម្រាប់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតនីមួយៗ ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនពេលចាប់ផ្តើម។

## ការទទួលខុសត្រូវរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា និង គបឃ.ស ក្នុងការចុះឈ្មោះបោះឆ្នោត

**ប្រការ៤.៦.-**

អនុលោមតាម ច.ប.ព.ស អ្នកបោះឆ្នោត និងអង្គបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិក គបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌរាជធានី ខេត្តនៃភូមិភាគនីមួយៗ។ គ.ជ.ប ត្រូវលើកសំណើសុំទៅរដ្ឋសភា ដើម្បីផ្ទេរសមត្ថកិច្ចជូនអគ្គលេខាធិការដ្ឋានរដ្ឋសភា និងក្រសួងមហាផ្ទៃ ដើម្បីធ្វើប្រតិភូកម្មអំណាចដល់ គបឃ.ស ឱ្យបំពេញតួនាទីជាតំណាងរបស់ គ.ជ.ប ក្នុងការចុះឈ្មោះបោះឆ្នោត ក្នុងក្របខណ្ឌការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតនីមួយៗ។

៤.៦.១ ដើម្បីធានាការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប បានផ្ទេរសមត្ថកិច្ច និងធ្វើប្រតិភូកម្មអំណាច អគ្គលេខាធិការដ្ឋានរដ្ឋសភា និង គបឃ.ស ត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

៤.៦.១.១ អនុវត្តឱ្យបានត្រឹមត្រូវតាម ច.ប.ព.ស និង ប.ន.ព.ស នេះ។ ប្រកាន់ជំហរអព្យាក្រឹត និងមិនលម្អៀងក្នុងពេលបំពេញការងារ និងធានាឱ្យដំណើរការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព។

៤.៦.១.២ ចាត់វិធានការសមស្រប ដើម្បីធានាថា ដំណើរការនៃការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង។

៤.៦.១.៣ ធានាឱ្យអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សនយោបាយដែលមានការបញ្ជាក់ទទួលស្គាល់ដោយ គ.ជ.ប និង លធ.ខប មានលទ្ធភាពសង្កេតការណ៍ក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោតក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

៤.៦.១.៤ ស្រង់ឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក គបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌរាជធានី ខេត្តនៃភូមិភាគនីមួយៗម្នាក់ម្តងៗ និងត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត។ ប្រសិនបើឃើញថា ត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់ចូលទៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក គបឃ.ស ទាំងអស់ក្នុងតំណែង។

៤.៦.១.៥ មិនបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ចំពោះអ្នកដែលមិនបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងប្រការ ៤.២ នៃ ប.ន.ព.ស នេះ។

៤.៦.១.៦ ជម្រាបជូនអ្នកដែលត្រូវបានចុះឈ្មោះទៅក្នុងបញ្ជីតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ក្នុងករណីគាត់មកបង្ហាញខ្លួនឱ្យចងចាំលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងឱ្យគាត់យកទៅជាមួយនូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

៤.៦.១.៧ ជូនដំណឹងចំពោះអ្នកដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ប៉ុន្តែមិនបានមកបង្ហាញខ្លួនតាមមធ្យោបាយដែលមាននូវខ្លឹមសារ និងព័ត៌មានដូចមានចែងក្នុងចំណុច ៤.៦.១.៦ ខាងលើនេះ។

៤.៦.១.៨ ធានាថា តំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌរាជធានី ខេត្តនៃភូមិភាគនីមួយៗ ត្រូវបានបញ្ចូលទៅក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង។

៤.៦.១.៩ រាយការណ៍ជូន គ.ជ.ប តាមលំដាប់ឋានានុក្រមនូវរាល់ហេតុការណ៍ដែលបានកើតមានក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហា។

៤.៦.១.១០ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យចុះឈ្មោះបោះឆ្នោត នៅពេលដែលការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ និងរៀបចំបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង តាមលំដាប់ឋានានុក្រមមក គ.ជ.ប ដើម្បីរៀបចំជាបញ្ជីបោះឆ្នោតដំបូង។

៤.៦.១.១១ ចូលរួមបំភ្លឺក្នុងរាល់សវនាការរបស់ គធ.ខប គ.ជ.ប និង ក្រុមប្រឹក្សាធម្មនុញ្ញដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និង ពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូង (ប្រសិន មានតម្រូវការជាចាំបាច់)។

៤.៦.២ គ.ជ.ប ត្រូវណែនាំជាក់ស្តែង និងផ្តល់ទម្រង់បែបបទមួយចំនួនដល់ អគ្គលេខាធិការដ្ឋានរដ្ឋសភា និង កបឃ.ស ដើម្បីអនុវត្តការងារនេះ។

## សម្ភារ ឯកសារសម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការចុះឈ្មោះបោះឆ្នោត

## ប្រការ៤.៧._

គ.ជ.ប ត្រូវជានាការផ្គត់ផ្គង់សម្ភារ ឯកសារគ្រប់គ្រាន់សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការ ចុះឈ្មោះបោះឆ្នោតឱ្យបានទាន់ពេលវេលា។

៤.៧.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់ លធ.ខប ដើម្បីបន្តណែនាំសម្របសម្រួលក្នុងការងារចុះឈ្មោះបោះឆ្នោត នៅតាមអង្គបោះឆ្នោតនៃ កបឃ.ស នីមួយៗ ស្ថិតនៅក្នុងរាជធានី ខេត្ត។

៤.៧.២ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់ អគ្គលេខាធិការដ្ឋានរដ្ឋសភា និង កបឃ.ស ដែលទទួលអនុវត្តការចុះឈ្មោះ បោះឆ្នោតនៅតាមសាមីអង្គបោះឆ្នោត។

## ការចុះឈ្មោះបោះឆ្នោត ការរៀបចំ និងការបញ្ជូនបញ្ជីឈ្មោះតាមអង្គបោះឆ្នោតមក គ.ជ.ប

## ប្រការ៤.៨._

អនុលោមតាម ប.ន.ព.ស នេះ និងការណែនាំរបស់ គ.ជ.ប និងផ្អែកតាមការកំណត់ រយៈពេល និងកាលបរិច្ឆេទសម្រាប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានទទួលសម្ភារ ឯកសារ បម្រើការចុះឈ្មោះបោះឆ្នោត អគ្គលេខាធិការដ្ឋានរដ្ឋសភា និង កបឃ.ស ត្រូវចាត់ចែងបើក ការិយាល័យចុះឈ្មោះបោះឆ្នោតតាមប្រតិទិនកំណត់ និងត្រូវអនុវត្តឱ្យបានរួចរាល់ឆាប់រហ័សតាម ដែលអាចធ្វើទៅបាន ដើម្បីរៀបចំ និងបញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ឬបញ្ជីឈ្មោះ សមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង តាមលំដាប់ឋានានុក្រមមក គ.ជ.ប ឱ្យបានទាន់ពេលវេលា។ អគ្គលេខាធិការដ្ឋានរដ្ឋសភា និង កបឃ.ស ត្រូវ៖

៤.៨.១ ចាត់ចែងរៀបចំឱ្យមានបន្ទប់មួយ ព្រមទាំងតុ និងកៅអីមួយចំនួនសម្រាប់ ប្រើប្រាស់ជាការិយាល័យចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងប្រការ ៤.៧ ខាងលើនេះ។ ការិយាល័យចុះឈ្មោះបោះឆ្នោតអាចតាំងនៅបន្ទប់ធ្វើការរបស់ អគ្គលេខាធិការរដ្ឋសភា ឬប្រធាន កបឃ.ស។

៤.៨.២ បិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅមុខទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៃសាមីអង្គបោះឆ្នោតពាក់ព័ន្ធយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត។

៤.៨.៣ បិទផ្សាយប្រតិទិនសម្រាប់ការចុះឈ្មោះបោះឆ្នោតតាមអង្គបោះឆ្នោតពាក់ព័ន្ធ នៅខាងមុខការិយាល័យចុះឈ្មោះបោះឆ្នោត យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចុះឈ្មោះបោះឆ្នោត។ ប្រតិទិននេះ ត្រូវតែមានបញ្ជាក់រយៈពេល និងកាលបរិច្ឆេទសម្រាប់ដំណាក់កាលនីមួយៗ ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់នៃការចុះឈ្មោះបោះឆ្នោត ព្រមទាំងពេលម៉ោង និងថ្ងៃធ្វើការ។

៤.៨.៤ ចាប់ផ្តើមបើកការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមអង្គបោះឆ្នោតនីមួយៗ នៅថ្ងៃតែមួយទូទាំងប្រទេស តាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប។

**ប្រការ៤.៩.-**

អគ្គលេខាធិការរដ្ឋសភាត្រូវមានវត្តមាននៅការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ដើម្បីស្រង់ឈ្មោះ និងចុះឈ្មោះបោះឆ្នោតជូនតំណាងរាស្ត្រក្នុងតំណែង និងបំពេញទម្រង់បញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមគំរូផ្តល់ជូនដោយ គ.ជ.ប និងផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់តំណាងរាស្ត្រក្នុងតំណែងទាំងនោះ។ អគ្គលេខាធិការរដ្ឋសភាត្រូវ៖

៤.៩.១ ស្រង់ឈ្មោះតំណាងរាស្ត្រក្នុងតំណែង និងផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងប្រការ ៤.២ នៃ ប.ន.ព.ស នេះ ក្នុងករណីមានលក្ខណៈត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់នៅក្នុងបញ្ជីតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលរាជធានី ខេត្តនីមួយៗ តាមគំរូដែល គ.ជ.ប ផ្តល់ជូន។

៤.៩.១.១ ការចុះឈ្មោះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង តាមមណ្ឌលរាជធានី ខេត្តនីមួយៗ អាចបំពេញដោយដៃតាមទម្រង់ដែលផ្តល់ជូនស្រាប់ដោយ គ.ជ.ប ឬអាចរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រ តាមគំរូទម្រង់ដែលផ្តល់ជូនស្រាប់ដោយ គ.ជ.ប។

៤.៩.១.២ នាមត្រកូល និងនាមខ្លួនរបស់តំណាងរាស្ត្រក្នុងតំណែងនៅក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ចេញដោយប្រធានរដ្ឋសភា ដែលត្រូវប្រើប្រាស់នៅថ្ងៃបោះឆ្នោត ត្រូវតែដូចគ្នាជាមួយនាមត្រកូល និងនាមខ្លួនរបស់សាមីខ្លួនដែលចុះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលរាជធានី ខេត្តនីមួយៗ។

៤.៩.២ ជម្រាបជូនតំណាងរាស្ត្រក្នុងតំណែងដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង និងដែលបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតអំពី៖

៤.៩.២.១ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅទីប្រជុំជនរាជធានី ខេត្តពាក់ព័ន្ធដែល គ.ជ.ប បានកំណត់ និងផ្តល់ជូនស្រាប់។

៤.៩.២.២ តម្រូវការចាំបាច់នូវ អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ចេញដោយប្រធានរដ្ឋសភា របស់សាមីខ្លួន ដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

៤.៩.២.៣ ការត្រៀមទុកជាមុននូវ អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៤.៩.៣ ប្រើប្រាស់មធ្យោបាយដែលមាន ដើម្បីជម្រាបជូនតំណាងរាស្ត្រក្នុងតំណែងដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែង ប៉ុន្តែមិនបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតអំពីខ្លឹមសារ និងព័ត៌មានទាំងឡាយដូចមានចែងក្នុងចំណុច ៤.៩.២ ខាងលើនេះ។

៤.៩.៤ ចុះហត្ថលេខា បោះត្រាអគ្គលេខាធិការដ្ឋានរដ្ឋសភា និងកាលបរិច្ឆេទលើបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលរាជធានី ខេត្តនីមួយៗ នៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត រួចរៀបចំបញ្ជីឈ្មោះទាំងនេះដាក់ស្នើសុំបញ្ជាក់ការឯកភាពពីប្រធានរដ្ឋសភា។ ក្រោយទទួលបានការបញ្ជាក់ឯកភាពពីប្រធានរដ្ឋសភារួចហើយ ត្រូវថតចម្លងបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលរាជធានី ខេត្តនីមួយៗបន្ថែមចំនួន ២ (ពីរ) ច្បាប់ទៀតរួចបោះត្រាអគ្គលេខាធិការដ្ឋានរដ្ឋសភា ហើយចាត់ចែងប្រើប្រាស់ដូចខាងក្រោម៖

៤.៩.៤.១ ផ្ញើជូន គ.ជ.ប នូវច្បាប់ដើម ១ (មួយ) ច្បាប់ និងច្បាប់ចម្លង ១ (មួយ) ច្បាប់។

៤.៩.៤.២ រក្សាទុកជាឯកសារនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ១ (មួយ) ច្បាប់។

៤.៩.៥ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតតំណាងរាស្ត្រក្នុងតំណែង ២ (ពីរ) ច្បាប់ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ បោះត្រាអគ្គលេខាធិការដ្ឋានរដ្ឋសភា ហើយចាត់ចែងប្រើប្រាស់ដូចខាងក្រោម៖

៤.៩.៥.១ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់។

៤.៩.៥.២ រក្សាទុកជាឯកសារនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ១ (មួយ) ច្បាប់។

៤.៩.៦ បញ្ជូនបញ្ជីឈ្មោះតំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលរាជធានី ខេត្តនីមួយៗ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោតតំណាងរាស្ត្រ ដូចមានចែងក្នុងចំណុច ៤.៩.៤.១ និងចំណុច ៤.៩.៥.១ ខាងលើនេះ ជូន គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស) ឱ្យបានតាមការកំណត់ដូចមានចែងក្នុងចំណុច ៤.១.៤ និងចំណុច ៤.៥.១ នៃ ប.ន.ព.ស នេះ។ អគ្គលេខាធិការរដ្ឋសភាត្រូវត្រៀមជាស្រេចនូវដីកាអមចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការប្រគល់ ទទួលបញ្ជីឈ្មោះ និងរបាយការណ៍ ដើម្បីបញ្ជាក់ថា គ.ជ.ប បានទទួលរួចហើយ។

៤.៩.៧ ក្នុងដំណាក់កាលរៀបចំបញ្ជីបោះឆ្នោតដំបូង ករណីមានអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់ ដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែងរួចហើយ ប៉ុន្តែបែរជាលែងស្ថិតក្នុងតំណែងជាតំណាងរាស្ត្រតទៅទៀត និងដែលមានតំណាងរាស្ត្រក្នុងតំណែងថ្មីចូលជំនួសជាផ្លូវការ អគ្គលេខាធិការដ្ឋានរដ្ឋសភាត្រូវលើកសំណើដោយមានការបញ្ជាក់ឯកភាពតាមលំដាប់ឋានានុក្រមមក គ.ជ.ប ដើម្បីសុំកែតម្រូវបញ្ជីបោះឆ្នោត។

៤.៩.៧.១ សំណើសុំកែតម្រូវបញ្ជីបោះឆ្នោត ត្រូវតែបានបញ្ជូនមកដល់ គ.ជ.ប រហូតដល់យ៉ាងតិច ២ (ពីរ) ថ្ងៃ មុនថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

៤.៩.៧.២ គ.ជ.ប ត្រូវពិនិត្យ សម្រេចជាបន្ទាន់លើសំណើសុំកែតម្រូវបញ្ជីបោះឆ្នោត និងត្រូវចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោតនិងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសកែតម្រូវបញ្ជីបោះឆ្នោតជាបន្ទាន់ តាមការសម្រេចរបស់ គ.ជ.ប។

**ប្រការ៤.១០.-**

ប្រធាន កបឃ.ស និងជាមេឃុំ ចៅសង្កាត់ត្រូវមានវត្តមាននៅការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ដើម្បីទទួលចុះឈ្មោះបោះឆ្នោតជូនសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ដែលត្រូវបំពេញក្នុងទម្រង់បញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង តាមគំរូផ្តល់ជូនដោយ គ.ជ.ប និងផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ដល់សមាជិក កបឃ.ស ក្នុងតំណែងទាំងនោះ។ ប្រធាន កបឃ.ស ត្រូវ៖

៤.១០.១ ស្រង់ឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងផ្ទៀងផ្ទាត់លក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងប្រការ ៤.២ នៃ ប.ន.ព.ស នេះ

ក្នុងករណីមានលក្ខណៈត្រឹមត្រូវពិតប្រាកដហើយ ត្រូវចុះឈ្មោះរបស់គាត់នៅក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង។

៩.១០.១.១ ការចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង អាចបំពេញដោយដៃតាមទម្រង់ដែលផ្តល់ជូនស្រាប់ដោយ គ.ជ.ប ឬអាចរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រតាមគំរូទម្រង់ដែលផ្តល់ជូនស្រាប់ដោយ គ.ជ.ប។

៩.១០.១.២ នាមត្រកូល និងនាមខ្លួនរបស់សមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៅក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស ក្នុងតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដែលត្រូវប្រើប្រាស់នៅថ្ងៃបោះឆ្នោត ត្រូវតែដូចគ្នាជាមួយនឹងនាមត្រកូល និងនាមខ្លួនរបស់សាមីខ្លួន ដែលបានចុះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង។

៩.១០.២ ជម្រាបជូនសមាជិក កបឃ.ស ក្នុងតំណែង ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងដែលបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតអំពី៖

៩.១០.២.១ លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅទីប្រជុំជនរាជធានី ខេត្តពាក់ព័ន្ធដែល គ.ជ.ប បានកំណត់ និងផ្តល់ជូនស្រាប់។

៩.១០.២.២ តម្រូវការជាចាំបាច់នូវ អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស ក្នុងតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធរបស់សាមីខ្លួន ដើម្បីបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

៩.១០.២.៣ ការត្រៀមទុកជាមុននូវ អ.ខ ឬលិខិតសម្គាល់ខ្លួនជាសមាជិក កបឃ.ស ក្នុងតំណែង ចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

៩.១០.៣ ប្រើប្រាស់មធ្យោបាយដែលមាន ដើម្បីជម្រាបជូនសមាជិក កបឃ.ស ក្នុងតំណែងដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ប៉ុន្តែមិនបានមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតអំពីខ្លឹមសារ និងព័ត៌មានទាំងឡាយដូចមានចែងក្នុងចំណុច ៩.១០.២ ខាងលើនេះ។

៩.១០.៤ នៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត ឬនៅពេលបានចុះឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងរួចរាល់ហើយ ត្រូវថតចម្លងបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងបង្គ្រប់ចំនួន ៥ (ប្រាំ) ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រារដ្ឋបាលឃុំ សង្កាត់។ បន្ទាប់មកត្រូវចាត់ចែងបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ជូន គ.ជ.ប ដោយដាក់ស្នើសុំការបញ្ជាក់ឯកភាពតាមលំដាប់ឋានានុក្រមពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលក្នុងនោះត្រូវ៖

៩.១០.៤.១ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ នៅសាលាឃុំ សង្កាត់។

៩.១០.៤.២ ផ្ញើ ៤ (បួន) ច្បាប់ ដើម្បីស្នើសុំការបញ្ជាក់ឯកភាពតាមលំដាប់ឋានានុក្រមពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៩.១០.៥ ធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតនៃអង្គបោះឆ្នោត កបឃ.ស តាមគំរូទម្រង់ដែល គ.ជ.ប ផ្តល់ជូនចំនួន ៣ (បី) ច្បាប់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រារដ្ឋបាលឃុំ សង្កាត់ ហើយចាត់ចែងប្រើប្រាស់ដូចខាងក្រោម៖

៩.១០.៥.១ រក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់។

៩.១០.៥.២ ផ្ញើ ១ (មួយ) ច្បាប់ជូន លធ.ខប និង ១ (មួយ) ច្បាប់ផ្ញើជូន គ.ជ.ប តាមរយៈអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៩.១០.៦ បញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងចំណុច ៩.១០.៤.២ និងចំណុច ៩.១០.៥.២ ខាងលើនេះ ជូនអភិបាលនៃគណៈអភិបាលក្រុងស្រុក ខណ្ឌ ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់ឯកភាព។

៩.១០.៧ ក្នុងដំណាក់កាលរៀបចំបញ្ជីបោះឆ្នោតដំបូង ករណីមានអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់ដែលបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតដែលជាសមាជិក កបឃ.ស ក្នុងតំណែងរួចហើយ ប៉ុន្តែបែរជាលែងស្ថិតក្នុងតំណែងជាសមាជិក កបឃ.ស តទៅទៀត និងដែលមានសមាជិក កបឃ.ស ក្នុងតំណែងថ្មីចូលជំនួសជាផ្លូវការ កបឃ.ស ត្រូវលើកសំណើដោយមានការបញ្ជាក់ឯកភាពតាមលំដាប់ឋានានុក្រម មក គ.ជ.ប ដើម្បីសុំកែតម្រូវបញ្ជីបោះឆ្នោត។

៤.១០.៧.១ សំណើសុំកែតម្រូវបញ្ជីបោះឆ្នោត ត្រូវតែបានបញ្ជូនមកដល់ គ.ជ.ប រហូតដល់យ៉ាងតិច ២ (ពីរ) ថ្ងៃ មុនថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

៤.១០.៧.២ គ.ជ.ប ត្រូវពិនិត្យ សម្រេចជាបន្ទាន់លើសំណើសុំកែតម្រូវបញ្ជីបោះឆ្នោត និងត្រូវចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោតនិងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស កែតម្រូវបញ្ជីបោះឆ្នោតជាបន្ទាន់តាមការសម្រេចរបស់ គ.ជ.ប។

**ប្រការ៤.១១.-**

បន្ទាប់ពីទទួលបានបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវផ្តល់កិច្ចសហការជួយត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់ការឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌនៃរាជធានី ខេត្តពាក់ព័ន្ធ ក្នុងករណីបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗមានលក្ខណៈត្រឹមត្រូវពិតប្រាកដ។

លធ.ខប ត្រូវសម្របសម្រួល និងសហការឱ្យបានជិតស្និទ្ធជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការចុះទៅទទួលយកដោយផ្ទាល់នៅសាលាក្រុង ស្រុក ខណ្ឌ ឬក្នុងការចាត់ចែងបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងរាជធានី ខេត្ត ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់ការឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងរាជធានី ខេត្តពាក់ព័ន្ធសម្រាប់បញ្ជូនទៅ គ.ជ.ប ឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបាន។

៤.១១.១ នៅពេលទទួលបានបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់នានាដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ និងត្រូវចាត់ចែងជាបន្ទាន់៖

៤.១១.១.១ បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗក្នុងករណីត្រឹមត្រូវពិតប្រាកដ។

៤.១១.១.២ សុំឱ្យប្រធាន កបឃ.ស បកស្រាយបំភ្លឺ ឬ/និងកែតម្រូវ ក្នុងករណីមានលក្ខណៈមិនត្រឹមត្រូវ។ បន្ទាប់ពីបានកែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នោះ។

៤.១១.១.៣ រៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ដែលបានបញ្ជាក់ឯកភាពរួចហើយចំនួន ៣ (បី) ច្បាប់ និង របាយការណ៍ទាំង ២ (ពីរ) ច្បាប់ ដោយដាក់តាមឃុំ សង្កាត់ នីមួយៗ ដើម្បីបញ្ជូនទៅសាលារាជធានី ខេត្ត និងត្រូវធ្វើដីកា អមបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍នៃឃុំ សង្កាត់ទាំងអស់ ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ ជូនអភិបាលនៃគណៈអភិបាល រាជធានី ខេត្តផង។

៤.១១.១.៤ រក្សាទុកបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួន ១ (មួយ) ច្បាប់ ជា ឯកសារនៅសាលាក្រុង ស្រុក ខណ្ឌ។

៤.១១.២ លធ.ខប ត្រូវទាក់ទងព័ត៌មានជាប្រចាំជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បី ឱ្យដឹងប្រាកដថា អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌបានត្រៀម រៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងរបាយការណ៍ សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ សម្រាប់ការបញ្ជូនទៅសាលារាជធានី ខេត្តរួចរាល់ហើយឬនៅ។ លធ.ខប ត្រូវចាត់ចែងមន្ត្រីឱ្យចុះទៅទទួលយកបញ្ជីឈ្មោះ និងរបាយការណ៍ នៃឃុំ សង្កាត់ទាំងអស់ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌពាក់ព័ន្ធដោយផ្ទាល់ ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬស្នើសុំឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌបញ្ជូនបញ្ជីឈ្មោះ និងរបាយការណ៍ទាំងនោះមកសាលា រាជធានី ខេត្ត ប្រសិនបើរដ្ឋបាលក្រុង ស្រុក ខណ្ឌមានភារកិច្ចត្រូវឡើងមក ទាក់ទងការងារ ស្របពេលគ្នានៅសាលារាជធានី ខេត្ត។

៤.១១.៣ នៅពេលទទួលបានបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតពីឃុំ សង្កាត់នានា ដែលស្ថិតក្នុងរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់ នីមួយៗ ដែលអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ បានបញ្ជាក់ឯកភាព រួចហើយ និងត្រូវចាត់ចែងជាបន្ទាន់៖

៤.១១.៣.១ បញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ក្នុងករណីត្រឹមត្រូវពិត ប្រាកដ។

៩.១១.៣.២ សុំឱ្យប្រធាន កបឃ.ស និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ បកស្រាយបំភ្លឺ ឬ/និងកែតម្រូវ ក្នុងករណីមានលក្ខណៈមិនត្រឹមត្រូវ។ បន្ទាប់ពីបានកែតម្រូវរួច ត្រូវបញ្ជាក់ឯកភាពលើបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នោះ។

៩.១១.៣.៣ រៀបចំបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយចំនួន ២ (ពីរ) ច្បាប់ និងរបាយការណ៍ទាំង ២ (ពីរ) ច្បាប់ ដោយដាក់តាមឃុំ សង្កាត់នីមួយៗ ដើម្បីបញ្ជូនទៅ គ.ជ.ប តាមរយៈ លធ.ខប។

៩.១១.៣.៤ រក្សាទុកបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងដែលបានបញ្ជាក់ឯកភាពរួចហើយ ចំនួន ១ (មួយ) ច្បាប់ ជាឯកសារនៅសាលារាជធានី ខេត្ត។

៩.១១.៤ ប្រធាន លធ.ខប ត្រូវទាក់ទងព័ត៌មានជាប្រចាំជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីទៅទទួលយកបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងដែលមានការបញ្ជាក់ឯកភាពពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់នានាដែលស្ថិតក្នុងរាជធានី ខេត្ត។ ប្រធាន លធ.ខប ត្រូវត្រៀមបែងចែក វេចខ្ចប់ និងប្រើប្រាស់បញ្ជីឈ្មោះ និងរបាយការណ៍ទាំងនេះដូចខាងក្រោម៖

៩.១១.៤.១ បញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ១ (មួយ) ច្បាប់ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ១ (មួយ) ច្បាប់ ជូន គ.ជ.ប។

៩.១១.៤.២ រក្សាទុកបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ ១ (មួយ) ច្បាប់ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ចំនួន ១ (មួយ) ច្បាប់ ជាឯកសារនៅ លធ.ខប។

៩.១១.៥ ប្រធាន លធ.ខប ត្រូវធ្វើរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទូទាំងរាជធានី ខេត្តចំនួន ២ (ពីរ) ច្បាប់ ដែលក្នុងនោះត្រូវរក្សាទុក ១ (មួយ) ច្បាប់ជាឯកសារ និងបញ្ជូន ១ (មួយ) ច្បាប់ជូន គ.ជ.ប។

៤.១១.៦ ប្រធាន លធ.ឧប ត្រូវបញ្ជូនបញ្ជីឈ្មោះសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៃឃុំ សង្កាត់នីមួយៗ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ដូចមានចែងក្នុងចំណុច ៤.១១.៤.១ ខាងលើនេះ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតនៅគ្រប់ឃុំ សង្កាត់ទូទាំងរាជធានី ខេត្ត ១ (មួយ) ច្បាប់ ជូន គ.ជ.ប (នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស) ឱ្យបានតាមការកំណត់ដូចមានចែងក្នុងចំណុច ៤.៥.១ នៃ ប.ន.ព.ស នេះ ឬឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន។

៤.១១.៧ ប្រធាន លធ.ឧប ត្រូវត្រៀមជាស្រេចនូវលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើប្រាស់ក្នុងការប្រគល់ ទទួលបញ្ជីឈ្មោះ និងរបាយការណ៍ដូចមានចែងក្នុងចំណុច ៤.១១.៦ ខាងលើនេះ ដើម្បីបញ្ជាក់ថា គ.ជ.ប បានទទួលរួចហើយ។

## ការប្រគល់ និងការទទួលបញ្ជីឈ្មោះតាមអង្គបោះឆ្នោត និងការរៀបចំបញ្ជីបោះឆ្នោតដំបូងដោយប្រព័ន្ធកុំព្យូទ័រនៅ គ.ជ.ប

## ប្រការ៤.១២.-

នៅពេលទទួលបញ្ជីឈ្មោះតាមអង្គបោះឆ្នោតពីអគ្គលេខាធិការដ្ឋានរដ្ឋសភា និង លធ.ឧប ដូចមានចែងក្នុងចំណុច ៤.៩.៦ និងចំណុច ៤.១១.៦ នៃ ប.ន.ព.ស នេះ មន្ត្រីទទួលឯកសាររបស់នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវចាត់ចែងពិនិត្យសំណុំឯកសារដែលបានប្រគល់ រួចចុះហត្ថលេខាបញ្ជាក់ការទទួលប្រសិនបើពិនិត្យឃើញថា គ្រប់គ្រាន់ហើយ។ ប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ត្រូវចាត់ចែងមន្ត្រីឱ្យផ្ទៀងផ្ទាត់របាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមអង្គបោះឆ្នោតនីមួយៗជាមួយនឹងបញ្ជីឈ្មោះតាមអង្គបោះឆ្នោតពាក់ព័ន្ធ។ ក្នុងករណីត្រឹមត្រូវហើយត្រូវចាត់ចែងឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និងបញ្ចូលទិន្នន័យអ្នកបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីរៀបចំជាបញ្ជីបោះឆ្នោតដំបូង។ ក្នុងដំណើរការនៃការរៀបចំបញ្ជីបោះឆ្នោតដំបូង ប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវៈ

៤.១២.១ ធានាថា នៅរាល់ពេលប្រគល់ ទទួលបញ្ជីឈ្មោះតាមអង្គបោះឆ្នោតនីមួយៗ និងរបាយការណ៍សរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត មន្ត្រីទទួលឯកសារបានចុះហត្ថលេខាលើដីការអម ឬលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ឱ្យមន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ឬមន្ត្រី លធ.ឧប ដែលទទួលបន្ទុកបញ្ជូនសំណុំឯកសារវិញ ១ (មួយ)

ច្បាប់ ដើម្បីបញ្ជាក់ថា បានទទួលគ្រប់ចំនួនមែន និងត្រូវរក្សាទុក ១ (មួយ) ច្បាប់ជាឯកសារ។ ក្នុងករណីសំណុំឯកសារដែលបានប្រគល់មានលក្ខណៈ មិនទាន់គ្រប់គ្រាន់ មន្ត្រីទទួលឯកសារអាចស្នើសុំឱ្យមន្ត្រីទទួលបន្ទុកការបញ្ជូន យកមកបន្ថែមនូវឯកសារដែលខ្វះ។

៩.១២.២ ធានាថា សំណុំឯកសារនៃការចុះឈ្មោះបោះឆ្នោតដែលបានទទួល ត្រូវបាន បំបែក រួចផ្តុំបញ្ចូលគ្នាទៅតាមរាជធានី ខេត្ត ដោយឡែកពីគ្នានូវបញ្ជីឈ្មោះ តំណាងរាស្ត្រក្នុងតំណែងតាមមណ្ឌលរាជធានី ខេត្ត និងបញ្ជីឈ្មោះសមាជិក កបយ.ស ទាំងអស់ក្នុងតំណែងតាមរាជធានី ខេត្ត ព្រមទាំងបានបែងចែក ទៅតាមការិយាល័យបោះឆ្នោតនីមួយៗ ដែលស្ថិតក្នុងរាជធានី ខេត្តពាក់ព័ន្ធ និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព។

៩.១២.៣ ធានាថា តួលេខ និងទិន្នន័យនៃបញ្ជីឈ្មោះតាមអង្គបោះឆ្នោតនីមួយៗ ត្រូវ បានត្រួតពិនិត្យ ផ្ទៀងផ្ទាត់បន្ថែមឱ្យបានហ្មត់ចត់ និងត្រឹមត្រូវ ដើម្បីត្រៀម សម្រាប់ការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រ។ ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ បន្ថែមនេះ ត្រូវផ្អែកជាមូលដ្ឋានលើបញ្ជីបេក្ខជនតំណាងរាស្ត្រ ឬ/និងបញ្ជី បេក្ខជនសមាជិក កបយ.ស ផ្លូវការដែលមានរក្សាទុកជាឯកសារនៅ គ.ជ.ប។ ក្នុងករណីមានភាពមិនប្រក្រតី ឬភាពមិនត្រឹមត្រូវពាក់ព័ន្ធនឹងចំនួន និងទិន្នន័យ ក្នុងបញ្ជីឈ្មោះ ត្រូវរាយការណ៍ជាបន្ទាន់តាមលំដាប់ឋានានុក្រមទៅ គ.ជ.ប ដើម្បីសុំយោបល់ណែនាំ។

៩.១២.៤ ចាត់ចែងមន្ត្រីឱ្យបូកសរុបលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត និងបញ្ចូល ទិន្នន័យអ្នកបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយផ្អែកតាមបញ្ជីឈ្មោះ និង របាយការណ៍ដែលបានពិនិត្យ ផ្ទៀងផ្ទាត់ត្រឹមត្រូវរួច ក្នុងនោះត្រូវធានាថា៖

៩.១២.៤.១ មន្ត្រីបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រមានការទទួលខុសត្រូវ ខ្ពស់ក្នុងការវាយបញ្ចូលឈ្មោះអ្នកបោះឆ្នោត និងទិន្នន័យ ពាក់ព័ន្ធបានយ៉ាងត្រឹមត្រូវ និងឆាប់រហ័ស។

៩.១២.៤.២ ចំនួនឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យ បោះឆ្នោតនីមួយៗក្នុងប្រព័ន្ធកុំព្យូទ័រត្រូវតែស្មើគ្នានឹងចំនួន ដែលមានក្នុងបញ្ជីឈ្មោះតាមអង្គបោះឆ្នោត ដែលបានកំណត់ សម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

៩.១២.៤.៣ បញ្ជីបោះឆ្នោតដំបូងតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវ មានទិន្នន័យដូចខាងក្រោម៖

- លេខរៀងភូមិភាគ
- លេខកូដ និងឈ្មោះរាជធានី ខេត្ត
- លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត
- លេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង
- អត្តលេខ (បញ្ជីបោះឆ្នោតសកល)
- រូបថត
- នាមត្រកូល និងនាមខ្លួន ដែលរៀបចំតាមលំដាប់អក្ខរក្រម ខ្មែរ
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- ឋានៈក្នុងតំណែងតាមអង្គបោះឆ្នោត
- លំនៅឋាន ឬទីសំណាក់នៃអ្នកបោះឆ្នោត។

៤.១២.៤.៤ នៅគ្រប់ទំព័រនៃបញ្ជីបោះឆ្នោតដំបូងតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតដំបូងសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ហើយនៅទំព័រចុងក្រោយនៃបញ្ជីបោះឆ្នោតដំបូងនេះ ទុកឱ្យមានចន្លោះសម្រាប់ចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រា គ.ជ.ប។ នៅគ្រប់ទំព័រផ្សេងទៀតនៃបញ្ជីបោះឆ្នោតដំបូងរបស់ការិយាល័យបោះឆ្នោតនីមួយៗ ក៏ត្រូវមានបោះត្រា គ.ជ.ប ផងដែរ។

៤.១២.៤.៥ ឈ្មោះអ្នកបោះឆ្នោត និងរាល់ទិន្នន័យពាក់ព័ន្ធនៅលើបញ្ជីបោះឆ្នោតដំបូងត្រូវតែបានត្រួតពិនិត្យ និងកែតម្រូវយ៉ាងហ្មត់ចត់ និងត្រឹមត្រូវមុននឹងបោះពុម្ព និងដាក់ជូន គ.ជ.ប ពិនិត្យសម្រេចជាបញ្ជីបោះឆ្នោតដំបូង។

## ការបញ្ជូន និងការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង

## ប្រការ៤.១៣._

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវបោះពុម្ពបញ្ជីបោះឆ្នោតដំបូងដែលបានរៀបចំរួចស្រេចចំនួន ២ (ពីរ) ច្បាប់ ហើយដាក់ជូន គ.ជ.ប ពិនិត្យ សម្រេចជាបញ្ជីបោះឆ្នោតដំបូង។ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវធានាថា បញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតនីមួយៗត្រូវបានថតចម្លងបន្ថែមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់វេចខ្ចប់ និងបញ្ជូនទៅ គធ.ខប ប្រើប្រាស់ក្នុងការបិទផ្សាយ ដើម្បីបម្រើគោលដៅនៃការពិនិត្យ កែតម្រូវតាមរយៈការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនោះ។

៤.១៣.១ បញ្ជីបោះឆ្នោតដំបូងនឹងត្រូវបង្ហោះនៅលើគេហទំព័រ voterlist.nec.gov.kh និង Mobile App (NEC KH)។

៤.១៣.២ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរក្សាទុកច្បាប់ដើមនៃបញ្ជីបោះឆ្នោតដំបូងដែល គ.ជ.ប បានពិនិត្យ សម្រេចរួចហើយ ១ (មួយ) ច្បាប់ ជាឯកសារនៅ គ.ជ.ប និងត្រូវវេចខ្ចប់តាមការិយាល័យបោះឆ្នោតនីមួយៗ ដោយឡែកពីគ្នានូវបញ្ជីបោះឆ្នោតដំបូងច្បាប់ដើម ១ (មួយ) ច្បាប់ និងច្បាប់ចម្លង ៤ (បួន) ច្បាប់ រួចបញ្ជូនទៅ គធ.ខប ឱ្យបានទាន់ពេលវេលាមុនការកំណត់ឱ្យបិទផ្សាយ។

៤.១៣.៣ ពេលទទួលបានកញ្ចប់បញ្ជីបោះឆ្នោតដំបូង គធ.ខប ត្រូវដករក្សាទុកច្បាប់ដើម ១ (មួយ) ច្បាប់ ជាឯកសារ និងត្រូវចាត់ចែងបិទផ្សាយច្បាប់ចម្លងយ៉ាងតិច ៤៨ (សែសិបប្រាំបី) ថ្ងៃ មុនថ្ងៃបោះឆ្នោត ដោយត្រូវបិទផ្សាយដូចខាងក្រោម៖

៤.១៣.៣.១ នៅ លគធ.ខប ១ (មួយ) ច្បាប់។

៤.១៣.៣.២ នៅកន្លែង ៣ ផ្សេងគ្នាក្នុងទីប្រជុំជនរាជធានី ខេត្ត ក្នុងកន្លែងនីមួយៗ ១ (មួយ) ច្បាប់។

៤.១៣.៤ នៅពេលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង គធ.ខប ត្រូវធ្វើកំណត់ហេតុស្តីពីការបិទផ្សាយនេះ ៦ (ប្រាំមួយ) ច្បាប់ ដោយមានបញ្ជាក់អំពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងនៃការបិទផ្សាយ ហើយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ខប ផង។ គធ.ខប ត្រូវបិទផ្សាយកំណត់ហេតុនេះ ១ (មួយ) ច្បាប់ អមជាមួយនឹងបញ្ជីបោះឆ្នោតដំបូង នៅតាមទីតាំងដូចមានចែងក្នុងចំណុច ៤.១៣.៣ ខាងលើនេះ រួចផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៤.១៣.៥ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង គឺដើម្បីបម្រើគោលដៅនៃការពិនិត្យ កែតម្រូវតាមរយៈការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ពាក់ព័ន្ធនឹងបញ្ជីបោះឆ្នោតដំបូងនេះ។ បញ្ជីបោះឆ្នោតដំបូងត្រូវបានបិទផ្សាយជាសាធារណៈក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដែលក្នុងរយៈពេលកំណត់នេះ ជនណាក៏ដោយក៏មានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទាក់ទងទៅនឹងបញ្ជីបោះឆ្នោតដំបូងនេះបានដែរ។ ការដាក់ពាក្យបណ្តឹងត្រូវធ្វើនៅ លគធ.ខប។

៤.១៣.៦ គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយមានសិទ្ធិសុំបញ្ជីបោះឆ្នោតដំបូងច្បាប់ថតចម្លងបាន ដោយបង់ថ្លៃ។ តម្លៃនេះ

ត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ។ ម៉្យាងទៀតក៏អាចទទួលបាននូវទិន្នន័យបញ្ជីបោះឆ្នោតតាមទម្រង់ PDF ដែលមានបង្ហោះតាមគេហទំព័រ voterlist.nec.gov.kh និង Mobile App (NEC KH) ផងដែរ។

៤.១៣.៧ គធ.ខប អាចទទួលថតចម្លងបញ្ជីបោះឆ្នោតដំបូងដោយផ្ទាល់ តាមលទ្ធភាពជាក់ស្តែងរបស់ខ្លួន ដើម្បីផ្គត់ផ្គង់តាមសំណើសុំដូចមានចែងក្នុងចំណុច ៤.១៣.៦ ខាងលើនេះ (ប្រសិនបើមាន)។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

### គោលការណ៍ទូទៅ

**ប្រការ៤.១៤.-**

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងតាមលំដាប់ឋានានុក្រមទៅ គធ.ខប គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ។

៤.១៤.១ ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ករណីប្តឹងជំទាស់)។ ពាក្យបណ្តឹង (ទ.១២០២) នេះ ត្រូវបានប្រគល់ជូនអ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ។

៤.១៤.២ អ្នកប្តឹងអាចថតចម្លងពាក្យបណ្តឹង (ទ.១២០២) ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជួសខ្លួនបាន។

៤.១៤.៣ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

៤.១៤.៣.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង។

៤.១៤.៣.២ កម្មវត្ថុនៃពាក្យបណ្តឹង។

៤.១៤.៣.៣ ប្រភេទនៃអំពើល្មើស។

៤.១៤.៣.៤ ពេលវេលា និងទីកន្លែងនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

៤.១៤.៣.៥ បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោតដែលបានរំលោភ។

៤.១៤.៣.៦ អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់។

៩.១៤.៣.៧ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)។

៩.១៤.៣.៨ ភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)។

៩.១៤.៤ ពាក្យបណ្ដឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្ដឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

៩.១៤.៥ ក្នុងដំណើរការប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ថ្ងៃធ្វើការត្រូវបានកំណត់គិតទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ប៉ុន្តែការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការទេ។

៩.១៤.៦ ពាក្យបណ្ដឹងតវ៉ាអាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ទៅតាមករណីដូចខាងក្រោម៖

៩.១៤.៦.១ សាមីអ្នកប្ដឹងតវ៉ាជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិក កបឃ.ស ក្នុងតំណែង ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូងនៃការិយាល័យបោះឆ្នោតណាមួយនៅរាជធានី ខេត្ត ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូងនៅរាជធានី ខេត្តផ្សេង។

៩.១៤.៦.២ សាមីអ្នកប្ដឹងតវ៉ាជាតំណាងរាស្ត្រក្នុងតំណែង ឬជាសមាជិក កបឃ.ស ក្នុងតំណែងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ព័ន្ធដែលបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូងមានភាពមិនច្បាស់លាស់ ឬមិនដូចគ្នានឹងទិន្នន័យក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងរបស់គាត់។

៩.១៤.៧ ពាក្យបណ្ដឹងជំទាស់ អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង៖

៩.១៤.៧.១ ក្នុងករណីដែលជននោះគ្មានសិទ្ធិបោះឆ្នោត ដោយសារមិនមែនជាតំណាងរាស្ត្រក្នុងតំណែង ឬមិនមែនជាសមាជិក កបឃ.ស ក្នុងតំណែងនៅក្នុងក្របខណ្ឌនៃភូមិភាគនីមួយៗ។

៩.១៤.៧.២ ក្នុងករណីដែលជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

## ការដាក់ ការទទួលពាក្យបណ្តឹងនៅ គធ.ខប

៩.១៤.៨ អ្នកប្តឹងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬ ៤ (បួន) ច្បាប់ (ករណីប្តឹងជំទាស់)។ អ្នកប្តឹងដំបូងអាចថតចម្លងពាក្យបណ្តឹង (ទ.១២០២) ដែលខ្លួនបានបំពេញរួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹង ឬតវ៉ាជូសខ្លួនបាន។

៩.១៤.៩ នៅពេលបានទទួលពាក្យបណ្តឹង សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ទី២ កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

៩.១៤.១០ បន្ទាប់មកសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

៩.១៤.១១ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

៩.១៤.១១.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១៤.១១.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៩.១៤.៣ ខាងលើនេះ ឬតំណាងមិនមានលិខិត

ប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១៩.១១.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងមានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) រក្សាទុកក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

៩.១៩.១២ គធ.ខប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

៩.១៩.១៣ ក្នុងករណីដែល គធ.ខប ប្រជុំសម្រេចបដិសេធមិនទទួលពាក្យបណ្តឹង គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាចទទួលយកមកដោះស្រាយបានទៅអ្នកប្តឹង ឬតំណាង ហើយផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១៩.១៤ ក្នុងករណីដែល គធ.ឧប បើកសវនាការសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹង គធ.ឧប ត្រូវចេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៤ (បួន)ច្បាប់ (ករណីប្តឹងជំទាស់)។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ឈ្មោះ ហើយបោះត្រា គធ.ឧប និងចុះកាលបរិច្ឆេទ រួចត្រូវជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១៩.១៥ បន្ទាប់ពី គធ.ឧប បើកសវនាការលើពាក្យបណ្តឹងតវ៉ា ក្នុងករណីដែល៖

៩.១៩.១៥.១ បដិសេធលើពាក្យបណ្តឹងតវ៉ា៖ គធ.ឧប ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ឧប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៩.១៩.១៥.២ យល់ព្រមលើពាក្យបណ្តឹងតវ៉ា៖ គធ.ឧប ធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដើម្បីសុំបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតជំបូងនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

៩.១៩.១៦ បន្ទាប់ពី គធ.ឧប បើកសវនាការលើពាក្យបណ្តឹងជំទាស់ ក្នុងករណីដែល៖

៩.១៩.១៦.១ បដិសេធលើពាក្យបណ្តឹងជំទាស់៖ គធ.ឧប ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គធ.ឧប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៩.១៩.១៦.២ យល់ព្រមលើពាក្យបណ្តឹងជំទាស់៖ គធ.ឧប ជូនដំណឹងទៅអ្នកដែលត្រូវគេប្តឹងជំទាស់ថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ឧប ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) ព្រមទាំងធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប ដោយភ្ជាប់ជាមួយសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៩.១៩.១៧ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ឧប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៩ នៃ ប.ន.ព.ស នេះ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

### ការដាក់ ការទទួលពាក្យបណ្ដឹងនៅ គ.ជ.ប

៩.១៩.១៨ អ្នកប្ដឹងតវ៉ា ឬអ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្ដីសម្រេចរបស់ គធ.ខប មានសិទ្ធិប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប។

៩.១៩.១៩ អ្នកប្ដឹង ឬតំណាងត្រូវបំពេញពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្ដឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ករណីប្ដឹងជំទាស់)។

៩.១៩.២០ នៅពេលបានទទួលពាក្យបណ្ដឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង ទី២ កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប។

៩.១៩.២១ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនោះ។

៩.១៩.២២ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

៩.១៩.២២.១ ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្ដីសម្រេច(ទ.១២០៣)របស់ គធ.ខប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១៩.២២.២ ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៩.១៩.៣ ខាងលើនេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិន

ត្រឹមត្រូវ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយ កត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែល ដល់ពេលកំណត់អ្នកប្ដឹង ឬតំណាងមិនបានបំពេញបន្ថែមនូវ ចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្ដឹង នោះដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬ តំណាង១(មួយ)ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១(មួយ)ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១៩.២២.៣ ពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងឬសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប និងមានព័ត៌មានចាំបាច់ និងមាន លិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ មន្ត្រីជំនាញនៃនាយកដ្ឋាន សេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងឈ្មោះលើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន អ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកប្រើ ក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជា សាធារណៈ ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

៩.១៩.២៣ គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្ដឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង (ទ.១២០២)។

៩.១៩.២៤ ក្នុងករណីដែល គ.ជ.ប ប្រជុំសម្រេចបដិសេធមិនទទួលពាក្យបណ្ដឹង គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធ ដោយបញ្ជាក់ពីមូលហេតុដែលមិនអាច ទទួលយកមកដោះស្រាយបានទៅអ្នកប្ដឹង ឬតំណាង ហើយប្រគល់ជូន អ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ករណីប្ដឹងជំទាស់) ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១៩.២៥ ក្នុងករណីដែល គ.ជ.ប បើកសវនាការសង្ខេប ឬជាសាធារណៈសម្រេច យល់ព្រម ឬបដិសេធលើពាក្យបណ្ដឹង គ.ជ.ប ត្រូវចេញសម្រង់សេចក្ដីសម្រេច

(ទ.១២០៣) ចំនួន ៤ (បួន) ច្បាប់ (ករណីប្តឹងតវ៉ា) ឬចំនួន ៥ (ប្រាំ) ច្បាប់ (ករណីប្តឹងជំទាស់)។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ត្រូវចុះហត្ថលេខាឈ្មោះ ដោយប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចត្រូវជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូន ឬផ្ញើជូនអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ករណីប្តឹងជំទាស់) ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១៤.២៦ បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្តឹងតវ៉ា ក្នុងករណីដែលៈ

៩.១៤.២៦.១ បដិសេធលើពាក្យបណ្តឹងតវ៉ាៈ គ.ជ.ប ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៩.១៤.២៦.២ យល់ព្រមលើពាក្យបណ្តឹងតវ៉ាៈ គ.ជ.ប ចាត់ចែងអនុវត្តការចុះឈ្មោះបោះឆ្នោត ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតដូចមានចែងក្នុងចំណុច ៩.១៥.២.១ ខាងក្រោមនេះ។

៩.១៤.២៧ បន្ទាប់ពី គ.ជ.ប បើកសវនាការសម្រេចលើពាក្យបណ្តឹងជំទាស់ ក្នុងករណីដែលៈ

៩.១៤.២៧.១ បដិសេធលើពាក្យបណ្តឹងជំទាស់ៈ គ.ជ.ប ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៩.១៤.២៧.២ យល់ព្រមលើពាក្យបណ្តឹងជំទាស់ៈ គ.ជ.ប ជម្រាបអ្នកត្រូវគេប្តឹងជំទាស់ថា គាត់អាចប្តឹងទៅនឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៩.១៤.២៨ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៩ នៃ ប.ន.ព.ស នេះ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ការដាក់ ការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៤.១៤.២៩ អ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គ.ជ.ប។

៤.១៤.៣០ ការដាក់ និងការទទួលពាក្យបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៤.១៤.៣១ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

៤.១៤.៣២ ការដោះស្រាយពាក្យបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

៤.១៤.៣៣ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្ដីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

៤.១៤.៣៤ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ខប ឬសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប ឬសេចក្ដីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាធម្មនុញ្ញ

**ប្រការ៤.១៥.-**

សេចក្ដីសម្រេចស្ថាពររបស់ គធ.ខប ឬសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប ឬសេចក្ដីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវអនុវត្តដូចខាងក្រោម៖

### ការអនុវត្តសេចក្ដីសម្រេចស្ថាពររបស់ គធ.ខប

៤.១៥.១ បន្ទាប់ពីបានទទួលរបាយការណ៍ដែលមានភ្ជាប់មកជាមួយនូវសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ដូចមានចែងក្នុងចំណុច ៤.១៤.១៥.២ និងចំណុច ៤.១៤.១៦.២ ខាងលើនេះ ដែលបានចូលជាស្ថាពរហើយ ក្នុងករណីដែល៖

៤.១៥.១.១ យល់ព្រមលើពាក្យបណ្ដឹងតវ៉ា៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

៤.១៥.១.២ យល់ព្រមលើពាក្យបណ្តឹងជំទាស់៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតលុបឈ្មោះអ្នកដែលត្រូវគេប្តឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

**ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ គ.ជ.ប**

៤.១៥.២ បន្ទាប់ពីសេចក្តីសម្រេចរបស់ គ.ជ.ប បានចូលជាស្ថាពរហើយ ក្នុងករណីដែល៖

៤.១៥.២.១ យល់ព្រមលើពាក្យបណ្តឹងតវ៉ា៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

៤.១៥.២.២ យល់ព្រមលើពាក្យបណ្តឹងជំទាស់៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតលុបឈ្មោះអ្នកដែលត្រូវគេប្តឹងជំទាស់ ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

**ការអនុវត្តសេចក្តីសម្រេចស្ថាពររបស់ក្រុមប្រឹក្សាធម្មនុញ្ញ**

៤.១៥.៣ បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងករណីដែល៖

៤.១៥.៣.១ យល់ព្រមលើពាក្យបណ្តឹងតវ៉ា៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតបញ្ចូលឈ្មោះ ឬកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់ និងផ្ញើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ ជូន គធ.ខប ពាក់ព័ន្ធដើម្បីជាព័ត៌មាន និងទុកជាឯកសារ។

៤.១៥.៣.២ យល់ព្រមលើពាក្យបណ្តឹងជំទាស់៖ គ.ជ.ប ចាត់ឱ្យនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតលុបឈ្មោះអ្នកដែលត្រូវគេប្តឹងជំទាស់ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធជាបន្ទាន់។

**ប្រការ៤.១៦.-**

គ.ជ.ប ត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ជាផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ក្នុងរយៈពេលយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃមុនថ្ងៃបោះឆ្នោត។

**ប្រការ៤.១៧.-**

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវធានាថា សេចក្តីព្រាងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងទម្រង់ឯកភាពតែមួយ ដែលបានពិនិត្យកែតម្រូវរួចក្នុងប្រព័ន្ធកុំព្យូទ័រត្រូវតែបានបោះពុម្ពដោយឡែកពីគ្នាតាមការិយាល័យបោះឆ្នោតនីមួយៗ និងដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

៤.១៧.១ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរៀបចំក្នុងប្រព័ន្ធកុំព្យូទ័រនូវសេចក្តីព្រាងបញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗដែលមានទិន្នន័យដូចខាងក្រោម៖

- លេខរៀងភូមិភាគ
- លេខកូដ និងឈ្មោះរាជធានី ខេត្ត
- លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត
- ប្រអប់តូចសម្រាប់គូសសម្គាល់ពេលមកបោះឆ្នោត
- លេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត
- អត្តលេខ (បញ្ជីបោះឆ្នោតសកល)
- រូបថត
- នាមត្រកូល និងនាមខ្លួន ដែលរៀបចំតាមលំដាប់អក្ខរក្រមខ្មែរ
- ភេទ
- ថ្ងៃខែឆ្នាំកំណើត
- ឋានៈក្នុងតំណែងតាមអង្គបោះឆ្នោត
- លំនៅឋាន ឬទីសំណាក់នៃអ្នកបោះឆ្នោត
- ការបញ្ជាក់ចំនួនអ្នកបោះឆ្នោតសរុបក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនីមួយៗ
- ការបញ្ជាក់ថា ជាបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅគ្រប់ទំព័រ
- ចន្លោះបម្រុងទុកសម្រាប់ការចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប នៅលើទំព័រចុងក្រោយ។

៤.១៧.២ សេចក្តីព្រាងបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗដូចមានចែងក្នុងចំណុច ៤.១៧.១ ខាងលើនេះ ត្រូវដាក់ជូន គ.ជ.ប ចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការនៅលើទំព័រចុងក្រោយ។ នៅគ្រប់ទំព័រផ្សេងទៀតនៃបញ្ជីបោះឆ្នោតផ្លូវការនេះ ក្រៅពីទំព័រចុងក្រោយក៏ត្រូវមានបោះត្រា គ.ជ.ប ផងដែរ។

៤.១៧.៣ ច្បាប់ដើមនៃបញ្ជីបោះឆ្នោតផ្លូវការតាមការិយាល័យបោះឆ្នោតនីមួយៗ ១ (មួយ) ច្បាប់ ត្រូវរក្សាទុកជាឯកសារនៅ គ.ជ.ប។

៤.១៧.៤ បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនីមួយៗដូចមានចែងក្នុងចំណុច ៤.១៧.៣ ខាងលើនេះ ត្រូវបានថតចម្លងបន្ថែមចំនួន ៥ (ប្រាំ) ច្បាប់ទៀត ដែលត្រូវរៀបចំតាមលំដាប់លេខកូដនៃការិយាល័យបោះឆ្នោតដែលមានទីតាំងនៅទីប្រជុំជនរាជធានី ខេត្ត និងវេចខ្ចប់ដោយឡែកពីគ្នាតាមរាជធានី ខេត្ត នីមួយៗ។ ក្នុងការវេចខ្ចប់បញ្ជីបោះឆ្នោតផ្លូវការនេះ ត្រូវតែត្រៀមលក្ខណៈសម្រាប់បែងចែកជាស្រេចឱ្យដល់ គជ.ខប ចំនួន ៣ (បី) ច្បាប់ និង គ.ក.ប នីមួយៗចំនួន ២ (ពីរ) ច្បាប់។

៤.១៧.៥ រាល់កញ្ចប់បញ្ជីបោះឆ្នោតផ្លូវការដែលវេចខ្ចប់ និងបញ្ជូនខាងលើនេះ ត្រូវតែមានសម្គាល់លេខរៀងភូមិភាគ ឈ្មោះរាជធានី ខេត្ត ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្ត ព្រមទាំងគោលដៅដែលត្រូវទទួល និងការប្រើប្រាស់បញ្ជីបោះឆ្នោតនោះ។

៤.១៧.៦ បញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលត្រូវបាន គ.ជ.ប ផ្តល់សុពលភាពរួចហើយ មិនអាចកែប្រែបានទេ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព។

៤.១៧.៧ ក្នុងករណីមានតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព រដ្ឋសភា ឬក្រសួងមហាផ្ទៃត្រូវបំពេញបែបបទផ្លាស់ប្តូរសមាជិកនោះ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យ គ.ជ.ប ដាក់ជំនួសក្នុងបញ្ជីបោះឆ្នោតផ្លូវការ។

៤.១៧.៨ គ.ជ.ប ត្រូវធានាថា នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសបានចាត់វិធានការហ្មត់ចត់ ក្នុងការថែរក្សាសុវត្ថិភាពបញ្ជីបោះឆ្នោតផ្លូវការដូចមានចែងក្នុងចំណុច ៤.១៧.១ ខាងលើនេះ ជាឯកសាររបស់ គ.ជ.ប និងរក្សាសុវត្ថិភាពទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការនេះក្នុងប្រព័ន្ធកុំព្យូទ័របានល្អប្រសើរ។

៤.១៧.៩ គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិស្នើសុំបញ្ជីបោះឆ្នោតផ្លូវការច្បាប់ថតចម្លងបានដោយបង់ថ្លៃ។ តម្លៃនេះ ត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ។ ម្យ៉ាងទៀតក៏អាចទទួលបាននូវទិន្នន័យ

បញ្ជីបោះឆ្នោតតាមទម្រង់ PDF ដែលបង្ហាញទិន្នន័យអំពីលេខរៀងភូមិភាគ លេខកូដ និងឈ្មោះរាជធានី ខេត្ត លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត នាមត្រកូល និងនាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើត តាមតម្លៃផលិត។

៤.១៧.១០ គ.ជ.ប ត្រូវបង្ហោះបញ្ជីបោះឆ្នោតផ្លូវការនៅលើគេហទំព័រ voterlist.nec.gov.kh និង Mobile App (NEC KH)។ ទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការ ត្រូវបានរក្សាទុកដោយសុវត្ថិភាព (Backup Database) និងអាចត្រួតពិនិត្យបាន។

## លក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

### ប្រការ៤.១៨.-

អ្នកមានសិទ្ធិបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គឺតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង នៅក្នុងក្របខណ្ឌនៃភូមិភាគនីមួយៗ។ គ.ជ.ប ត្រូវណែនាំដល់អ្នកបោះឆ្នោត អង្គបោះឆ្នោត អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធអំពីសិទ្ធិបោះឆ្នោត និងលក្ខខណ្ឌសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៤.១៨.១ ដើម្បីមានសិទ្ធិបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង ត្រូវមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងមាន អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង។

៤.១៨.២ នៅថ្ងៃបោះឆ្នោត តំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងណាដែលគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ទោះបីមាន អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង ក៏ដោយ ក៏មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដែរ។

៤.១៨.៣ នៅថ្ងៃបោះឆ្នោត តំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការហើយ ប៉ុន្តែស្ថិតក្នុងស្ថានភាពដូចខាងក្រោមនេះ មិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ។

៤.១៨.៣.១ ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត។

៤.១៨.៣.២ ជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

៤.១៨.៤ ឈ្មោះអ្នកបោះឆ្នោតនៅក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង ត្រូវតែដូចគ្នានឹងឈ្មោះអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតផ្លូវការ។

៤.១៨.៥ ដើម្បីជួយដល់អ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានយល់ដឹងច្បាស់អំពីលេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត លេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ព្រមទាំងប្រភេទឯកសារដែលត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គ.ជ.ប ត្រូវអនុវត្តការផ្តល់បណ្ណព័ត៌មានអ្នកបោះឆ្នោត។ ដំណើរការផលិត និងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប។

## ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

### ប្រការ៤.១៩.-

គ.ជ.ប ត្រូវកំណត់ក្នុងជំហានដំបូងនូវការិយាល័យបោះឆ្នោតចំនួនមួយ ឬច្រើនដែលមានទីតាំងនៅទីប្រជុំជននៃរាជធានី ខេត្តនីមួយៗចំណុះភូមិភាគពាក់ព័ន្ធនៅក្នុងរយៈពេលយ៉ាងតិច ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមចុះឈ្មោះបោះឆ្នោត។ ចំនួន និងទីតាំងការិយាល័យបោះឆ្នោត អាចនឹងកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប បន្ទាប់ពីការចុះឈ្មោះបោះឆ្នោត បានបញ្ចប់ និងត្រូវធ្វើឱ្យហើយរួចរាល់នៅក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ការិយាល័យបោះឆ្នោតទាំងអស់នឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត នៅពេលរាប់សន្លឹកឆ្នោត។

៤.១៩.១ សម្រាប់ការចុះឈ្មោះបោះឆ្នោតបម្រើការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការកំណត់ចំនួនការិយាល័យបោះឆ្នោតដែលមានទីតាំងនៅទីប្រជុំជនរាជធានី ខេត្តនីមួយៗ ត្រូវផ្អែកលើមូលដ្ឋានចំនួនសរុបនៃអ្នកបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៅក្នុងក្របខណ្ឌរាជធានី ខេត្តនីមួយៗ ចំណុះភូមិភាគពាក់ព័ន្ធ។

៤.១៩.២ ការកែសម្រួលទីតាំងការិយាល័យបោះឆ្នោត ឬ/និងការបង្កើតការិយាល័យបោះឆ្នោតថ្មីនៅទីប្រជុំជននៃរាជធានី ខេត្តនីមួយៗចំណុះភូមិភាគពាក់ព័ន្ធ ត្រូវគោរពតាមលក្ខខណ្ឌជាក់ស្តែង និងសុវត្ថិភាពនៃកិច្ចប្រតិបត្តិការបោះឆ្នោត។

៤.១៩.៣ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបម្រើឱ្យតំបន់បោះឆ្នោតមួយដែលបានកំណត់។ ការិយាល័យបោះឆ្នោត និងតំបន់បោះឆ្នោតស្ថិតក្នុងដែនសមត្ថកិច្ចដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវតែរួមបញ្ចូលនូវសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងនៅក្នុងក្រុង ស្រុក ខណ្ឌមួយចំនួន ដែលស្ថិតក្នុងព្រំប្រទល់រដ្ឋបាលរាជធានី ខេត្តនីមួយៗចំណុះភូមិភាគពាក់ព័ន្ធ និងអាចបន្ថែមតំណាងរាស្ត្រក្នុងតំណែងនៃមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ។

៤.១៩.៤ គ.ជ.ប ត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីបង្កើតការិយាល័យបោះឆ្នោតមួយ ឬច្រើននៅទីប្រជុំជនរាជធានី ខេត្ត សម្រាប់សមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងក្នុងរាជធានី ខេត្តនោះ និងតំណាងរាស្ត្រក្នុងតំណែងនៃមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធនោះបានចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតទាំងអស់គ្នា។

៤.១៩.៥ ការិយាល័យបោះឆ្នោតមួយ ត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹមចំនួន ៧៥០ (ប្រាំពីររយហាសិប) នាក់។

៤.១៩.៦ ការិយាល័យបោះឆ្នោតដែលបញ្ជីបោះឆ្នោតនៃការិយាល័យនោះត្រូវបានផ្តល់សុពលភាពជាផ្លូវការដោយ គ.ជ.ប និងត្រូវប្រើជាការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៤.១៩.៧ ការិយាល័យបោះឆ្នោតគឺជាការិយាល័យនៅមួយកន្លែងដែល គ.ជ.ប បង្កើតឡើងនៅទីតាំងជាក់លាក់មួយសម្រាប់តំបន់បោះឆ្នោតមួយជាកំណត់ ហើយដែលត្រូវបើកទទួលអ្នកបោះឆ្នោតទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះមកបោះឆ្នោតនៅថ្ងៃបោះឆ្នោត។

៤.១៩.៨ ក្នុងការកំណត់ទីតាំងការិយាល័យបោះឆ្នោត ត្រូវយកចិត្តទុកដាក់ចំពោះទីតាំងសាលារៀន ទីវត្តអារាម និងទីសាធារណៈ និងបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាព។

៤.១៩.៩ ការិយាល័យបោះឆ្នោតមិនត្រូវបានបង្កើតនៅក្នុងបរិវេណទីធ្លា និងអគាររបស់រាជរដ្ឋាភិបាល ដូចជា សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ សង្កាត់ជាដើម ឬនៅបន្ទាយ ឬអគារនៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ ឬ/និងអគាររបស់គណបក្សនយោបាយនៅគ្រប់លំដាប់ថ្នាក់។

## ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

### ប្រការ៤.២០.-

គ.ជ.ប ត្រូវផ្សព្វផ្សាយ និងត្រូវបោះពុម្ពផ្សាយនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅតាមដំណាក់កាលនីមួយៗទៅអគ្គលេខាធិការដ្ឋានរដ្ឋសភា លធ.ឧប ឬ គធ.ឧប និង កបឃ.ស ដើម្បីចាត់ចែងបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតទាំងនោះនៅតាមទីកន្លែង និងតាមកាលបរិច្ឆេទដែល គ.ជ.ប បានកំណត់។

៤.២០.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត តាមគេហទំព័រ www.nec.gov.kh និង Mobile App (NEC KH)។

៤.២០.២ គ.ជ.ប ត្រូវណែនាំអគ្គលេខាធិការដ្ឋានរដ្ឋសភា លធ.ខប និង កបឃ.ស ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា លធ.ខប និងសាលាឃុំ សង្កាត់ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត។

៤.២០.៣ នៅក្រោយពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត និងបន្ទាប់ពីបានកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប នូវចំនួន និងទីតាំងការិយាល័យបោះឆ្នោត គ.ជ.ប ត្រូវណែនាំ គធ.ខប ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា នៅ លគធ.ខប នៅតាមសាលាឃុំ សង្កាត់ នៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ និងនៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនរាជធានី ខេត្ត យ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៤.២០.៤ តំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង គណបក្សនយោបាយ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិស្នើសុំពី គ.ជ.ប នូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតផ្លូវការនៃរាជធានី ខេត្តមួយ ឬច្រើន ឬនៃភូមិភាគមួយ ឬច្រើន ដោយត្រូវបង់ថ្លៃត្រឹមតម្លៃផលិត។ ការផ្គត់ផ្គង់ចំពោះការស្នើសុំនេះ ត្រូវផ្អែកតាមលំដាប់មុនក្រោយនៃការស្នើសុំ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់មុនស្មើនឹង ១០០ (មួយរយ) ភាគរយនៃតម្លៃផលិត។

## ទីតាំងរដ្ឋបាល និងសន្តិសុខសម្រាប់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

## ប្រការ៤.២១._

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ គឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ។

៤.២១.១ បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអគារដែលការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាំងនៅ ហើយដែលខណ្ឌដោយរង្វង់មណ្ឌលមួយមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចូលមួយ និងច្រកចេញមួយ។

៤.២១.២ បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលខណ្ឌដោយវណ្ឌមណ្ឌលមានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬតូចជាង អាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជាបរិវេណរបងនៃសាលារៀន វត្តអារាម សាលមហោស្រព ឬទីសាធារណៈ ជាដើម។

៤.២១.៣ នៅទីប្រជុំជន បរិវេណខាងក្រៅត្រូវបានកំណត់ដោយ គធ.ខប ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងតំបន់នោះ។

៤.២១.៤ នៅតំបន់ទីប្រជុំជន ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមួយតាំងនៅប្រមាណ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យពាក់ព័ន្ធមួយផ្សេងទៀត មួយផ្នែកនៃផ្លូវនេះ ត្រូវតែបិទចរាចរណ៍។

## វិធានការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់

### ប្រការ៤.២២.-

ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន ការអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប គធ.ខប និង គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានាដូចខាងក្រោម៖

៤.២២.១ ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែក្នុងករណីមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលប្រធាន គ.ជ.ប ឬ/និង ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មានភារកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ស្របតាមលក្ខខណ្ឌដូចមានចែងក្នុង ច.ប.ព.ស។

៤.២២.១.១ ប្រធាន គ.ជ.ប និងប្រធាន គធ.ខប ត្រូវប្រគល់សិទ្ធិអំណាចពេញលេញឱ្យដល់ប្រធាន គ.ក.ប/គ.ក.រ ក្នុងការស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីដូចបញ្ជាក់ក្នុងចំណុច ៤.២២.១ ខាងលើនេះ។

៤.២២.១.២ ក្នុងករណីមានសំណូមពរពីប្រធាន គ.ក.ប/គ.ក.រ ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតណាមួយនោះ ភ្នាក់ងារសន្តិសុខបោះឆ្នោតមានបំពាក់អាវុធដែលត្រូវបានចាត់តាំងអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធ។

៤.២២.២ ហាមយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិណាម្នាក់ក្នុងឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខ លើកលែងតែក្នុងករណីអ្នកទាំងនោះត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានប្រធាន គ.ក.ប/គ.ក.រ ស្នើសុំឱ្យធ្វើអន្តរាគមន៍ដូចមានចែងក្នុងចំណុច ៤.២២.១.២ និងលក្ខខណ្ឌទាំងឡាយក្នុងចំណុច ៤.២២.១ ខាងលើនេះ។

៤.២២.៣ ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត មុនពេលចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖

៤.២២.៣.១ មន្ត្រីបោះឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប។

៤.២២.៣.២ ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលបានអនុញ្ញាតហើយមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ខប។

៤.២២.៣.៣ អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬដោយ គធ.ខប។

៤.២២.៣.៤ អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប។

៤.២២.៣.៥ អ្នកដែលមានសិទ្ធិបោះឆ្នោតហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

៤.២២.៣.៦ ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនមានពិការភាព តាមលក្ខខណ្ឌដូចមានចែងក្នុង ច.ប.ត.រ។

៤.២២.៣.៧ ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.ប ធ្វើសំណូមពរ ក្នុងករណីចាំបាច់។

៤.២២.៤ ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត មុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖

៤.២២.៤.១ មន្ត្រីរាប់សន្លឹកឆ្នោតដែលបានទទួលការតែងតាំងពី គ.ជ.ប។

៤.២២.៤.២ ភ្នាក់ងារគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលបានអនុញ្ញាតហើយមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គធ.ខប។

៤.២២.៤.៣ អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ឬដោយ គធ.ខប។

៤.២២.៤.៤ អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប។

៤.២២.៤.៥ ភ្នាក់ងារសន្តិសុខបោះឆ្នោត និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធាន គ.ក.រ ធ្វើសំណូមពរ ក្នុងករណីចាំបាច់។

៤.២២.៥ សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖

៤.២២.៥.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៤.២២.៥.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោត បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។

៤.២២.៥.៣ ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៤.២២.៥.៤ ការរារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

៤.២២.៥.៥ ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

៤.២២.៥.៦ ការធ្វើសកម្មភាពនានាដែលនាំឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

៤.២២.៥.៧ ការបង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

៤.២២.៥.៨ ការធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

៤.២២.៥.៩ ការប្រើប្រាស់ឧបករណ៍ដែលអាចថតរូប ឬវីដេអូបាន នៅក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតផ្សេងពីនេះ ដោយ គ.ជ.ប។

៤.២២.៥.១០ ការធ្វើសកម្មភាពទាំងឡាយណាដែល ច.ប.ព.ស ច.ប.ត.រ ច.រ.ច.ប និង ប.ន.ព.ស ហាមឃាត់។

៤.២២.៦ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖

៤.២២.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៤.២២.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោតរាប់គំនូសនៅលើសន្លឹកឆ្នោត ដើម្បីបំពេញចិត្ត ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៤.២២.៦.៣ ការបង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

៤.២២.៦.៤ ការធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលរាប់សន្លឹកឆ្នោត។

៤.២២.៦.៥ ការធ្វើសកម្មភាពទាំងឡាយណាដែល ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះហាមឃាត់។

៤.២២.៧ ក្នុងករណីចាំបាច់ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចអនុវត្តនូវលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៤.២២.៣ និងចំណុច ៤.២២.៤ ខាងលើនេះ ចំពោះបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។

៤.២២.៨ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងណែនាំរបស់ គ.ជ.ប ស្របតាមលក្ខខណ្ឌនៃ ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ។

## វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ

### ប្រការ៤.២៣.-

គ.ជ.ប ត្រូវចាត់វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់ផ្សេងទៀត ដើម្បីបង្ការការពារ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

ជនគ្រប់រូបដែលនៅបរិវេណខាងក្នុង បរិវេណខាងក្រៅ និងក្នុងការិយាល័យបោះឆ្នោត ឬក្នុងការិយាល័យរាប់សន្លឹកឆ្នោតត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំផ្សេងៗ ស្តីពីវិធានការការពារ និងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ក្នុងករណីតម្រូវឱ្យអនុវត្ត។

### ប្រការ៤.២៤.-

ចំពោះការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេងដែលមានសុវត្ថិភាព។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណៈអំពីសេចក្តីសម្រេចនេះ។

### ប្រការ៤.២៥.-

សាលារៀន ទីវត្តអារាម រាល់សំណង់ អគារ សាល ឬទីសាធារណៈត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់គោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

# ជំពូកទី៥
# ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

## ភាពមានសិទ្ធិឈរឈ្មោះជាបេក្ខជន

### ប្រការ៥.១.-

ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ប្រជាពលរដ្ឋខ្មែរម្នាក់ៗ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

៥.១.១ មានសញ្ជាតិខ្មែរពីកំណើត។

៥.១.២ មានអាយុ ៤០ (សែសិប) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត។

៥.១.៣ មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត។

៥.១.៤ បានអនុវត្តសិទ្ធិបោះឆ្នោតដោយបានបោះឆ្នោតសម្រាប់ការបោះឆ្នោតជាសកលចំនួន២(ពីរ)លើកចុងក្រោយជាប់គ្នា ដែលរៀបចំឡើងដោយគ.ជ.ប លើកលែងតែករណីដែលការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតនេះមានមូលហេតុសមស្រប។

៥.១.៥ មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

៥.១.៦ មានការតែងតាំងពីគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត។

### ប្រការ៥.២.-

សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ បញ្ញត្តិដូចមានចែងក្នុងចំណុច ៥.១.៤ ខាងលើនេះ ត្រូវបានកំណត់យកត្រឹមការបោះឆ្នោតជាសកលមួយលើកចុងក្រោយ ដែលរៀបចំឡើងដោយ គ.ជ.ប គឺការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

### ប្រការ៥.៣.-

មូលហេតុសមស្របនៃការមិនអាចអនុវត្តសិទ្ធិបោះឆ្នោតពាក់ព័ន្ធនឹងលក្ខខណ្ឌដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដូចមានចែងក្នុងចំណុច ៥.១.៤ ខាងលើនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

៥.៣.១ ស្ថិតនៅក្រៅប្រទេស នៅថ្ងៃបោះឆ្នោត ដោយសារជាប់បំពេញបេសកកម្មផ្លូវការ ឬបំពេញការសិក្សា ឬបំពេញការងារដែលមានកិច្ចសន្យាការងារស្របច្បាប់។

៥.៣.២ មានជំងឺដែលមិនអាចទៅបោះឆ្នោតបាន នៅថ្ងៃបោះឆ្នោត។

៥.៣.៣ ស្ត្រីសម្រាលកូន នៅថ្ងៃបោះឆ្នោត។

៥.៣.៤ ត្រូវបានព្យួរសិទ្ធិបោះឆ្នោតជាបណ្ដោះអាសន្នស្របតាមច្បាប់ជាធរមាន។

៥.៣.៥ ករណីប្រធានសក្ដិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលអ្នកបោះឆ្នោតមិនអាចបោះឆ្នោតបានស្របតាមបទប្បញ្ញត្តិនៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

អ្នកបោះឆ្នោតដែលមិនបានអនុវត្តសិទ្ធិបោះឆ្នោត ដោយមូលហេតុសមស្របដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ហើយមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបញ្ជាក់ពីមូលហេតុជាលាយលក្ខណ៍អក្សរ និងត្រូវមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ ដល់ គ.ជ.ប។

## ភាពគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជន

### ប្រការ៥.៤.-

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាចំពោះ៖

៥.៤.១ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា ឬ

៥.៤.២ ជនដែលត្រូវបានតុលាការផ្ដន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ

៥.៤.៣ ជនដែលត្រូវបានផ្ដន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត

៥.៤.៤ ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

៥.៤.៥ ជនដែលត្រូវដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោតដោយ គ.ជ.ប ឬ

៥.៤.៦ សមាជិក គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ

៥.៤.៧ សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

៥.៤.៨ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។

## ការដាក់ពាក្យសុំច្បាប់ឈប់ពិសេស

### ប្រការ៥.៥.-

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនាដែល

មានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត។

៥.៥.១ លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ស្ថាប័ន ឬអង្គភាព អាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។ ក្នុងករណីមិនអាចធ្វើទាន់ គណបក្សនយោបាយ ត្រូវភ្ជាប់ច្បាប់ថតចម្លងលិខិតស្នើសុំអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ស្ថាប័ន ឬអង្គភាព ដោយមានចុះហត្ថលេខារបស់ថ្នាក់លើមួយថ្នាក់យ៉ាងតិច ដែលខ្លួននៅក្រោមឱវាទជូន គ.ជ.ប។ បេក្ខជនឈរឈ្មោះត្រូវធ្វើកិច្ចសន្យា តាមទម្រង់ដែលផ្តល់ជូនដោយ គ.ជ.ប ដើម្បីធានាថានឹងប្រគល់លិខិត អនុញ្ញាតច្បាប់ឈប់ពិសេស ដែលប្រធានក្រសួង ស្ថាប័ន ឬអង្គភាពសម្រេចជា ផ្លូវការមក គ.ជ.ប ឱ្យបានយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមបើក យុទ្ធនាការឃោសនាបោះឆ្នោត។

៥.៥.២ ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅ ក្រសួង ឬសាមីអង្គភាព ទៅបម្រើការក្រៅក្របខណ្ឌដើមក្នុងរយៈពេលអាណត្តិ របស់ខ្លួន។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខណ្ឌដើម សាមីខ្លួនត្រូវមានសិទ្ធិ ឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារ សម្រាប់ទទួលសោធននិវត្តន៍។

៥.៥.៣ នៅពេលចប់អាណត្តិជាសមាជិកព្រឹទ្ធសភា សាមីខ្លួនអាចសុំត្រឡប់មក បម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមី ក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច។

## ការប្រកាសបេក្ខភាពបេក្ខជនគណបក្សនយោបាយ

### ប្រការ៥.៦._

គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពី គណបក្សនយោបាយមានសិទ្ធិចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជី បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៥.៦.១ គណបក្សនយោបាយដូចមានចែងក្នុងប្រការ ៥.៦ ខាងលើនេះ ដែលមានបំណង ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវរៀបចំបញ្ជីបេក្ខជនរបស់ខ្លួនតាមភូមិភាគនីមួយៗ។ គណបក្សនយោបាយ

ដែលបានតែងតាំងបេក្ខជន ត្រូវបំពេញបែបបទសេចក្ដីប្រកាសបេក្ខភាព ដែលផ្ដល់ដោយ គ.ជ.ប។ បញ្ជីបេក្ខជនឈរឈ្មោះតាមភូមិភាគត្រូវៈ

៥.៦.១.១ ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ។

៥.៦.១.២ មានសេចក្ដីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរឃុំ សង្កាត់ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជាសកល។

៥.៦.១.៣ ភ្ជាប់សេចក្ដីប្រកាសរបស់បេក្ខជនយល់ព្រមទទួលការតែងតាំងជាបេក្ខជនតាមភូមិភាគរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។

៥.៦.២ បេក្ខជនម្នាក់ៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ភូមិភាគតែមួយគត់។ បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះលើសពីមួយភូមិភាគ ត្រូវបានប្រកាសថា បាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយ គ.ជ.ប ទោះបីជាសាមីខ្លួនទៅឈរឈ្មោះជាបេក្ខជនឈរឈ្មោះក្នុងគណបក្សនយោបាយផ្សេងទៀតក៏ដោយ។

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

### ប្រការ៥.៧.-

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវចាប់ផ្ដើម ៩០ (កៅសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត។

## លក្ខខណ្ឌ និងបែបបទក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

### ប្រការ៥.៨.-

ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាជាផ្លូវការ គណបក្សនយោបាយត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ តាមបែបបទកំណត់ដោយ គ.ជ.ប យ៉ាងយូរ ៧០ (ចិតសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត។

៥.៨.១ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ (ទ.១០០៨) ត្រូវបានផ្ដល់ដោយឥតគិតថ្លៃជូនគណបក្សនយោបាយ

ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ គណបក្សនយោបាយត្រូវបំពេញពាក្យសុំនេះ ចំនួន ២ (ពីរ) ច្បាប់។

៥.៨.២ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិនេះ មិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

៥.៨.៣ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ (ទ.១០០៨) ត្រូវភ្ជាប់មកជាមួយនូវ៖

៥.៨.៣.១ សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ជាសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្មដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឬការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ១ (មួយ) ច្បាប់។

៥.៨.៣.២ ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់គណបក្សនយោបាយ។

៥.៨.៣.៣ អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ។

៥.៨.៣.៤ បញ្ជីបេក្ខជនឈរឈ្មោះសរុបទូទាំងប្រទេស។ បញ្ជីនេះ ត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិច ១/៣ (មួយភាគបី) នៃចំនួនអាសនៈក្នុងព្រឹទ្ធសភា និងបេក្ខជនបម្រុងចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ ដោយមិនគិតអាសនៈដែលត្រូវបានចាត់តាំង និងជ្រើសតាំង។

៥.៨.៣.៥ ឈ្មោះភូមិភាគដែលគណបក្សនយោបាយមានបំណងទៅឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះតាមភូមិភាគទាំងនោះ។ បញ្ជីបេក្ខជនឈរឈ្មោះតាមភូមិភាគត្រូវមានបេក្ខជនគ្រប់តាមចំនួនកំណត់អាសនៈ និងបំពេញតាមគំរូដែល គ.ជ.ប ផ្តល់ឱ្យ។

៥.៨.៣.៦ សេចក្តីប្រកាសអំពីគណនីធនាគារដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗ រួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។

៥.៨.៣.៧ លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ស្តីពីការបង្កើតគណបក្សនយោបាយ។

៥.៨.៣.៨ សេចក្តីប្រកាសរបស់គណបក្សនយោបាយសន្យាថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលបោះឆ្នោតដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងចូលរួមអនុវត្ត ច.ប.ព.ស ច.ប.ត.រ ច.រ.ច.ប ប.ន.ព.ស នេះ ក្រមសីលធម៌របស់ គ.ជ.ប និងច្បាប់ស្តីពីគណបក្សនយោបាយ។

៥.៨.៣.៩ បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ។

៥.៨.៣.១០ បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួន១៥.០០០.០០០(ដប់ប្រាំលាន) រៀលដែលចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ។ ប្រាក់តម្កល់នេះត្រូវបានបង្វិលជូនទៅសាមីគណបក្សនយោបាយវិញ ក្នុងករណីដែលគណបក្សនយោបាយនោះបានទទួលសន្លឹកឆ្នោតយ៉ាងតិច ៣ (បី) ភាគរយនៃចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈ ១ (មួយ) ក្នុងព្រឹទ្ធសភា។

## ការដាក់ឱ្យប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

### ប្រការ៥.៩.-

គ.ជ.ប អាចដាក់ឱ្យប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដើម្បីជាជំនួយដល់គណបក្សនយោបាយដែលមានបំណងរៀបចំបញ្ជីបេក្ខជនឈរឈ្មោះតាមកម្មវិធី និងសម្រួលដល់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃបញ្ជីបេក្ខជនឈរឈ្មោះរបស់គណបក្សនយោបាយនីមួយៗ ដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប។

បែបបទ និងនីតិវិធីនៃការប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ គ.ជ.ប។

## ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

### ប្រការ៥.១០.-

គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៥.១០.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ ទីកន្លែង និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។

៥.១០.២ ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ដល់ម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) ដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី។

៥.១០.៣ គ.ជ.ប ត្រូវចេញបង្កាន់ដៃនៃការទទួលពាក្យជូនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីឈរឈ្មោះបោះឆ្នោតនិងរក្សាគល់បញ្ជីទុកជាឯកសារ។

៥.១០.៤ បង្កាន់ដៃនៃការទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារដែលបានទទួល ដោយត្រូវចុះកាលបរិច្ឆេទប្រគល់ ទទួល និងហត្ថលេខា ឬស្នាមមេដៃនៃអ្នកប្រគល់ទទួល។ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់និងវិវាទកម្មត្រូវបញ្ចូលព័ត៌មានរបស់គណបក្សនយោបាយ និងស្កេនបង្កាន់ដៃទទួលពាក្យនោះបញ្ចូលទៅក្នុងកម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ។

## ការពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

## ប្រការ៥.១១.-

គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

៥.១១.១ ក្នុងករណីយល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជូនសាមីគណបក្សនយោបាយ។

៥.១១.២ ក្នុងករណីពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយណាមួយពុំបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥.១ ប្រការ ៥.២ ប្រការ ៥.៣ ប្រការ ៥.៤ ប្រការ ៥.៦ ប្រការ ៥.៧ និងប្រការ ៥.៨ នៃ ប.ន.ព.ស នេះ គ.ជ.ប ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញ ដើម្បីបំពេញបន្ថែម។

៥.១១.២.១ សាមីគណបក្សនយោបាយត្រូវបំពេញលក្ខខណ្ឌដែលខ្វះខាតក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង។

៥.១១.២.២ ក្នុងករណីសាមីគណបក្សនយោបាយមិនបានបំពេញលក្ខខណ្ឌតាមការកំណត់រយៈពេលដូចមានចែងក្នុងចំណុច ៥.១១.២.១ ខាងលើនេះ គ.ជ.ប ចាត់ទុកថា សាមីគណបក្សនយោបាយនោះបោះបង់ការសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។

៥.១១.៣ ក្នុងករណីសម្រេចបដិសេធ គ.ជ.ប ត្រូវ៖

៥.១១.៣.១ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្តីសម្រេចបដិសេធចំនួន ៣ (បី) ច្បាប់ រួចត្រូវ៖

- ផ្ញើជូនសាមីគណបក្សនយោបាយ ឬតំណាង ១ (មួយ) ច្បាប់
- ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៥.១១.៣.២ ផ្តល់ព័ត៌មានទៅសាមីគណបក្សនយោបាយ ឬតំណាងថា គាត់អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ការដាក់ ការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

**ប្រការ៥.១២.-**

បេក្ខភាព ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ហើយត្រូវបានបដិសេធដោយ គ.ជ.ប សាមីខ្លួន ឬសាមីគណបក្សនយោបាយ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ។

៥.១២.១ ក្នុងករណីទទួលសេចក្តីសម្រេចបដិសេធហើយ ប៉ុន្តែសាមីគណបក្សនយោបាយ ឬតំណាង ពុំបានដាក់ពាក្យបណ្តឹងតវ៉ាទៅតាមពេលវេលាដូចមានចែងក្នុងប្រការ ៥.១២ ខាងលើនេះទេ ត្រូវចាត់ទុកថា សាមីគណបក្សនយោបាយនោះបានបោះបង់ចោលការសុំចុះបញ្ជីគណបក្សនយោបាយជាស្ថាពរ។

៥.១២.២ ការដាក់ និងការទទួលពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៥.១២.៣ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើពាក្យបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

៥.១២.៤ ការដោះស្រាយពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

៥.១២.៥ ក្នុងករណីយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

៥.១២.៦ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

### ការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

**ប្រការ៥.១៣.-**

បន្ទាប់ពីបានបញ្ចប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ឬ/និងក្រោយពេលដែលពាក្យបណ្តឹងតវ៉ាត្រូវបានដោះស្រាយជាស្ថាពរ គ.ជ.ប ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះតាមភូមិភាគរបស់គណបក្សនយោបាយទាំងនោះ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ព្រមទាំងបង្ហោះនៅលើគេហទំព័រ www.nec.gov.kh។

### សិទ្ធិទទួលបាននូវការការពារសុវត្ថិភាពរបស់បេក្ខជន

**ប្រការ៥.១៤.-**

បេក្ខជនម្នាក់ៗមានសិទ្ធិទទួលការការពារសន្តិសុខ និងសុវត្ថិភាពដូចមានចែងក្នុងមាត្រា៣២ នៃជំពូកទី៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៥.១៤.១ ប្រសិនបើបេក្ខជនអាចផ្តល់ភស្តុតាង ឬមានមូលហេតុច្បាស់លាស់ថា សន្តិសុខ និងសុវត្ថិភាពរបស់ខ្លួនត្រូវបាន និងកំពុងរងនូវការគំរាមកំហែងនោះ បេក្ខជនអាចប្តឹងទៅ គ.ជ.ប ជាបន្ទាន់។

៥.១៤.២ គ.ជ.ប ត្រូវប្រជុំការងារសន្តិសុខ ដើម្បីដោះស្រាយពាក្យបណ្តឹង ដោយបើកការស៊ើបអង្កេត ហើយទន្ទឹមគ្នានេះ ត្រូវចាត់វិធានការចាំបាច់គ្រប់រូបភាព ដើម្បីផ្តល់សន្តិសុខ និងសុវត្ថិភាពជូនបេក្ខជន។

## ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត

**ប្រការ៥.១៥.-**

គ.ជ.ប ត្រូវរៀបចំពិធីចាប់ឆ្នោតមួយ ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលនឹងត្រូវបោះពុម្ពលើសន្លឹកឆ្នោត។

៥.១៥.១ ផ្អែកលើបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការ គ.ជ.ប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត។

៥.១៥.២ ការចាប់ឆ្នោតត្រូវធ្វើឡើងជាសាធារណៈ។ គ.ជ.ប ត្រូវប្រកាសផ្សាយជាសាធារណៈ អំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ ២៤ (ម្ភៃបួន) ម៉ោង មុនការចាប់ផ្តើមពិធីចាប់ឆ្នោត។

៥.១៥.៣ លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការយ៉ាងហោចណាស់ ២៤(ម្ភៃបួន)ម៉ោងមុនពិធីចាប់ឆ្នោតចាប់ផ្តើម។ លិខិតអញ្ជើញនេះ ត្រូវមានហត្ថលេខារបស់អ្នកទទួល ដើម្បីទុកជាឯកសារ។

៥.១៥.៤ របៀបវារៈនៃពិធីចាប់ឆ្នោតមានដូចខាងក្រោមនេះ៖

- ៥.១៥.៤.១ សុន្ទរកថាបើកពិធី ថ្លែងដោយប្រធាន គ.ជ.ប។
- ៥.១៥.៤.២ ការបង្ហាញសន្លឹកឆ្នោត និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតសម្រាប់ចាប់ឆ្នោត។
- ៥.១៥.៤.៣ ការចាប់ឆ្នោតត្រូវធ្វើឡើងដោយព្រះសង្ឃ ឬឥស្សរជនចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ។
- ៥.១៥.៤.៤ ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត។
- ៥.១៥.៤.៥ ការបិទពិធីចាប់ឆ្នោត។

៥.១៥.៥ គ.ជ.ប ត្រូវរៀបចំសន្លឹកឆ្នោត ១ (មួយ) សន្លឹកសម្រាប់គណបក្សនយោបាយមួយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះរួចហើយ។

- ៥.១៥.៥.១ ក្រដាសសន្លឹកឆ្នោតត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា។
- ៥.១៥.៥.២ ឈ្មោះគណបក្សនយោបាយត្រូវបោះពុម្ពជាអក្សរ ដែលមានពណ៌ ប្រភេទ និងទំហំតួអក្សរដូចគ្នានៅលើសន្លឹកឆ្នោត។

៥.១៥.៥.៣ សន្លឹកឆ្នោត ១ (មួយ) សន្លឹក ដែលមានបោះពុម្ពឈ្មោះគណបក្សនយោបាយមួយ ត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នាដែលមិនអាចសម្គាល់បានរួចមូរ និងចងកៅស៊ូកងពណ៌ដូចគ្នា។

៥.១៥.៦ មុនចាប់ផ្ដើមធ្វើការចាប់ឆ្នោត គ.ជ.ប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយនីមួយៗនៅចំពោះមុខអង្គពិធី។

៥.១៥.៦.១ សន្លឹកឆ្នោតនីមួយៗត្រូវបត់ជាពីរផ្នត់ ហើយស៊កបញ្ចូលក្នុងស្រោមសំបុត្ររួចបិទភ្ជិតរួចមូរ និងចងកៅស៊ូកងពណ៌ដូចគ្នា។

៥.១៥.៦.២ សំបុត្រឆ្នោតទាំងអស់ត្រូវដាក់ក្នុងហិបឆ្នោតតែមួយ ហើយត្រូវច្របល់សំបុត្រឆ្នោតនោះ។

៥.១៥.៧ បន្ទាប់មកត្រូវនិមន្តព្រះសង្ឃ ឬអញ្ជើញឥស្សរជនដែលចូលនិវត្តន៍ ឬចាស់ព្រឹទ្ធាចារ្យដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ៥.១៥.៤.៣ ខាងលើនេះ ចាប់យកសំបុត្រឆ្នោតម្ដងមួយៗពីក្នុងហិបឆ្នោត។

៥.១៥.៧.១ សំបុត្រឆ្នោតដែលចាប់បាន ត្រូវប្រគល់ទៅមន្ត្រីបោះឆ្នោតម្នាក់ក្នុងចំណោមពីរនាក់។

៥.១៥.៧.២ មន្ត្រីបោះឆ្នោតមួយរូប ត្រូវបើកសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយនៅចំពោះមុខអង្គពិធី ហើយជូនសន្លឹកឆ្នោតនោះទៅឱ្យមន្ត្រីទីពីរ។

៥.១៥.៧.៣ មន្ត្រីទីពីរត្រូវអានឈ្មោះគណបក្សនយោបាយនៅលើសន្លឹកឆ្នោតឱ្យបានឮៗ និងសរសេរលេខរៀង "ទី១" នៅលើសន្លឹកឆ្នោតនោះ។

៥.១៥.៧.៤ លទ្ធផលនៃការចាប់ឆ្នោតត្រូវបង្ហាញក្នុងអង្គពិធី។

៥.១៥.៧.៥ ការចាប់ឆ្នោត និងចុះលេខរៀង ត្រូវធ្វើបន្តតាមលំដាប់រហូតដល់សំបុត្រឆ្នោតចុងក្រោយបង្អស់។

៥.១៥.៨ លេខាធិការនៃអង្គពិធីចាប់ឆ្នោត ត្រូវធានាបំពេញកំណត់ហេតុនៃពិធីចាប់ឆ្នោតកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតឱ្យបានរួចរាល់ ដោយត្រូវភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្សនយោបាយដែលបានចុះលេខរៀងរួចហើយ ដូចមានចែងក្នុងចំណុច ៥.១៥.៧.៣ និងចំណុច ៥.១៥.៧.៥ ខាងលើនេះ។

៥.១៥.៩ គ.ជ.ប ត្រូវធ្វើគំរូ និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់ភូមិភាគនីមួយៗ។

៥.១៥.៩.១ ការបោះពុម្ពសន្លឹកឆ្នោត ត្រូវផ្អែកតាមបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតផ្លូវការនៅតាមភូមិភាគ។ សន្លឹកឆ្នោតសម្រាប់ភូមិភាគណាប្រើប្រាស់បានតែនៅក្នុងភូមិភាគនោះតែប៉ុណ្ណោះ។

៥.១៥.៩.២ ឈ្មោះ និងសញ្ញាសម្គាល់គណបក្សនយោបាយនៅលើសន្លឹកឆ្នោតត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់គណបក្សនយោបាយត្រូវដាក់ជាលេខរៀងតាមលទ្ធផលនៃការចាប់ឆ្នោត។

**ប្រការ៥.១៦.-**

បញ្ជីបេក្ខជនផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ។

**ប្រការ៥.១៧.-**

គណបក្សនយោបាយ និងបេក្ខជននៅក្នុងបញ្ជីបេក្ខជនគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីជាផ្លូវការត្រូវគោរពតាម ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប ប.ន.ព.ស នេះ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត។

# ជំពូកទី៦
# ការឃោសនាបោះឆ្នោត

## គោលការណ៍នៃការឃោសនាបោះឆ្នោត

### ប្រការ៦.១._

អនុលោមតាម ច.ប.ព.ស និង ច.ប.ត.រ ការឃោសនាបោះឆ្នោតមានទិសដៅឱ្យបេក្ខជន និងគណបក្សនយោបាយដែលបានចុះបញ្ជីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត។

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើឡើងជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឱ្យបោះឆ្នោតគាំទ្របេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ មានដូចជា៖

៦.១.១ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន។

៦.១.២ ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅមណ្ឌលភូមិភាគនីមួយៗ ត្រូវកំណត់យ៉ាងច្រើន ២ (ពីរ) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

៦.១.៣ ការជួបជុំ ឬការឃោសនាតាមផ្ទះ។

៦.១.៤ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន។

៦.១.៥ ការផ្សព្វផ្សាយតាមរលកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ។

៦.១.៦ សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនាបោះឆ្នោតនានា។

៦.១.៧ សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ។

៦.១.៨ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀត ដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជនជូនអ្នកបោះឆ្នោត។

៦.១.៩ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទប្រកាសផ្សាយ។

៦.១.១០ ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត។

៦.១.១១ ការរៀបចំកម្មវិធីប្រកួតកីឡា។

**ប្រការ៦.២.-**

ការឃោសនាត្រូវបើករយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ (ដប់បួន) ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត។

៦.២.១ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើមពីម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០:០០ (ដប់) យប់។

៦.២.២ គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ១០:០០ (ដប់) យប់ ដល់ម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក។

៦.២.៣ សកម្មភាពឃោសនាបោះឆ្នោតដោយឧបករណ៍បំពងសំឡេងត្រូវបានកំណត់ដូចខាងក្រោម៖

- ត្រូវហាមឃាត់ចាប់ពីម៉ោង ១២:០០ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២:០០ (ពីរ) រសៀល
- ត្រូវហាមឃាត់នៅក្បែរមន្ទីរពេទ្យ
- ត្រូវហាមឃាត់នៅក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានាក្នុងពេលម៉ោងសិស្សកំពុងសិក្សា។

៦.២.៤ រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោតត្រូវបញ្ឈប់ ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីការបោះឆ្នោត។ រាល់ការរៀបចំការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង
- រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ
- ការគោរពសិទ្ធិ សេរីភាពរបស់បុគ្គល
- រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត

- ការមិនបង្កឱ្យមានអសន្តិសុខ ភាពចលាចល ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬការធ្វើឱ្យភាន់ច្រឡំក្នុងដំណើរការបោះឆ្នោត
- លទ្ធផលដែលបានមកពីការស្ទង់មតិ ត្រូវផ្តល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព។

៦.២.៥ គ្រប់សកម្មភាពឃោសនាបោះឆ្នោតដែលមានចែងក្នុងជំពូកទី៦ នៃ ប.ន.ព.ស នេះ ត្រូវបញ្ឈប់ទាំងអស់ក្នុងអំឡុងពេល ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។ ជនណាប្រព្រឹត្តល្មើសនឹងបម្រាមនេះ នឹងត្រូវទទួលការផាកពិន័យតាម ច.ប.ព.ស ច.ប.ត.រ និង ច.រ.ច.ប។

៦.២.៦ អ្នកបោះឆ្នោតជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែង អាចស្នាក់នៅជុំគ្នានៅមុនថ្ងៃបោះឆ្នោតមួយថ្ងៃក្នុងទីប្រជុំជនរាជធានី ខេត្តដែលការិយាល័យបោះឆ្នោតរបស់ពួកគាត់តាំងនៅ។ ការស្នាក់នៅនេះមិនចាត់ទុកថាជាសកម្មភាពឃោសនាបោះឆ្នោតឡើយ។

## ប្រការ៦.៣._

គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រឹមត្រូវតាម ច.ប.ព.ស អាចលើកស្លាកសញ្ញាគណបក្ស ឬបិទផ្សាយឯកសារឃោសនាបោះឆ្នោតបម្រើឱ្យគោលដៅឃោសនាបោះឆ្នោតបាននៅទីសាធារណៈ ឬនៅទីស្នាក់ការរបស់ខ្លួន ឬទីកន្លែងឯកជន ឬលំនៅឋានឯកជន ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

៦.៣.១ ស្លាកសញ្ញា និងសម្ភារឃោសនាបោះឆ្នោតផ្សេងៗរបស់គណបក្សនយោបាយ អាចលើក ឬបិទនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។

៦.៣.២ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៦.៣.៣ ហាមគណបក្សនយោបាយលើក ឬបិទស្លាកគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តបណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនបើមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិត្តបណ្ណរបស់គណបក្សណាមួយបាន។

៦.៣.៤ ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៦.៣.៥ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវបណ្ណប្រកាស ឬបណ្ណបិទផ្សាយ បដា ឯកសារឃោសនាបោះឆ្នោតទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។

**ប្រការ៦.៤.-**

ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះ មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះ មានលក្ខណៈជាឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹង គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៤.១ ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដែលមានផ្លាកលេខ ឬដោះផ្លាកលេខចេញ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងហាមប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋដែលមានផ្លាកលេខ ឬដោះផ្លាកលេខចេញ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

៦.៤.២ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ត្រូវបានកំណត់ដូចជា រថយន្ត ត្រីចក្រយានយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ផ្លាកលេខសម្គាល់យានជំនិះដែលមានអក្សររាជការ ឬ/និងរដ្ឋ នគរបាលខេមរភូមិន្ទ ឬ/និងរាជរដ្ឋាភិបាល។

៦.៤.៣ ការដឹកជញ្ជូនមានលក្ខណៈប្រមូលផ្តុំ ឬរៀបចំទុកជាមុនត្រូវហាមឃាត់ លើកលែងតែករណីចាំបាច់មានការសម្រេចផ្សេងពីនេះ ដោយ គ.ជ.ប។

**ប្រការ៦.៥.-**

ការស្លៀកពាក់ (សម្លៀកបំពាក់ មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា ឬសារនយោបាយ របស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរាប់បញ្ចូលទៅក្នុងសកម្មភាព ឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុង បរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត។

**ប្រការ៦.៦.-**

គណបក្សនយោបាយអាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតយ៉ាងច្រើន ២ (ពីរ) ដង នៅក្នុងមណ្ឌលភូមិភាគដែលគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះ។

៦.៦.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ដូចខាងក្រោម៖

៦.៦.១.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទត្រូវធ្វើឡើងក្នុងក្របខណ្ឌព្រំប្រទល់ភូមិភាគ ដែលសាមីគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

៦.៦.១.២ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឆ្លងភូមិភាគឡើយ។

៦.៦.១.៣ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទក្នុងរាជធានី ខេត្តចំណុះភូមិភាគ ឬការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទពីរាជធានី ខេត្តមួយទៅរាជធានី ខេត្តមួយផ្សេងទៀតក្នុងភូមិភាគដដែល ត្រូវបានចាត់ទុកថាជាការហែក្បួនចំនួន ១ (មួយ) ដង ក្នុងក្របខណ្ឌមណ្ឌលភូមិភាគ។

៦.៦.១.៤ គណបក្សនយោបាយដែលហែក្បួនឃោសនាបោះឆ្នោតក្នុងរាជធានី ខេត្តចំណុះភូមិភាគ ដែលខ្លួនមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយតម្រាយផ្លូវនៃក្បួនឃោសនានោះត្រូវឆ្លងកាត់រាជធានី ខេត្តដទៃ ដោយសារស្ថានភាពទីតាំងភូមិសាស្ត្រជាក់ស្តែងនៃរាជធានី ខេត្តនោះមានព្រំប្រទល់ជាប់គ្នា ដែលមិនអាចវាងបាន គណបក្សនយោបាយសាមីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ខប ពាក់ព័ន្ធយ៉ាងតិចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនាបោះឆ្នោត ទោះបីជារាជធានី ខេត្តដែលត្រូវឆ្លងកាត់នោះខ្លួនមាន ឬគ្មានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក៏ដោយ។ ក្នុងដំណើរឆ្លងកាត់នេះ សាមីគណបក្សនយោបាយត្រូវបិទឧបករណ៍បំពងសំឡេង និងផ្អាករាល់សកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន។

គជ.ខប ពាក់ព័ន្ធត្រូវស្នើសុំកិច្ចសហការ និងការសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចាត់វិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងពេលឃោសនាបោះឆ្នោត។

៦.៦.១.៥ ការហែក្បួនឃោសនាបោះឆ្នោត ត្រូវបានកំណត់ដោយទម្រង់ និងទំហំដូចខាងក្រោម៖

- មានការរៀបចំជាក្បួន មានបិទបដា ឬ/និងពាក្យស្លោក ឬ/និងសារនយោបាយនៅភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង
- ចំនួនអ្នកចូលរួមមានចាប់ពី ២០ (ម្ភៃ) នាក់ឡើងទៅ ដោយក្រុមថ្មើរជើង ឬ/និងប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ ក្នុងការឃោសនាបោះឆ្នោតមាន៖
  - រថយន្តចាប់ពី ២ (ពីរ) គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ១០ (ដប់) គ្រឿងឡើងទៅ
  - ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ២០ (ម្ភៃ) គ្រឿងឡើងទៅ
  - ជលយានគ្រប់ប្រភេទចាប់ពី ៥ (ប្រាំ) គ្រឿងឡើងទៅ។

៦.៦.២ គណបក្សនយោបាយមានបំណងហែក្បួនឃោសនាបោះឆ្នោត សាមីគណបក្សនយោបាយនោះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គជ.ខប ពាក់ព័ន្ធ យ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនឃោសនាបោះឆ្នោត។ ការជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី៖

៦.៦.២.១ នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ។

៦.៦.២.២ កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន។

៦.៦.២.៣ ទីតាំងប្រមូលផ្តុំ និងគម្រោងផ្លូវដែលត្រូវហែក្បួន និងទីតាំងរំសាយ។

៦.៦.២.៤ ចំនួនអ្នកចូលរួម។

៦.៦.២.៥ ចំនួនយានជំនិះតាមប្រភេទនីមួយៗ។

៦.៦.៣ គជ.ខប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីសម្របសម្រួល ទីកន្លែង ផ្លូវ ពេលវេលា និងកម្មវិធីនៃការហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ។

៦.៦.៤ ក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ត្រូវរក្សានូវសណ្តាប់ធ្នាប់ល្អតាមដងផ្លូវ ទីប្រជុំជន ទីសាធារណៈ និងត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

**ប្រការ៦.៧.-**

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវធ្វើសកម្មភាពដូចខាងក្រោម៖

៦.៧.១ ប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោតដូចជា ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។

៦.៧.២ ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋដើម្បីឃោសនាបោះឆ្នោតស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧.៣ ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ។ ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត ដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ដូចតទៅ៖

៦.៧.៣.១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៦.៧.៣.២ ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៦.៧.៣.៣ ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧.៣.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧.៣.៥ ការធ្វើសកម្មភាពចែកចាយសម្ភារដល់អ្នកបោះឆ្នោតក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៦.៧.៣.៦ ការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

៦.៧.៣.៧ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។

**ប្រការ៦.៨.-**

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន និងមិនត្រូវមានអាវុធជាប់នឹងខ្លួន ហើយមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

**ប្រការ៦.៩.-**

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេសត្រូវប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងនៅក្នុងការបោះឆ្នោត។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជាមិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីដូចខាងក្រោម៖

៦.៩.១ ផ្តួចផ្តើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្តួចផ្តើម ឬការចូលរួមឃោសនា រួមមាន៖

៦.៩.១.១ ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនាបោះឆ្នោត ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.១.២ ការចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.១.៣ ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.១.៤ ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៦.៩.២ ចេញសេចក្ដីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការចេញសេចក្ដីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀង រួមមាន៖

៦.៩.២.១ ការស្ទង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.២.២ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្ដល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.២.៣ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថ មាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.២.៤ ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.៣ ផ្ដល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការផ្ដល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស រួមមាន៖

៦.៩.៣.១ ការផ្ដល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.៣.២ ការផ្ដល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋសម្រាប់ចូលរួមឃោសនាបោះឆ្នោត ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.៣.៣ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារ សម្រាប់ក្បួនដង្ហែឃោសនាបោះឆ្នោត ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ព សម្ភារឃោសនាបោះឆ្នោត ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩.៤ ហាមជនបរទេសដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

**ប្រការ៦.១០.-**

មុននឹងបើកការឃោសនាបោះឆ្នោត គធ.ខប ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានកំណត់ក្នុងប្រការ ៦.៧ នៃ ប.ន.ព.ស នេះ តាមរយៈអាជ្ញាធរដែនដី កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីភារកិច្ច និងអព្យាក្រឹតភាពក្នុងម៉ោងធ្វើការ ទាក់ទិនដល់ការឃោសនាបោះឆ្នោត។

**ប្រការ៦.១១.-**

គធ.ខប ត្រូវរៀបចំកម្មវិធីប្រជុំប្រចាំសប្តាហ៍ និងតាមការចាំបាច់ជាមួយនឹងតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានា ដើម្បី៖

៦.១១.១ ជម្រាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត។

៦.១១.២ ជម្រាបជូនជាសង្ខេបពី ប.ន.ព.ស នេះ។

៦.១១.៣ ស្តាប់មតិយោបល់ សំណូមពរ និងការកត់សម្គាល់ផ្សេងៗ។

៦.១១.៤ ពិភាក្សាលើបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត។

**ប្រការ៦.១២.-**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ និងបេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវតែគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុង ច.ប.ព.ស ច.ប.គ.រ ចវ.ច.ប ប.ន.ព.ស នេះ ក្រមសីលធម៌ គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៦.១២.១ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូរ។

៦.១២.២ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារ ឯកសារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ។

៦.១២.៣ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.១២.៤ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ។

៦.១២.៥ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន ឬអ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់ឡើយ។

៦.១២.៦ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ។

៦.១២.៧ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត។

៦.១២.៨ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ ក្នុងពេលឃោសនាបោះឆ្នោត។

គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវព្យាយាមដោយទុច្ចរិតតាមគ្រប់មធ្យោបាយដើម្បីរារាំង ឬញុះញង់អ្នកបោះឆ្នោតមិនឱ្យចូលរួមក្នុងដំណើរការបោះឆ្នោត ឬណែនាំញុះញង់អ្នកបោះឆ្នោតឱ្យបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត ឬដំណើរការបោះឆ្នោត។

៦.១២.៩ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ។ ការគំរាមកំហែង និងបំបាក់ទឹកចិត្ត រួមមាន៖

៦.១២.៩.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ។

៦.១២.៩.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថានឹងធ្វើទារុណកម្ម។

៦.១២.៩.៣ ការវាយតប់បន្តិចបន្តួច ឬធ្វន់ធ្ងរលើបុគ្គលណាម្នាក់។

៦.១២.៩.៤ ការរំលោភដោយពាក្យសម្ដីថានឹងធ្វើទារុណកម្មដល់រាងកាយ។

៦.១២.៩.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ។

៦.១២.៩.៦ ការលើកឡើងផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលយោងទៅព្រឹត្តិការណ៍ពីអតីតកាលដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់។

៦.១២.៩.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលណាម្នាក់។

៦.១២.៩.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់សុវត្ថិភាព និងអាយុជីវិតរបស់ខ្លួន ឬបងប្អូនក្រុមគ្រួសាររបស់ខ្លួន។

៦.១២.៩.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន។

៦.១២.៩.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬការធ្វើឱ្យខូចប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត។

៦.១២.៩.១១ ការប្រមូល ឬការដកហូត ឬការបំផ្លាញឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតរបស់អ្នកបោះឆ្នោត។

៦.១២.៩.១២ ការដាក់កំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោតក្នុងការស្វែងរក ឬស្ដាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា។

**ប្រការ៦.១៣.-**

គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ដែលប្រព្រឹត្តផ្ទុយនឹងប្រការ ៦.១២ ខាងលើនេះ នឹងត្រូវទទួលទោសតាមបញ្ញត្តិនៃ ច.ប.ព.ស ច.ប.គ.រ និង ច.វ.ច.ប។

## សម្ភារអប់រំអ្នកបោះឆ្នោត

**ប្រការ៦.១៤.-**

អគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ដែលមាននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈជាសេនាធិការ ទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការបោះឆ្នោត។

៦.១៤.១ គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចូលរួមការអប់រំផ្សព្វផ្សាយ ដើម្បីឱ្យការអប់រំសាធារណជនអំពីការបោះឆ្នោតកាន់តែមានប្រសិទ្ធភាពខ្ពស់។

៦.១៤.២ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលកំពុងបំពេញភារកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំសាធារណជនអំពីការបោះឆ្នោត អាចទាក់ទងជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ។

៦.១៤.៣ សម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវតែអព្យាក្រឹត និងមិនលម្អៀង។ សម្ភារនោះមិនត្រូវគាំទ្រ ឬបន្ទុះបង្អាប់គណបក្សនយោបាយ ហើយត្រូវគោរពទៅតាម ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប និង ប.ន.ព.ស នេះ។

៦.១៤.៤ សម្ភារព័ត៌មានសាធារណៈ និងសម្ភារអប់រំដែលផលិតដោយ គ.ជ.ប និងសម្ភារអប់រំដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលបានទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ។

៦.១៤.៥ ដើម្បីធានាថា ខ្លឹមសារនៃសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិត្រឹមត្រូវតាមបច្ចេកទេស និងតាមច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ គ.ជ.ប នឹងជួយផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រម និងណែនាំដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្រប ច្បាប់នៃសម្ភារអប់រំនេះ។

៦.១៤.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ។

៦.១៤.៧ ទោះបីជាសម្ភារអប់រំអ្នកបោះឆ្នោតត្រូវបានទទួល ឬមិនត្រូវបានទទួលការយល់ព្រមក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយមិនទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះខ្លឹមសារបច្ចេកទេសនៃសម្ភារអប់រំទាំងនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ។ ម្ចាស់សម្ភារអប់រំបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

៦.១៤.៨ ក្នុងករណីដែលមានការស្នើសុំការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រម គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយដូចមានចែងក្នុងប្រការ ៦.១៦ ខាងក្រោមនេះ មានភារកិច្ចក្នុងការផ្តល់សេវាកម្មពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រមក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីទទួលបានសំណើសុំពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានាសុំឱ្យជួយពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំអ្នកបោះឆ្នោតនោះ។ ក្នុងករណីពិនិត្យឃើញថា សម្ភារ ឬខ្លឹមសារអប់រំអ្នកបោះឆ្នោតមិនសមស្របតាម ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ គណៈកម្មការសម្របសម្រួលត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យមានការកែតម្រូវ និងប្រគល់ឱ្យគណៈកម្មការសម្របសម្រួលពិនិត្យឡើងវិញ។ ក្នុងករណីគណៈកម្មការសម្របសម្រួល ធ្វើការពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំបោះឆ្នោតរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលហួសរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលបានឯកភាពលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន។

៦.១៩.៩ សម្ភារអប់រំអ្នកបោះឆ្នោតដែលអាចត្រូវបានពិនិត្យ ផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប មានដូចជា៖

៦.១៩.៩.១ ស្ប៉តវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ។

៦.១៩.៩.២ កាសែ្សតម៉ាញ៉េ ឬខ្សែអាត់សំឡេង ឬស៊ីឌី (CD) ឬអឹមភីស្រ៊ី (MP3) ឬយូអេសប៊ី (USB)។

៦.១៩.៩.៣ ខិត្តបណ្ណផ្សេងៗ និងបដា។

៦.១៩.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត។

៦.១៩.៩.៥ ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារព័ត៌មាន។

៦.១៩.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើសម្លៀកបំពាក់ ឬមួក។

៦.១៩.១០ សម្ភារដែលបានពិនិត្យ ផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខ ១ (មួយ) ច្បាប់ សម្រាប់ជាឯកសារ។

៦.១៩.១១ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រមដែលផ្តល់ដោយ គ.ជ.ប ត្រូវទទួលខុសត្រូវតាមបញ្ញត្តិនៃ ច.ប.ព.ស ច.ប.ត.រ និង ច.វ.ច.ប។ ប្រសិនបើព័ត៌មានដែលមានក្នុងសម្ភារអប់រំអ្នកបោះឆ្នោត ដែលខ្លួនបានផលិតនោះ ត្រូវបានរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ពុំត្រឹមត្រូវតាម ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ គ.ជ.ប ត្រូវឱ្យសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារនោះទាំងស្រុងតែម្តង។ សម្ភារដែលរកឃើញថា លម្អៀងក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ដូចមានចែងក្នុងចំណុច ៦.១៥.៥ ខាងក្រោមនេះ។

៦.១៩.១២ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះ អាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋាន មុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈបានតែក្នុងអំឡុងពេលឃោសនាបោះឆ្នោតតែប៉ុណ្ណោះ។

៦.១៤.១៣ គ.ជ.ប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬសម្ភារអប់រំបោះឆ្នោតទាំងអស់ដែលមិនគោរពតាមចំណុច ៦.១៤.៣ និងចំណុច ៦.១៤.១២ ខាងលើនេះ សាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវធ្វើការកែតម្រូវតាមសំណើរបស់ គ.ជ.ប ជាចាំបាច់។ ក្នុងករណីកំហុសឆ្គងមានលក្ខណៈធ្ងន់ធ្ងរ សាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវទទួលទោសតាម ច.ប.ព.ស ច.ប.ត.រ និង ច.វ.ច.ប។

## រូបភាព និងសម្ភារឃោសនាបោះឆ្នោត

## ប្រការ៦.១៥.-

អនុលោមតាមប្រការ ៦.២ នៃ ប.ន.ព.ស នេះ គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារឃោសនាបោះឆ្នោតសម្រាប់ផ្សព្វផ្សាយដូចជា៖

៦.១៥.១ ខិត្តបណ្ណឃោសនាបោះឆ្នោត។

៦.១៥.២ ការឃោសនាតាមរលកអាកាស ឬតាមឧបករណ៍បំពងសំឡេង ឬតាមឧបករណ៍បញ្ចាំងរូបភាព។

៦.១៥.២.១ អត្ថបទឃោសនា។

៦.១៥.២.២ បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ។

៦.១៥.២.៣ ការសូត្រកំណាព្យ។

៦.១៥.២.៤ ការប្រគំតន្ត្រីនៅនឹងកន្លែង។

៦.១៥.២.៥ សម្ភាសន៍ដោយបន្តផ្ទាល់ ឬដោយមិនបន្តផ្ទាល់។

៦.១៥.២.៦ ការសម្តែងសិល្បៈ។

៦.១៥.២.៧ ការចាក់ផ្សាយកាសែ្សតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ។

៦.១៥.២.៨ ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមផ្លូវការរបស់ខ្លួន។

៦.១៥.៣ ដោយយោងលើរូបភាព និងសម្ភារឃោសនាបោះឆ្នោតដូចបានបញ្ជាក់ខាងលើ មធ្យោបាយផ្សេងៗទៀត រួមមាន៖

៦.១៥.៣.១ រឿងល្ខោនខ្លីៗ និងការសម្តែងសិល្បៈ ការបញ្ចាំងខ្សែភាពយន្តវីដេអូ។

៦.១៥.៣.២ ប៉េងប៉ោង ឬ/និងខ្លែង។

៦.១៥.៣.៣ សម្ភារបោះពុម្ព មានជាអាទិ៍រូបភាពបិទផ្សាយ សម្លៀកបំពាក់ អាវយឺត មួក ស្លាកសញ្ញា ពាក្យស្លោក ឬរូបភាពបិទតាមយានយន្តលោហៈខ្វាស់ បដា។

៦.១៥.៣.៤ ការស្រែកឃោសនាតាមទីសាធារណៈ។

៦.១៥.៤ គ្រប់សម្ភារ ឯកសារឃោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយដោយបេក្ខជន ឬ/និងគណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសម្គាល់របស់សាមីគណបក្ស (ឈ្មោះ ឬ/និងអាសយដ្ឋាន)។

៦.១៥.៥ សម្ភារឃោសនាបោះឆ្នោតដែលត្រូវបានផ្សព្វផ្សាយជាទម្រង់អត្ថបទបោះពុម្ព ឬតាមឧបករណ៍បំពងសំឡេង ឬការចាក់ផ្សាយ ឬបង្ហោះផ្សព្វផ្សាយខ្លឹមសារតាមប្រព័ន្ធអនឡាញ មិនត្រូវរួមបញ្ចូល ឬប្រើប្រាស់នូវរូបភាពណាមួយដូចខាងក្រោម៖

៦.១៥.៥.១ ប្រើប្រាស់រូបភាព ឬភាសាដែលញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ឬធ្វើឱ្យបាត់បង់ជំនឿជឿជាក់លើភាពសម្ងាត់នៃការបោះឆ្នោត។

៦.១៥.៥.២ ប្រើប្រាស់រូបភាព ឬភាសាដែលមាក់ងាយ បំភិតបំភ័យ ប្រមាថសម្ដែងការមាក់ងាយ ឬអសីលធម៌ ឬការរើសអើងប្រកាន់ពូជសាសន៍។

៦.១៥.៥.៣ ប្រើប្រាស់រូបភាព ឬភាសាដែលសាបព្រោះភាពភ័យខ្លាច ធ្វើឱ្យភាន់ច្រឡំប៉ះពាល់ដល់សន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយ និងខូចរបៀបរបបសង្គម។

៦.១៥.៥.៤ ប្រើប្រាស់រូបភាព ឬភាសាដែលមានព័ត៌មានមិនត្រឹមត្រូវចំពោះដំណើរការបោះឆ្នោត។

៦.១៥.៥.៥ ប្រើប្រាស់សារជាសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន។

៦.១៥.៦ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារឃោសនាបោះឆ្នោតដែលត្រូវបានរកឃើញថា រំលោភលើចំណុច ៦.១៥.៥ ខាងលើនេះ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារខុសច្បាប់ទាំងនោះ។

៦.១៥.៧ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះសម្ភារឃោសនាបោះឆ្នោតដែលខ្លួនផ្សព្វផ្សាយ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើសម្ភារទាំងនោះរំលោភលើលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៦ នៃ ប.ន.ព.ស នេះ។

៦.១៥.៨ ហាមធ្វើសកម្មភាពឃោសនាដោយយកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ថ និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីយ៍ ព្រះវររាជមាតា និងរូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសំឡេងឆ្នោត។

៦.១៥.៩ ហាមលើកបដាឃោសនាបោះឆ្នោត ស្លាកសញ្ញាគណបក្សនយោបាយ និងរូបសញ្ញាណាមួយដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់កាត់ទទឹងផ្លូវសាធារណៈ។

## ប្រការ៦.១៦.-

គ.ជ.ប ត្រូវបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ ហៅកាត់ថា "គណៈកម្មការសម្របសម្រួល" តាមសេចក្ដីសម្រេចរបស់ គ.ជ.ប ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់សម្ភារអប់រំអ្នកបោះឆ្នោតរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល ឬ/និងសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ព្រមទាំងរៀបចំគោលការណ៍កម្មវិធីស្មើភាព ឬ/និងសមធម៌។

៦.១៦.១ តួនាទី និងភារកិច្ចរបស់គណៈកម្មការសម្របសម្រួល ត្រូវបានកំណត់ដូចខាងក្រោម៖

៦.១៦.១.១ ពិនិត្យ ផ្ទៀងផ្ទាត់ និងយល់ព្រម ឬ/និងកែសម្រួលលើខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងករណីមានការស្នើសុំពីសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

៦.១៦.១.២ ត្រួតពិនិត្យសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្ដឹងពីគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ឬតំណាង ដោយយោងតាម ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និងយោងតាមចំណុច ៦.១២.៨ ចំណុច ៦.១៥.៥ និងចំណុច ៦.១៥.៨ នៃ ប.ន.ព.ស នេះ។

៦.១៦.១.៣ សម្របសម្រួលកម្មវិធីស្មើភាព ឬ/និងសមធម៌ ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ។

៦.១៦.១.៤ សម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជនក្នុងពេលឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីមានឱកាសទិញ ឬជួលម៉ោងផ្សាយ ផ្អែកតាមគោលការណ៍ស្មើភាព ឬ/និងសមធម៌ និងតាមលំដាប់មុនក្រោយ។

៦.១៦.១.៥ សម្របសម្រួលជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត។

៦.១៦.២ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានគោលការណ៍រៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ជូនគណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាជាផ្លូវការ មានឱកាសផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយនីមួយៗដល់អ្នកបោះឆ្នោតតាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ ផ្អែកតាមគោលការណ៍របស់ គ.ជ.ប និងតាមលំដាប់មុនក្រោយ។

៦.១៦.២.១ គណៈកម្មការសម្របសម្រួលត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដើម្បីពិភាក្សាកំណត់អំពីការរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ ហើយត្រូវមានបទបញ្ជាមួយសម្រាប់ថតកម្មវិធី ដែលអនុម័តដោយ គ.ជ.ប។

៦.១៦.២.២ គណៈកម្មការសម្របសម្រួលត្រូវអនុវត្តតាមគោលការណ៍ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព ឬ/និងសមធម៌របស់ គ.ជ.បក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ។

៦.១៦.៣ កម្មវិធីស្មើភាព ឬ/និងសមធម៌ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម៖

៦.១៦.៣.១ កម្មវិធីចាក់ផ្សាយកិច្ចពិភាក្សាតាមប្រធានបទ រវាងបេក្ខជនឈរឈ្មោះបោះឆ្នោត ឬតំណាងគណបក្សនយោបាយអំពីកម្មវិធីនយោបាយរបស់ខ្លួន តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ។

៦.១៦.៣.២ កម្មវិធីចាក់ផ្សាយស្ប៉តរបស់គណបក្សនយោបាយតាមវិទ្យុ និងទូរទស្សន៍រដ្ឋ។

៦.១៦.៣.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនាអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើមទាំងស្រុងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតលើព្រឹត្តិបត្រគោលនយោបាយគណបក្សដែលបានបោះពុម្ពផ្សាយដោយ គ.ជ.ប។

៦.១៦.៤ គណៈកម្មការសម្របសម្រួលត្រូវជួបពិភាក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ និងឯកជន និងភាគីពាក់ព័ន្ធ ដើម្បីពន្យល់ណែនាំអំពីបទបញ្ញា និងនីតិវិធីក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត និងគោលការណ៍ណែនាំអំពីការឃោសនាបោះឆ្នោតរបស់ គ.ជ.ប។

៦.១៦.៥ ក្នុងករណីគណបក្សនយោបាយធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយប្រើប្រាស់នូវរាល់សម្ភារឃោសនាបោះឆ្នោតផ្សេងពីសម្ភារឃោសនាបោះឆ្នោតដូចមានចែងក្នុងចំណុច ៦.១៦.៣ ខាងលើនេះ ដែលគណៈកម្មការសម្របសម្រួលបានពិនិត្យ និងឯកភាពគ្នារួចហើយ គណបក្សនយោបាយសាមីត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

## ប្រការ៦.១៧.-

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យាន ឬទីសាធារណៈ ឬសាលសាធារណៈត្រូវផ្ដល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតដែលសុំជួលប្រើប្រាស់សម្រាប់ធ្វើការឃោសនាបោះឆ្នោត ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការស្នើសុំ។ គណបក្សនយោបាយ ឬបេក្ខជនដែលមានបំណងជួលរោងមហោស្រព ឬមណ្ឌលកីឡា ឧទ្យានសាធារណៈ ឬទីសាធារណៈ ឬសាលសាធារណៈត្រូវដាក់ពាក្យសុំទៅអ្នកគ្រប់គ្រងយ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនាបោះឆ្នោត ហើយត្រូវធ្វើសេចក្ដីចម្លងនៃពាក្យសុំនេះ ១ (មួយ) ច្បាប់ ដល់ គធ.ខប។ អ្នកគ្រប់គ្រងត្រូវឆ្លើយតបទៅនឹងពាក្យសុំមិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ក្រោយពីបានទទួលពាក្យសុំ។

៦.១៧.១ គធ.ខប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីកំណត់ទីសាធារណៈសម្រាប់ការឃោសនាបោះឆ្នោត ហើយត្រូវផ្សព្វផ្សាយជាសាធារណៈនៅក្នុងរាជធានី ខេត្ត យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្ដើមឃោសនាបោះឆ្នោត។

៦.១៧.២ បន្ទាប់ពីបានទទួលនូវសេចក្ដីជូនដំណឹងដូចមានចែងក្នុងចំណុច ៦.១៧.១ ខាងលើនេះ គធ.ខប ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីសម្របសម្រួល អំពីការងារសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ សម្រាប់ឱ្យគណបក្សនយោបាយ ឬបេក្ខជនធ្វើការឃោសនាបោះឆ្នោត។

៦.១៧.៣ គធ.ខប ត្រូវមានសៀវភៅសម្រាប់ចុះលិខិតចម្លងនៃពាក្យសុំធ្វើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬបេក្ខជន ដែលបានចម្លងជូន ដើម្បីឱ្យបានដឹងថា គណបក្សនយោបាយណាបានសុំធ្វើការឃោសនាមុន និងគណបក្សនយោបាយណាបានសុំធ្វើការឃោសនាបោះឆ្នោតបន្តបន្ទាប់។

៦.១៧.៤ គជ.ខប ត្រូវធ្វើកាលវិភាគប្រចាំសប្តាហ៍ ស្តីពីកាលកំណត់តាមលំដាប់លំដោយនៃការសុំប្រើប្រាស់ទីធ្លាសាធារណៈ និងទីកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈនៅ លគជ.ខប ១ (មួយ) ច្បាប់ និងនៅទីកន្លែងដែលត្រូវធ្វើការឃោសនាបោះឆ្នោត ១ (មួយ) ច្បាប់។

៦.១៧.៥ គជ.ខប ជាអ្នកសម្របសម្រួល និងរៀបចំតាមលំដាប់នៃការជូនដំណឹងស្តីពីការធ្វើការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ដោយណែនាំឱ្យគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត និងចាត់វិធានការទប់ស្កាត់ និងដោះស្រាយចំពោះការឃោសនាបោះឆ្នោតទាំងឡាយណាដែលផ្ទុយនឹង ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប និង ប.ន.ព.ស នេះ។

**ប្រការ៦.១៨.-**

គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយត្រូវរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយឱ្យបានល្អ និងត្រឹមត្រូវតាមពេលវេលា ទីកន្លែងកំណត់ តាមដងផ្លូវ ទីប្រជុំជន និងទីសាធារណៈ។

**ប្រការ៦.១៩.-**

គណបក្សនយោបាយ ឬបេក្ខជនអាចធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅតាមកន្លែងឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គជ.ខប យ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃប្រជុំឃោសនាបោះឆ្នោត។ អ្នកគ្រប់គ្រងទីកន្លែងត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់គ្រប់បេក្ខជន ឬគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតដែលមានបំណងជួលប្រើប្រាស់សម្រាប់បម្រើការឃោសនាបោះឆ្នោត ដោយផ្អែកលើតម្លៃស្មើៗគ្នា និងតាមលំដាប់លំដោយ តាមកាលបរិច្ឆេទនៃការសុំជួល។

**ប្រការ៦.២០.-**

គណបក្សនយោបាយ ឬ/និងបេក្ខជន ឬ/និងអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរំខាន ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ឬ/និងអ្នកគាំទ្រផ្សេងទៀតឡើយ។ សកម្មភាពដែលជ្រៀតជ្រែក និងធ្វើឱ្យរំខាន រាំងស្ទះនោះរួមមាន៖

៦.២០.១ ការនិយាយដៀមដាម ប្រមាថមើលងាយ។

៦.២០.២ ការធ្វើទារុណកម្មដល់រាងកាយ។

៦.២០.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់។

៦.២០.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សកំពុងធ្វើការឃោសនាបោះឆ្នោត ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាលអ្នកណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ។

៦.២០.៥ ការរារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមកាលកំណត់។

៦.២០.៦ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ទច់បង្អាក់មិនឱ្យក្បួនដង្ហែឃោសនាបោះឆ្នោតទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាបោះឆ្នោតផ្សេងៗទៀត។

៦.២០.៧ ការហាមឃាត់ ឬរារាំងប្រជាពលរដ្ឋមិនឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬក្បួនដង្ហែរបស់គណបក្សនយោបាយណាមួយ។

៦.២០.៨ ការប្រើគ្រឿងផ្ទុះ ដើម្បីរំខានដល់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬបេក្ខជន។

៦.២០.៩ ការប្រើឧបករណ៍បំពងសំឡេង ដើម្បីរំខានដល់ទីកន្លែងដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនាបោះឆ្នោត ឬការជួបប្រជុំ។

៦.២០.១០ ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្សនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ។

**ប្រការ៦.២១.-**

បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នាក្នុងការទទួលបានការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៦.២១.១ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈសម្រាប់ការឃោសនាបោះឆ្នោត។

៦.២១.២ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានភារកិច្ច និងការទទួលខុសត្រូវដោយធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត។

៦.២១.៣ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិដែលមានភារកិច្ចការពារមិនត្រូវឈរក្បែរ ឬដើរកៀកពេកទៅនឹងទីតាំង ឬក្បួនឃោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីឃោសនាបោះឆ្នោតនានា លើកលែងតែមានការស្នើសុំដោយបេក្ខជន ឬ/និងគណបក្សនយោបាយណាមួយ។

៦.២១.៤ ក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត គជ.ខប ត្រូវតាមដានជារៀងរាល់ថ្ងៃ អំពីកម្រិតសន្តិសុខ និងសុវត្ថិភាពក្នុងរាជធានី ខេត្ត និងត្រូវជូនព័ត៌មានទៅ គ.ជ.ប ជារៀងរាល់ថ្ងៃ។

**ប្រការ៦.២២.-**

គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនី ដើម្បីកត់ត្រាចំណូល ប្រភពនៃប្រាក់ចំណូល និងចំណាយសម្រាប់ការឃោសនាបោះឆ្នោត។

៦.២២.១ វិភាគទានទាំងអស់ដែលគណបក្សនយោបាយទទួលបាន ត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនាបោះឆ្នោតត្រូវតែចេញពីគណនីតែមួយនេះ។

៦.២២.២ គ.ជ.ប អាចត្រួតពិនិត្យសៀវភៅគណនីរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត តាមការចាំបាច់។

## កិច្ចសហការ និងភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និង គ.ជ.ប

**ប្រការ៦.២៣.-**

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការ និងការគាំទ្រពីក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោតជូនសាធារណជន និងតាមដានការផ្សព្វផ្សាយ ត្រួតពិនិត្យ និងចាត់វិធានការ ក្នុងករណីមិនគោរពតាម ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត។

**ប្រការ៦.២៤.-**

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ឯកជន ដែលមានបំណងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោតត្រូវអនុវត្តតាមក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌។

**ប្រការ៦.២៥.-**

គ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ទាំងរដ្ឋ ទាំងឯកជនត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមិនគោរពតាម ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

**ប្រការ៦.២៦.-**

រាល់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោតត្រូវអនុវត្តតាមជំពូកទី៩ នៃប.ន.ព.សនេះ។

# ជំពូកទី៧
# ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន

## ភ្នាក់ងារគណបក្សនយោបាយ

### ប្រការ៧.១.-

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវចាត់ចែងអនុវត្តការងារទាក់ទងទៅនឹងភ្នាក់ងារគណបក្សនយោបាយ។

៧.១.១ ភ្នាក់ងារគណបក្សនយោបាយ គឺជាតំណាងដែលចាត់តាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាតដោយ គ.ជ.ប ឬ គធ.ខប ឬ លធ.ខប ដើម្បីសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត និងដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។ ភ្នាក់ងារគណបក្សនយោបាយ គឺជាអ្នកសង្កេតការណ៍ដែលមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់។

៧.១.២ ការផ្តល់បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ សម្រាប់សង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត ឬការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៧.១.៣ គណបក្សនយោបាយត្រូវបណ្តុះបណ្តាលដល់ភ្នាក់ងាររបស់ខ្លួនអំពី ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និងច្បាប់ស្តីពីគណបក្សនយោបាយ ព្រមទាំង ប.ន.ព.ស នេះ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត។

៧.១.៤ បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត ឬការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

៧.១.៥ ភ្នាក់ងារពេញសិទ្ធិនៃគណបក្សនយោបាយនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត តាមចំនួនសមស្រប ដោយមានការសម្របសម្រួលពីអគ្គលេខាធិការរដ្ឋសភា ឬប្រធាន កបយ.ស ឬប្រធាន គ.ក.ប/គ.ក.រ។ ភ្នាក់ងារបម្រុងនៃគណបក្សនយោបាយត្រូវអនុញ្ញាតឱ្យចាំនៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីអវត្តមាន។

៧.១.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវផ្តល់គំរូពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ដល់គណបក្សនយោបាយដោយឥតគិតថ្លៃ។ គណបក្សនយោបាយអាចថតចម្លងគំរូពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័រ www.nec.gov.kh។

៧.១.៧ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវធ្វើជា ៣ (បី) ច្បាប់ តាមគំរូទម្រង់ដែលកំណត់ដោយ គ.ជ.ប។ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវភ្ជាប់មកជាមួយនូវ៖

៧.១.៧.១ សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ជាសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលបញ្ជាក់នីត្យានុកូលកម្មដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឬការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ គណបក្សនយោបាយត្រូវផ្ញើសេចក្តីចម្លងប្រកាសនេះ ១ (មួយ) ច្បាប់មក គ.ជ.ប ដើម្បីតម្កល់ទុក ហើយសម្រាប់ការដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយនៅ លធ.ខប ឬ គ.ជ.ប (ក្នុងករណីសង្កេតមើលការចុះឈ្មោះបោះឆ្នោតនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា) សម្រាប់ការចុះឈ្មោះបោះឆ្នោត គណបក្សនយោបាយគ្រាន់តែថតចម្លងសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្មនេះ ភ្ជាប់ជាមួយពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧)។

៧.១.៧.២ បញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងសេចក្តីប្រកាសគោរព ច.ប.ព.ស ច.ប.គ.រ ចវ.ច.ប ប.ន.ព.ស ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត និងច្បាប់ស្តីពីគណបក្សនយោបាយចំនួន៣(បី)ច្បាប់។សម្រាប់ការចុះឈ្មោះបោះឆ្នោត បញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយនេះ ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាន និងការិយាល័យចុះឈ្មោះបោះឆ្នោតដែលភ្នាក់ងារនោះត្រូវបំពេញ

ការងារ។ សម្រាប់ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត បញ្ជីឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុង ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាន និងការិយាល័យបោះឆ្នោត ដែលភ្នាក់ងារនោះត្រូវបំពេញការងារ។

៧.១.៧.៣ លិខិតបញ្ជាក់របស់មេឃុំ ចៅសង្កាត់នៃរាជធានី ខេត្តពាក់ព័ន្ធជាបុគ្គល ឬជាបញ្ជីដែលបញ្ជាក់ថា ភ្នាក់ងារនោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នៃរាជធានី ខេត្តនោះ ១ (មួយ) ច្បាប់។

៧.១.៨ ភ្នាក់ងារគណបក្សនយោបាយត្រូវជាអ្នក៖

៧.១.៨.១ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្តនោះ។

៧.១.៨.២ មានសមត្ថភាពអាចបំពេញការងារបានតាមការធានារបស់គណបក្សនយោបាយសាមី។

៧.១.៨.៣ បានទទួលការបណ្តុះបណ្តាលជាភ្នាក់ងារគណបក្សនយោបាយតាមការធានារបស់គណបក្សនយោបាយសាមី។

៧.១.៩ ភ្នាក់ងារគណបក្សនយោបាយត្រូវចុះហត្ថលេខាក្នុងខ្ទង់ហត្ថលេខាត្រង់បន្ទាត់ឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយ ដើម្បីជាភស្តុតាងនៃការប្រកាសសន្យាថា៖

៧.១.៩.១ ស្ម័គ្រចិត្តយល់ព្រមតាមការតែងតាំងរបស់គណបក្សឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសម្រាប់សង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត ឬការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៧.១.៩.២ គោរព ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប ប.ន.ព.ស នេះ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត។

៧.១.៩.៣ ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណីសាមីខ្លួនរំលោភបំពានលើសេចក្តីប្រកាសសន្យានៅចំណុច ៧.១.៩.២ ខាងលើនេះ។

៧.១.១០ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) ត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយ ដែលទទួលបានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះមានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

៧.១.១១ គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិចាត់តាំងភ្នាក់ងាររបស់ខ្លួនមួយចំនួនតាមការចាំបាច់របស់គណបក្ស ដើម្បីសង្កេតមើលការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តនៃភូមិភាគ និងនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា។

៧.១.១១.១ គណបក្សនយោបាយដែលមានបំណងដាក់ភ្នាក់ងាររបស់ខ្លួនដើម្បីសង្កេតមើលការចុះឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ គ.ជ.ប (ក្នុងករណីសង្កេតមើលការចុះឈ្មោះបោះឆ្នោតនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា) ឬ លធ.ខប (ក្នុងករណីសង្កេតមើលការចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់នៃរាជធានី ខេត្ត) ក្នុងរយៈពេលយ៉ាងយូរ៧(ប្រាំពីរ)ថ្ងៃ មុនថ្ងៃចាប់ផ្តើមការចុះឈ្មោះបោះឆ្នោតរហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត។

៧.១.១១.២ គ.ជ.ប ឬ លធ.ខប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងចេញសេចក្តីសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះភ្នាក់ងារគណបក្សនយោបាយដែលមានក្នុងបញ្ជីឈ្មោះស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃក្រោយពីបានទទួលពាក្យសុំ។ បន្ទាប់ពី គ.ជ.ប ឬ លធ.ខប ពិនិត្យនិងសម្រេចលើបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គ.ជ.ប ឬ លធ.ខប ត្រូវចុះហត្ថលេខា ឈ្មោះ និងបោះត្រា គ.ជ.ប ឬបោះត្រា លធ.ខប លើគ្រប់ទំព័រទាំង ៣ (បី) ច្បាប់ ដើម្បី៖

- ផ្ញើទៅសាមីគណបក្សនយោបាយ ១ (មួយ) ច្បាប់
- ផ្ញើជូនអគ្គលេខាធិការដ្ឋានរដ្ឋសភា ១ (មួយ) ច្បាប់ (ករណីដាក់ពាក្យសុំនៅ គ.ជ.ប) ឬផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ (ករណីដាក់ពាក្យសុំនៅ លធ.ខប)
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.១.១១.៣ ប្រសិនបើ គ.ជ.ប ឬ លធ.ខប ពិនិត្យលើពាក្យសុំឃើញថាភ្នាក់ងារគណបក្សនយោបាយណាម្នាក់ពុំមានលក្ខណសម្បត្តិត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គ.ជ.ប ឬ លធ.ខប ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍

អក្សរទៅតំណាងសាមីគណបក្សនយោបាយ ដោយបញ្ជាក់ពីមូលហេតុ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ ក្រោយពីបានទទួលពាក្យសុំ។ គណបក្សនយោបាយមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនជាថ្មីម្តងលើកទៀតជំនួសឈ្មោះភ្នាក់ងារដែលបានបដិសេធមក គ.ជ.ប ឬ លធ.ឃប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីការបដិសេធនេះ។ ក្នុងរយៈពេលនេះ ប្រសិនបើតំណាងគណបក្សនយោបាយនៅតែពុំព្រមកែតម្រូវតាមលក្ខខណ្ឌដូចបានកំណត់ទេនោះ គ.ជ.ប ឬ លធ.ឃប ត្រូវសម្រេចទទួលស្គាល់តែឈ្មោះភ្នាក់ងារគណបក្សនយោបាយណាដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ។ បន្ទាប់ពី គ.ជ.ប ឬ លធ.ឃប សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គ.ជ.ប ឬ លធ.ឃប ត្រូវផ្តល់បណ្ណសម្គាល់ជូនភ្នាក់ងារគណបក្សនយោបាយតែ ២ (ពីរ) បណ្ណប៉ុណ្ណោះ ១ (មួយ) បណ្ណសម្រាប់ភ្នាក់ងារពេញសិទ្ធិ និង ១ (មួយ) បណ្ណសម្រាប់ភ្នាក់ងារបម្រុង។ គ.ជ.ប ឬ លធ.ឃប ត្រូវបំពេញឈ្មោះគណបក្សនយោបាយ គូសធីកលើពាក្យ "ពេញសិទ្ធិ" ឬ "បម្រុង" និងបំពេញឈ្មោះអគ្គលេខាធិការដ្ឋានរដ្ឋសភា ចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប ឬឈ្មោះរាជធានី ឬខេត្ត និងឈ្មោះឃុំ សង្កាត់ ចុះហត្ថលេខា ឈ្មោះ បោះត្រា លធ.ឃប និងចុះកាលបរិច្ឆេទលើបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ និងផ្តល់ជូនភ្នាក់ងារនោះ ដើម្បីពាក់ក្នុងពេលបំពេញការងារ ដោយភ្ជាប់ជាមួយនូវឯកសារដែលអាចបញ្ជាក់ពីអត្តសញ្ញាណរបស់សាមីខ្លួន។

៧.១.១១.៤ បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ មានសុពលភាពប្រើប្រាស់សម្រាប់តែការសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត។

៧.១.១១.៥ អគ្គលេខាធិការដ្ឋានរដ្ឋសភា និង កបយ.ស ត្រូវរាយការណ៍ទៅ គ.ជ.ប អំពីវត្តមាន និងសកម្មភាពនានារបស់ភ្នាក់ងារគណបក្សនយោបាយក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត។

៧.១.១២ គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត មានសិទ្ធិចាត់តាំងភ្នាក់ងាររបស់ខ្លួន ២ (ពីរ) រូប ភ្នាក់ងារពេញសិទ្ធិ ១ (មួយ) រូប និងភ្នាក់ងារបម្រុង ១ (មួយ) រូប ដើម្បីសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត នៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗនៅតាមរាជធានី ខេត្តនៃភូមិភាគដែលខ្លួនឈរឈ្មោះបោះឆ្នោត។

៧.១.១២.១ គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការដូចមានចែងក្នុងប្រការ ៥.១៣ នៃ ប.ន.ព.ស នេះ។

៧.១.១២.២ គធ.ខប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងចេញសេចក្ដីសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះភ្នាក់ងារគណបក្សនយោបាយដែលមានក្នុងបញ្ជីឈ្មោះស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ ក្រោយពីថ្ងៃបានទទួលពាក្យស្នើសុំ។ បន្ទាប់ពី គធ.ខប ពិនិត្យ និងសម្រេចលើបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គធ.ខប ត្រូវចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប លើគ្រប់ទំព័រទាំង ៣ (បី) ច្បាប់ ដើម្បី៖

- ផ្ញើទៅសាមីគណបក្សនយោបាយ ១ (មួយ) ច្បាប់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.១.១២.៣ ប្រសិនបើ គធ.ខប ពិនិត្យលើពាក្យសុំឃើញថា ភ្នាក់ងារគណបក្សនយោបាយណាម្នាក់ ពុំមានលក្ខណសម្បត្តិត្រឹមត្រូវតាមលក្ខខណ្ឌដូចបានកំណត់ខាងលើ គធ.ខប ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅតំណាងសាមីគណបក្សនយោបាយ ដោយបញ្ជាក់ពីមូលហេតុ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ ក្រោយពីថ្ងៃបានទទួលពាក្យសុំ។ គណបក្សនយោបាយមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនជាថ្មីមួយលើកទៀតជំនួសឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលបានបដិសេធមក

គជ.ខប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងអំពីការបដិសេធនេះ។ ក្នុងរយៈពេលនេះ ប្រសិនបើតំណាងគណបក្សនយោបាយនៅតែពុំព្រមកែតម្រូវតាមលក្ខខណ្ឌដូចបានកំណត់ទេនោះ គជ.ខប ត្រូវសម្រេចទទួលស្គាល់តែឈ្មោះភ្នាក់ងារគណបក្សនយោបាយណាដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ។ បន្ទាប់ពី គជ.ខប សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គជ.ខប ត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងបោះត្រា គជ.ខប នៅលើជ្រុងខាងស្តាំនៃរូបថត និងផ្តល់ជូនភ្នាក់ងារនោះ ដើម្បីពាក់ក្នុងពេលបំពេញការងារ។

៧.១.១២.៤ បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយមានសុពលភាពប្រើប្រាស់សម្រាប់តែការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៧.១.១២.៥ គណបក្សនយោបាយដែលបានទទួលស្គាល់ឱ្យចុះឈ្មោះភ្នាក់ងារ ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតមានសិទ្ធិផ្លាស់ប្តូរភ្នាក់ងាររបស់ខ្លួនរហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី ថ្ងៃសុក្រមុនថ្ងៃបោះឆ្នោតពីរថ្ងៃ។

៧.១.១២.៦ គ.ក.ប/គ.ក.រ និង គជ.ខប ត្រូវរាយការណ៍ទៅថ្នាក់លើមួយថ្នាក់របស់ខ្លួនអំពីវត្តមាន និងសកម្មភាពនានារបស់ភ្នាក់ងារគណបក្សនយោបាយក្នុងអំឡុងពេលនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

## សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ

៧.១.១៣ ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

៧.១.១៣.១ មានវត្តមាននៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនបានទទួលការអនុញ្ញាត តាមទីកន្លែងដែលបានកំណត់ដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា កបយ.ស គ.ក.ប/គ.ក.រ ឬ គ.ជ.ប និងត្រូវចុះបញ្ជីវត្តមាន។

៧.១.១៣.២ ចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ។ ភ្នាក់ងារបម្រុងត្រូវរង់ចាំនៅក្រៅការិយាល័យ ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីមានការផ្លាស់ប្តូរ។

៧.១.១៣.៣ ជំទាស់ ឬតវ៉ារាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់។ ការជំទាស់ ឬតវ៉ាត្រូវធ្វើឡើងទៅអគ្គលេខាធិការរដ្ឋសភា ឬ កបឃ.ស ឬប្រធាន គ.ក.ប/គ.ក.រ។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់ ឬតវ៉ាអាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គ.ជ.ប។

៧.១.១៣.៤ ចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗដែលកំណត់ដោយ គ.ជ.ប។

៧.១.១៣.៥ ចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៧.១.១៣.៦ មានសិទ្ធិទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៧.១.១៣.៧ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៧.១.១៣.៨ ប្តឹងជំទាស់ ឬប្តឹងតវ៉ាស្របតាម ប.ន.ព.ស នេះ ប្រសិនបើពិនិត្យឃើញថា មានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹង ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ ក្នុងដំណើរការបោះឆ្នោត។

៧.១.១៣.៩ ទទួលបានដោយស្មើភាពគ្នា ក្នុងការការពារសន្តិសុខ សុវត្ថិភាព ក្នុងអំឡុងពេលធ្វើសកម្មភាពនានា ក្នុងដំណើរការបោះឆ្នោត។

**បម្រាមចំពោះគណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយ**

៧.១.១៤ ក្នុងដំណើរការបោះឆ្នោត គណបក្សនយោបាយ និងភ្នាក់ងារគណបក្សនយោបាយមិនត្រូវ៖

៧.១.១៤.១ ប្រព្រឹត្តអំពើគំរាមកំហែង ឬអំពើបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ឬគណបក្សនយោបាយដទៃទៀត។

៧.១.១៤.២ ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀត។

៧.១.១៤.៣ និយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាម្នាក់។

៧.១.១៤.៤ រិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ។

៧.១.១៤.៥ ធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។

៧.១.១៤.៦ ផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្តទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័នអង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ក្នុងរយៈពេលឃោសនាបោះឆ្នោត ថ្ងៃស និងថ្ងៃបោះឆ្នោត។

៧.១.១៤.៧ ធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅចន្លោះពីម៉ោង ១០:០០ (ដប់) យប់ ដល់ម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក។

៧.១.១៤.៨ ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ចាប់ពីម៉ោង ១២:០០ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២:០០ (ពីរ) រសៀល។

៧.១.១៤.៩ ជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៧.១.១៤.១០ ប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន។

៧.១.១៤.១១ រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប។

៧.១.១៤.១២ ប្រើកម្លាំង អំពើហិង្សា អំពើរំលោភ បំភិតបំភ័យ ឬប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

៧.១.១៤.១៣ បង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន។

៧.១.១៤.១៤ បង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត។

៧.១.១៤.១៥ ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

៧.១.១៤.១៦ ទិញសន្លឹកឆ្នោត ដោយសម្ភារ ឬដោយប្រាក់កាស។

៧.១.១៤.១៧ បង្ខាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត។

៧.១.១៤.១៨ ធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

៧.១.១៤.១៩ ទាមទារ ឬចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើភ្នាក់ងារគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយ។

៧.១.១៤.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត។

៧.១.១៤.២១ ជ្រៀតជ្រែកដល់ដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោត។

៧.១.១៤.២២ ញុះញង់ឱ្យមានការរើសអើងប្រកាន់បក្ខពួក ភេទ ឋានៈក្នុងសង្គម សមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ និងតាមគ្រប់រូបភាពទាំងអស់។

៧.១.១៤.២៣ រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាពលរដ្ឋមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀត។

៧.១.១៤.២៤ ប្រើប្រាស់ភាសា ពាក្យសំដីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយ។

៧.១.១៤.២៥ ដាក់តាំង ឬបង្ហាញ ឬចែកចាយខិត្តបណ្ណដែលពិពណ៌នាអំពីការវាយប្រហារដោយពាក្យសម្តី ឬដោយអាវុធ។

៧.១.១៤.២៦ ប្រើភាសា ឬរូបភាពរំលោភបំពាន ខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សាតាមរយៈសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តបណ្ណ រូបភាពបិទផ្សាយ និងសម្ភារឃោសនាបោះឆ្នោតផ្សេងទៀត។

៧.១.១៤.២៧ ចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗលុបលើសំឡេងឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៧.១.១៤.២៨ ធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយឧបករណ៍បំពងសំឡេងនៅក្បែរមន្ទីរពេទ្យ ឬក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា។

៧.១.១៤.២៩ យកព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រី ព្រះវររាជមាតា រូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ ដើម្បីរកសំឡេងឆ្នោត។

៧.១.១៤.៣០ ចម្លងយកសញ្ញាសម្គាល់របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់ បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន។

៧.១.១៤.៣១ បិទបណ្ណ ខិត្តបណ្ណ រូបភាពឃោសនាបោះឆ្នោត សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសារឃោសនាបោះឆ្នោតដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃ។

៧.១.១៤.៣២ បក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវបណ្ណបិទផ្សាយ ខិត្តបណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសារឃោសនាបោះឆ្នោត ឬសេចក្តីណែនាំផ្សេងៗរបស់គណបក្សនយោបាយដទៃ ក្រសួង ស្ថាប័ននានា ឬអាជ្ញាធរដែនដី។

៧.១.១៤.៣៣ បិទបណ្ណផ្សព្វផ្សាយរូបភាពឃោសនាបោះឆ្នោត សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារឃោសនាបោះឆ្នោតដទៃទៀតក្បែរការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង ១០០ (មួយរយ) ម៉ែត្រ លើកលែងតែទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៧.១.១៥.៣៤ ចងបដា ឬរបសញ្ញាឃោសនាបោះឆ្នោតណាមួយឆ្លងកាត់ផ្លូវសាធារណៈ។

៧.១.១៥.៣៥ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៧.១.១៥.៣៦ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដូចជារថយន្ត ត្រីចក្រយានយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទដែលប្រើប្រាស់ផ្លាកសញ្ញារាជការឬរដ្ឋ រាជរដ្ឋាភិបាល នគរបាល ឬ ន.ប ឬខេមរភូមិន្ទ ឬ ខ.ម ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

៧.១.១៥.៣៧ ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ដើម្បីទទួលបានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលឃោសនាបោះឆ្នោត រហូតដល់ថ្ងៃបោះឆ្នោត។

៧.១.១៥.៣៨ ប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបានការគាំទ្រ។

៧.១.១៥.៣៩ ក្លែងបន្លំ បំផ្លាញឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោត។

៧.១.១៥.៤០ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត។

៧.១.១៥.៤១ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៧.១.១៥.៤២ ជក់បារី និងគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧.១.១៥.៤៣ ធ្វើសកម្មភាពផ្សេងទៀតដែលត្រូវបានហាមឃាត់ដូចកំណត់ក្នុង ប.ន.ព.ស នេះ និងគោលការណ៍ណែនាំរបស់ គ.ជ.ប។

## អ្នកសង្កេតការណ៍បោះឆ្នោត

### ប្រការ៧.២.-

អ្នកសង្កេតការណ៍រួមមានអ្នកសង្កេតការណ៍ជាតិ និងអ្នកសង្កេតការណ៍អន្តរជាតិ៖

៧.២.១ អ្នកសង្កេតការណ៍ជាតិ គឺជាជនជាតិខ្មែរ ឬជនបរទេសជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងអនុញ្ញាតដោយ គ.ជ.ប។

៧.២.២ បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កបឃ.ស មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធមិនត្រូវបានអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍ ដើម្បីសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោតការបោះឆ្នោតនិងការរាប់សន្លឹកឆ្នោតឡើយ។

៧.២.៣ អ្នកសង្កេតការណ៍ជាតិចល័តសំដៅដល់ថ្នាក់ដឹកនាំ ឬមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិដែលសាមីអង្គភាពស្នើសុំ និងដែលត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទូទាំងប្រទេស។

៧.២.៤ អ្នកសង្កេតការណ៍អន្តរជាតិ គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានា ដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ឬ គ.ជ.ប ហើយនិងអនុញ្ញាតដោយ គ.ជ.ប។

៧.២.៥ រាល់ការចំណាយទាំងឡាយរបស់អ្នកសង្កេតការណ៍ជាបន្ទុករបស់ស្ថាប័ន សមាគម ឬអង្គការ ឬសាមីខ្លួន។

## អ្នកសង្កេតការណ៍ជាតិ

### ប្រការ៧.៣.-

គ.ជ.ប ត្រូវធ្វើសេចក្តីជូនដំណឹងជាមុន អំពីប្រតិទិននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិត្រូវធ្វើនៅ គ.ជ.ប។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិននៃការបោះឆ្នោត រហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៧.៣.១ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

៧.៣.១.១ មានលិខិតបញ្ជាក់ការចុះបញ្ជីជាផ្លូវការ នៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា។

៧.៣.១.២ មានលក្ខន្តិកៈ ឬឯកសារប្រហាក់ប្រហែលគ្នា ដែលបញ្ជាក់ពីគោលបំណង ឬទិសដៅក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ

ប្រជាធិបតេយ្យ ឬការបោះឆ្នោត ឬសិទ្ធិមនុស្ស ឬច្បាប់ ឬយុត្តិធម៌សង្គម។

៧.៣.១.៣ មានកម្មវិធីបណ្តុះបណ្តាលអប់រំពីការបោះឆ្នោតជូនសមាជិកសង្កេតការណ៍របស់ខ្លួន។

៧.៣.១.៤ មានផែនការការងារ និងស្ថានភាពថវិការបស់ខ្លួន។

៧.៣.២ ដើម្បីចូលរួមសង្កេតការណ៍មើលការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោត សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានលក្ខណសម្បត្តិដូចខាងលើ ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួនទៅគ.ជ.បតាមប្រតិទិនសម្រាប់ការបោះឆ្នោតដែលកំណត់ដោយគ.ជ.ប។

៧.៣.៣ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវផ្តល់គំរូនៃពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ដោយឥតគិតថ្លៃ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័រ www.nec.gov.kh។ ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ ត្រូវធ្វើចំនួន ១ (មួយ) ច្បាប់ ដោយភ្ជាប់មកជាមួយ៖

៧.៣.៣.១ លក្ខខណ្ឌដូចមានចែងក្នុងចំណុច ៧.៣.១ ខាងលើនេះ។

៧.៣.៣.២ បញ្ជីឈ្មោះអ្នកសង្កេតការណ៍តាមរាជធានី ខេត្ត ដែលត្រូវធ្វើការសង្កេតការណ៍ ចំនួន ៤ (បួន) ច្បាប់។

៧.៣.៣.៣ សេចក្តីប្រកាសគោរព ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប ប.ន.ព.ស នេះ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត។

៧.៣.៤ អ្នកសង្កេតការណ៍ត្រូវជាអ្នក៖

៧.៣.៤.១ មានសិទ្ធិបោះឆ្នោត លើកលែងតែជនបរទេសដូចមានចែងក្នុងចំណុច ៧.២.១ ខាងលើនេះ។

៧.៣.៤.២ បានទទួលការបណ្តុះបណ្តាលអំពី ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប ប.ន.ព.ស នេះ និងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត។

៧.៣.៥ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

៧.៣.៦ ក្នុងករណីពិនិត្យបញ្ជីឈ្មោះដែលដាក់ស្នើសុំមកឃើញថា អ្នកសង្កេតការណ៍ណាម្នាក់ពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ គ.ជ.ប ត្រូវបដិសេធឈ្មោះរបស់ជននោះ ដោយត្រូវ៖

៧.៣.៦.១ រក្សាទុកឈ្មោះអ្នកសង្កេតការណ៍ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់។

៧.៣.៦.២ គូសបន្ទាត់លុបលើឈ្មោះ ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់ និងចារ "បដិសេធ" នៅខាងចុងឈ្មោះត្រង់ខ្ទង់ផ្សេងៗ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ។

៧.៣.៧ គ.ជ.ប ត្រូវចេញសេចក្ដីសម្រេចអនុញ្ញាតជាលាយលក្ខណ៍អក្សរ ចំពោះតែអ្នកសង្កេតការណ៍ណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបដិសេធឈ្មោះអ្នកសង្កេតការណ៍ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់នោះចោល។

៧.៣.៨ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួនជាថ្មី តាមប្រតិទិនដែលកំណត់ដោយ គ.ជ.ប។

៧.៣.៩ សេចក្ដីសម្រេចអនុញ្ញាតលើឈ្មោះអ្នកសង្កេតការណ៍ជាតិ ត្រូវធ្វើជា៤(បួន)ច្បាប់ ដើម្បី៖

- ជូនសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ២ (ពីរ) ច្បាប់
- ផ្ញើជូន លធ.ខប ឬ គធ.ខប ពាក់ព័ន្ធ ១ (មួយ)
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៧.៣.១០ បញ្ជីឈ្មោះអ្នកសង្កេតការណ៍ដែលត្រូវបានសម្រេចត្រូវបោះត្រាលើគ្រប់ទំព័រ រួចផ្ញើបញ្ជីឈ្មោះនោះទៅ លធ.ខប ឬ គធ.ខប ពាក់ព័ន្ធ និងសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។

៧.៣.១១ លធ.ខប ឬ គធ.ខប ត្រូវផ្ដល់បណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិបំពេញការងារសង្កេតការណ៍នៅរាជធានី ខេត្តរបស់ខ្លួន។ លធ.ខប ឬ គធ.ខប ពាក់ព័ន្ធត្រូវផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកសង្កេតការណ៍ដែលតំណាងរបស់សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបង្ហាញជូនជាមួយនឹងបញ្ជីឈ្មោះអ្នកសង្កេតការណ៍ដែលផ្ញើជូនជាផ្លូវការដោយ គ.ជ.ប។

៧.៣.១២ ក្រោយពីបានពិនិត្យឃើញថា ត្រឹមត្រូវហើយ លធ.ខប ឬ គធ.ខប ត្រូវ៖

៧.៣.១២.១ ប្រគល់បណ្ណគ្រប់ចំនួនតាមឈ្មោះនៃអ្នកសង្កេតការណ៍ដែលមាននៅក្នុងបញ្ជីឈ្មោះដើម្បីឱ្យតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបំពេញ និងបិទរូបថត។

៧.៣.១២.២ ប្រាប់ទៅតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលបណ្ណសម្គាល់អ្នកសង្កេតការណ៍គ្រប់ចំនួនហើយនោះថា ឱ្យបំពេញឱ្យបានត្រឹមត្រូវ។

៧.៣.១២.៣ ចុះហត្ថលេខា និងបោះត្រា លធ.ខប ឬ គធ.ខប លើបណ្ណសម្គាល់អ្នកសង្កេតការណ៍ ដែលសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល បានបំពេញត្រឹមត្រូវ និងបិទរូបថតរួចដោយសាមីខ្លួនអាចចុះហត្ថលេខាជាក្រោយ។

៧.៣.១៣ បណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិដែលយកជាផ្លូវការបាន ក្នុងដំណើរការសង្កេតការណ៍បោះឆ្នោតគឺៈ

៧.៣.១៣.១ បណ្ណសម្គាល់ចេញដោយ គ.ជ.ប តាមរយៈ លធ.ខប ឬ គធ.ខប។

៧.៣.១៣.២ បណ្ណមានបិទរូបថត និងបំពេញត្រឹមត្រូវតាមខ្លឹមសារក្នុងបណ្ណសម្គាល់។

៧.៣.១៣.៣ ត្រូវបាន លធ.ខប ឬ គធ.ខប បោះត្រានៅលើជ្រុងខាងស្តាំផ្នែកខាងក្រោមនៃរូបថត។

៧.៣.១៤ ប្រធាន ឬតំណាងរបស់សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវចុះហត្ថលេខាលើការធានា និងការទទួលខុសត្រូវលើបញ្ជីឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួន ជាពិសេស គឺការទទួលខុសត្រូវចំពោះមុខច្បាប់ អំពីអត្តសញ្ញាណរបស់អ្នកសង្កេតការណ៍ម្នាក់ៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។

៧.៣.១៥ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចស្នើសុំដាក់អ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសរបស់ខ្លួនបានយ៉ាងច្រើន ១០ (ដប់) នាក់ ក្នុងករណីសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ មានអ្នកសង្កេតការណ៍របស់ខ្លួនចាប់ពី ៥ (ប្រាំ) រាជធានី ខេត្តឡើងទៅ។ បណ្ណសម្គាល់អ្នកសង្កេតការណ៍ចល័តទូទាំងប្រទេសមានគំរូ និងពណ៌ផ្សេងគ្នាពីបណ្ណអ្នកសង្កេតការណ៍ជាតិ។ ការដាក់ពាក្យសុំអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេស មាននីតិវិធីដូចគ្នានឹងការដាក់ពាក្យសុំអ្នកសង្កេតការណ៍ជាតិដែរ។ អ្នកសង្កេតការណ៍ចល័តទូទាំងប្រទេសមានសិទ្ធិ និងភារកិច្ចដូចមានចែងក្នុង ប.ន.ព.ស នេះ ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត និងគោលការណ៍ណែនាំនានារបស់ គ.ជ.ប។

៧.៣.១៦ អង្គការដែលបង្កើតដោយរាជរដ្ឋាភិបាល មិនអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍ឡើយ។

៧.៣.១៧ លធ.ខប ឬ គធ.ខប ត្រូវធ្វើរបាយការណ៍បូកសរុបចំនួនអ្នកសង្កេតការណ៍ជាតិតាមដំណាក់កាលនីមួយៗ រួចផ្ញើមក គ.ជ.ប។

## អ្នកសង្កេតការណ៍អន្តរជាតិ

### ប្រការ៧.៤._

នៅពេលអញ្ជើញចូលមកដល់ព្រះរាជាណាចក្រកម្ពុជា អ្នកសង្កេតការណ៍អន្តរជាតិត្រូវទៅបង្ហាញខ្លួននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីទទួលព័ត៌មានផ្សេងៗ។

៧.៤.១ អ្នកសង្កេតការណ៍អន្តរជាតិដែលមានបំណងចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ នៅ គ.ជ.ប ឬតាមរយៈអ៊ីមែល info@nec.gov.kh ចាប់តាំងពីថ្ងៃប្រកាសផ្សាយប្រតិទិនបោះឆ្នោតរហូតដល់ ៣ (បី) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៧.៤.២ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវផ្តល់ជូននូវគំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ និងបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិ ដោយឥតគិតថ្លៃ ដើម្បីបំពេញ និងបិទរូបថត។ ទម្រង់បែបបទស្នើសុំ អាចទាញយកពីគេហទំព័រ www.nec.gov.kh។

៧.៤.៣ គ.ជ.ប ត្រូវពិនិត្យពាក្យសុំ និងបណ្ណសម្គាល់ដែលបានបំពេញហើយ និងចេញសេចក្តីសម្រេចអនុញ្ញាតយល់ព្រមឱ្យអ្នកសង្កេតការណ៍អន្តរជាតិ ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ។

៧.៤.៤ ក្រោយពីពិនិត្យឃើញថា ពាក្យសុំរៀបចំពុំទាន់បានត្រឹមត្រូវ គ.ជ.ប ត្រូវណែនាំអ្នកសង្កេតការណ៍អន្តរជាតិនោះឱ្យបំពេញ ឬកែតម្រូវឡើងវិញភ្លាមៗ ដើម្បី គ.ជ.ប ចេញសេចក្តីសម្រេចអនុញ្ញាត។

៧.៤.៥ ក្នុងករណីពិនិត្យឃើញថា ពាក្យសុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ហើយ គ.ជ.ប ត្រូវជូនបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិឱ្យសាមីខ្លួន ឬតំណាង ដើម្បីសរសេរបំពេញ បិទរូបថត និងចុះហត្ថលេខាសាមីខ្លួន រួចហើយត្រូវជូនបណ្ណនោះមក គ.ជ.ប វិញ។

៧.៤.៦ បន្ទាប់ពីទទួលបណ្ណដែលបានបំពេញត្រឹមត្រូវហើយ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាត ចុះហត្ថលេខា និងបោះត្រានៅលើជ្រុងខាងស្តាំផ្នែកខាងក្រោមនៃរូបថតអ្នកសង្កេតការណ៍អន្តរជាតិ រួចប្រគល់ជូនទៅអ្នកសង្កេតការណ៍នោះវិញ ដើម្បីពាក់បំពេញការងារ។

៧.៤.៧ អ្នកសង្កេតការណ៍អន្តរជាតិ ដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប មានសិទ្ធិសង្កេតមើលដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាល និងគ្រប់ទីកន្លែងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

៧.៤.៨ អ្នកបកប្រែភាសារបស់អ្នកសង្កេតការណ៍អន្តរជាតិ ត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយនឹងពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង។ អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសង្កេតការណ៍អន្តរជាតិឡើយ ប៉ុន្តែអាចចូលរួមដំណើរជាមួយអ្នកសង្កេតការណ៍អន្តរជាតិទៅគ្រប់កន្លែងធ្វើការសង្កេតការណ៍។

## សិទ្ធិរបស់អ្នកសង្កេតការណ៍

៧.៤.៩ នៅពេលត្រូវបានទទួលស្គាល់ជាផ្លូវការ និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍រួចហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិដូចខាងក្រោម៖

៧.៤.៩.១ អ្នកសង្កេតការណ៍ជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានីខេត្តដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប។

៧.៤.៩.២ អ្នកសង្កេតការណ៍អន្តរជាតិអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។

៧.៤.៩.៣ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជួយដោះស្រាយទាន់ពេលវេលា។

៧.៤.៩.៤ អមដំណើរជាមួយ គ.ក.ប/គ.ក.រ គធ.ខប និង គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនសម្ភារ បរិក្ខារបោះឆ្នោត។

៧.៤.៩.៥ សង្កេតការណ៍នូវរាល់សកម្មភាពរបស់ គ.ក.ប/គ.ក.រ ឬ គធ.ខប និង គ.ជ.ប នៅមុនពេល ក្នុងពេល និងក្រោយពេលបោះឆ្នោតតាមប្រតិទិនកំណត់ដោយ គ.ជ.ប។

៧.៤.៩.៦ ចេញ ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយមិនត្រូវបង្កការរំខាន។

៧.៤.៩.៧ ជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោត នៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់

សន្លឹកឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះមិនទាក់ទងនឹង ការគាំទ្រ ឬប្រឆាំងនឹងបេក្ខជនណាម្នាក់ ឬគណបក្សនយោបាយណាមួយ។

## ភារកិច្ចរបស់អ្នកសង្កេតការណ៍

៧.៤.១០ អ្នកសង្កេតការណ៍ទាំងឡាយមានភារកិច្ចដូចខាងក្រោម៖

៧.៤.១០.១ ត្រូវគោរពច្បាប់ដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលស្គាល់ និងគោរពអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

៧.៤.១០.២ ត្រូវយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។ ក្នុងករណីមានការរំលោភច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី ត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន។

៧.៤.១០.៣ ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្ខពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋាន ពណ៌ ឬវត្ថុដទៃទៀតដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១០.៤ រក្សាការសម្ងាត់នៃការបោះឆ្នោត។

៧.៤.១០.៥ ត្រូវបង្ហាញភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចដែលបានសាកសួរខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួនដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយ លធ.ខប ឬ គធ.ខប ឬ គ.ជ.ប។

៧.៤.១០.៦ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធីដែលបានកំណត់ដោយ គ.ជ.ប និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរនៃការបោះឆ្នោត ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ។

៧.៤.១០.៧ ធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន

ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួន។

៧.៥.១០.៨ ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ញា និងនីតិវិធី ដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងអាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ផង។

៧.៥.១០.៩ ត្រូវគោរពតាមការកំណត់របស់អគ្គលេខាធិការរដ្ឋសភា ឬ កបឃ.ស ឬប្រធាន គ.ក.ប/គ.ក.រ ដែលតម្រូវឱ្យផ្លាស់ប្តូរគ្នាចូលសង្កេតការណ៍ម្តង ៤ (បួន) នាក់ ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពី ៤(បួន)នាក់ សម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោតមួយ។

## បម្រាមចំពោះអ្នកសង្កេតការណ៍

៧.៥.១១ ក្នុងការសង្កេតមើលការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោត អ្នកសង្កេតការណ៍មិនត្រូវ៖

៧.៥.១១.១ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។

៧.៥.១១.២ ជជែកពិភាក្សាជាមួយនឹងអ្នកបោះឆ្នោតទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាម្នាក់ ។

៧.៥.១១.៣ យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន។

៧.៥.១១.៤ បញ្ចុះបញ្ចូល ឬប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនាដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.៥ ចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.៦ ចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.៧ ចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៧.៤.១១.៨ ស្វង់មតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.៩ សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.១០ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.១១ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.១២ ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្តរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលរបស់ខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.១៣ ផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.១៤ ផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋសម្រាប់ចូលរួមក្នុងសកម្មភាពឃោសនាបោះឆ្នោត ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.១៥ ផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ដង្ហែក្បួនឃោសនាបោះឆ្នោត ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនាបោះឆ្នោត ទោះដោយផ្ទាល់ក្តី ឬ

ប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៧.៤.១១.១៦ រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ នៅពេលដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត កំពុងប្រព្រឹត្តទៅ។

៧.៤.១១.១៧ ប៉ះពាល់ឯកសារ ឬសម្ភារ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង។

៧.៤.១១.១៨ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោត។

៧.៤.១១.១៩ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៧.៤.១១.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត និងបង្អាក់ដំណើរការបោះឆ្នោត។

៧.៤.១១.២១ រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៧.៤.១១.២២ ចូលរួមជជែកវែកញែកក្នុងដំណើរការដោះស្រាយពាក្យបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោត ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយពាក្យបណ្តឹងនេះបាន។

៧.៤.១១.២៣ ធ្វើសកម្មភាពផ្សេងទៀតដែលត្រូវបានហាមឃាត់ដូចកំណត់ក្នុង ប.ន.ព.ស នេះ និងគោលការណ៍ណែនាំរបស់ គ.ជ.ប។

## អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ

### ប្រការ៧.៥.-

សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ្យដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះដោយផ្ទាល់នៅ គ.ជ.ប។

៧.៥.១ នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ត្រូវអនុវត្តការងារទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកសារព័ត៌មានជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានឯករាជ្យដែលចូលរួមក្នុងដំណើរការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៧.៥.២ គ.ជ.ប ត្រូវផ្តល់ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានដល់សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ្យ តាមការស្នើសុំដោយឥតគិតថ្លៃ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័រ www.nec.gov.kh។

៧.៥.២.១ រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ គឺចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិនរហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៧.៥.២.២ រយៈពេលនៃការដាក់ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ គឺចាប់ផ្តើមពីថ្ងៃប្រកាសផ្សាយប្រតិទិនរហូតដល់ ៣ (បី) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៧.៥.៣ ពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិ និងអន្តរជាតិត្រូវភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម៖

៧.៥.៣.១ សម្រាប់អ្នកសារព័ត៌មានជាតិ ត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- លិខិតស្នើសុំធ្វើបណ្ណអ្នកសារព័ត៌មានពី គ.ជ.ប របស់សាមីអង្គភាព
- ច្បាប់ចម្លងនៃបណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប។

៧.៥.៣.២ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិដែលមានការិយាល័យអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជាត្រូវភ្ជាប់មកជាមួយនូវ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- លិខិតស្នើសុំធ្វើបណ្ណអ្នកសារព័ត៌មានពី គ.ជ.ប របស់សាមីអង្គភាព
- ច្បាប់ចម្លងនៃបណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប
- ច្បាប់ចម្លងនៃលិខិតឆ្លងដែន (សម្រាប់ជនបរទេស)។

៧.៥.៣.៣ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យដោយផ្ទាល់នៅ គ.ជ.ប ឬតាមរយៈអ៊ីមែល info@nec.gov.kh ត្រូវភ្ជាប់ជាមួយនូវ៖

- ច្បាប់ចម្លងនៃលិខិតឆ្លងដែន

- បណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប។

៧.៥.៣.៤ សម្រាប់អ្នកសារព័ត៌មានឯករាជ្យ ត្រូវភ្ជាប់មកជាមួយនូវៈ
- ច្បាប់ចម្លងនៃបណ្ណសារព័ត៌មានដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមអ្នកសារព័ត៌មាន
- ប្រវត្តិរូបសង្ខេប
- អត្ថបទចុងក្រោយដែលខ្លួនបានសរសេរចុះផ្សាយក្នុងសារព័ត៌មាន ស្របច្បាប់ក្នុងអំឡុងឆ្នាំចុងក្រោយចំនួន ៣ (បី) អត្ថបទ។

៧.៥.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ សម្រាប់អ្នកសារព័ត៌មានជាតិ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកសារព័ត៌មាន អាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀត ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតបដិសេធ។

៧.៥.៥ គ.ជ.ប ត្រូវពិនិត្យ សម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកសារព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀត ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតបដិសេធ។

៧.៥.៦ គ.ជ.ប ត្រូវបោះពុម្ពបណ្ណអ្នកសារព័ត៌មានជាតិ និងបណ្ណអ្នកសារព័ត៌មានអន្តរជាតិ ដើម្បីផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកសារព័ត៌មានដែលត្រូវបានអនុញ្ញាតឱ្យយកព័ត៌មានដោយ គ.ជ.ប ដើម្បីពាក់ក្នុងពេលបំពេញការងារ។

៧.៥.៧ អ្នកសារព័ត៌មានត្រូវគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប ប.ន.ព.ស នេះ ក្រមសីលធម៌របស់ គ.ជ.ប និងវិជ្ជាជីវៈអ្នកសារព័ត៌មាន។

៧.៥.៨ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលបានទទួលការអនុញ្ញាតដោយ គ.ជ.ប អាចយកព័ត៌មានក្នុងដំណើរការបោះឆ្នោតទាំងមូល ដោយត្រូវគោរព ច.ប.ព.ស

ច.ប.ត.រ ច.វ.ច.ប ប.ន.ព.ស នេះ និងគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត។

៧.៥.៩ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិមានសិទ្ធិថត និងយកព័ត៌មាន។

៧.៥.១០ ការយកព័ត៌មានដោយរូបភាពក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវជម្រាបជូនដំណឹងទៅអគ្គលេខាធិការរដ្ឋសភា ឬប្រធាន កបឃ.ស ឬប្រធាន គ.ក.ប/គ.ក.រ ជាមុន។

៧.៥.១១ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិមិនត្រូវៈ

- ជ្រៀតជ្រែក ឬរំខានដល់ការងារចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ធ្វើសម្ភាសន៍នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧.៥.១២ អ្នកបកប្រែរបស់អ្នកសារព័ត៌មានអន្តរជាតិ ត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយនឹងពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង។ អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសារព័ត៌មានអន្តរជាតិឡើយ ប៉ុន្តែអាចចូលរួមដំណើរជាមួយអ្នកសារព័ត៌មានអន្តរជាតិទៅគ្រប់កន្លែង។

៧.៥.១៣ អ្នកសារព័ត៌មានមិនត្រូវប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើសមាជិក គ.ក.ប/គ.ក.រ ឬអ្នកសង្កេតការណ៍ ឬបេក្ខជន ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោតឡើយ។

# ជំពូកទី៨
# ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល
# នៃការបោះឆ្នោត

## ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

### ប្រការ៨.១.-

គ.ជ.ប ត្រូវកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ហើយត្រូវបោះពុម្ព និងចាត់ចែងឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនេះ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា លគធ.ខប សាលាឃុំ សង្កាត់ និងនៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនរាជធានី ខេត្ត យ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៨.១.១ នាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ត្រូវបោះពុម្ព និងបញ្ជូនបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ទៅក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានរដ្ឋសភា លគធ.ខប និង កបឃ.ស សម្រាប់បម្រើការបិទផ្សាយ និងប្រើប្រាស់ដូចខាងក្រោម៖

៨.១.១.១ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៃគ្រប់រាជធានី ខេត្តចំណុះភូមិភាគទាំងអស់ ១ (មួយ) ច្បាប់ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា។

៨.១.១.២ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៃរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ នៅ លគធ.ខប។

៨.១.១.៣ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៃរាជធានី ខេត្តពាក់ព័ន្ធ ១(មួយ)ច្បាប់ នៅទីកន្លែងមួយចំនួនក្នុងទីប្រជុំជនរាជធានី ខេត្តនោះ។

៨.១.១.៤ បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៃរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ នៅសាលាឃុំ សង្កាត់។

៨.១.១.៥ រក្សាបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៃរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ នៅ លគធ.ខប ដើម្បីទុកជាឯកសារ និងបម្រើការផ្សព្វផ្សាយជាសាធារណៈ។

៨.១.១.៦ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់។

៨.១.២ នាយកដ្ឋានប្រតិបត្តិការត្រូវសហការជាមួយនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ដើម្បីរៀបចំបញ្ជីឈ្មោះទីតាំងការិយាល័យ

បោះឆ្នោត។ នាយកដ្ឋានប្រតិបត្តិការត្រូវផ្តល់បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតជូននាយកដ្ឋានរដ្ឋបាលនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ១ (មួយ) ច្បាប់ ដើម្បីសហការគ្នាធ្វើជាសេនាធិការជូន គ.ជ.ប ក្នុងការកំណត់ចំនួនមន្ត្រីការិយាល័យបោះឆ្នោត ដើម្បីជ្រើសរើសសមាសភាព គ.ក.ប/គ.ក.រ។

៨.១.៣ គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត អាចសុំថតចម្លងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដោយបង់ថ្លៃ។ តម្លៃគិតត្រឹមតែតម្លៃផលិតតែប៉ុណ្ណោះ។ ការផ្គត់ផ្គង់ចំពោះការស្នើសុំនេះ ត្រូវផ្អែកលើលទ្ធភាពផលិត និងតាមលំដាប់មុនក្រោយនៃការស្នើសុំ។ រាល់ការស្នើសុំតម្រូវឱ្យបង់ប្រាក់មុនស្មើនឹង ១០០ (មួយរយ) ភាគរយនៃតម្លៃផលិត។

## ការផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតចាំបាច់សម្រាប់ការបោះឆ្នោត

## ប្រការ៨.២.-

គ.ជ.ប ត្រូវផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនៃរាជធានី ខេត្តឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា។

៨.២.១ គ.ជ.ប ធានាបោះពុម្ពសន្លឹកឆ្នោតគ្រប់ចំនួនសម្រាប់រាជធានី ខេត្តនីមួយៗនៅលើក្រដាសពណ៌ស។

៨.២.២ សន្លឹកឆ្នោតនីមួយៗត្រូវមានគល់បញ្ជីសន្លឹកឆ្នោត។ លេខរៀងតាមលំដាប់តគ្នានៃសន្លឹកឆ្នោតត្រូវបោះនៅលើគល់បញ្ជីសន្លឹកឆ្នោត។

៨.២.៣ សន្លឹកឆ្នោតនីមួយៗត្រូវមានសញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់។ សញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ដែលត្រូវដាក់នៅលើសន្លឹកឆ្នោតត្រូវដាក់តាមលំដាប់លំដោយ ផ្អែកតាមលទ្ធផលនៃការចាប់ឆ្នោតដូចមានចែងក្នុងប្រការ ៥.១៥ នៃ ប.ន.ព.ស នេះ។

៨.២.៤ ភូមិភាគនីមួយៗ ត្រូវមានសន្លឹកឆ្នោតដោយឡែករបស់ខ្លួន ដែល គ.ជ.ប ផ្តល់ជូន។

៨.២.៥ គ.ជ.ប ត្រូវធានាផ្តល់ហិបឆ្នោតឱ្យបានគ្រប់ចំនួនសម្រាប់រាជធានី ខេត្តនីមួយៗ។ គ្រប់ហិបឆ្នោតទាំងអស់ត្រូវៈ

- មានគម្របជាប់មកជាមួយ ដែលអាចចាក់បិទបានដោយប្រើប្រាស់សោឃ្លុំមានលេខ

- ធានានូវសុវត្ថិភាពដែលមិនអាចហូតយកសន្លឹកឆ្នោតចេញពីក្នុងហិបឆ្នោតបាន ប្រសិនបើមិនបើកគម្រប
- មានសោ ឬឧបករណ៍ផ្សេងទៀតសម្រាប់កិបពេលបិទហិបឆ្នោត
- មានស្លាកលេខ ឬសញ្ញាសម្គាល់នៅផ្នែកខាងក្រៅយ៉ាងច្បាស់ដែលមិនអាចដូរ ឬលុបបានដោយងាយ ហើយស្លាកលេខ ឬសញ្ញាសម្គាល់នេះត្រូវមានតែមួយគត់សម្រាប់ហិបឆ្នោតនោះ និងសម្គាល់បានថា ហិបឆ្នោតនោះទាក់ទងទៅនឹងរាជធានី ខេត្ត និងការិយាល័យបោះឆ្នោតណាមួយ។

៨.២.៦ គ.ជ.ប ត្រូវធានាឱ្យមានត្រាសម្ងាត់ជាផ្លូវការគ្រប់ចំនួន និងខុសៗគ្នាសម្រាប់ការិយាល័យបោះឆ្នោតនៃរាជធានី ខេត្តនីមួយៗ។

៨.២.៧ គ.ជ.ប ត្រូវតាក់តែងបទបញ្ជា និងនីតិវិធីសម្រាប់ការប្រគល់ ទទួល និងការប្រគល់ត្រឡប់មកវិញ និងធានាភាពសម្ងាត់នៃត្រាសម្ងាត់។

៨.២.៨ គ.ជ.ប ត្រូវធានាឱ្យការិយាល័យបោះឆ្នោតនីមួយៗ មានសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម៖

១- បញ្ជីបោះឆ្នោត។
២- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់។
៣- ហិបឆ្នោត។
៤- បន្ទប់សម្ងាត់។
៥- ត្រា គ.ក.ប។
៦- ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។
៧- ទឹកខ្មៅលុបមិនជ្រះ។
៨- សោ និងប្រដាប់ឃ្លុំ។
៩- ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល។
១០- ប៊ិកសរសេរដែលមានគុណភាពល្អ។
១១- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ។
១២- ថង់ប្លាស្ទិក។
១៣- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗទៀត។

## ភារៈទទួលខុសត្រូវ និងភារកិច្ចរបស់ គ.ក.ប/គ.ក.រ

## ប្រការ៨.៣.–

គ.ក.ប/គ.ក.រ នីមួយៗមានភារកិច្ចចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែល គ.ក.ប/គ.ក.រ នោះទទួលខុសត្រូវ។

៨.៣.១ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនទទួលខុសត្រូវ និងត្រូវ៖

៨.៣.១.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៣.១.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ព.ស ច.ប.គ.រ ប.ន.ព.ស នេះ និងការណែនាំរបស់ គ.ជ.ប។

៨.៣.១.៣ ទទួលពិនិត្យ ផ្ទៀងផ្ទាត់ និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារ ឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ពិសេសពិនិត្យលេខកូដនៃកញ្ចប់សន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតសម្រាប់រាជធានី ខេត្ត។

៨.៣.១.៤ រៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត និងបំពាក់គ្រឿងសង្ហារិម។

៨.៣.១.៥ តាមដាន និងត្រួតពិនិត្យការបំពេញការងាររបស់សមាសភាព គ.ក.ប/គ.ក.រ នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងអាណត្តិរបស់ខ្លួន។

៨.៣.១.៦ ដាក់ជំនួសតំណែងសមាជិក គ.ក.ប/គ.ក.រ ណាដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា ដោយយោងទៅតាមចំណុច ៨.៤.៩ ខាងក្រោមនេះ។

៨.៣.១.៧ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។ ក្នុងពេលកំពុងដំណើរការបោះឆ្នោតយ៉ាងយូរ ១ (មួយ) ម៉ោងម្តង ត្រូវចូលក្នុងបន្ទប់សម្ងាត់ ដើម្បីធ្វើអនាម័យសម្លាប់មេរោគ និងត្រួតពិនិត្យសុវត្ថិភាព សម្ភារដែលបំពាក់នៅទីនោះ និងសណ្តាប់ធ្នាប់ ក្នុងករណីគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់។

៨.៣.១.៨ ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបានបំពេញ និងចុះហត្ថលេខាត្រឹមត្រូវ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាជាសាក្សី។

៨.៣.១.៩ ត្រួតពិនិត្យបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ និង បណ្ណសម្គាល់អ្នកសង្កេតការណ៍ដែលត្រូវចូលរួមសង្កេតមើល ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៣.១.១០ អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ផ្លាស់ប្តូរទីកន្លែងពិនិត្យមើលដំណើរការបោះឆ្នោត ដោយត្រូវ រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ និងធានាឱ្យបាននូវការសម្ងាត់ នៃការបោះឆ្នោត។

៨.៣.១.១១ ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតដល់អ្នកដែលមានវត្តមាន នៅក្នុងការិយាល័យបោះឆ្នោត។

៨.៣.១.១២ បើក និងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅក្នុងការិយាល័យ បោះឆ្នោត។

៨.៣.១.១៣ ចាត់វិធានការនានា ដើម្បីធានាឱ្យបាននូវសណ្តាប់ធ្នាប់ របៀប រៀបរយ និងការប្រព្រឹត្តទៅជាប្រក្រតីនៃការបោះឆ្នោត និង ការរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ឬការិយាល័យ រាប់សន្លឹកឆ្នោត ព្រមទាំងបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៨.៣.១.១៤ ចាក់ ឬកាត់ផ្តាច់សោឃ្លុំការពារហិបឆ្នោត។

៨.៣.១.១៥ ធានាឱ្យប្រាកដថា អ្នកបោះឆ្នោតម្នាក់ៗត្រូវបានបង្រៀនឱ្យ ចេះពីរបៀបបោះឆ្នោត និងតាមដានពិនិត្យមើល ដើម្បីឱ្យ ប្រាកដថា នៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបាន បត់សន្លឹកឆ្នោតតាមផ្នត់ដើម ដូចការណែនាំ។

៨.៣.១.១៦ ធានាឱ្យប្រាកដថា ការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះត្រូវតែ បានអនុវត្តតាមការណែនាំ។

៨.៣.១.១៧ ធានាឱ្យប្រាកដថា ការលើកយោបល់ជំទាស់ និងការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ក្នុងការិយាល័យបោះឆ្នោតដោយភ្នាក់ងារ គណបក្សនយោបាយ ត្រូវបានដោះស្រាយភ្លាម ដោយអនុវត្ត ស្របតាម ប.ន.ព.ស នេះ និងការណែនាំរបស់ គ.ជ.ប។

៨.៣.១.១៨ ជួយអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោត ដោយខ្លួនឯងបាន តាមការស្នើសុំរបស់សាមីខ្លួន។

៨.៣.១.១៩ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ និង រាប់សន្លឹកឆ្នោត។

៨.៣.១.២០ ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្សនយោបាយដែលបានទទួលសំឡេងឆ្នោត។

៨.៣.១.២១ ប្រគល់ជូន គឃ.ខប នូវស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត។

៨.៣.១.២២ ប្រគល់ជូន គឃ.ខប នូវកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតបាន។

៨.៣.១.២៣ បំពេញភារកិច្ចរបស់ខ្លួនក្នុងជំហរអព្យាក្រឹត និងមិនលម្អៀង។

៨.៣.១.២៤ បំពេញភារកិច្ចផ្សេងៗទៀតដែល គឃ.ខប តម្រូវឱ្យធ្វើ។

៨.៣.២ អនុប្រធាន គ.ក.ប/គ.ក.រ ត្រូវជួយប្រធាន គ.ក.ប/គ.ក.រ និងមានភារកិច្ចដោយឡែកដូចខាងក្រោមៈ

៨.៣.២.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៣.២.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ព.ស ច.ប.គ.រ ប.ន.ព.ស នេះ និងការណែនាំរបស់ គ.ជ.ប។

៨.៣.២.៣ ជំនួសតំណែងប្រធាន គ.ក.ប/គ.ក.រ ក្នុងករណីប្រធាន គ.ក.ប/គ.ក.រ មិនអាចមកបំពេញការងារបាន។

៨.៣.២.៤ រាប់ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែងសម្រាប់ប្រើក្នុងការិយាល័យបោះឆ្នោត មុននឹងបើកកិច្ចប្រតិបត្តិការបោះឆ្នោត។

៨.៣.២.៥ ហែកសន្លឹកឆ្នោតផ្តាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បោះត្រាសម្ងាត់លើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្នត់តាមការណែនាំរបស់ គ.ជ.ប រួចប្រគល់ជូនអ្នកបោះឆ្នោត។

៨.៣.២.៦ ផ្តល់ការណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត។

៨.៣.២.៧ អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់ នៅពេលដែលបន្ទប់សម្ងាត់នោះទំនេរគ្មានអ្នកបោះឆ្នោតផ្សេងទៀត។

៨.៣.២.៨ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតនៅពេលបញ្ចប់ការបោះឆ្នោត។

៨.៣.២.៩ ត្រួតពិនិត្យ និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់នៅខាងខ្នង មុននឹងប្រគល់ជូនប្រធាន គ.ក.រ។

៨.៣.២.១០ កត់ត្រាសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗ បានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)។

៨.៣.២.១១ អមដំណើរប្រធាន គ.ក..រ ក្នុងការបញ្ជូន និងប្រគល់ស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតជូន គធ.ខប។

៨.៣.២.១២ បំពេញភារកិច្ចផ្សេងទៀតដែល គធ.ខប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ។

៨.៣.៣ លេខាធិការនៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/គ.ក.រ និងជាអ្នកទទួលបន្ទុកការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងការបំពេញទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ហើយត្រូវ៖

៨.៣.៣.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៣.៣.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ព.ស ច.ប.ត.រ ប.ន.ព.ស នេះ និងការណែនាំរបស់ គ.ជ.ប។

៨.៣.៣.៣ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត។

៨.៣.៣.៤ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

៨.៣.៣.៥ ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បោះឆ្នោត នៅមុនពេលពិនិត្យឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត។

៨.៣.៣.៦ សួរបញ្ជាក់ឈ្មោះ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពដូចគ្នារវាងរូបពិត ឈ្មោះ និងទិន្នន័យក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង

របស់សាមីអ្នកបោះឆ្នោតជាមួយនឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត រួចគូសសម្គាល់ថាបានមកបោះឆ្នោតក្នុងកូនប្រអប់បួនជ្រុងទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះលើបញ្ជីបោះឆ្នោត។

៨.៣.៣.៧ រាប់គំនូសសញ្ញាលើបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធាន គ.ក.ប អំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងមិនបានបោះឆ្នោត។

៨.៣.៣.៨ បំពេញកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងដាក់ជូនប្រធាន គ.ក.ប ចុះហត្ថលេខា រួចដាក់បង្ហាញឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល។

៨.៣.៣.៩ កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកយោបល់ជំទាស់ ឬតវ៉ា ឬករណីប្ដឹងជំទាស់ ឬប្ដឹងតវ៉ាទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៣.៣.១០ កត់ត្រាសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)។

៨.៣.៣.១១ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងដាក់ជូនប្រធាន គ.ក.រ ចុះហត្ថលេខា។

៨.៣.៣.១២ បំពេញភារកិច្ចផ្សេងទៀតដែល គធ.ឧប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ។

៨.៣.៤ សមាជិកទី១ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/គ.ក.រ និងត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

៨.៣.៤.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៣.៤.២ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត។

៨.៣.៤.៣ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

៨.៣.៤.៤ ត្រួតពិនិត្យហិបឆ្នោត និងការស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតក្នុងពេលកំពុងដំណើរការបោះឆ្នោត។

៨.៣.៤.៥ រាយការណ៍ជូនប្រធាន គ.ក.ប ក្នុងករណីពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បាន និងកំពុងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលក្នុងហិបឆ្នោត។

៨.៣.៤.៦ ជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោតដែលបានបោះឆ្នោតរួច ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះឱ្យដល់គល់ក្រចក និងណែនាំ គាត់ឱ្យរង់ចាំទឹកខ្មៅស្ងួតមុននឹងចេញពីការិយាល័យបោះឆ្នោត។

៨.៣.៤.៧ រាប់ចំនួនសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីផ្ទៀងផ្ទាត់ ទៅនឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងដកយក វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដាក់ទៅក្នុង ស្រោមសំបុត្រដោយឡែក។

៨.៣.៤.៨ លាសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីត្រួតពិនិត្យ ស្នាមគ្រាសម្ងាត់នៅផ្នែកខាងខ្នង និងបែងចែកតាមពំនូក សន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់។

៨.៣.៤.៩ កត់ត្រាសំឡេងឆ្នោតដែលគណបក្សនយោបាយនីមួយៗ បានទទួលនៅលើផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត។

៨.៣.៤.១០ បំពេញភារកិច្ចផ្សេងទៀតដែល គធ.ខប និងប្រធាន គ.ក.ប/ គ.ក.រ តម្រូវឱ្យធ្វើ។

៨.៣.៥ សមាជិកទី២ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/ គ.ក.រ និងត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

៨.៣.៥.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការ បោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៣.៥.២ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

៨.៣.៥.៣ ជួយរកឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតដែលបិទ នៅខាងក្រៅការិយាល័យបោះឆ្នោត និងប្រាប់លេខរៀង ឈ្មោះ របស់គាត់។

៨.៣.៥.៤ ចាត់ចែង និងថែរក្សារបៀបរៀបរយជូនអ្នកបោះឆ្នោត (ក្នុង ករណីចាំបាច់ អាចផ្តល់បណ្ណលេខរៀងតាមលំដាប់អ្នកមក មុនមកក្រោយ) ព្រមទាំងរាយការណ៍ជូនប្រធាន គ.ក.ប អំពី

ការរំខាន ឬការអុកឡុក ឬការរារាំង ឬការជ្រៀតជ្រែកនានា ក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត(ប្រសិនបើមាន)។

៨.៣.៥.៥ រាយការណ៍ជូនប្រធាន គ.ក.ប ក្នុងករណីពិនិត្យឃើញថា មានអ្នកបោះឆ្នោតណាម្នាក់បានយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។

៨.៣.៥.៦ ប្រមូល អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង ពីអ្នកបោះឆ្នោតដែលស្ថិតក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅពេលដល់ម៉ោងបញ្ចប់ការបោះឆ្នោតម៉ោង ១៥:០០ (ដប់ប្រាំ) (ប្រសិនបើមាន)។

៨.៣.៥.៧ ចោះ ឬកាត់សន្លឹកឆ្នោតដែលនៅសល់មិនបានប្រើប្រាស់ បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត។

៨.៣.៥.៨ សហការជាមួយសមាជិកទី៣ ក្នុងការការពារមាត់ទ្វារការិយាល័យបោះឆ្នោត ការថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៨.៣.៥.៩ បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅមុខការិយាល័យបោះឆ្នោត។

៨.៣.៥.១០ បញ្ជូនស្រោមសំបុត្រដែលមានដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ទៅ គធ.ខប។

៨.៣.៥.១១ បំពេញភារកិច្ចផ្សេងទៀតដែល គធ.ខប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ។

៨.៣.៦ សមាជិកទី៣ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន គ.ក.ប/គ.ក.រ និងត្រូវបំពេញភារកិច្ច ដូចខាងក្រោម៖

៨.៣.៦.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៣.៦.២ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត។

៨.៣.៦.៣ ជួយប្រធាន គ.ក.ប/គ.ក.រ ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប។

៨.៣.៦.៤ ត្រួតពិនិត្យច្រកទ្វារចូលនៃការិយាល័យបោះឆ្នោត ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តគ្នាជាជួរតាមលំដាប់មុនក្រោយ និងត្រូវរក្សាគម្លាតសុវត្ថិភាពបុគ្គល ប្រសិនបើគាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ និងត្រួតពិនិត្យ អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងរបស់គាត់។

៨.៣.៦.៥ អនុញ្ញាតឱ្យអ្នកបោះឆ្នោតមានវត្តមានក្នុងការិយាល័យបោះឆ្នោត ចំនួន ៤ (បួន) នាក់ ក្នុងពេលតែមួយ។

៨.៣.៦.៦ ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត ចំពោះអ្នកបោះឆ្នោតជាមនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនមានពិការភាព និងអ្នកមានជំងឺ បន្ទាប់មកគឺអ្នកឈរខាងមុខគេក្នុងជួរ។

៨.៣.៦.៧ ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត។

៨.៣.៦.៨ ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការរំខាន ឬការអុកឡុក ឬការរាំងស្ទះ ឬការជ្រៀតជ្រែក ជូនប្រធាន គ.ក.ប។

៨.៣.៦.៩ សហការជាមួយសមាជិកទី២ ក្នុងការការពារសន្តិសុខនៅច្រកផ្លូវចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

៨.៣.៦.១០ បំពេញភារកិច្ចផ្សេងទៀតដែល គ.ជ.ប និងប្រធាន គ.ក.ប/គ.ក.រ តម្រូវឱ្យធ្វើ។

## ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត

**ប្រការ៨.៤.-**

គ.ជ.ប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោតត្រូវតែបានបញ្ជូន និងប្រគល់ជូន គ.ក.ប តាមចំនួនសមស្រប និងទាន់តាមពេលវេលាកំណត់។ នៅពេលព្រឹកថ្ងៃសៅរ៍ មុនថ្ងៃបោះឆ្នោតមួយថ្ងៃ ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គ.ក.ប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីធ្វើការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរៀបចំប្លង់ការិយាល័យបោះឆ្នោត។

៨.៤.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារបោះឆ្នោតគ្រប់គ្រាន់សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតជូន គធ.ខប និង គ.ក.ប ទាំងអស់។

៨.៤.២ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវទទួលខុសត្រូវក្នុងការផលិតបញ្ជីបោះឆ្នោតផ្លូវការចំនួន ៣ (បី) ច្បាប់ ក្នុងការិយាល័យបោះឆ្នោតនីមួយៗសម្រាប់បែងចែកជូន គធ.ខប និង គ.ក.ប ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៨.៤.៣ នាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ បច្ចេកទេសត្រូវរៀបចំផែនការបែងចែក និងត្រៀមសម្ភារ ឯកសារបោះឆ្នោតសម្រាប់ដឹកជញ្ជូនទៅកាន់គោលដៅនានាដើម្បីបម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឱ្យបានគ្រប់គ្រាន់ជាមុន។ សម្ភារ ឯកសារសម្រាប់បម្រើការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតត្រូវបានរៀបចំដាក់ក្នុងហិបដែលរួមមាន ៣ (បី) ប្រភេទគឺៈ

៨.៤.៣.១ ហិបបរិក្ខារសម្រាប់បណ្តុះបណ្តាលដែលត្រូវបញ្ជូន និងប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតនៃអគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ និង គធ.ខប។

៨.៤.៣.២ ហិបបរិក្ខារ គធ.ខប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប។

៨.៤.៣.៣ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប។

៨.៤.៤ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវផ្គត់ផ្គង់សម្ភារ បរិក្ខារកុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀតដល់ គធ.ខប សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៨.៩.៥ នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ ទទួលហិបបរិក្ខារ និងសម្ភារផ្សេងៗ ដូចមានចែងក្នុងចំណុច ៨.៩.៣ និងចំណុច ៨.៩.៤ ខាងលើនេះ មន្ត្រីដែលទទួលបន្ទុកការបញ្ជូននៅតាមថ្នាក់នីមួយៗត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ហើយត្រូវឱ្យមន្ត្រីដែលទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗចុះហត្ថលេខាបញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ។

៨.៩.៦ ហិបបរិក្ខារ គធ.ឃប ដែលត្រូវបញ្ជូន និងប្រគល់ជូន គធ.ឃប សម្រាប់ប្រើប្រាស់ក្នុងដំណើរការបោះឆ្នោតដូចមានក្នុងឧបសម្ព័ន្ធទី៧ ស្ដីពីសម្ភារ ឯកសារដែលត្រូវប្រគល់ជូន គធ.ឃប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល។

៨.៩.៧ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ដូចមានក្នុងឧបសម្ព័ន្ធទី៨ ស្ដីពីសម្ភារ ឯកសារដែលត្រូវប្រគល់ជូន គ.ក.ប/គ.ក.រ សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល ដែល គធ.ឃប ត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប នីមួយៗ មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោង មុនថ្ងៃបោះឆ្នោតឡើយ។

៨.៩.៨ គ.ជ.ប និង គធ.ឃប ត្រូវធានាក្នុងការបញ្ជូន និងប្រគល់ឱ្យបានគ្រប់គ្រាន់ជូន គ.ក.ប នៅមុនថ្ងៃបោះឆ្នោតមួយថ្ងៃ នូវសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៩.៧ ខាងលើនេះ។ គធ.ឃប ត្រូវជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីចូលរួមសង្កេតមើល គ.ក.ប នៅពេលធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៩.៩ ខាងក្រោមនេះ។

៨.៩.៩ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវតែមកបង្ហាញខ្លួនតាមការកោះអញ្ជើញរបស់ប្រធាន គ.ក.ប និងត្រូវធានាថា មានវត្តមានក្នុងការបំពេញការងារនៅថ្ងៃបោះឆ្នោត។

៨.៩.៩.១ មុនថ្ងៃបោះឆ្នោត ២៤ (ម្ភៃបួន) ម៉ោង ប្រធាន គ.ក.ប ត្រូវប្រជុំសមាជិកទាំងអស់ ដើម្បីពិនិត្យវត្តមាន និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារ ឯកសារបម្រើឱ្យការបោះឆ្នោត។ ក្នុងករណីបើមានសមាជិកណាម្នាក់អវត្តមាន សមាជិកនោះត្រូវជំនួសដោយមន្ត្រីថ្មីដែលជ្រើសតាំងឡើងតាមការសម្រេចរបស់ គធ.ឃប ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុង ប.ន.ព.ស នេះ។

៨.៤.៩.២ ប្រសិនបើសមាសភាពណាម្នាក់នៃ គ.ក.ប មិនអាចបំពេញការងារក្នុងថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវតែជូនដំណឹងដល់ គធ.ខប ជាបន្ទាន់ ដើម្បីដាក់អ្នកជំនួស។

៨.៤.៩.៣ ប្រសិនបើប្រធាន គ.ក.ប មិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធាន គ.ក.ប ត្រូវចូលកាន់តំណែងប្រធាន គ.ក.ប ហើយសមាជិកទី១ ចូលកាន់តំណែងអនុប្រធាន គ.ក.ប ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មីចេញពីក្នុងចំណោមប្រជាពលរដ្ឋដែលបានដាក់ពាក្យសុំចូលបម្រើការងារ ត្រូវចូលកាន់តំណែងជំនួសសមាជិកទី១។

៨.៤.៩.៤ ប្រសិនបើអនុប្រធាន គ.ក.ប មិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី១ ជាអនុប្រធាន គ.ក.ប ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងកាន់តំណែងជាសមាជិកទី១។

៨.៤.៩.៥ ប្រសិនបើលេខាធិការមិនអាចមកធ្វើការបាន ត្រូវតែងតាំងសមាជិកទី១ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មីនឹងកាន់តំណែងជាសមាជិកទី១។

៨.៤.៩.៦ សមាសភាពទាំងអស់នៃ គ.ក.ប រួមទាំងអ្នកដែលទើបតែជ្រើសរើសថ្មីត្រូវរួមគ្នាសិក្សាឡើងវិញនូវនីតិវិធីនៃការបោះឆ្នោត និងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។

៨.៤.៩.៧ អ្នកតែងតាំងថ្មីទាំងអស់ត្រូវតែបានទទួលការបណ្តុះបណ្តាល និងអនុវត្តដូចមានចែងក្នុងចំណុច ៨.៤.៩.៦ ខាងលើនេះ។

៨.៤.៩.៨ ប្រធាន គ.ក.ប ត្រូវតែជូនដំណឹងជាបន្ទាន់ដល់ គធ.ខប អំពីអ្វីដែលបានអនុវត្តពាក់ព័ន្ធនឹងការដាក់ជំនួសតំណែងណាមួយនៃ គ.ក.ប។

៨.៤.១០ បន្ទាប់ពីអនុវត្តចំណុច ៨.៤.៩ ខាងលើនេះរួច គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែល គ.ក.ប បានទទួល ហើយដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)។

៨.៤.១០.១ គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោត ដោយប្រើតារាងត្រួតពិនិត្យសម្ភារឯកសារបោះឆ្នោត (ទ.១១១២)។

៨.៥.១០.២ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលមានចំនួនគ្រប់គ្រាន់ហើយ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវចុះហត្ថលេខាលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២)។

៨.៥.១០.៣ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតណាមួយ ឬច្រើនដែលបានទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់នៅលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ហើយត្រូវផ្ញើតារាងត្រួតពិនិត្យនេះ ១ (មួយ) ច្បាប់ ជាបន្ទាន់ទៅ គធ.ខប។

៨.៥.១០.៤ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់ទៅនោះជាសម្ភារ ឯកសារបោះឆ្នោតសំខាន់សម្រាប់ការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិក ២ (ពីរ) រូប ឱ្យធ្វើដំណើរទៅ លគធ.ខប ដើម្បីទទួលសម្ភារ ឯកសារបោះឆ្នោតថ្មីជំនួសសម្ភារ ឯកសារបោះឆ្នោតដែលខ្វះ ឬបានបាត់បង់ លើកលែងតែមានវិទ្យុទាក់ទង ឬទូរសព្ទដែលអាចបញ្ជូនព័ត៌មានស្នើសុំ គធ.ខប ដោះស្រាយបញ្ហានេះបាន។

៨.៥.១០.៥ ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតខាងលើនេះ គ.ក.ប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនោះ ហើយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលបានកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតជាដាច់ខាត
- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថា ពិតជាមានត្រាសម្ងាត់នៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រជាដាច់ខាត។

៨.៥.១១ សម្ភារ ឯកសារបោះឆ្នោតសំខាន់ៗដែល គ.ក.ប មិនបានទទួល ហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន៖

៨.៥.១១.១ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់។

៨.៩.១១.២ ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។

៨.៩.១១.៣ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

៨.៩.១១.៤ ហិបឆ្នោត និងសោឃ្លុំមានលេខ។

៨.៩.១១.៥ ទឹកខ្មៅលុបមិនជ្រះ។

៨.៩.១២ សម្ភារ ឯកសារបោះឆ្នោតដទៃទៀតដែលប្រសិនបើមិនបានផ្តល់ដោយ គធ.ខប នោះ គ.ក.ប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង។

៨.៩.១២.១ កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើបិទបាំងជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៨.៩.១២.២ ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុជាគំរូ។

៨.៩.១២.៣ ប៊ិកសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង...។

៨.៩.១៣ នៅពេលដែលសម្ភារ ឯកសារបោះឆ្នោតមានគ្រប់ចំនួនហើយ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ១ (មួយ) ច្បាប់ នៅមុខទីតាំងការិយាល័យបោះឆ្នោត លើកស្លាកការិយាល័យបោះឆ្នោត និងបិទលេខកូដការិយាល័យបោះឆ្នោតនៅនឹងមាត់ទ្វារចូលការិយាល័យបោះឆ្នោត។

៨.៩.១៤ បន្ទាប់ពីបានអនុវត្តចំណុច ៨.៩.១៣ ខាងលើនេះរួច គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ការិយាល័យបោះឆ្នោត ដើម្បីឱ្យប្រាកដថាទីតាំងការិយាល័យបោះឆ្នោតនោះអាចដំណើរការបោះឆ្នោតបានហើយ ដែលអាចរៀបចំឱ្យរួចស្រេចនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹកនៃថ្ងៃបោះឆ្នោត។

៨.៩.១៤.១ គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ឯកភាពគ្នាមួយ ដោយត្រូវគោរពតាមគោលការណ៍ ដូចមានណែនាំក្នុងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។

៨.៩.១៤.២ ប្រសិនបើគ្មានគ្រឿងសង្ហារិមនៅក្នុងការិយាល័យបោះឆ្នោតទេ ប្រធាន គ.ក.ប ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់នូវគ្រឿងសង្ហារិមចាំបាច់មួយចំនួនសម្រាប់បម្រើការបោះឆ្នោត ដូចជា តុ កៅអី និងសម្ភារដទៃទៀត ដែលអាចសម្រួលដល់ការងារបោះឆ្នោត។

៨.៩.១៤.៣ ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខយាមកាមរក្សាសន្តិសុខទីតាំងការិយាល័យបោះឆ្នោត ហើយប្រសិនបើអាចធ្វើបាន ប្រធាន គ.ក.ប ត្រូវបិទទ្វារចាក់សោទីតាំងការិយាល័យបោះឆ្នោតនោះផង។

៨.៤.១៥ ប្រធាន គ.ក.ប រួមជាមួយសមាជិក គ.ក.ប ត្រូវរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងនោះឱ្យបានហ្មត់ចត់នៅមុនពេលបោះឆ្នោត។

៨.៤.១៥.១ សម្ភារ ឯកសារបោះឆ្នោតអាចនឹងរក្សាទុកនៅផ្ទះរបស់ប្រធាន គ.ក.ប ឬសមាជិក គ.ក.ប ណាម្នាក់ ឬនៅទីតាំងណាមួយដែល គ.ក.ប ឯកភាពគ្នាថា មានសុវត្ថិភាព។

៨.៤.១៥.២ យ៉ាងហោចណាស់ត្រូវមានសមាជិក គ.ក.ប ៣ (បី) នាក់ គិតទាំងប្រធាន គ.ក.ប ផង សម្រាកនៅផ្ទះ ឬទីតាំងដែលទទួលរក្សាសម្ភារ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព។

៨.៤.១៥.៣ ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោត។

៨.៤.១៦ ប្រធាន គ.ក.ប ត្រូវណាត់ជាមួយសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០ (ប្រាំ សាមសិប) នាទីព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោតទៅកាន់ទីតាំងការិយាល័យបោះឆ្នោត។

៨.៤.១៧ សមាជិកទាំងអស់នៃ គ.ក.ប ត្រូវត្រៀមអាហារសម្រាប់រយៈពេល ១ (មួយ) ថ្ងៃ សម្រាប់ហូបនៅពេលទំនេរ ដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប។

## ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

**ប្រការ៨.៥.-**

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅដូចមានចែងក្នុងប្រការ ៤.២២ នៃជំពូកទី៤ នៃ ប.ន.ព.ស នេះ។ ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងឃាមកាមយ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៨.៥.១ ប្រធាន គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងការិយាល័យទាំងនោះ ឱ្យចៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខាន ការអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងអស់នៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតទាំងនោះ។

៨.៥.២ ក្របខណ្ឌនៃការិយាល័យបោះឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រការ ៤.២២ និងចំណុច ៤.២២.១ ចំណុច ៤.២២.២ ចំណុច ៤.២២.៣ ចំណុច ៤.២២.៥ ចំណុច ៤.២២.៧ និងចំណុច ៤.២២.៨ នៃជំពូកទី៤ នៃ ប.ន.ព.ស នេះ ត្រូវតែបានអនុវត្ត។

៨.៥.៣ ក្របខណ្ឌនៃការិយាល័យរាប់សន្លឹកឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រការ ៤.២២ និងក្នុងចំណុច ៤.២២.១ ចំណុច ៤.២២.២ ចំណុច ៤.២២.៤ ចំណុច ៤.២២.៦ ចំណុច ៤.២២.៧ និងចំណុច ៤.២២.៨ នៃជំពូកទី៤ នៃ ប.ន.ព.ស នេះ ត្រូវតែបានអនុវត្ត។

៨.៥.៤ ហាមដាច់ខាតយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងហាមស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេសពីប្រធាន គ.ជ.ប។

## ការប្រព្រឹត្តទៅនៃការបោះឆ្នោត

### ប្រការ៨.៦.-

គ.ក.ប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត ដោយនាំមកជាមួយនូវសម្ភារ ឯកសារបោះឆ្នោតឱ្យបានទាន់ពេលនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក នាថ្ងៃបោះឆ្នោតជាកំហិត ដើម្បីគ្រប់គ្រង និងចាត់ចែងការបោះឆ្នោត។

៨.៦.១ បន្ទាប់ពី គ.ក.ប បានចូលដល់ក្នុងការិយាល័យបោះឆ្នោតភ្លាម ប្រធាន គ.ក.ប ត្រូវប្រកាសឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យបណ្ណសម្គាល់ជាផ្លូវការម្នាក់ម្តងៗ រួចប្រាប់ទីកន្លែងដែលបម្រុងទុកសម្រាប់ពួកគាត់ដូចមានចែងក្នុងចំណុច ៨.៦.២.៥ ខាងក្រោមនេះ។

៨.៦.២ ទន្ទឹមពេលអនុវត្តចំណុច ៨.៦.១ ខាងលើនេះ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី២ ឱ្យទៅបំពេញមុខនាទីរបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ព្រមទាំងត្រូវចាត់ចែងសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យរៀបចំគ្រឿងសង្ហារិម និងដាក់សម្ភារ ឯកសារបោះឆ្នោតដូចបានកំណត់ឯកភាពគ្នាលើគំរូប្លង់ការិយាល័យបោះឆ្នោតដែលបានរៀបចំមុនមួយថ្ងៃ និងដូចមានណែនាំនៅក្នុងសៀវភៅណែនាំ គ.ក.ប/គ.ក.រ។

៨.៦.២.១ តុមួយដាក់នៅប៉ែកខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូលសម្រាប់ប្រធាន គ.ក.ប ដែលនៅលើនោះមានសម្ភារ ឯកសារបោះឆ្នោត រួមទាំងបញ្ជីវត្តមានអ្នកសង្កេតការណ៍ ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត(ទ.១១២០) សម្រាប់អ្នកសង្កេតការណ៍ចុះហត្ថលេខា និងពាក្យបណ្តឹង (ទ.១២០២) សម្រាប់ផ្តល់ជូនភ្នាក់ងារគណបក្សនយោបាយ។

៨.៦.២.២ តុវែងមួយ ឬតុតូចពីរដាក់នៅប៉ែកខាងស្តាំដៃ បន្ទាប់ពីផ្លូវចូលសម្រាប់លេខាធិការ និងអនុប្រធាន គ.ក.ប អង្គុយជាប់គ្នា ដែលនៅចំកន្លែងលេខាធិការមានដាក់បញ្ជីបោះឆ្នោត ត្រា គ.ក.ប ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងទម្រង់បែបបទផ្សេងទៀត ហើយនៅចំកន្លែងអនុប្រធាន គ.ក.ប មានដាក់កញ្ចប់សន្លឹកឆ្នោត តាំប៉ុង និងស្រោមសំបុត្រដាក់ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត។

៨.៦.២.៣ បន្ទប់សម្ងាត់សម្រាប់បិទបាំងការគូសសន្លឹកឆ្នោតចំនួន ២ (ពីរ) ដែលមានប៊ិកចងខ្សែភ្ជាប់ស្រាប់ ដាក់នៅលើតុពីរក្បែរជញ្ជាំង ប្រមាណ ១,៥០ (មួយក្បៀសហាសិប) ម៉ែត្រ ពីជញ្ជាំង និងមានចម្ងាយពីគ្នាយ៉ាងតិច ១,៥០ (មួយក្បៀសហាសិប) ម៉ែត្រ ។ ផ្ទាំងក្រដាសសម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ១ (មួយ) សន្លឹក ត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់នីមួយៗ។ បន្ទប់សម្ងាត់ត្រូវមានពន្លឺគ្រប់គ្រាន់។

៨.៦.២.៤ ហិបឆ្នោត ទឹកខ្មៅលុបមិនជ្រះ និងកំណាត់សម្រាប់ជូតដាក់នៅលើតុវែងមួយ ដែលស្ថិតនៅត្រង់កណ្តាលបន្ទប់ទល់មុខតុរបស់ប្រធាន គ.ក.ប សម្រាប់សមាជិកទី១។

៨.៦.២.៥ តុ និងកៅអីសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ (ប្រសិនបើមាន) ដាក់នៅអែបជញ្ជាំងប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន គ.ក.ប និងនៅក្រោយតុអនុប្រធាន គ.ក.ប និងលេខាធិការ។

៨.៦.២.៦ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលមានសម្ភារឯកសារបោះឆ្នោតមិនទាន់ត្រូវប្រើប្រាស់ រក្សាទុកនៅក្បែរតុប្រធាន គ.ក.ប។

៨.៦.៣ ពេលអនុវត្តចំណុច ៨.៦.១ និងចំណុច ៨.៦.២ ខាងលើនេះរួចរាល់ ប្រធាន គ.ក.ប ត្រូវចាត់លេខាធិការឱ្យកត់ត្រាសមាសភាពភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នៅលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងត្រូវពន្យល់ណែនាំជារួមដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗដែលត្រូវអនុវត្តដូចខាងក្រោម៖

៨.៦.៣.១ ត្រូវគោរព ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប ប.ន.ព.ស នេះ ក្រមសីលធមិសម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត ក្រមសីលធមិសម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត និងក្រមសីលធមិសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត ដែលកំណត់ដោយ គ.ជ.ប។

៨.៦.៣.២ ត្រូវតាមដានជាប្រចាំកិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត បង្ការក្រែងមានករណីមិនប្រក្រតីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៨.៦.៣.៣ ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតក្លែងក្លាយចូលក្នុងការិយាល័យបោះឆ្នោត និងការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត។

៨.៦.៣.៤ មិនត្រូវណែនាំ ឬស្តីបន្ទោសអ្វីដល់សមាសភាព គ.ក.ប/គ.ក.រ ឬថតឯកសារ។

៨.៦.៣.៥ មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត។

៨.៦.៣.៦ មិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ។

៨.៦.៣.៧ ត្រូវលើកសំណួរ សំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន គ.ក.ប/គ.ក.រ ចំពោះភ្នាក់ងារគណបក្សនយោបាយ។

៨.៦.៣.៨ ត្រូវបំពេញបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ដោយត្រូវបញ្ជាក់ឈ្មោះសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខា។

៨.៦.៣.៩ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវចូលតាមទីកន្លែងដូចបានកំណត់ក្នុងចំណុច ៨.៦.២.៥ ខាងលើនេះ។

៨.៦.៤ នៅចន្លោះពីម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ៦:៣០ (ប្រាំមួយ សាមសិប) នាទី ព្រឹកនៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតជូនអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត តាមនីតិវិធីដូចខាងក្រោម៖

៨.៦.៤.១ ប្រធាន គ.ក.ប ត្រូវពិនិត្យឡើងវិញនូវហិបឆ្នោត ដើម្បីឱ្យប្រាកដថា ត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ។

៨.៦.៤.២ ប្រធាន គ.ក.ប ត្រូវបើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោត រួចបង្ហាញហិបឆ្នោតទទេចំពោះមុខអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវបិទគម្របក្នុងនៃហិបឆ្នោតទៅវិញ មួលភ្ជិតគម្របសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោត ហើយខ្ទាស់គន្លឹះគម្របក្នុងរួចចាក់សោឃ្លុំ និងប្រាប់លេខាធិការឱ្យកត់ត្រាលេខសោឃ្លុំក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៨.៦.៤.៣ ប្រធាន គ.ក.ប ត្រូវយកក្រដាសលេខកូដការិយាល័យបោះឆ្នោត ២ (ពីរ) សន្លឹក និងបោះត្រា គ.ក.ប រួចបិទភ្ជាប់ទៅនឹងជញ្ជាំងមុខ និងក្រោយនៃហិបឆ្នោត ហើយបន្ទាប់មកអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

៨.៦.៤.៤ លេខាធិការត្រូវកត់ត្រាពេលម៉ោងនៃការពិនិត្យហិបឆ្នោតនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៨.៦.៥ ហិបឆ្នោតដែលបានចាក់សោឃ្លុំរួចហើយ និងបិទសម្គាល់លេខកូដការិយាល័យបោះឆ្នោត ដូចមានចែងក្នុងចំណុច ៨.៦.៤.២ និងចំណុច ៨.៦.៤.៣ ខាងលើនេះ គ.ក.ប ត្រូវធានាដូចខាងក្រោម៖

៨.៦.៥.១ មិនអនុញ្ញាតឱ្យបើកចំហដាច់ខាត លើកលែងតែក្នុងគោលបំណងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់ពីការបោះឆ្នោតបានបញ្ចប់។

៨.៦.៥.២ មិនអនុញ្ញាតឱ្យយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែ គ.ជ.ប សម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន។

៨.៦.៦ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតត្រូវបានប្រគល់ ទទួលនៅក្រោយម៉ោង ៦:៣០ (ប្រាំមួយ សាមសិប) នាទីព្រឹក ប៉ុន្តែមិនហួសពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក ប្រធាន គ.ក.ប ត្រូវពន្យារការអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៨.៦.៧ ខាងក្រោមនេះ នៅការិយាល័យបោះឆ្នោតនោះជាបណ្ដោះអាសន្នសិន រហូតទាល់តែនីតិវិធីដូចមានចែងក្នុងចំណុច ៨.៦.៤ ខាងលើនេះ ត្រូវបានបំពេញចប់សព្វគ្រប់។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាអំពីពេល ម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោតនីមួយៗទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ឱ្យបានច្បាស់លាស់។

៨.៦.៧ នៅចន្លោះពីម៉ោង ៦:៣០ (ប្រាំមួយ សាមសិប) នាទីព្រឹកដល់ម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកនៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតដែលទទួលជាក់ស្ដែង ព្រមទាំងត្រួតពិនិត្យ និងបង្ហាញត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

៨.៦.៧.១ អនុប្រធាន គ.ក.ប ត្រូវត្រួតពិនិត្យមើលកញ្ចប់សន្លឹកឆ្នោតដើម្បីឱ្យប្រាកដថា សន្លឹកឆ្នោតនេះ ជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាប្រាកដមែន។ ក្នុងករណីពិនិត្យឃើញថា សន្លឹកឆ្នោតនេះមិនមែនជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាទេ គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ គធ.ខប ជូន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ។

៨.៦.៧.២ បន្ទាប់មកអនុប្រធាន គ.ក.ប ត្រូវបើកកញ្ចប់សន្លឹកឆ្នោត រួចរាប់សន្លឹកឆ្នោត ដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោតដែលមានក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះក្នុងចន្លោះពី ២៥(ម្ភៃប្រាំ)ដល់ ៧៤(ចិតសិបបួន)សន្លឹក។

៨.៦.៧.៣ លេខាធិការត្រូវកត់ត្រាចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាក់ស្ដែង ព្រមទាំងលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកឆ្នោតចុងក្រោយនៃក្បាលចុងក្រោយទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។ ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្ដែងមានចំនួនលើស ឬខ្វះធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ឱ្យក្តី ក៏លេខាធិការត្រូវកត់ត្រាចំនួនលើស ឬខ្វះនោះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ផងដែរ។

៨.៦.៧.៤ លេខាធិការត្រូវពិនិត្យចំនួនអ្នកបោះឆ្នោតដែលមាននៅក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៨.៦.៧.៥ ប្រធាន គ.ក.ប ត្រូវបើកស្រោមសំបុត្រដែលមានត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រួចដកយកត្រានោះមកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស និងលើកបង្ហាញអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ឱ្យបានឃើញច្បាស់ និងចំណាំបាននូវរូបសញ្ញានៃត្រានោះ។

៨.៦.៨ ប្រធាន គ.ក.ប ត្រូវប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួននៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកនៃថ្ងៃបោះឆ្នោត។ ផ្អែកតាមករណីដូចមានចែងក្នុងចំណុច ៨.៦.៦ ខាងលើនេះ ប្រសិនបើប្រធាន គ.ក.ប មិនអាចប្រកាសបើកការបោះឆ្នោតនៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកបាន គាត់អាចប្រកាសបើកការបោះឆ្នោតនៅក្រោយម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង ៨:០០ (ប្រាំបី) ព្រឹកឡើយ។

៨.៦.៩ សមាជិកទី២ ត្រូវបន្តចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោតនៅបរិវេណខាងក្នុងដោយជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ប្រាប់លេខរៀងឈ្មោះរបស់គាត់ ចេញក្រដាសលេខរៀងតាមលំដាប់មុនក្រោយ និងណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តគ្នាជាជួរ។

៨.៦.១០ បន្ទាប់ពីប្រធាន គ.ក.ប ប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ សមាជិកទី៣ ដែលប្រចាំការនៅត្រង់មាត់ទ្វារត្រូវជម្រាបអ្នកបោះឆ្នោតដែលកំពុងឈរជាជួរបន្តគ្នាតម្រង់ទៅកាន់មាត់ទ្វារចូលការិយាល័យបោះឆ្នោតអំពីអាទិភាពក្នុងការចូលបោះឆ្នោតតាមលំដាប់លំដោយ គឺមនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ ជនមានពិការភាពមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយអមដំណើរជនមានពិការភាពនោះ ព្រមទាំងអ្នកឈរក្នុងជួរខាងមុខគេ។ សមាជិកទី៣ អាចសួររំឭកអ្នកបោះឆ្នោតថាបានស្នើឱ្យសមាជិកទី២ ជួយរកឈ្មោះ និងឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះហើយឬនៅ។ សមាជិកទី៣ ត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតមានវត្តមានក្នុងការិយាល័យបោះឆ្នោតតែចំនួន ៤ (បួន) នាក់ ក្នុងពេលតែមួយ ដោយត្រូវយកចិត្តទុកដាក់ដូចខាងក្រោម៖

៨.៦.១០.១ ត្រូវពិនិត្យមើលអ្នកបោះឆ្នោតមាន អ.ខ ដែលមានសុពលភាព ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង សម្រាប់បោះឆ្នោតឬទេ។

៨.៦.១០.២ ត្រូវពិនិត្យមើលម្រាមដៃអ្នកបោះឆ្នោត ដែលពិតជាពុំមានស្នាមទឹកខ្មៅលុបមិនជ្រះមែន។ ករណីឃើញមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះត្រូវនាំគាត់ទៅជួបប្រធាន គ.ក.ប។

៨.៦.១០.៣ ត្រូវជម្រាបអ្នកបោះឆ្នោតដែលចូលក្នុងការិយាល័យបោះឆ្នោត ឱ្យដើរតម្រង់ទៅតុលេខាធិការ និងអនុប្រធាន គ.ក.ប និងឱ្យបង្ហាញ អ.ខ ដែលមានសុពលភាព ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងទៅលេខាធិការ។

៨.៦.១១ នៅពេលអ្នកបោះឆ្នោតចូលមកដល់ លេខាធិការត្រូវសុំឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង របស់ខ្លួន។ ពេលនោះ លេខាធិការត្រូវៈ

៨.៦.១១.១ ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថា គ្មានស្នាមទឹកខ្មៅលុបមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ។

៨.៦.១១.២ ពិនិត្យមើលលេខរៀងនៅលើបណ្ណព័ត៌មានអ្នកបោះឆ្នោត (ប្រសិនបើមាន) ដើម្បីរកឈ្មោះអ្នកបោះឆ្នោត រួចប្រគល់បណ្ណព័ត៌មានអ្នកបោះឆ្នោតជូនអ្នកបោះឆ្នោតវិញ។ បន្ទាប់មកសួរបញ្ជាក់ឈ្មោះ ពិនិត្យផ្ទៀងផ្ទាត់ អ.ខ ដែលមានសុពលភាព ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង របស់គាត់ជាមួយនឹងរូបពិត រួចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត។

៨.៦.១១.៣ ដាក់បន្ទាត់តម្រង់តាមបណ្ដោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាធិក បញ្ជាក់ការបានមកបោះឆ្នោតរបស់អ្នកបោះឆ្នោតក្នុងកូនប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះរួចហុចអ.ខឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងរបស់គាត់បន្តទៅឱ្យអនុប្រធាន គ.ក.ប ប្រសិនបើឈ្មោះ និងទិន្នន័យ

ក្នុង អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង របស់អ្នកបោះឆ្នោតដូចគ្នានឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត។

៨.៦.១១.៤ ប្រាប់អ្នកបោះឆ្នោតឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន គ.ក.ប។

៨.៦.១២ ប្រសិនបើក្នុងពេលអនុវត្តចំណុច ៨.៦.១១ ខាងលើនេះ លេខាធិការបានរកឃើញថា អ្នកបោះឆ្នោតមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះជាប់នៅនឹងម្រាមដៃ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នាត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍អំពីករណីនេះ។

៨.៦.១២.១ ប្រធាន គ.ក.ប ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយត្រូវឱ្យអ្នកបោះឆ្នោតរូបនេះ ពន្យល់អំពីស្នាមទឹកខ្មៅលុបមិនជ្រះដែលមានជាប់នឹងម្រាមដៃរបស់គាត់ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា។

៨.៦.១២.២ ប្រសិនបើអ្នកបោះឆ្នោតនោះមិនអាចផ្តល់ការពន្យល់របស់ខ្លួនបានសមហេតុផលអំពីបញ្ហាទឹកខ្មៅ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នានេះទេនោះ គាត់នឹងត្រូវបានសន្និដ្ឋានថា មានបំណងបោះឆ្នោតលើសពីមួយដង ឬមានចេតនាទុច្ចរិតក្នុងការបោះឆ្នោតដែលត្រូវមានទោសតាមច្បាប់។

៨.៦.១២.៣ ប្រធាន គ.ក.ប ត្រូវដកហូត អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងរបស់គាត់ជាបណ្ដោះអាសន្ន ហើយបញ្ជូនទៅ គធ.ខប ដើម្បីចាត់វិធានការបន្ត។

៨.៦.១២.៤ លេខាធិការត្រូវកត់ត្រាទុកអំពីហេតុការណ៍នេះនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងត្រូវស្រង់ឈ្មោះ និងទិន្នន័យពី អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង របស់ជននោះសម្រាប់ជាការតាមដានបន្ថែមទៀត។

៨.៦.១២.៥ ប្រសិនបើអ្នកបោះឆ្នោតនោះមិនយល់ព្រមតាមការអនុវត្តនីតិវិធីខាងលើ ប្រធាន គ.ក.ប ឬ គធ.ខប ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះរហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់។

៨.៦.១៣ ប្រសិនបើក្នុងពេលអនុវត្តចំណុច ៨.៦.១១.២ ខាងលើនេះ លេខាធិការមិនឃើញមានឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតទេ ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍អំពីករណីនេះ។

៨.៦.១៣.១ ប្រធាន គ.ក.ប ត្រូវប្រាប់អ្នកបោះឆ្នោតនោះថា គាត់មិនអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះបានទេ ពីព្រោះគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះ ទោះបីជាគាត់មាន អ.ខ ដែលមានសុពលភាព ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបយ.ស ក្នុងតំណែងក៏ដោយ។

៨.៦.១៣.២ ប្រសិនបើជាករណីច្រឡំការិយាល័យបោះឆ្នោត ប្រធាន គ.ក.ប ត្រូវណែនាំគាត់អំពីទីតាំងការិយាល័យបោះឆ្នោតណាមួយផ្សេងទៀតដែលមានទីតាំងក្នុងទីប្រជុំជនរាជធានី ខេត្ត។

៨.៦.១៣.៣ ប្រធាន គ.ក.ប ត្រូវប្រាប់គាត់ឱ្យចេញពីការិយាល័យបោះឆ្នោត។

៨.៦.១៤ បន្ទាប់ពីអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៨.៦.១១ ខាងលើនេះរួច អនុប្រធាន គ.ក.ប ត្រូវហែកសន្លឹកឆ្នោត ១ (មួយ) សន្លឹកចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្នត់តាមការកំណត់របស់ គ.ជ.ប ហើយប្រគល់ជូនអ្នកបោះឆ្នោត រួមជាមួយ អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបយ.ស ក្នុងតំណែងរបស់គាត់ផង។ អនុប្រធាន គ.ក.ប មិនត្រូវប្រគល់សន្លឹកឆ្នោត និងមិនត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតបន្ទាប់ចូលក្នុងបន្ទប់សម្ងាត់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញផុតពីបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតនៅឡើយ។ នៅពេលប្រគល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតរួចហើយ អនុប្រធាន គ.ក.ប ត្រូវណែនាំជាសង្ខេបចំពោះអ្នកបោះឆ្នោតដូចខាងក្រោម៖

៨.៦.១៤.១ នេះគឺជាសន្លឹកឆ្នោត។

៨.៦.១៤.២ អ្នកត្រូវដើរទៅកាន់បន្ទប់សម្ងាត់ ប្រើប៊ិកដែលមាននៅទីនោះស្រាប់ ឬប៊ិកផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ) អ្នកត្រូវគូសសញ្ញាគាំទ្រនៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយដែលអ្នកពេញចិត្ត។ អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់មុននឹងគូសសញ្ញា ដើម្បីបង្ការការខូចសន្លឹកឆ្នោតដោយសារការផ្លាស់ប្តូរចិត្ត បន្ទាប់ពីបានគូសសញ្ញារួច។

៨.៦.១៤.៣ មុននឹងចេញពីបន្ទប់សម្ងាត់ អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលអ្នកបានគូសស្ថិតនៅក្នុងផ្នត់មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ។

៨.៦.១៥ ក្រោយពេលទទួលបានសន្លឹកឆ្នោត អ្នកបោះឆ្នោតមិនត្រូវសួរអ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោតឱ្យបង្ហាញពីគណបក្សនយោបាយជាក់លាក់ណាមួយនៅលើសន្លឹកឆ្នោត ឬ/និងមិនត្រូវធ្វើសកម្មភាពណាមួយដែលរំលោភទៅលើការសម្ងាត់នៃការបោះឆ្នោតឡើយ។

៨.៦.១៥.១ អ្នកបោះឆ្នោតមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យដឹងអំពីគណបក្សនយោបាយជាក់លាក់ណាមួយដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ។

៨.៦.១៥.២ អ្នកបោះឆ្នោតទូទៅមិនអាចស្នើសុំជំនួយពីជនណាម្នាក់ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត ឱ្យជួយគាត់ក្នុងការបោះឆ្នោតឡើយ លើកលែងតែអ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯងដូចមានចែងក្នុងចំណុច ៨.៦.១៨ ខាងក្រោមនេះ។

៨.៦.១៥.៣ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលនៅក្នុងការិយាល័យបោះឆ្នោតមិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតទេ ទោះបីអ្នកបោះឆ្នោតនោះស្នើសុំឱ្យជួយក៏ដោយ។

៨.៦.១៥.៤ ហាមអ្នកបោះឆ្នោត និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប្រើទូរសព្ទដៃ ឬ/និងម៉ាស៊ីនថត ឬ/និងឧបករណ៍ផ្សេងទៀតដែលអាចថតរូប ឬ/និងសំឡេងបាន និងហាមធ្វើសកម្មភាពរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។ អ្នកសារព័ត៌មានដែលទទួលស្គាល់ដោយ គ.ជ.ប និងបានការអនុញ្ញាតពីប្រធាន គ.ក.ប អាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោត ប៉ុន្តែមិនត្រូវរំលោភលើការសម្ងាត់នៃការបោះឆ្នោត។

៨.៦.១៦ បន្ទាប់ពីទទួលបានសន្លឹកឆ្នោត និងអនុវត្តតាមការណែនាំរបស់អនុប្រធាន គ.ក.ប ដូចមានចែងក្នុងចំណុច ៨.៦.១៤.២ និងចំណុច ៨.៦.១៤.៣ ខាងលើនេះរួច អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោត។

៨.៦.១៦.១ អ្នកបោះឆ្នោតត្រូវបង្ហាញសន្លឹកឆ្នោតរបស់ខ្លួនដែលបានបត់រួចនោះ ដោយដាក់បែរផ្នែកខាងខ្នងដែលមានបោះត្រាសម្ងាត់ទៅរកសមាជិកទី១ ហើយស៊កវាដោយខ្លួនឯង តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត លើកលែងតែអ្នកបោះឆ្នោតជាជនមានពិការភាព ដែលមិនអាចស៊កដោយខ្លួនឯងបាន។

៨.៦.១៦.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោតដែលបត់រួចបម្រុងនឹងស៊កទៅក្នុងហិបឆ្នោត សមាជិកទី១ ត្រូវពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការតែមួយសន្លឹក ដែលមានបោះត្រាសម្ងាត់ជាផ្លូវការសម្រាប់ការិយាល័យបោះឆ្នោតនោះ។

៨.៦.១៦.៣ បន្ទាប់មក អ្នកបោះឆ្នោតត្រូវយល់ព្រមឱ្យសមាជិកទី១ ជ្រលក់ឱ្យលិចដល់គល់ក្រចកនៃម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀត ប្រសិនបើម្រាមចង្អុលដៃស្តាំពិការចូលទៅក្នុងដបទឹកខ្មៅលុបមិនជ្រះដូចដែលបានកំណត់ក្នុងចំណុច ៨.៦.១៧ ខាងក្រោមនេះ។

៨.៦.១៦.៤ ប្រសិនបើសមាជិកទី១ ពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់មានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលទៅក្នុងហិបឆ្នោត ត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប។ ក្នុងករណីនេះ ប្រធាន គ.ក.ប ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការឆែកឆេររកសន្លឹកឆ្នោតផ្លូវការ។

៨.៦.១៦.៥ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់ដែលត្រូវបានសមាជិកទី១ ចាប់ភស្តុតាងបានថា មានបំណងស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពី ១ (មួយ) សន្លឹកទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោសដោយផ្អែកតាម ច.ប.ព.ស ច.ប.ត.រ និង ច.វ.ច.ប។

៨.៦.១៦.៦ ប្រធាន គ.ក.ប ត្រូវឃាត់អ្នកបោះឆ្នោតដូចបញ្ជាក់ក្នុងចំណុច ៨.៦.១៦.៥ ខាងលើនេះ មិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវទាំងនោះ និងឆែកឆេររកសន្លឹកឆ្នោតផ្លូវការ (ប្រសិនបើមាន) ដាក់ទៅក្នុងស្រោមសំបុត្រមានការខ្វងថា “សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត” បន្ទាប់មកត្រូវដកហូត អ.ខ

ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង របស់ជននោះជាបណ្តោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្តឹងចោទប្រកាន់ជនប្រព្រឹត្តអំពើល្មើសទៅ គធ.ខប។

៨.៦.១៦.៧ ប្រសិនបើជនដែលបានប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះ ហើយបើមានភស្តុតាងគ្រប់គ្រាន់នោះ គធ.ខប ត្រូវប្តឹងទៅ គ.ជ.ប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

៨.៦.១៧ ទឹកខ្មៅលុបមិនជ្រះដែលអាចមើលឃើញច្បាស់ ត្រូវបានដាក់បញ្ញត្តិឱ្យប្រើក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់បង្ការការបោះឆ្នោតលើសពី ១ (មួយ) ដង។

៨.៦.១៧.១ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានផ្គត់ផ្គង់ទឹកខ្មៅលុបមិនជ្រះចំនួន ២ (ពីរ) ដប។

៨.៦.១៧.២ ដបទឹកខ្មៅលុបមិនជ្រះ ១ (មួយ) ដប ត្រូវបានបើកគម្របប្រើនៅពេលបើកការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងបម្រុងទុក ១ (មួយ) ដប សម្រាប់ប្រើនៅពេលអស់ទឹកខ្មៅលុបមិនជ្រះដបទីមួយ។

៨.៦.១៧.៣ បន្ទាប់ពីអ្នកបោះឆ្នោតបានស៊កសន្លឹកឆ្នោតរបស់ខ្លួនទៅក្នុងហិបឆ្នោត និងនៅមុនពេលគាត់ដើរចេញពីការិយាល័យបោះឆ្នោត គាត់ត្រូវយល់ព្រមឱ្យសមាជិកទី១ ជ្រលក់ម្រាមចង្អុលដៃស្តាំរបស់គាត់ឱ្យលិចគល់ក្រចកទៅក្នុងដបទឹកខ្មៅលុបមិនជ្រះ និងរង់ចាំល្មមទឹកខ្មៅស្ងួត ទើបចេញពីការិយាល័យបោះឆ្នោត។

៨.៦.១៧.៤ ក្នុងករណីម្រាមចង្អុលដៃស្តាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ឬមេដៃឆ្វេង។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើរាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាបានការ។

៨.៦.១៧.៥ រៀងរាល់ ៣០ (សាមសិប) នាទីម្តង ដបទឹកខ្មៅលុបមិនជ្រះត្រូវតែបានបិទគម្របយ៉ាងជិតហើយក្រឡុក។

៨.៦.១៧.៦ ប្រសិនបើគ្មានអ្នកបោះឆ្នោតមួយរយៈពេលយូរគួរសម សមាជិកទី១ ត្រូវបិទគម្របដបទឹកខ្មៅលុបមិនជ្រះ ដើម្បីការពារកុំឱ្យវាហួត។

៨.៦.១៨ គ្មានជនណាម្នាក់ចូលទៅជ្រៀតជ្រែកនៅក្នុងការិយាល័យបោះឆ្នោត ឬជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានឡើយ លើកលែងតែអ្នកបោះឆ្នោតនោះជាជនមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយបានស្នើសុំអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពីប្រធាន គ.ក.ប ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

៨.៦.១៨.១ បន្ទាប់ពីបានអនុញ្ញាតឱ្យចូលការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន និងអ្នកជំនួយជានីតិជនម្នាក់ដែលអមដំណើរជាមួយ ដើម្បីជួយគាត់ក្នុងការបោះឆ្នោត ត្រូវអនុវត្តជាបន្តបន្ទាប់តាមចំណុច ៨.៦.១១ ចំណុច ៨.៦.១៤ និងចំណុច ៨.៦.១៦ ខាងលើនេះ។

៨.៦.១៨.២ បន្ទាប់ពីបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន ដែលមានបំណងស្នើសុំជំនួយពីប្រធាន គ.ក.ប ត្រូវទៅជួបប្រធាន គ.ក.ប ដោយផ្ទាល់។ បន្ទាប់មកប្រធាន គ.ក.ប ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនមានពិការភាពនោះ អនុវត្តជាបន្តបន្ទាប់តាមចំណុច ៨.៦.១១ ចំណុច ៨.៦.១៤ និងចំណុច ៨.៦.១៦ ខាងលើនេះ។ ក្នុងករណីនេះ ប្រធាន គ.ក.ប អាចចាត់សមាជិក គ.ក.ប ណាម្នាក់ឱ្យជួយក៏បាន ប៉ុន្តែត្រូវមានការយល់ព្រមពីអ្នកបោះឆ្នោតជាជនមានពិការភាពនោះ។

៨.៦.១៨.៣ អ្នកបោះឆ្នោតជាជនមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបានត្រូវសួរនាំ ឬប្រាប់អំពីគណបក្សនយោបាយដែលខ្លួនពេញចិត្តទៅប្រធាន គ.ក.ប ឬអ្នកជំនួយដែលខ្លួនជ្រើសរើសតែនៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតប៉ុណ្ណោះ។

៨.៦.១៨.៤ នៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ប្រធាន គ.ក.ប ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលជួយអ្នកបោះឆ្នោតជាជនមានពិការភាពក្នុងការបោះឆ្នោតត្រូវសួរអ្នកបោះឆ្នោតជា

ជនមានពិការភាពនោះថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ដោយសួរតិចៗធ្វើយ៉ាងណាកុំឱ្យមនុស្សដែលនៅក្នុងការិយាល័យបោះឆ្នោតឮឱ្យសោះ។ បន្ទាប់មកប្រធាន គ.ក.ប ឬសមាជិក គ.ក.ប ឬអ្នកជំនួយត្រូវគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោតដែលឆ្លើយតបនឹងការជ្រើសរើសរបស់អ្នកបោះឆ្នោតជាជនមានពិការភាព ហើយបត់សន្លឹកឆ្នោតនោះតាមផ្នត់ដើមដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅក្នុងផ្នត់ រួចត្រូវនាំអ្នកបោះឆ្នោតជាជនមានពិការភាពទៅកាន់ហិបឆ្នោត និងជួយសឹកសន្លឹកឆ្នោតរបស់គាត់តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត។

៨.៦.១៨.៥ ប្រធាន គ.ក.ប ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលបានជួយអ្នកបោះឆ្នោតជាជនមានពិការភាពដូចលក្ខខណ្ឌមានចែងក្នុងចំណុច ៨.៦.១៨ ខាងលើនេះ ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់។

៨.៦.១៩ ចំពោះអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតនោះឱ្យប្រើក្របក្រដាសពិសេសដែលជាសម្ភារជំនួយដល់ការបោះឆ្នោត។

៨.៦.១៩.១ ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាងនោះទៅជួបលេខាធិការ ដើម្បីអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៨.៦.១១ ខាងលើនេះ។ នៅពេលអនុវត្តចំណុច ៨.៦.១១ ខាងលើនេះ រួចរាល់ លេខាធិការត្រូវហុចឯកសារពាក់ព័ន្ធជូនអនុប្រធាន គ.ក.ប។

៨.៦.១៩.២ អនុប្រធាន គ.ក.ប ត្រូវហែកសន្លឹកឆ្នោត ១ (មួយ) សន្លឹកចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្នត់តាមការកំណត់ និងត្រូវណែនាំអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាងនោះ ឱ្យស្ទាបសន្លឹកឆ្នោត និងស្នាមបត់ រួចលាសន្លឹកឆ្នោតឱ្យស្មើឡើងវិញ និងដាក់នៅក្នុងក្របក្រដាសពិសេស ដោយឱ្យផ្នែកខាងមុខនៃសន្លឹកឆ្នោតលេចចេញប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សតាមប្រហោងសម្រាប់គូស និងប្រើឃ្នាបគាបសន្លឹកឆ្នោតនោះ

ភ្ជាប់នឹងក្របក្រដាសពិសេស ដើម្បីបង្ការកុំឱ្យប្រអប់លេខរៀង សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយងាក ឬល្អៀង ចេញពីប្រហោងនៃក្របក្រដាសពិសេស។

៨.៦.១៩.៣ អនុប្រធាន គ.ក.ប ត្រូវប្រគល់ក្របក្រដាសពិសេសដែលមានដាក់សន្លឹកឆ្នោតខាងក្នុងជូនទៅអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាង និងកាន់ម្រាមដៃណាមួយរបស់គាត់ឱ្យមកប៉ះ និងស្ទាបប្រហោងរាងបួនជ្រុងទ្រវែងដែលចោះលើក្របក្រដាសពិសេសពីលើចុះក្រោម និងជម្រាបគាត់ថា៖

- អ្នកអាចស្ទាប និងរាប់ប្រហោងរាងបួនជ្រុងទ្រវែង ដែលកំណត់លេខរៀង និងចំនួនគណបក្សនយោបាយទាំងអស់នៅលើសន្លឹកឆ្នោត។ ប្រហោងរាងបួនជ្រុងទ្រវែង គឺជាប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលមានបញ្ជីបេក្ខជនឈរឈ្មោះក្នុងភូមិភាគនេះ
- អ្នកត្រូវចងចាំអំពីលេខរៀងរបស់គណបក្សនយោបាយដែលអ្នកពេញចិត្ត
- អ្នកត្រូវប្រើប៊ិកគូសសញ្ញាគាំទ្រក្នុងប្រហោងរាងបួនជ្រុងទ្រវែង បន្ទាប់ពីអ្នកបានស្ទាប និងដឹងច្បាស់អំពីប្រអប់លេខរៀងគណបក្សដែលអ្នកពេញចិត្ត
- អ្នកត្រូវដោះឃ្នាប និងដកសន្លឹកឆ្នោតចេញពីក្របក្រដាសពិសេស រួចបត់តាមផ្នត់ដើម ហើយស្នើសុំប្រធាន គ.ក.ប ឱ្យជួយជូនទៅស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត។

៨.៦.១៩.៤ ប្រធាន គ.ក.ប ត្រូវអនុវត្តភារកិច្ចដូចខាងក្រោម បន្ទាប់ពីអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាងបានទទួលក្របក្រដាសពិសេស ដែលមានសន្លឹកឆ្នោតផ្លូវការនៅខាងក្នុងរួចហើយ។

- ជួយជូនអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាងនោះទៅកាន់បន្ទប់សម្ងាត់ និងជួយរកប៊ិកសម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ
- ជួយរៀបចំក្របក្រដាសពិសេសឱ្យមានភាពត្រឹមត្រូវ ប្រសិនបើពិនិត្យឃើញថា ក្របក្រដាសពិសេសនោះមានសភាពមិនប្រក្រតី ឬដាក់មិនទំនង

- ចេញពីបន្ទប់សម្ងាត់ និងរង់ចាំជួយបន្ថែមទៀត ប្រសិនបើមានសំណូមពរពីអ្នកបោះឆ្នោតនោះ។

៨.៦.១៩.៥ ការអនុវត្តនីតិវិធីខាងលើនេះ ត្រូវធ្វើឡើងចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត។

៨.៦.១៩.៦ គ.ជ.ប ត្រូវរៀបចំឱ្យមានក្របក្រដាសពិសេសមានទម្រង់ជា ២ (ពីរ) សន្លឹកជាប់គ្នា ដែលមានក្របមុខ និងក្របខាងខ្នងមានទំហំប៉ុនគ្នានឹងសន្លឹកឆ្នោតផ្លូវការនៃភូមិភាគនីមួយៗ ហើយក្របក្រដាសពិសេសនេះ ត្រូវចោះប្រហោងរាងបួនជ្រុងទ្រវែងមានទំហំប៉ុនគ្នានៅចំប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយដែលមាននៅលើសន្លឹកឆ្នោតផ្លូវការ។

៨.៦.២០ ប្រសិនបើក្នុងការិយាល័យបោះឆ្នោតគ្មានអ្នកបោះឆ្នោតនោះទេ សមាជិកទី១ ត្រូវបិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតជាបណ្ដោះអាសន្ន ហើយត្រូវបើកឡើងវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត។

៨.៦.២១ គ្មានជនណាម្នាក់ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត អាចពិនិត្យមើលការគូសសញ្ញាលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតឡើយ លើកលែងតែអ្នកដែលជួយអ្នកបោះឆ្នោតជាជនមានពិការភាពដូចមានចែងក្នុងចំណុច ៨.៦.១៨ ខាងលើនេះ។

៨.៦.២១.១ ជនណាក៏ដោយដូចមានចែងក្នុងចំណុច ៨.៦.២១ ខាងលើនេះ ដែលប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ជននោះនឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.ប។ ការប៉ុនប៉ងជាលើកទីពីរ ដើម្បីធ្វើឱ្យបែកខ្ញែកខ្វាយនូវគោលការណ៍សម្ងាត់នៃការបោះឆ្នោតនឹងត្រូវចាត់ទុកថា ជាការរំលោភទៅលើច្បាប់ ហើយជនដែលមានការពាក់ព័ន្ធត្រូវតែបានបណ្ដេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ព.ស ច.ប.ត.រ និង ច.វ.ច.ប។

៨.៦.២១.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះ ក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត។

៨.៦.២១.៣ ប្រសិនបើជនប្រព្រឹត្តអំពើល្មើសលើគោលការណ៍សម្ងាត់នៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៦.២១.១ ខាងលើនេះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ប្រធាន គ.ក.ប ត្រូវបញ្ជូនកំណត់ហេតុស្ដីពីហេតុការណ៍នោះទៅ គជ.ខប។

៨.៦.២១.៤ ពេលបានទទួលកំណត់ហេតុដូចមានចែងក្នុងចំណុច ៨.៦.២១.៣ ខាងលើនេះភ្លាម គជ.ខប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនោះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន ត្រូវតែប្តឹងជនប្រព្រឹត្តអំពើល្មើសទៅ គ.ជ.ប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

៨.៦.២២ អ្នកបោះឆ្នោតណាម្នាក់ដែលបានធ្វើឱ្យខូចសន្លឹកឆ្នោតដោយអចេតនា ដោយធ្វើឱ្យរហែក ឬធ្វើឱ្យប្រឡាក់ ឬដែលបានគូសសញ្ញានៅលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ គាត់អាចសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀតពីប្រធាន គ.ក.ប។

៨.៦.២២.១ អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោត១(មួយ)សន្លឹកផ្សេងទៀត ត្រូវបត់សន្លឹកឆ្នោតខូចតាមផ្នត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្នត់ រួចប្រគល់ជូនប្រធាន គ.ក.ប។

៨.៦.២២.២ ប្រធាន គ.ក.ប ត្រូវស៊កសន្លឹកឆ្នោតដែលខូចនោះទៅក្នុងស្រោមសំបុត្រមួយដែលមានកាខ្វងស្រាប់ថា "សន្លឹកឆ្នោតខូច"។

៨.៦.២២.៣ លេខាធិការដែលបានគូសសញ្ញាសម្គាល់ម្តងហើយ ក្នុងប្រអប់នៅប៉ែកខាងដើមទន្ទឹមនឹងឈ្មោះគាត់ក្នុងបញ្ជីបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៦.១១.៣ ខាងលើនេះ មិនចាំបាច់គូសសញ្ញាសម្គាល់ជាលើកទីពីរឡើយ ប៉ុន្តែត្រូវកត់ចំណាំទុកសម្រាប់សរសេរចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៨.៦.២២.៤ ប្រធាន គ.ក.ប ត្រូវអនុញ្ញាតឱ្យអនុប្រធាន គ.ក.ប ផ្តល់សន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀតចំពោះអ្នកបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៦.២២ ខាងលើនេះ តែមួយលើកគត់ និងត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងត្រូវរំឭកអនុប្រធាន គ.ក.ប ឱ្យណែនាំអ្នកបោះឆ្នោតបន្ទាប់តាមខ្លឹមសារនៃចំណុច ៨.៦.១៤.២ ខាងលើនេះ ដោយផ្អែកលើចំនួនជាក់ស្តែងនៃសន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

៨.៦.២២.៥ ក្នុងករណីមានអ្នកបោះឆ្នោតមួយចំនួនជាបន្តបន្ទាប់គ្នាសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀតដូចមានចែងក្នុងចំណុច ៨.៦.២២ ខាងលើនេះ ដែលអាចចាត់ទុកថា ជាភាព

មិនប្រក្រតីមួយនោះ ប្រធាន គ.ក.ប អាចសម្រេចមិនព្រមផ្តល់សន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀត តាមការស្នើសុំទេ ហើយឱ្យលេខាធិការកត់ត្រាបញ្ហាទាំងនេះចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៨.៦.២៣ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់ជំទាស់ ឬតវ៉ានឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬការសម្រេចណាមួយរបស់ គ.ក.ប គាត់ត្រូវលើកការជំទាស់ ឬការតវ៉ានោះដោយផ្ទាល់ទៅប្រធាន គ.ក.ប ដោយបង្ហាញអំពីមូលហេតុ ឬ/និងភស្តុតាងដែលនាំឱ្យគាត់ជឿថា មានភាពមិនប្រក្រតី ឬការរំលោភច្បាប់ ឬ/និងការរំលោភ ប.ន.ព.ស នេះ ក្នុងការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

៨.៦.២៣.១ ប្រសិនបើយល់ឃើញថាសមហេតុផល ប្រធាន គ.ក.ប ត្រូវបញ្ឈប់ជាបណ្តោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ដើម្បីស្តាប់ការជំទាស់ ឬការតវ៉ារបស់ភ្នាក់ងារគណបក្សនយោបាយនោះ ហើយបន្ទាប់មកពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គ.ក.ប ដទៃទៀត។

៨.៦.២៣.២ បន្ទាប់ពីបានពិនិត្យឡើងវិញអំពីករណីដែលបានលើកជំទាស់ ឬតវ៉ា ប្រសិនបើប្រធាន គ.ក.ប យល់ព្រមតាមការជំទាស់ ឬការតវ៉ា ប្រធាន គ.ក.ប ត្រូវណែនាំ និងរំឭកសមាជិក គ.ក.ប និងអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោតអំពីខ្លឹមសារពាក់ព័ន្ធដូចមានចែងក្នុង ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប និង ប.ន.ព.ស នេះ ហើយត្រូវចាត់វិធានការដោះស្រាយភាពមិនប្រក្រតីនោះជាបន្ទាន់។

៨.៦.២៣.៣ ប្រសិនបើប្រធាន គ.ក.ប បដិសេធការជំទាស់ ឬការតវ៉ា គាត់ត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះជូនភ្នាក់ងារគណបក្សនយោបាយ។

៨.៦.២៣.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ា ប្រធានគ.ក.បត្រូវកត់ត្រាការជំទាស់ ឬការតវ៉ានេះក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដោយឱ្យអ្នកជំទាស់ ឬអ្នកតវ៉ានោះចុះហត្ថលេខាលើកំណត់ហេតុនេះ។

៨.៦.២៣.៥ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនោះមិនយល់ព្រមចុះហត្ថលេខា ករណីនៃការជំទាស់ ឬការតវ៉ានោះ មិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោត(ទ.១១០១)ឡើយ។

៨.៦.២៣.៦ ការសម្រេចរបស់ប្រធាន គ.ក.ប ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធាន គ.ក.ប ត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត។

៨.៦.២៣.៧ ចំណុច ៨.៦.២៣.៦ ខាងលើនេះ មិនបានច្រានចោលជាមុននូវដំណើរហេតុដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្ដឹងជំទាស់ ឬប្ដឹងតវ៉ាទៅ គជ.ខប អំពីករណីដែលគាត់បានលើកជំទាស់ ឬតវ៉ាក្នុងការិយាល័យបោះឆ្នោតនោះទេ ប៉ុន្តែក្នុងស្ថានភាពនេះ គាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គ.ក.ប និងមិនត្រូវរំខាន ឬជៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោតឡើយ។

៨.៦.២៣.៨ ប្រធាន គ.ក.ប ត្រូវផ្ដល់ពាក្យបណ្ដឹង (ទ.១២០២) សម្រាប់បំពេញពាក្យបណ្ដឹង ប្រសិនបើភ្នាក់ងារគណបក្សនយោបាយស្នើសុំសម្រាប់ប្ដឹងបន្តទៅ គជ.ខប។

៨.៦.២៤ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់រំខានដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់ស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យក្ដី ប្រធាន គ.ក.ប ត្រូវណែនាំឱ្យគាត់រក្សារបៀបរៀបរយ។ ក្នុងករណីអ្នកបោះឆ្នោតនោះបដិសេធមិនព្រមគោរពតាមបញ្ជារបស់ខ្លួន ប្រធាន គ.ក.ប ត្រូវស្នើកម្លាំងសន្តិសុខឱ្យបណ្ដេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់។

៨.៦.២៥ ប្រធាន គ.ក.ប អាចស្នើសុំកម្លាំងសន្តិសុខឱ្យរៀបចំសាឡើងវិញនូវរបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ប្រសិនបើកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិតដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី។ ការរំខានដល់អ្នកបោះឆ្នោត ឬដល់ការប្រព្រឹត្តទៅនៃការបោះឆ្នោត គឺជាសកម្មភាពទាំងឡាយណានៅក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតដូចខាងក្រោមនេះជាអាទិ៍៖

៨.៦.២៥.១ ការបញ្ចេញសម្រែកខ្លាំងៗ ឬការបញ្ចេញសម្ដីគំរាមកំហែង ឬជេរប្រមាថ មាក់ងាយ។

៨.៦.២៥.២ ការធ្វើសកម្មភាពរារាំងអ្នកបោះឆ្នោត មិនឱ្យទៅបោះឆ្នោត។

៨.៦.២៥.៣ ការរុញច្រានដោយប្រើកម្លាំងធ្ងន់។

៨.៦.២៥.៤ ការគប់វត្ថុផ្សេងៗសំដៅអ្នកបោះឆ្នោតឬការិយាល័យបោះឆ្នោត។

៨.៦.២៥.៥ ការអុកឡុកនៃបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត។

៨.៦.២៥.៦ ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ។

៨.៦.២៥.៧ ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗប្រកបដោយគ្រោះថ្នាក់។

៨.៦.២៦ ប្រសិនបើការបោះឆ្នោតឈានដល់ម៉ោង ១៥:០០ (ដប់ប្រាំ) នៃថ្ងៃបោះឆ្នោតដែលជាពេលវេលាកំណត់សម្រាប់ការបញ្ចប់ដំណើរការបោះឆ្នោត ហើយនៅតែមានអ្នកបោះឆ្នោតស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរ ឬស្ថិតនៅក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោតទៀត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត។

៨.៦.២៦.១ ក្នុងករណីនេះ សមាជិកទី២ ត្រូវប្រកាសប្រាប់អ្នកបោះឆ្នោតដែលមានវត្តមាននៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងត្រូវប្រមូលយក អ.ខ ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែងពីអ្នកបោះឆ្នោតដែលនៅក្នុងជួរ ដោយចាប់ផ្តើមពីអ្នកបោះឆ្នោតដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ទៅឱ្យសមាជិកទី៣ នៅត្រង់មាត់ទ្វារ។

៨.៦.២៦.២ សមាជិកទី៣ ត្រូវហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗរហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោតតាមលំដាប់លំដោយរហូតដល់អស់អ្នកបោះឆ្នោត។

៨.៦.២៦.៣ អ្នកបោះឆ្នោតដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតនៅនាទីចុងក្រោយ នាម៉ោង ១៥:០០ (ដប់ប្រាំ) នៃថ្ងៃបោះឆ្នោតទេនោះ អ្នកបោះឆ្នោតទាំងនោះពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ។

៨.៦.២៧ ប្រសិនបើអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតមិនទាន់បានមកបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី ប្រធាន គ.ក.ប មិនអាចបិទការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ១៥:០០ (ដប់ប្រាំ) នៃថ្ងៃបោះឆ្នោតបានឡើយ។

៨.៦.២៨ ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គ.ក.ប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួននៅមុនម៉ោង ១៥:០០ (ដប់ប្រាំ)។

## ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត

### ប្រការ៨.៧._

នៅពេលដែលអ្នកបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី៣ ចាត់វិធានការចាំបាច់ ដើម្បីការពារច្រកចូលការិយាល័យបោះឆ្នោតកុំឱ្យអ្នកគ្មានភារកិច្ចចេញចូល។ ប្រធាន គ.ក.ប ត្រូវប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់មកត្រូវចាត់ចែងការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត និងការបំពេញកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៨.៧.១ បន្ទាប់ពីបានប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ប្រធាន គ.ក.ប ត្រូវចាត់ចែងតាមនីតិវិធី ដើម្បីធានាសុវត្ថិភាពហិបឆ្នោតដែលក្នុងនោះ៖

៨.៧.១.១ ប្រធាន គ.ក.ប ត្រូវបិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោត ព្រមទាំងបិទក្រដាសស្ដើងមួយសន្លឹក ដែលមានហត្ថលេខារបស់ប្រធាន គ.ក.ប និងភ្នាក់ងារគណបក្សនយោបាយពាសពីលើសន្ទះបិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតទាំងពីរនោះផង។

៨.៧.១.២ ប្រធាន គ.ក.ប ត្រូវបិទគម្របខាងក្រៅនៃហិបឆ្នោត និងចាក់សោឃ្លុំមានលេខ នៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោត រួចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំងពីរនោះ។

៨.៧.១.៣ លេខាធិការត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) នូវពេលវេលានៃការបិទការបោះឆ្នោត ព្រមទាំងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំងពីរ។

៨.៧.១.៤ ប្រធាន គ.ក.ប ត្រូវចាត់វិធានការការពារហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុងយ៉ាងហ្មត់ចត់ សម្រាប់ការរាប់សន្លឹកឆ្នោតនៅនឹងកន្លែងការិយាល័យបោះឆ្នោត ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេង ប្រសិនបើមានការសម្រេចឱ្យធ្វើដូច្នេះដោយ គ.ជ.ប។

៨.៧.១.៥ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោត ក្រោយពីការប្រកាសបិទការបោះឆ្នោត ដោយសុំការអនុញ្ញាតពីប្រធាន គ.ក.ប។

៨.៧.២ បន្ទាប់មកស្ថិតនៅចំពោះវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិក គ.ក.ប ឱ្យធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ និងសន្លឹកឆ្នោតខូច (ប្រសិនបើមាន) ដែលក្នុងនោះ៖

៨.៧.២.១ លេខាធិការត្រូវរាប់ចំនួនគំនូសសញ្ញាក្នុងកូនប្រអប់ផ្នែកខាងដើមនៅក្នុងបញ្ជីបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៦.១១.៣ ខាងលើនេះ និងរាយការណ៍ជូនប្រធាន គ.ក.ប អំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត។

៨.៧.២.២ អនុប្រធាន គ.ក.ប ត្រូវកំណត់សម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ និងគល់បញ្ជីនៃសន្លឹកឆ្នោតដែលមិនទាន់បានប្រើ រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូចដោយឡែកពីគ្នា។ ប្រសិនបើចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែងដូចមានបញ្ជាក់ក្នុងចំណុច ៨.៦.៧.៣ ខាងលើនេះ ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតដូចមានបញ្ជាក់ក្នុងចំណុច ៨.៧.២.១ ខាងលើនេះ លេខាធិការត្រូវកត់ត្រាតួលេខចំនួនទាំងនេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១)។

៨.៧.២.៣ ប្រសិនបើក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថា នៅមានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត លេខាធិការត្រូវផ្ទៀងផ្ទាត់ជាលើកទីពីរនូវចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនៅលើបញ្ជីបោះឆ្នោត ហើយអនុប្រធាន គ.ក.ប ក៏ត្រូវផ្ទៀងផ្ទាត់ឡើងវិញផងដែរនូវចំនួនសន្លឹកឆ្នោតដែលបានប្រើ (រាប់ចំនួនសន្លឹកគល់បញ្ជីនៃសន្លឹកឆ្នោតដែលបានប្រើ) ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច។ ប្រសិនបើភាពខុសគ្នានៅតែមាន លេខាធិការត្រូវកត់ត្រានូវតួលេខនៃចំនួនដែលខុសគ្នានោះ

ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ហើយប្រធាន គ.ក.ប ត្រូវបន្តចាត់ចែងអនុវត្តតាមនីតិវិធីជាបន្ត។

៨.៧.២.៤ សមាជិកទី២ ត្រូវចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើទាំងអស់ជាមួយនឹងប្រដាប់ចោះ ឬកន្ត្រៃ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ។

៨.៧.២.៥ អនុប្រធាន គ.ក.ប ត្រូវដាក់សន្លឹកឆ្នោតមោឃភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងប្លាស្ទិកតែមួយ រួចបិទឱ្យជិត។

៨.៧.៣ ប្រធាន គ.ក.ប ត្រូវធានាថា លេខាធិការបានកត់ត្រាជាមុននូវលេខសោឃ្លុំដែលនឹងត្រូវប្រើចាក់ឃ្លុំមាត់ស្បោង "ខ" ដូចមានចែងក្នុងចំណុច ៨.២០.៦ នៃ ប.ន.ព.ស នេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងបោះត្រាសម្ងាត់នៅជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុនេះ។ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ចំនួន២ (ពីរ) ច្បាប់ ដែលលេខាធិការបានបំពេញរួចត្រូវចុះហត្ថលេខាដោយលេខាធិការ និងប្រធាន គ.ក.ប ហើយបោះត្រា គ.ក.ប។

៨.៧.៣.១ ប្រធាន គ.ក.ប ត្រូវដាក់បង្ហាញកំណត់ហេតុដូចមានចែងក្នុងចំណុច ៨.៧.៣ ខាងលើនេះ ចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ។

៨.៧.៣.២ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះ។

៨.៧.៣.៣ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុពីភ្នាក់ងារគណបក្សនយោបាយណាម្នាក់ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានទេ។

៨.៧.៤ ប្រធាន គ.ក.ប ត្រូវរៀបចំកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដែលបានចុះហត្ថលេខារួចដូចមានចែងក្នុងចំណុច ៨.៧.៣ ខាងលើនេះដូចខាងក្រោម៖

៨.៧.៤.១ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្វងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គធ.ខប"។

៨.៧.៤.២ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្វងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាង

កត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប”។

៨.៧.៥ បន្ទាប់មកប្រធាន គ.ក.ប ត្រូវរៀបចំដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព“ក”ដែលមានបោះពុម្ពសម្គាល់ថា“ការិយាល័យបោះឆ្នោតលេខ...”នូវៈ

៨.៧.៥.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដូចមានចែងក្នុងចំណុច ៨.៧.៤.២ ខាងលើនេះ។

៨.៧.៥.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត។

៨.៧.៥.៣ ស្រោមសំបុត្រដាក់ “សន្លឹកឆ្នោតខូច” (ប្រសិនបើមាន)។

៨.៧.៥.៤ ស្បោងប្លាស្ទិកដាក់ “សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ”។

៨.៧.៥.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់។

៨.៧.៥.៦ ស្រោមសំបុត្រដាក់ “សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត” (ប្រសិនបើមាន)។

៨.៧.៥.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន)។

៨.៧.៦ ប្រធាន គ.ក.ប ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ថា រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៧.៥ ខាងលើនេះ ត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព “ក”។ ប្រធាន គ.ក.ប ត្រូវធានាថា កញ្ចប់សុវត្ថិភាព “ក” មិនទាន់ត្រូវបិទភ្ជិតនៅពេលនេះនៅឡើយ ហើយនឹងត្រូវបិទភ្ជិតដោយការសុវត្ថិភាពបម្រុងស្រាប់ លុះណាតែ គ.ក.រ បានបញ្ចប់ការរាប់សន្លឹកឆ្នោត និងបានដាក់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត(ទ.១១០២) និងសម្ភារឯកសារបោះឆ្នោតផ្សេងទៀតទៅក្នុងកញ្ចប់សុវត្ថិភាព “ក” ពាក់ព័ន្ធរួចរាល់សិន។

៨.៧.៧ ប្រធាន គ.ក.ប ត្រូវធានាថា កញ្ចប់សុវត្ថិភាព “ក” ដូចមានចែងក្នុងចំណុច ៨.៧.៦ ខាងលើនេះ និងស្រោមសំបុត្រដូចមានចែងក្នុងចំណុច ៨.៧.៤.១ និងចំណុច ៨.៧.៤.២ ខាងលើនេះ ត្រូវបានបំពេញលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធយ៉ាងត្រឹមត្រូវ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ក្នុងពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតកំពុងដំណើរការ។

៨.៧.៨ ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិកឱ្យរៀបចំទុកដាក់សម្ភារ ឯកសារបោះឆ្នោត ដែលនៅសល់ក្នុងកេសស័ង្កសី និងវេចខ្ចប់ដបទឹកខ្មៅលុបមិនជ្រះដោយឡែក។ ទន្ទឹមនឹងនេះ ត្រូវរុះរើបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតទាំង ២ (ពីរ) រួចច្រកទៅក្នុងការុងនីឡុង ឬកេសក្រដាសដែលបានប្រើសម្រាប់ដាក់បន្ទប់សម្ងាត់ ដូចនៅពេលប្រគល់ជូន គ.ក.ប នាពេលដំបូង។

## ការបិទការិយាល័យបោះឆ្នោត ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន

## ប្រការ៨.៨.-

មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួនស្ថិតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះបាន។

៨.៨.១ ការសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតបាន លុះត្រាតែការិយាល័យបោះឆ្នោតនោះ ឬទាំងនោះស្ថិតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន។ ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ត្រូវបានកំណត់ដូចខាងក្រោម៖

៨.៨.១.១ អសន្តិសុខជាសាធារណៈ។

៨.៨.១.២ ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយផែនដី ឬគ្រោះធម្មជាតិផ្សេងទៀត។

៨.៨.១.៣ ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោតដោយយថាហេតុណាមួយ ឬអគ្គិភ័យ ឬការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់។

៨.៨.១.៤ ការរាំងស្ទះផ្នែករដ្ឋបាល ដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន។

៨.៨.១.៥ ជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរ។

៨.៨.២ នៅមុនថ្ងៃបោះឆ្នោត ប្រសិនបើមានកើតករណីណាមួយនៃករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដូចមានចែងក្នុងចំណុច ៨.៨.១ ខាងលើនេះ ប្រធាន គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់អំពីស្ថានភាពជាក់ស្តែងទៅ គធ.ខប។

៨.៨.២.១ គធ.ខប ត្រូវវាយតម្លៃសភាពការណ៍ជាក់ស្តែង ពិនិត្យលទ្ធភាពអាចបើកការិយាល័យបោះឆ្នោតបាន ឬមិនបាន និងរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប។

៨.៨.២.២ ក្រោយការសម្រេចបើក ឬមិនបើកការិយាល័យបោះឆ្នោត គ.ជ.ប ត្រូវជូនដំណឹងជាបន្ទាន់ទៅ គធ.ខប ដើម្បី គធ.ខប ចាត់ចែងបន្ត។

៨.៨.២.៣ ការរាយការណ៍បន្ទាន់ និងការជូនដំណឹងបន្ទាន់ខាងលើ ត្រូវធ្វើតាមរយៈទូរសព្ទ ទូរសារ ឬវិទ្យុទាក់ទង ឬអ៊ីមែល។

៨.៨.៣ នៅក្នុងថ្ងៃបោះឆ្នោត នៅមុនពេល ឬក្នុងពេលដំណើរការបោះឆ្នោត ប្រសិនបើកើតមានករណីណាមួយនៃករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដូចមានចែងក្នុងចំណុច ៨.៨.១ ខាងលើនេះ ប្រធាន គ.ក.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោត។ ប្រធាន គ.ក.ប ត្រូវរាយការណ៍ទៅ គធ.ខប ដើម្បី គធ.ខប រាយការណ៍បន្ទាន់ជូន គ.ជ.ប។

៨.៨.៤ ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬដែលត្រូវបានសម្រេចបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នត្រូវតែបិទរហូតពេញមួយថ្ងៃ។

**ប្រការ៨.៩.-**

គ.ជ.ប ត្រូវរាយការណ៍ភ្លាមទូលថ្វាយព្រះមហាក្សត្រ ជូនព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាធម្មនុញ្ញ អំពីការិយាល័យបោះឆ្នោតណាមួយដែលមិនត្រូវបានបើក ឬត្រូវបានបិទដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ននៅមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត។

**ប្រការ៨.១០.-**

ក្នុងករណីមានការិយាល័យបោះឆ្នោតណាមួយ ឬច្រើនដែលមិនត្រូវបានបើក ឬត្រូវបានបិទដោយករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដោយមាន គ.ក.ប ជាជំនួយ គធ.ខប ពាក់ព័ន្ធត្រូវ៖

៨.១០.១ ជូនដំណឹងដល់អ្នកបោះឆ្នោតដែលត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះឬទាំងនោះអំពីការមិនបើកឬការបិទការិយាល័យបោះឆ្នោតនោះឬទាំងនោះដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់។

៨.១០.២ ប្រមូលសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធផ្សេងទៀតសម្រាប់បម្រើការបោះឆ្នោតមករក្សាទុកនៅ គធ.ខប។

៨.១០.៣ ប្រមូលសន្លឹកឆ្នោតដែលបានបោះរួចហើយនៅការិយាល័យបោះឆ្នោតដែលត្រូវបានបិទក្នុងអំឡុងការបោះឆ្នោត រាប់ចំនួន និងកត់ត្រាទុកក្នុងកំណត់ហេតុ រួចដាក់ក្នុងស្បោងដោយឡែក។ សន្លឹកឆ្នោតទាំងនេះ ត្រូវទុកជាជាមោឃៈ គឺមិនត្រូវរាប់បញ្ចូលក្នុងលទ្ធផលនៃការបោះឆ្នោតឡើយ។

៨.១០.៤ ធ្វើកំណត់ហេតុស្ដីពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាយការណ៍ជូន គធ.ខប ដើម្បី គធ.ខប រាយការណ៍ជូន គ.ជ.ប។

៨.១០.៥ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសមានអាសន្នកើតមានឡើងនៅការិយាល័យបោះឆ្នោតក្រោយពេលបិទការបោះឆ្នោត ដែលពេលនោះកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ត្រូវបានធ្វើរួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង និងសម្ភារ ឯកសារបោះឆ្នោតនៅរក្សាបានល្អ គ.ក.ប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គធ.ខប ដើម្បីចាត់ចែងរាប់សន្លឹកឆ្នោតតាមការកំណត់នៃ ប.ន.ព.ស នេះ។

៨.១០.៦ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតមានឡើងនៅការិយាល័យបោះឆ្នោតនៅក្រោយពេលបិទការបោះឆ្នោត ហើយកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ត្រូវបានធ្វើរួចរាល់ ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង និងសម្ភារ ឯកសារបោះឆ្នោតត្រូវបានបំផ្លាញ ឬខូចខាត គ.ក.ប ត្រូវវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតទាំងនោះបញ្ជូនទៅ គធ.ខប ដើម្បីបន្តរាយការណ៍ជូន គ.ជ.ប សុំឱ្យមានការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

**ប្រការ៨.១១.-**

សមាសភាព គ.ក.ប នៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ ត្រូវរំសាយ និងទទួលបានប្រាក់កម្រៃស្របតាមកិច្ចសន្យា។

**ប្រការ៨.១២.-**

គ.ក.ប នៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបិទ ត្រូវអនុវត្តដំណើរការនៃការបោះឆ្នោត ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រមូល ការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតធម្មតាតាម ប.ន.ព.ស នេះ។

៨.១២.១ គធ.ខប ត្រូវរក្សាទុក និងការពារឱ្យបានគត់មត់នូវសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងដែលមិនទាន់បានប្រើប្រាស់ លទ្ធផលនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៃការិយាល័យបោះឆ្នោតដែលមិនត្រូវបានបិទនៅ លគធ.ខប រហូតដល់ពេលបញ្ចប់ការបោះឆ្នោតសាជាថ្មីនៅការិយាល័យ បោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទ។

៨.១២.២ គធ.ខប ត្រូវរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅការិយាល័យបោះឆ្នោត ដែលត្រូវធ្វើការបោះឆ្នោតសាជាថ្មី ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬ កាលៈទេសៈមានអាសន្ន តាមការសម្រេចរបស់ គ.ជ.ប ប៉ុន្តែមិនត្រូវលើសពី ៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចមិនបើក ឬបិទ។

៨.១២.៣ ការបោះឆ្នោតសាជាថ្មី ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈ មានអាសន្នដូចមានចែងក្នុងប្រការ ៨.៨ នៃ ប.ន.ព.ស នេះ ត្រូវអនុវត្តតាមការ សម្រេចរបស់ គ.ជ.ប ស្របតាម ច.ប.ព.ស និងអនុលោមតាមប្រការ ៨.១៣ រហូតដល់ប្រការ ៨.១៧ នៃ ប.ន.ព.ស នេះ។

## ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬ/និងត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន

## ប្រការ៨.១៣.-

ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬត្រូវបានបិទតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៨.៨ នៃ ប.ន.ព.ស នេះ គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតសាជាថ្មីក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចមិនបើក ឬបិទ នៅទីតាំងដដែល ឬទីតាំងណាមួយមិនឆ្ងាយពីទីតាំងចាស់នៅក្នុងទីប្រជុំជនរាជធានី ខេត្ត ដែលមានសន្តិសុខ និងសុវត្ថិភាពល្អ។ ក្នុងករណីមិនអាចរៀបចំការបោះឆ្នោតសាជាថ្មីតាមកាលកំណត់ ដោយមូលហេតុករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ននោះមិនទាន់វិលមករកប្រក្រតីភាពនៅឡើយ គ.ជ.ប មានសិទ្ធិសម្រេចឱ្យបន្តរៀបចំ ឬមិនបាច់រៀបចំការបោះឆ្នោតសាជាថ្មី។

៨.១៣.១ គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទ និងទីតាំងនៃការបោះឆ្នោតសាជាថ្មី និងណែនាំ គធ.ខប ឱ្យផ្សព្វផ្សាយ និងបិទផ្សាយនៅ លគធ.ខប និងនៅទីតាំងការិយាល័យ បោះឆ្នោតដែលត្រូវបោះឆ្នោតសាជាថ្មីយ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃបោះឆ្នោត សាជាថ្មី។

៨.១៣.២ ដើម្បីគ្រប់គ្រង និងចាត់ចែងរៀបចំការបោះឆ្នោតសាជាថ្មី គ.ជ.ប ត្រូវ៖

៨.១៣.២.១ ណែនាំដោយឡែកចំពោះ គធ.ខប និង គ.ក.ប ពាក់ព័ន្ធអំពី ការងារជាក់ស្តែងទាក់ទងនឹងការបោះឆ្នោតសាជាថ្មី។

៨.១៣.២.២ ណែនាំការជ្រើសរើស គ.ក.ប សម្រាប់ការបោះឆ្នោតសាជាថ្មី តាមបែបបទ និងនីតិវិធីនៃការជ្រើសរើសដូចមានចែងក្នុង ប.ន.ព.ស នេះ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

៨.១៣.៣ អាណត្តិរបស់ គធ.ខប និង គ.ក.ប សម្រាប់ការបោះឆ្នោតសាជាថ្មី ត្រូវបញ្ចប់តាមការកំណត់របស់ គ.ជ.ប។

៨.១៣.៤ សិទ្ធិអំណាច និងភារកិច្ចរបស់ គធ.ខប និង គ.ក.ប សម្រាប់ការបោះឆ្នោតសាជាថ្មី ត្រូវអនុលោមតាម ច.គ.ជ.ប ច.ប.ព.ស និង ប.ន.ព.ស នេះ ទៅតាមតម្រូវការជាក់ស្តែងនៃការបោះឆ្នោតសាជាថ្មីដែលកំណត់ដោយ គ.ជ.ប។

៨.១៣.៥ អ្នកបោះឆ្នោតទាំងអស់ដែលមានសិទ្ធិបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតសាជាថ្មី គឺអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ទោះបីជាបានបោះឆ្នោតហើយក្តី ឬមិនទាន់បានបោះឆ្នោតក្តី។

៨.១៣.៦ ដើម្បីបោះឆ្នោតបានក្នុងការបោះឆ្នោតសាជាថ្មី អ្នកបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិក កបឃ.ស ទាំងអស់ក្នុងតំណែងត្រូវៈ

៨.១៣.៦.១ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនោះ។

៨.១៣.៦.២ មាន អ.ខ ដែលមានសុពលភាព ឬលិខិតសម្គាល់ខ្លួនជាតំណាងរាស្ត្រក្នុងតំណែង ឬសមាជិក កបឃ.ស ក្នុងតំណែង ។

៨.១៣.៧ បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ត្រូវបានប្រើប្រាស់ក្នុងការបោះឆ្នោតសាជាថ្មី។ បញ្ជីបោះឆ្នោតនេះ ត្រូវបិទផ្សាយនៅ លគធ.ខប នៅទីកន្លែងណាមួយក្នុងទីប្រជុំជនរាជធានី ខេត្ត និងនៅការិយាល័យបោះឆ្នោតសាជាថ្មី ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត។

៨.១៣.៨ សមាសភាពភ្នាក់ងារគណបក្សនយោបាយដែលត្រូវសង្កេតមើលការិយាល័យបោះឆ្នោតនោះនៅក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវរក្សាទុកដដែល សម្រាប់ការបោះឆ្នោតសាជាថ្មី។

៨.១៣.៩ គ.ជ.ប ត្រូវបោះពុម្ពសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតសាជាថ្មី តាមគំរូសន្លឹកឆ្នោតលើកមុននៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតលើកមុន និងត្រូវឱ្យមានចំនួនគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់។

៨.១៣.១០ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារបោះឆ្នោតឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ដល់ គធ.ខប និង គ.ក.ប។

៨.១៣.១១ ក្នុងការបោះឆ្នោតសាជាថ្មី ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តនៃភូមិភាគពាក់ព័ន្ធ ត្រូវហាមឃាត់។

**ប្រការ៨.១៤._**

ការបោះឆ្នោតសាជាថ្មីត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុង ប.ន.ព.ស នេះ។ ដោយឡែកការជ្រលក់ទឹកខ្មៅលុបមិនជ្រះ អ្នកបោះឆ្នោតត្រូវប្រើម្រាមចង្អុលដៃឆ្វេងរបស់ខ្លួន។ ក្នុងករណីម្រាមចង្អុលដៃឆ្វេងពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយ តាមលំដាប់ដូចតទៅៈ ម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ឬមេដៃឆ្វេង ឬចង្អុលដៃស្តាំ ឬម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ។ ប្រសិនបើអ្នកបោះឆ្នោតនោះ មិនអាចធ្វើបានតាមការកំណត់រាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាបានការ។

**ប្រការ៨.១៥._**

នៅពេលបញ្ចប់ការបោះឆ្នោតសាជាថ្មី គ.ក.ប/គ.ក.វ ត្រូវអនុវត្តការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រមូល ប្រគល់ និងទទួលសម្ភារ ឯកសារបោះឆ្នោត ដូចការបោះឆ្នោតធម្មតា ដូចមានចែងក្នុង ប.ន.ព.ស នេះ ផងដែរ។

**ប្រការ៨.១៦._**

បន្ទាប់ពីការបោះឆ្នោតសាជាថ្មី គធ.ខប ត្រូតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ស្របតាម ប.ន.ព.ស នេះ។ គធ.ខប ត្រូវបូកសរុបលទ្ធផលទូទាំងរាជធានី ខេត្ត គឺទាំងលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលមិនត្រូវបានបិទ ដូចប្រការ ៨.១២ នៃ ប.ន.ព.ស នេះ ទាំងលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតសាជាថ្មី រួចវេចខ្ចប់ និងបញ្ជូនកំណត់ហេតុ ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប។

**ប្រការ៨.១៧._**

ក្នុងដំណើរការនៃការបោះឆ្នោតសាជាថ្មី ចាប់ពីការរៀបចំដំបូង រហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ ការផ្សះផ្សា ឬ/និងសវនាការដោះស្រាយពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដូចមានចែងក្នុងប.ន.ព.សនេះ។

## ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

**ប្រការ៨.១៨._**

ច.ប.ព.ស បានបញ្ញត្តឱ្យអនុវត្តបែបបទ និងនីតិវិធីក្នុងការរាប់សន្លឹកឆ្នោត ដោយអនុលោមតាម ច.ប.ត.វ។ ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការរាប់សន្លឹកឆ្នោតត្រូវធ្វើដោយ

ផ្ទាល់នៅការិយាល័យបោះឆ្នោតនីមួយៗដែលមានទីតាំងនៅទីប្រជុំជនរាជធានី ខេត្ត នៅពេលបន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) រួច លើកលែងតែការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបានដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ហើយដែល គ.ជ.ប បានសម្រេចឱ្យ គធ.ខប ចាត់ចែងរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅ លគធ.ខប ឬនៅកន្លែងណាមួយដែលមានសុវត្ថិភាព។

៨.១៨.១ ក្នុងករណីដែលការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោត ការិយាល័យបោះឆ្នោតនោះនឹងក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត ហើយ គ.ក.ប នឹងក្លាយជា គ.ក.រ។ ក្នុងករណីនេះ ប្រធាន គ.ក.ប ក្លាយជាប្រធាន គ.ក.រ ត្រូវចាត់វិធានការដោយអនុវត្តតាមប្រការ ៨.៥ ចំណុច ៨.៥.១ និងចំណុច ៨.៥.៣ នៃ ប.ន.ព.ស នេះ ហើយទន្ទឹមនឹងនេះត្រូវចាត់ចែងឱ្យប្រមូលទុកដាក់សម្ភារ ឯកសារបោះឆ្នោតដែលបានប្រើនៅពេលបោះឆ្នោតឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព។ បន្ទាប់មកប្រធាន គ.ក.រ ត្រូវចាត់ចែងឱ្យរៀបចំឡើងវិញនូវប្លង់បន្ទប់សម្រាប់ការរាប់សន្លឹកឆ្នោត ដែលក្នុងនោះត្រូវៈ

៨.១៨.១.១ រៀបចំតុធំមួយ ឬតុតូចច្រើនផ្តុំគ្នា និងកៅអី ៤ (បួន) សម្រាប់សមាជិក គ.ក.រ ដោយដាក់នៅចំកណ្តាលបន្ទប់ ដើម្បីអាចឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានាដើរចុះឡើងជុំវិញតុក្នុងការសង្កេតតាមដានកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត។

៨.១៨.១.២ លើកហិបឆ្នោតដាក់នៅចំកណ្តាលតុ ព្រមទាំងយកកញ្ចប់សុវត្ថិភាព "ក" ដូចបានបញ្ជាក់ក្នុងចំណុច ៨.៧.៥ នៃ ប.ន.ព.ស នេះ និងរាល់សម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទចាំបាច់ត្រៀមសម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដាក់នៅលើតុត្រង់កន្លែងប្រធាន គ.ក.រ អង្គុយ។

៨.១៨.១.៣ ចាត់សមាជិកទី២ និងសមាជិកទី៣ ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលបើកចំហ កុំឱ្យមានអ្នកចេញចូល មើលថែរក្សាសុវត្ថិភាពសម្ភារ ឯកសារបោះឆ្នោតដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

៨.១៨.២ កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ត្រូវធ្វើនៅតែមួយកន្លែងសម្រាប់ការិយាល័យរាប់សន្លឹកឆ្នោតមួយ ដែលប្រសិនបើចាប់ផ្តើមហើយត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយពុំត្រូវឈប់សម្រាកឡើយ។ ប្រធាន គ.ក.រ ត្រូវចាត់ចែងត្រៀមឱ្យមាន

ភ្លើងបំភ្លឺនៅការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីបង្ការក្នុងករណីការរាប់សន្លឹកឆ្នោតត្រូវអូសបន្លាយដល់ពេលយប់។

៨.១៨.២.១ ក្នុងដំណើរការនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញសកម្មភាពទាំងឡាយនៃការរាប់សន្លឹកឆ្នោត។

៨.១៨.២.២ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលដំណើរការនៃការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ និងត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) នៅមុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត។

៨.១៨.២.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចផ្លាស់ប្តូរភ្នាក់ងារបម្រុងរបស់ខ្លួន (ប្រសិនបើមាន) ឱ្យបំពេញភារកិច្ចជំនួស និងត្រូវចូលរួមឱ្យបានចប់ចុងចប់ដើម។

៨.១៨.២.៤ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចថតយករូបភាពនៅការិយាល័យរាប់សន្លឹកឆ្នោតបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែក ធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

៨.១៨.៣ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ប្រធាន គ.ក.រ ត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយឱ្យអនុប្រធាន គ.ក.រ និងសមាជិកទី១ អង្គុយនៅអមសងខាងតុទល់មុខគ្នា។ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងបន្ទប់ ប្រធាន គ.ក.រ ត្រូវប្រកាសចាប់ផ្តើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ហើយត្រូវៈ

៨.១៨.៣.១ បម្រុងទុកនៅក្បែរខ្លួនគាត់នូវៈ

- កញ្ចប់សុវត្ថិភាព“ក”ដែលមានស្បោងប្លាស្ទិក ឬស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងសម្ភារៈឯកសារបោះឆ្នោតផ្សេងទៀត
- ពាក្យបណ្តឹង (ទ.១២០២) សម្រាប់ចែកជូនភ្នាក់ងារគណបក្សនយោបាយបំពេញពាក្យបណ្តឹង ប្រសិនបើគាត់ស្នើសុំ

- ស្បោងប្លាស្ទិកថ្លាសម្រាប់ដាក់សន្លឹកឆ្នោតបានការ និង ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ
- កៅស៊ូកង។

៨.១៨.៣.២ ប្រគល់ទៅឱ្យអនុប្រធាន គ.ក.រ នូវតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់។

៨.១៨.៣.៣ ប្រគល់ទៅលេខាធិការនូវកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ៣ (បី) ច្បាប់ តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)១(មួយ)ច្បាប់ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព “ក”។

៨.១៨.៣.៤ ប្រគល់ឱ្យសមាជិកទី១ នូវប៊ិកហ្វឺតធំ ១ (មួយ) ដើម និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ១ (មួយ) ផ្ទាំង សម្រាប់កត់ត្រាសំឡេងឆ្នោត។

៨.១៨.៣.៥ ចាត់លេខាធិការឱ្យចាប់ផ្តើមបំពេញតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានទទួល សន្លឹកឆ្នោតដែលមិនបានប្រើ សន្លឹកឆ្នោតខូច និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែលតួលេខទាំងនេះ ត្រូវបានពិនិត្យ ផ្ទៀងផ្ទាត់រួចហើយដូចមានចែងក្នុងចំណុច ៨.៧.២ នៃ ប.ន.ព.ស នេះ និងដែលបានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ព្រមទាំងចាត់ឱ្យអនុប្រធាន គ.ក.ប ធ្វើកិច្ចការដូចគ្នានេះនៅលើតារាងកត់ត្រាសំឡេងឆ្នោត(ទ.១១០៨) និងសមាជិកទី១ ធ្វើកិច្ចការដូចគ្នានេះនៅលើផ្ទាំងក្រដាសធំ។

៨.១៨.៤ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ ប្រធាន គ.ក.រ ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឱ្យច្បាស់ថា សោឃ្លុំទាំងពីរដែលចាក់ជាប់នឹងគម្របខាងក្រៅនៃហិបឆ្នោតស្ថិតក្នុងស្ថានភាពដើម រួចកាត់ផ្តាច់សោឃ្លុំទាំងនេះ ដោយកន្ត្រៃ ឬកូនកាំបិតដែលអាចរកបានដោយខ្លួនឯង និងបើកគម្របខាងក្រៅចេញ។ បន្ទាប់មកប្រធាន គ.ក.រ ត្រូវបន្តត្រួតពិនិត្យផ្ទៀងផ្ទាត់លេខសោឃ្លុំដែលចាក់ជាប់នឹងគន្លឹះខ្ទាស់បិទគម្របខាងក្នុងនៃហិបឆ្នោត និងក្រដាសស្ដើងដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រឡោះសម្រាប់

ស៊ិកសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថាគ្មានការរុះរើ រួចកាត់ផ្តាច់សោឃ្លុំ និងហែក ក្រដាសនេះចោល។ ចុងក្រោយ ប្រធាន គ.ក.រ ត្រូវបើកគម្របខាងក្នុងនៃ ហិបឆ្នោត និងចាក់សន្លឹកឆ្នោតឱ្យអស់ពីហិបឆ្នោតដាក់នៅលើតុត្រង់ចន្លោះ អនុប្រធាន គ.ក.រ និងសមាជិកទី១ ហើយដាក់ហិបឆ្នោតទទេនៅក្បែរគាត់។

៨.១៨.៤.១ សមាជិកទី១ ត្រូវរើសយកវត្ថុមិនមែនជាសន្លឹកឆ្នោត ដែល មិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត (ប្រសិនបើមាន) ចេញពី គំនរសន្លឹកឆ្នោតរួចដាក់ទៅក្នុងស្រោមសំបុត្រមួយបម្រុងស្រាប់។

៨.១៨.៤.២ លេខាធិការត្រូវកត់ត្រាអំពីករណីដូចមានចែងក្នុងចំណុច ៨.១៨.៤.១ ខាងលើនេះ (ប្រសិនបើមាន) ក្នុងកំណត់ហេតុនៃ ការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៨.១៨.៥ ប្រធាន គ.ក.រ ត្រូវបង្គាប់អនុប្រធាន គ.ក.រ និងសមាជិកទី១ ឱ្យលា និងតម្រៀប សន្លឹកឆ្នោតដែលទើបបានចាក់ចេញពីហិបឆ្នោត ដោយដាក់ផ្កាប់ចុះក្រោម និងដាក់សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នងក្នុង ១ (មួយ) បាច់មាន ២៥ (ម្ភៃប្រាំ) សន្លឹកនៅពំនូកទី១ ហើយដាក់សន្លឹកឆ្នោតគ្មាន បោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង (ប្រសិនបើមាន) នៅពំនូកទី២។ បន្ទាប់ មក អនុប្រធាន គ.ក.រ និងសមាជិកទី១ ត្រូវរាប់សន្លឹកឆ្នោតទាំង ២ ពំនូក រួច រាយការណ៍ជូនប្រធាន គ.ក.រ អំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ។ ប្រធាន គ.ក.រ ត្រូវធានាថា នីតិវិធីមួយចំនួនដូចខាងក្រោម ត្រូវតែបានអនុវត្តៈ

៨.១៨.៥.១ ក្នុងករណី ចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើ មានចំនួន សរុបស្មើគ្នានឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬ ស្មើនឹងចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដកផលបូកនៃ ចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននេះក្នុងកំណត់ហេតុនៃ ការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៨.១៨.៥.២ ប្រសិនបើចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើមានចំនួន តិចជាង ឬច្រើនជាងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬម្យ៉ាងបើមានចំនួនតិចជាង ឬច្រើនជាងផលសងរវាងចំនួន សន្លឹកឆ្នោតរួមដែលបានទទួលជាក់ស្តែង ដកផលបូកនៃ ចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនបានប្រើនោះ ប្រធាន គ.ក.រ ត្រូវរាប់សន្លឹកឆ្នោតដូចបញ្ជាក់ក្នុងចំណុច ៨.១៨.៥ ខាងលើនេះ ឡើងវិញជាលើកទីពីរ។

៨.១៨.៥.៣ ប្រសិនបើបន្ទាប់ពីប្រធាន គ.ក.រ បានរាប់ឡើងវិញហើយ តួលេខនៃចំនួនសន្លឹកឆ្នោត នៅតែមានភាពខុសគ្នាដដែលដូចមានចែងក្នុងចំណុច ៨.១៨.៥.២ ខាងលើនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នានោះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៨.១៨.៥.៤ ប្រធាន គ.ក.រ ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ដូចមានចែងក្នុងចំណុច ៨.១៨.៥.១ ឬចំណុច ៨.១៨.៥.២ ឬ/និង ចំណុច ៨.១៨.៥.៣ ខាងលើនេះ ដើម្បីឱ្យអ្នកទាំងនោះអាចពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនោះបាន។

៨.១៨.៥.៥ អនុប្រធាន គ.ក.រ ត្រូវហុចសន្លឹកឆ្នោតពំនូកទី២ ដែលគ្មានត្រាសម្ងាត់ផ្លូវការនៅខាងខ្នង (ប្រសិនបើមាន) ជូនប្រធាន គ.ក.រ ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃគាត់។

៨.១៨.៥.៦ អនុប្រធាន គ.ក.រ ត្រូវហុចសន្លឹកឆ្នោតពំនូកទី១ ដែលខ្ទាស់ជាបាច់ក្នុងមួយបាច់ ២៥ (ម្ភៃប្រាំ) សន្លឹក ជូនប្រធាន គ.ក.រ ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃគាត់។

៨.១៨.៦ បន្ទាប់ពីការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតបានបញ្ចប់ ប្រធាន គ.ក.រ ត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ដែលជាដំបូងត្រូវពិនិត្យផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ហើយបន្ទាប់មកត្រូវប្រកាសសន្លឹកឆ្នោតដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ។ ប្រធាន គ.ក.រ ត្រូវធានាថា កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតត្រូវបានអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម៖

៨.១៨.៦.១ ដោយផ្អែកតាមការកំណត់ដូចមានចែងក្នុងប្រការ ៨.១៩ ខាងក្រោមនេះ ប្រធាន គ.ក.រ ត្រូវយកសន្លឹកឆ្នោតម្តង ១ (មួយ) សន្លឹកពីពំនូកទី១ មកពិនិត្យ ផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោតដែលបានកំណត់ហើយនោះ ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចមើលឃើញច្បាស់។

៨.១៨.៦.២ ប្រសិនបើប្រធាន គ.ក.រ កំណត់សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវប្រកាសថា "សន្លឹកឆ្នោតមិនបានការ"

រួចដាក់សន្លឹកឆ្នោតនោះ នៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ដែលស្ថិតនៅខាងស្តាំដៃគាត់។

៨.១៨.៦.៣ ប្រសិនបើប្រធាន គ.ក.រ កំណត់សន្លឹកឆ្នោតនោះជាសន្លឹកឆ្នោតបានការ គាត់ត្រូវប្រកាសឱ្យឮៗនូវឈ្មោះគណបក្សនយោបាយដែលសន្លឹកឆ្នោតនោះ ត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ ហើយត្រូវដាក់សន្លឹកឆ្នោតនោះទៅតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយពាក់ព័ន្ធនីមួយៗ។

៨.១៨.៦.៤ ផ្អែកតាមការប្រកាសរបស់ប្រធាន គ.ក.រ អនុប្រធាន គ.ក.រ និងលេខាធិការត្រូវគូសពិន្ទុ ១ (មួយ) សម្រាប់សន្លឹកឆ្នោត ១ (មួយ) សន្លឹក ដែលគណបក្សនយោបាយណាមួយត្រូវបានទទួល តាមការណែនាំរបស់ គ.ជ.ប នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨)។ ទន្ទឹមនឹងនេះ សមាជិកទី១ ត្រូវប្រើប៊ិកហ្វឺតគូសពិន្ទុ ១ (មួយ) នៅលើផ្ទាំងក្រដាសធំដែលបិទភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀន។

៨.១៨.៦.៥ ក្នុងករណី មានការជំទាស់ចំពោះសន្លឹកឆ្នោតដែលបានផ្ទៀងផ្ទាត់រាប់តាមចំណុច ៨.១៨.៦.៣ ខាងលើនេះ ប្រធាន គ.ក.រ ត្រូវដាក់សន្លឹកឆ្នោតដែលមានការជំទាស់នោះទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដូចមានចែងក្នុងចំណុច ៨.១៨.៦.២ ខាងលើនេះ។ សន្លឹកឆ្នោតទាំងនោះនឹងត្រូវពិនិត្យ ផ្ទៀងផ្ទាត់ និងកំណត់ម្តងទៀតជាចុងក្រោយ ដោយអនុវត្តតាមចំណុច ៨.១៨.៦.៦ ខាងក្រោមនេះ។

៨.១៨.៦.៦ នៅពេលផ្ទៀងផ្ទាត់សុពលភាព និងរាប់អស់សន្លឹកឆ្នោតពីពំនូកទី១ ប្រធាន គ.ក.រ ត្រូវបន្តយកសន្លឹកឆ្នោតម្តង ១ (មួយ) សន្លឹកៗពីពំនូកសន្លឹកឆ្នោតមិនបានការមកពិនិត្យ ផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្តងទៀតជាចុងក្រោយ ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ។

៨.១៨.៦.៧ ប្រសិនបើប្រធាន គ.ក.រ សម្រេចថា ជាសន្លឹកឆ្នោតបានការវិញ ត្រូវអនុវត្តចំណុច ៨.១៨.៦.៣ និងចំណុច ៨.១៨.៦.៤ ខាងលើនេះ។

៨.១៨.៦.៨ ប្រសិនបើប្រធាន គ.ក.រ សម្រេចថា ជាសន្លឹកឆ្នោតមិនបានការ ប្រធាន គ.ក.រ ត្រូវដាក់សន្លឹកឆ្នោតនោះ ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដដែល។

៨.១៨.៧ ក្នុងអំឡុងពេលនៃការពិនិត្យ ផ្ទៀងផ្ទាត់ និងកំណត់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ៨.១៨.៦.១ និងចំណុច ៨.១៨.៦.៦ ខាងលើនេះ ប្រសិនបើប្រធាន គ.ក.រ កត់សម្គាល់ឃើញថា សន្លឹកឆ្នោតណាមួយជាសន្លឹកឆ្នោតមិនច្បាស់លាស់ ដោយយោងទៅតាមសេចក្តីណែនាំដូចមានចែងក្នុងប្រការ ៨.១៩ ខាងក្រោមនេះ គាត់ត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គ.ក.រ អំពីសុពលភាព និងការកំណត់ប្រភេទនៃសន្លឹកឆ្នោតនោះម្តងទៀត ដើម្បីកំណត់ចុងក្រោយថា ពិតជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ។

៨.១៨.៧.១ ទោះបីប្រធាន គ.ក.រ កំណត់ថា ជាសន្លឹកឆ្នោតបានការក្តី ឬជាសន្លឹកឆ្នោតមិនបានការក្តី ប្រធាន គ.ក.រ ត្រូវប្រកាសឱ្យឮៗ អំពីហេតុផលសម្រាប់សន្លឹកឆ្នោតនោះ និងត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ធ្វើការត្រួតពិនិត្យសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការនោះ និងឱ្យចោទជាសំណួរចំពោះហេតុផលនៃការកំណត់របស់ប្រធាន គ.ក.រ ចំពោះសន្លឹកឆ្នោតនោះ។ ក្នុងករណីនេះ ភ្នាក់ងារគណក្សនយោបាយ និងអ្នកសង្កេតការណ៍មិនត្រូវបានអនុញ្ញាតឱ្យកាន់សន្លឹកឆ្នោតនោះឡើយ។

៨.១៨.៧.២ ក្នុងករណី ប្រធាន គ.ក.រ កំណត់ថា ជាសន្លឹកឆ្នោតបានការ ត្រូវអនុវត្តតាមចំណុច ៨.១៨.៦.៣ និងចំណុច ៨.១៨.៦.៤ ខាងលើនេះ។

៨.១៨.៧.៣ ក្នុងករណី ប្រធាន គ.ក.រ កំណត់ថា ជាសន្លឹកឆ្នោតមិនបានការ ប្រធាន គ.ក.រ ត្រូវដាក់សន្លឹកឆ្នោតនោះនៅពំនូកសន្លឹកឆ្នោតមិនបានការ។

៨.១៨.៧.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់មិនសុខចិត្តនឹងការសម្រេចរបស់ប្រធាន គ.ក.រ ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការខាងលើ ភ្នាក់ងារនោះមានសិទ្ធិលើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់នោះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។ ខ្លឹមសារ និងហេតុផលនៃការជំទាស់នោះមិន

ត្រូវបានកត់ត្រាឡើយ ក្នុងករណីភ្នាក់ងារនោះមិនយល់ព្រម ចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៨.១៨.៧.៥ ការសម្រេចរបស់ប្រធាន គ.ក.រ ត្រូវតែមានប្រសិទ្ធភាព ក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធាន គ.ក.រ ត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត។

៨.១៨.៧.៦ ការកំណត់ដូចមានចែងក្នុងចំណុច ៨.១៨.៧.៥ ខាងលើនេះ មិនបានច្រានចោលជាមុននូវដំណើរហេតុដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្ដឹងជំទាស់ទៅ គជ.ខប អំពីករណីដែលគាត់បានលើកការជំទាស់ដូចមានចែងក្នុងចំណុច ៨.១៨.៧.៤ ខាងលើនោះទេ ប៉ុន្តែគាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការនៃការគ្រប់គ្រងរបស់ប្រធាន គ.ក.រ និងមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតឡើយ។

៨.១៨.៧.៧ ប្រធាន គ.ក.រ ត្រូវផ្ដល់ពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ជូនភ្នាក់ងារគណបក្សនយោបាយ តាមសំណើសុំសម្រាប់បំពេញពាក្យបណ្ដឹងទៅ គជ.ខប។

៨.១៨.៨ ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ក្នុងពេលកំពុងរាប់សន្លឹកឆ្នោត ហាមជនគ្រប់រូបព្យាយាមធ្វើសកម្មភាពដោយទុច្ចរិតក្នុងគោលបំណងកត់សម្គាល់ ដើម្បីឱ្យដឹងថាតើអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់បានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។

៨.១៨.៨.១ ជនណាក៏ដោយដែលបានធ្វើសកម្មភាពដូចមានចែងក្នុងចំណុច ៨.១៨.៨ ខាងលើនេះ នឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.រ។ ការធ្វើសកម្មភាពដដែលឡើងវិញជាលើកទីពីរនឹងត្រូវចាត់ទុកថា ជាការរំលោភលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ហើយជនដែលមានការពាក់ព័ន្ធត្រូវតែបានបណ្ដេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ព.ស ច.ប.ត.រ និង ច.វ.ច.ប។

៨.១៨.៨.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត និងរាយការណ៍ជូន គជ.ខប។

៨.១៨.៨.៣ ពេលទទួលបានកំណត់ហេតុដូចមានចែងក្នុងចំណុច ៨.១៨.៨.២ ខាងលើនេះភ្លាម គធ.ខប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនេះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន គធ.ខប ត្រូវប្តឹងទៅ គ.ជ.ប ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់។

៨.១៨.៩ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួចហើយ ប្រធាន គ.ក.រ ត្រូវចាត់អនុប្រធាន គ.ក.រ និងលេខាធិការឱ្យបូកសរុប និងកត់ត្រាចំនួនសន្លឹកឆ្នោតមិនបានការសរុប ចំនួនសន្លឹកឆ្នោតបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ព្រមទាំងបង្គាប់សមាជិកទី១ ឱ្យធ្វើកិច្ចការដូចគ្នានេះនៅលើផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត។ ទន្ទឹមនេះដោយមានការពិនិត្យសង្កេតមើលរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គ.ក.រ ត្រូវរាប់ចំនួនសន្លឹកឆ្នោតបានការតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងតាមពំនូកសន្លឹកឆ្នោតមិនបានការ ហើយត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញជាមួយនឹងតួលេខចំនួនសន្លឹកឆ្នោតដែលអនុប្រធាន គ.ក.រ លេខាធិការ និងសមាជិកទី១ បានបូកសរុបឃើញខាងលើ។ ប្រធាន គ.ក.រ ត្រូវធានាថា តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ទាំង ២ (ពីរ) ច្បាប់ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ១ (មួយ) ផ្ទាំង ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ និងភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន (ប្រសិនបើភ្នាក់ងារទាំងនោះយល់ព្រម)។

៨.១៨.១០ ប្រធាន គ.ក.រ ត្រូវប្រកាសជាចំហនូវលទ្ធផលនៃការបូកសរុប និងការរាប់ចំនួនសន្លឹកឆ្នោត ដែលបានអនុវត្តតាមចំណុច ៨.១៨.៩ ខាងលើនេះ និងត្រូវធ្វើការផ្ទៀងផ្ទាត់ ដោយធ្វើប្រមាណវិធីបូកបញ្ចូលគ្នានូវចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ និងចំនួនសន្លឹកឆ្នោតមិនបានការទាំងអស់។

៨.១៨.១០.១ ប្រសិនបើផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ ស្មើគ្នាទៅនឹងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចមានចែងក្នុងចំណុច ៨.១៨.៥ ខាងលើនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនសន្លឹកឆ្នោតដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការទៅក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៨.១៨.១០.២ ប្រសិនបើផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះមានចំនួនតិចជាង ឬច្រើនជាងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចមានចែងក្នុងចំណុច ៨.១៨.៥ ខាងលើនេះ ប្រធាន គ.ក.រ ត្រូវរាប់សន្លឹកឆ្នោតតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការឡើងវិញម្តងទៀត។

៨.១៨.១០.៣ ប្រសិនបើបន្ទាប់ពីប្រធាន គ.ក.រ បានរាប់ឡើងវិញ និងធ្វើប្រមាណវិធីបូកឃើញផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះនៅតែមានភាពខុសគ្នាដដែល ម៉្យាងប្រសិនបើគ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោតទេ ឬ/និងគ្មានសន្លឹកឆ្នោតណាមួយ ឬច្រើនត្រូវបានគេរកឃើញនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដោយសារការធ្លាក់ជ្រុះទេនោះត្រូវសន្មតថាភាពខុសគ្នានេះបានកើតឡើងមុនជាយថាហេតុ។ ក្នុងករណីនេះលេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៨.១៨.១១ ប្រធាន គ.ក.រ ត្រូវធានាថា សន្លឹកឆ្នោតបានការដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចងនឹងកៅស៊ូកងឱ្យជាប់ដោយឡែកពីគ្នា។

៨.១៨.១២ ប្រធាន គ.ក.រ ត្រូវធានាថា សន្លឹកឆ្នោតមិនបានការទាំងអស់ត្រូវបានចងនឹងកៅស៊ូកង និងដាក់បញ្ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្វងថា “សន្លឹកឆ្នោតមិនបានការ”។

៨.១៨.១៣ ប្រធាន គ.ក.រ ត្រូវធានាថា សន្លឹកឆ្នោតបានការដែលបានចងនឹងកៅស៊ូកងដូចមានចែងក្នុងចំណុច ៨.១៨.១១ ខាងលើនេះ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការដូចមានចែងក្នុងចំណុច ៨.១៨.១២ ខាងលើនេះ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោតដូចមានចែងក្នុងចំណុច ៨.១៨.៩ ខាងលើនេះ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដូចមានចែងក្នុងចំណុច ៨.១៨.៤.១ ខាងលើនេះ ត្រូវបានដាក់រួមគ្នាក្នុងស្បោងប្លាស្ទិកតែមួយ ដែលមានបោះពុម្ពសម្គាល់ពីខាងក្រៅថា “សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការនៃការិយាល័យបោះឆ្នោតលេខ...” បន្ទាប់មកត្រូវបិទភ្ជិតមាត់ស្បោងប្លាស្ទិកនេះ និងត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយប្រើប៊ិកហ្វឺតធំលុបមិនជ្រះនៅលើផ្នែកខាងក្រៅនៃស្បោងប្លាស្ទិក ដើម្បីត្រៀមបញ្ជូន និងប្រគល់ជូន គឃ.ឌប។

៨.១៨.១៤ បន្ទាប់ពីបានអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៨.១៨ ខាងលើនេះ ប្រធាន គ.ក.រ ត្រូវចាត់លេខាធិការឱ្យបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ចំនួន ៣ (បី) ច្បាប់ និងត្រូវចុះហត្ថលេខាដោយលេខាធិការ និងប្រធាន គ.ក.រ និងភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមានក្នុងការិយាល័យរាប់សន្លឹកឆ្នោត (ប្រសិនបើភ្នាក់ងារទាំងនោះយល់ព្រម)។

៨.១៨.១៥ បន្ទាប់ពីធ្វើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) រួចហើយ ប្រធាន គ.ក.រ ត្រូវ៖

៨.១៨.១៥.១ ចាត់សមាជិកទី២ ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ជាសាធារណៈនៅត្រង់ច្រកចូលទីតាំងការិយាល័យរាប់សន្លឹកឆ្នោតរហូតដល់ថ្ងៃប្រកាសលទ្ធផលបោះឆ្នោតជាផ្លូវការ និងជម្រាបជូនភ្នាក់ងារគណបក្សនយោបាយថា គាត់អាចថតរូបភាព ឬចម្លងតួលេខពីកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលបិទផ្សាយនេះបាន និងសូមឱ្យគាត់ទៅទទួលយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅ លគធ.ខប។

៨.១៨.១៥.២ ចាត់លេខាធិការឱ្យដាក់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ចូលក្នុងស្រោមសំបុត្រ បោះពុម្ពដែលមានកាខ្ទង់ថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គធ.ខប" និងដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) បញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ចូលទៅក្នុងស្រោមសំបុត្រ រួចចាត់សមាជិកទី២ ឱ្យនាំយកស្រោមសំបុត្រទាំងពីរនេះ ទៅប្រគល់ជូន គធ.ខប ដើម្បីបូកសរុប និងបញ្ជូនទៅ គ.ជ.ប ប្រកាសផ្សព្វផ្សាយជាលទ្ធផលបឋមនៃការបោះឆ្នោត រួមនឹងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។

៨.១៨.១៥.៣ ប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានឱ្យចូលរួមអមដំណើរសមាជិកទី២ ក្នុងការបញ្ជូនស្រោមសំបុត្រដាក់កំណត់ហេតុដូចមានចែងក្នុងចំណុច ៨.១៨.១៥.២ ខាងលើនេះ និងត្រូវស្នើសុំភ្នាក់ងារសន្តិសុខបោះឆ្នោត ១ (មួយ) រូប ដើម្បីការពារសន្តិសុខ និងសុវត្ថិភាព ក្នុងកិច្ចដំណើរការបញ្ជូនស្រោមសំបុត្រទាំងនេះ។

៨.១៨.១៦ ក្នុងអំឡុងពេលនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹត្យ ឥតលម្អៀង ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុង ច.ប.ត.រ និងប្រការ ៦.៩ នៃ ប.ន.ព.ស នេះ។

## សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ

### ប្រការ៨.១៩.-

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គ.ក.រ ជាពិសេស ប្រធាន គ.ក.រ និងអនុប្រធាន គ.ក.រ ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ។

៨.១៩.១ សន្លឹកឆ្នោតបានការ គឺជាសន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅតាមរាជធានី ខេត្តនៃភូមិភាគនីមួយៗ និងមានបោះត្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង ហើយដែលនៅលើសន្លឹកឆ្នោតនោះ អ្នកបោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ពីបំណងរបស់ខ្លួន ដោយមានគូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងស្របនឹងគណបក្សនយោបាយណាមួយដែលគាត់ពេញចិត្ត។

៨.១៩.២ សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលត្រូវបានចាត់ទុកជាមោឃៈ ដែលក្នុងនោះរួមមានសន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ ឬ/និង ដែលគ្មានគំនូស ឬមានគំនូស ប៉ុន្តែ គ.ក.រ ដែលទទួលខុសត្រូវរាប់សន្លឹកឆ្នោតពុំអាចសន្និដ្ឋានថា បោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ ឬ/និងដែលមានសញ្ញានាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ឬ/និងដែលមានរហែក ឬប្រឡាក់ខូច ឬ/និងដែលគ្មានត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។ សន្លឹកឆ្នោតមិនបានការ រួមមាន ៥ ប្រភេទ ដូចខាងក្រោមដែលត្រូវបានចាត់ទុកជាមោឃៈ។

៨.១៩.២.១ សន្លឹកឆ្នោតមិនផ្លូវការត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតមានខ្នាតតូចជាង ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប
- សន្លឹកឆ្នោតដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើនដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅតាមភូមិភាគពាក់ព័ន្ធ
- សន្លឹកឆ្នោតមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅតាមភូមិភាគនីមួយៗ
- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សម្រាប់ភូមិភាគនីមួយៗ
- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោតដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ពាក់ព័ន្ធ។

៨.១៩.២.២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសដែលពុំអាចសន្និដ្ឋានថាបោះឆ្នោតគាំទ្រឱ្យគណបក្សនយោបាយណាមួយ ត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ)
- សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀង ទន្ទឹមនឹងគណបក្សនយោបាយលើសពីមួយគណបក្ស
- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើននៅក្រៅប្រអប់គណបក្សនយោបាយ ឬមិនចំលេខរៀងនៃគណបក្សនយោបាយណាមួយ ទោះបីជាមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែង ឬចំលេខរៀងគណបក្សនយោបាយណាមួយក៏ដោយ។

៨.១៩.២.៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ នាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នង
- សន្លឹកឆ្នោតមានផ្តិតស្នាមម្រាមដៃ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់នៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នង
- សន្លឹកឆ្នោតមានបិទតែមប្រៃ ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ ភ្ជាប់នៅត្រង់ប្រអប់គណបក្សនយោបាយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នង
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត។

៨.១៩.២.៤ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូច ត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់នៃគណបក្សនយោបាយណាមួយ
- សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងខាងខ្នង ដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរ ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយ។

៨.១៩.២.៥ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការសម្រាប់ការិយាល័យបោះឆ្នោតពាក់ព័ន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

## ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ

**ប្រការ៨.២០.-**

នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដូចមានចែងក្នុងប្រការ ៨.១៨ ខាងលើនេះ ត្រូវបានបំពេញរួចរាល់ ប្រធាន គ.ក.រ ត្រូវធានាថា តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ចំនួន ២ (ពីរ) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ចំនួន ៣ (បី) ច្បាប់ ដែលលេខាធិការបានបំពេញត្រឹមត្រូវហើយដូចមានចែងក្នុងចំណុច ៨.១៨.១៤ ខាងលើនេះ ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ ព្រមទាំងបោះត្រា គ.ក.ប។ ប្រធាន គ.ក.រ ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងរាល់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ដើម្បីបញ្ជូនទៅ គធ.ខប។

៨.២០.១ ប្រធាន គ.ក.រ ត្រូវដាក់បង្ហាញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដូចមានចែងក្នុងប្រការ ៨.២០ ខាងលើនេះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ព្រមទាំងអញ្ជើញភ្នាក់ងារគណបក្សនយោបាយឱ្យចូលរួមចុះហត្ថលេខាជាសាក្សី។

៨.២០.១.១ ភ្នាក់ងារគណបក្សនយោបាយអាចចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ខាងលើ។

៨.២០.១.២ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនៃកំណត់ហេតុនេះបានទេ។

៨.២០.២ ប្រធាន គ.ក.រ ត្រូវដាក់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ដូចមានចែងក្នុងចំណុច ៨.១៨.៩ ខាងលើនេះ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ទងថា "ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប"។ បន្ទាប់មកប្រធាន គ.ក.រ ត្រូវរៀបចំវេចខ្ចប់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប ព្រមទាំងរាល់ស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងកញ្ចប់សុវត្ថិភាព "ក" ហើយត្រូវបិទភ្ជិតដោយការ

សុវត្ថិភាពដែលបម្រុងស្រាប់ និងបំពេញលេខកូដការិយាល័យបោះឆ្នោត ពាក់ព័ន្ធឱ្យបានត្រឹមត្រូវ។ ប្រធាន គ.ក.រ ត្រូវធានាថា នៅក្នុងកញ្ចប់សុវត្ថិភាព "ក" ត្រូវមានសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម៖

៨.២០.២.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប។

៨.២០.២.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត។

៨.២០.២.៣ ស្រោមសំបុត្រដាក់ "សន្លឹកឆ្នោតខូច" (ប្រសិនបើមាន)។

៨.២០.២.៤ ស្បោងប្លាស្ទិកដាក់ "សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ"។

៨.២០.២.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់។

៨.២០.២.៦ ស្រោមសំបុត្រដាក់ "សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត" (ប្រសិនបើមាន)។

៨.២០.២.៧ ស្រោមសំបុត្រដាក់ឯកសារភស្តុតាងដែលបានដកហូត (ប្រសិនបើមាន)។

៨.២០.២.៨ ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (ប្រសិនបើមាន) ដូចមានចែងក្នុងចំណុច ៨.១៨.១៣ ខាងលើនេះ។

៨.២០.៣ ប្រធាន គ.ក.រ ត្រូវដាក់តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្វងថា "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គធ.ខប" ដូចមានចែងក្នុងចំណុច ៨.៧.៤.១ នៃ ប.ន.ព.ស នេះ។

៨.២០.៤ ប្រធាន គ.ក.រ ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញលម្អិតមុខសម្ភារ ឯកសារបោះឆ្នោត ដោយលេខាធិការ និងចុះហត្ថលេខាដោយប្រធាន

គ.ក.រ ផ្ទាល់ សម្រាប់ប្រើក្នុងការបញ្ជូន និងប្រគល់ ទទួលស្បោង "ខ" នៅ លគធ.ខប។ ប្រធាន គ.ក.រ ត្រូវ៖

៨.២០.៤.១ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្រ រួចដាក់ទៅក្នុងស្បោង "ខ"។

៨.២០.៤.២ ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ"។

៨.២០.៤.៣ រក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការចុះហត្ថលេខាប្រគល់ ទទួលស្បោង "ខ" នៅ លគធ.ខប។

៨.២០.៥ ប្រធាន គ.ក.រ ត្រូវធានាក្នុងការវេចខ្ចប់ដាក់ក្នុងស្បោង "ខ" ដើម្បីបញ្ជូនទៅ គធ.ខប នូវសម្ភារ ឯកសារបោះឆ្នោតដូចខាងក្រោម៖

៨.២០.៥.១ កញ្ចប់សុវត្ថិភាព "ក" ដាក់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធដូចមានចែងក្នុងចំណុច ៨.២០.២ ខាងលើនេះ។

៨.២០.៥.២ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ដូចមានចែងក្នុងចំណុច ៨.២០.៥.១ ខាងលើនេះ។

៨.២០.៥.៣ ស្រោមសំបុត្រតូចមួយដាក់ត្រា គ.ក.ប (ដាក់ក្រោយពេលបានបោះត្រាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) រួចរាល់ហើយ)។

៨.២០.៦ ប្រធាន គ.ក.រ ត្រូវធានាថា ស្បោង "ខ" ដែលផ្ទុកសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.២០.៥ ខាងលើនេះ ត្រូវបានចងភ្ជិត និងចាក់សោឃ្លុំមានលេខ សរសេរលេខកូដការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ និងដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង "ខ"។

៨.២០.៧ ប្រធាន គ.ក.រ ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ បានសង្កេតមើលក្នុងរាល់ដំណើរការនៃការរៀបចំ និងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ លគធ.ខប និងបានកត់ត្រាលេខសោឃ្លុំដែលបានចាក់នៅត្រង់មាត់ស្បោង "ខ" ដូចមានចែងក្នុងចំណុច ៨.២០.៦ ខាងលើនេះ។

៨.២០.៨ ប្រធាន គ.ក.រ ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលតម្រូវឱ្យផ្ញើជូន គ.ជ.ប វិញ ដូចជា ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ទឹកខ្មៅលុបមិនជ្រះ ស្លាកការិយាល័យបោះឆ្នោតជាដើម ហើយត្រូវបញ្ជូន និងប្រគល់សម្ភារ ឯកសារបោះឆ្នោតទាំងនោះជូន គធ.ខប អមជាមួយនឹង ការបញ្ជូនស្បោង "ខ"។ ប្រធាន គ.ក.រ ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ ត្រូវបាន បំពេញលម្អិតមុខសម្ភារ ឯកសារបោះឆ្នោតនៅសល់ទាំងអស់ សម្រាប់ប្រើក្នុង ពេលប្រគល់ ទទួលនៅ លគធ.ខប។

## កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការស្កេន និងបញ្ជូនរូបភាពកំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ទៅ គ.ជ.ប សម្រាប់ផ្សាយជាលទ្ធផលបឋមនៃការបោះឆ្នោត

## ប្រការ៨.២១.-

នៅរសៀលនៃថ្ងៃបោះឆ្នោត គធ.ខប ត្រូវរង់ចាំទទួលស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គធ.ខប និងស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត(ទ.១១២០) និងបញ្ជីវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ក្នុងពេលរាប់សន្លឹកឆ្នោត (ទ.១១១៥) ដែលសមាជិកទី២ នៃ គ.ក.រ នឹងប្រគល់ជូន។ បន្ទាប់មក គធ.ខប ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ជាលទ្ធផលបឋមនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដោយត្រូវចាត់ចែងបញ្ជូនលទ្ធផលនេះ តាមបែបបទ និងនីតិវិធីដូចខាងក្រោម៖

៨.២១.១ ប្រធាន លគធ.ខប ត្រូវពិនិត្យ ផ្ទៀងផ្ទាត់អំពីភាពពេញលេញនៃការបំពេញទិន្នន័យនានាក្នុងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) រួចចារបញ្ជាក់ពីការបានទទួលនៅលើផ្នែកខាងលើនៃកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ចុះកាលបរិច្ឆេទ និងពេលវេលានៃការទទួល រួចចុះហត្ថលេខា និងបោះត្រា លធ.ខប។

៨.២១.២ ចាត់ឱ្យមន្ត្រីផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសស្កេនកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ។

៨.២១.៣ បញ្ចូលទិន្នន័យ និងតួលេខលទ្ធផលពីកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដូចមានចែងក្នុងចំណុច ៨.២១.២ ខាងលើនេះ បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត រួចបញ្ជូនមក គ.ជ.ប តាមអ៊ីនធឺណិត ដើម្បីផ្សាយជាព័ត៌មានអំពីលទ្ធផលបឋមនៃការបោះឆ្នោត។

៨.២១.៤ បន្ទាប់មកមន្ត្រីផ្នែកប្រតិបត្តិការបោះឆ្នោត និងបច្ចេកទេសត្រូវបោះពុម្ពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដូចមានក្នុងចំណុច ៨.២១.២ ខាងលើនេះ តាមចំនួនគ្រប់គ្រាន់ និងត្រូវបោះត្រា គធ.ខប សម្រាប់ផ្តល់ជូនភ្នាក់ងារគណបក្សនយោបាយ តាមការស្នើសុំ។

៨.២១.៥ រក្សាទុកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) សម្រាប់ដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តដូចមានចែងក្នុងប្រការ ៨.២៧ នៃ ប.ន.ព.ស នេះ។

៨.២១.៦ បែបបទ និងនីតិវិធីអនុវត្តលម្អិតក្នុងប្រការ ៨.២១ ខាងលើនេះ ត្រូវកំណត់ដោយសៀវភៅណែនាំរបស់ គ.ជ.ប។

## ការបញ្ជូនស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ លគធ.ខប

## ប្រការ៨.២២.-

បន្ទាប់ពីបានធ្វើការវេចខ្ចប់ កញ្ចប់សុវត្ថិភាព "ក" ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតរួចសព្វគ្រប់ហើយ ប្រធាន គ.ក.រ ត្រូវចាត់វិធានការចាំបាច់ទាំងឡាយក្នុងការបញ្ជូនជាបន្ទាន់នូវស្បោង "ខ" ដូចមានចែងក្នុងចំណុច ៨.២០.៦ ខាងលើនេះ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ដូចមានចែងក្នុងចំណុច ៨.២០.៨ ខាងលើនេះ ឱ្យបានទៅដល់ លគធ.ខប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត។

៨.២២.១ ប្រធាន គ.ក.រ ត្រូវប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិដែលមានវត្តមានឱ្យចូលរួមជាសាក្សីក្នុងការបញ្ជូន និងការប្រគល់ ទទួលស្បោង "ខ" ដែលមានកញ្ចប់សុវត្ថិភាព "ក" ដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតខាងលើនេះ ហើយត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរ ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ ទទួលស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅ លគធ.ខប។

៨.២២.២ ប្រធាន គ.ក.រ ដែលអមដំណើរដោយអនុប្រធាន គ.ក.រ ត្រូវទទួលខុសត្រូវដឹកជញ្ជូនដោយផ្ទាល់នូវស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងប្រការ ៨.២២ ខាងលើនេះទៅ លគធ.ខប។ ប្រធាន គ.ក.រ ត្រូវចាត់សមាជិក គ.ក.រ តាមការចាំបាច់ ដើម្បីជួយដឹកជញ្ជូនឱ្យអស់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។

៨.២២.៣ ប្រសិនបើត្រូវការចាំបាច់ ប្រធាន គ.ក.រ ត្រូវស្នើសុំកម្លាំងសន្តិសុខបោះឆ្នោត ២ (ពីរ) នាក់ ដើម្បីអមដំណើរការដឹកជញ្ជូនស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ លគធ.ខប។

៨.២២.៤ នៅពេលទទួលស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងប្រការ ៨.២២ ខាងលើនេះ មន្ត្រី លគធ.ខប ត្រូវធានាថា បានត្រួតពិនិត្យរាល់សម្ភារ ឯកសារបោះឆ្នោត និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) បញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ។ ដោយឡែកក្នុងការប្រគល់ ទទួលស្បោង “ខ” មន្ត្រី លគធ.ខប ត្រូវ៖

៨.២២.៤.១ បើកស្បោង “ខ” ត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតខាងក្នុងដោយផ្អែកលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ ប៉ុន្តែមិនត្រូវរុះរើកញ្ចប់សុវត្ថិភាព “ក” ឡើយ រួចចងមាត់ស្បោង “ខ” វិញ។

៨.២២.៤.២ ចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ បន្ទាប់ពីបានត្រួតពិនិត្យត្រឹមត្រូវហើយ។

៨.២២.៤.៣ ប្រគល់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ដែលចុះហត្ថលេខារួច ១ (មួយ) ច្បាប់ ជូនប្រធាន គ.ក.រ ពាក់ព័ន្ធ ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង “ខ” វិញ និងរក្សាទុក ១ (មួយ) ច្បាប់ទុកជាឯកសារ។

៨.២២.៥ រាល់ស្បោង “ខ” ដែលមន្ត្រី លគធ.ខប បានទទួលខាងលើនេះ ត្រូវតែបានកត់ចំណាំ និងរក្សាទុកនៅកន្លែងមានសុវត្ថិភាព ដោយដាក់តាមលំដាប់លេខកូដការិយាល័យបោះឆ្នោតនីមួយៗក្នុងរាជធានី ខេត្ត។

៨.២២.៦ មន្ត្រី លគធ.ខប ត្រូវចាត់វិធានការយ៉ាងហ្មត់ចត់ក្នុងការការពារសន្តិសុខ និងសុវត្ថិភាពនៃស្បោង “ខ” ដែលមានកញ្ចប់សុវត្ថិភាព “ក” ដាក់កំណត់ហេតុ

នៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និង កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត។ ក្នុងនោះ ប្រធាន គធ.ខប ត្រូវះ

៨.២២.៦.១ ទំនាក់ទំនងស្នើសុំកម្លាំងសន្តិសុខបោះឆ្នោត ដើម្បីយាមការពារ បរិវេណ លគធ.ខប ឬអគារដែលត្រូវរក្សាទុកស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោត។

៨.២២.៦.២ ចាត់ចែងឱ្យមានភ្លើងបំភ្លឺនៅ លគធ.ខប ឬអគារដែលត្រូវរក្សាទុកស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោត។

## ការរាប់សន្លឹកឆ្នោតនៅ លគធ.ខប ឬទីតាំងសុវត្ថិភាពណាមួយ

## ប្រការ៨.២៣.–

ចំពោះការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងរាជធានី ខេត្ត ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ននៅពេលបន្ទាប់ពីបានបិទការបោះឆ្នោត ព្រមទាំងបានធ្វើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) រួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅរក្សាបានល្អ គ.ជ.ប ត្រូវណែនាំដល់ គធ.ខប ពាក់ព័ន្ធឱ្យចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅ លគធ.ខប ឬទីតាំងសុវត្ថិភាពណាមួយ។

៨.២៣.១ ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នត្រូវបានកំណត់ក្នុងចំណោមករណីណាមួយ ដូចមានចែងក្នុងចំណុច ៨.៨.១ នៃប្រការ ៨.៨ នៃជំពូកទី៨ នៃ ប.ន.ព.ស នេះ។

៨.២៣.២ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដែលកើតឡើងនៅក្រោយពេល គ.ក.ប បានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចមានចែងក្នុងប្រការ ៨.៧ នៃ ប.ន.ព.ស នេះ ហើយប្រសិនបើប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ននោះបានបណ្តាលឱ្យខូចខាតដល់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងរាល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ប្រធាន គ.ក.ប ត្រូវចាត់ចែងជាបន្ទាន់ដូចខាងក្រោមះ

៨.២៣.២.១ ធ្វើរបាយការណ៍ស្តីពីស្ថានភាពនៃករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ននោះ ព្រមទាំងការខូចខាតជាក់ស្តែងជូន គធ.ខប។

៨.២៣.២.២ ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតនៅសេសសល់ទាំងអស់ ដែលអមដោយរបាយការណ៍ខាងលើ រួចបញ្ជូន

និងប្រគល់ជូន គធ.ខប។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចចូលរួមអមដំណើរក្នុងការបញ្ជូននេះ។

៨.២៣.២.៣ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ លគធ.ខប។

៨.២៣.៣ នៅពេលប្រគល់របាយការណ៍ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើ មន្ត្រី លគធ.ខប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ជូនប្រធាន គ.ក.ប វិញ ១ (មួយ) ច្បាប់។

៨.២៣.៤ នៅពេលទទួលបានរបាយការណ៍ដូចមានចែងក្នុងចំណុច ៨.២៣.៣ ខាងលើនេះ គធ.ខប ត្រូវបន្តលើកយោបល់ស្នើជាបន្ទាន់ទៅ គ.ជ.ប សុំឱ្យមានការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

៨.២៣.៥ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដែលកើតឡើងនៅក្រោយពេល គ.ក.ប បានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចមានចែងក្នុងប្រការ ៨.៧ នៃ ប.ន.ព.ស នេះ ហើយប្រសិនបើប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ននោះមិនបានបណ្តាលឱ្យខូចខាតដល់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងរាល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ទេ ប្រធាន គ.ក.ប ត្រូវចាត់ចែងជាបន្ទាន់ដូចខាងក្រោម៖

៨.២៣.៥.១ ថែរក្សាហិបឆ្នោតដែលបានបិទភ្ជិត និងចាក់សោឃ្លុំរួចដូចមានចែងក្នុងចំណុច ៨.៧.១.២ នៃ ប.ន.ព.ស នេះ ឱ្យបានហ្មត់ចត់ត្រៀមសម្រាប់ការបញ្ជូនទៅ គធ.ខប។

៨.២៣.៥.២ រៀបចំស្រោមសំបុត្រសម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដូចមានចែងក្នុងចំណុច ៨.៧.៤.២ នៃ ប.ន.ព.ស នេះ និងវេចខ្ចប់រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៧.៥ នៃ ប.ន.ព.ស នេះ ទៅក្នុងកញ្ចប់សុវត្ថិភាព “ក” ប៉ុន្តែមិនចាំបាច់បិទភ្ជិតដោយការសុវត្ថិភាពនៅពេលនេះទេ បន្ទាប់មកត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

៨.២៣.៥.៣ វេចខ្ចប់កញ្ចប់សុវត្ថិភាព “ក” និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដូចមានចែងក្នុងចំណុច ៨.៧.៤.១ នៃ ប.ន.ព.ស នេះ ព្រមទាំងស្រោមសំបុត្រដាក់ត្រា

គ.ក.ប (បន្ទាប់ពីបោះត្រាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) រួច) ទៅក្នុងស្បោង “ខ” ហើយចងភ្ជិត និងចាក់សោឃ្លុំ។

៨.២៣.៥.៤ ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទាំងអស់ដោយឡែក។

៨.២៣.៥.៥ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ទទួលនៅ លគធ.ខប។

៨.២៣.៥.៦ បញ្ជូន និងប្រគល់ហិបឆ្នោត ស្បោង “ខ” និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើជូន គធ.ខប។ ប្រធាន គ.ក.ប ដែលអមដំណើរដោយអនុប្រធាន គ.ក.ប និងសមាជិក គ.ក.ប មួយចំនួនទៀត ត្រូវទទួលបន្ទុកក្នុងការបញ្ជូន និងប្រគល់ទទួលនេះដោយផ្ទាល់ ព្រមទាំងត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួម និងត្រូវស្នើសុំកម្លាំងសន្តិសុខបោះឆ្នោត ២ (ពីរ) នាក់ ឱ្យជួយការពារ និងជូនដំណើរ។

៨.២៣.៦ នៅពេលទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង “ខ” ដែលមានកញ្ចប់សុវត្ថិភាព “ក” ដាក់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើ មន្ត្រី លគធ.ខប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ជូនប្រធាន គ.ក.ប វិញ ១ (មួយ) ច្បាប់។

៨.២៣.៧ បន្ទាប់ពីបានទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង “ខ” មានកញ្ចប់សុវត្ថិភាព “ក” ដាក់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) នៅការិយាល័យបោះឆ្នោតដែលមានករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នភ្លាម គធ.ខប ត្រូវធ្វើការកត់ចំណាំ និងរក្សាទុកដោយឡែកនៅកន្លែងមានសុវត្ថិភាព និងត្រូវជូនដំណឹងដល់សមាសភាព គ.ក.ប ព្រមទាំងភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធឱ្យមកកាន់ លគធ.ខប នៅវេលាម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកនៃថ្ងៃបន្ទាប់ ដើម្បីរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតរបស់ខ្លួន។

៨.២៣.៧.១ គធ.ឧប អាចចាត់ចែងសមាសភាព គ.ក.ប ផ្សេង ឬមន្ត្រី លគធ.ឧប ឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ប្រសិនបើសមាសភាព គ.ក.ប ពាក់ព័ន្ធអវត្តមាន។

៨.២៣.៧.២ សមាសភាព គ.ក.ប ដែលត្រូវបំពេញភារកិច្ចរាប់សន្លឹកឆ្នោតនៅ លគធ.ឧប ឬនៅទីតាំងណាមួយដែលមានសុវត្ថិភាព ត្រូវតែបានទទួលប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ និងម្ហូបអាហារក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនោះ។

៨.២៣.៨ តាមពេលវេលាដូចមានចែងក្នុងចំណុច ៨.២៣.៧ ខាងលើនេះ គធ.ឧប ត្រូវចាត់ចែងឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតដែលជួបករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នដូចមានចែងក្នុងប្រការ ៨.២៣ ខាងលើនេះ នៅ លគធ.ឧប ឬនៅទីតាំងណាមួយដែលមានសុវត្ថិភាព។

៨.២៣.៩ នៅពេលសមាសភាព គ.ក.រ ឬមន្ត្រីបោះឆ្នោតដែលទទួលភារកិច្ចរាប់សន្លឹកឆ្នោតមានវត្តមាននៅក្នុងបន្ទប់រាប់សន្លឹកឆ្នោតហើយ មន្ត្រី លគធ.ឧប ត្រូវប្រគល់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង “ខ” ដែលមានកញ្ចប់សុវត្ថិភាព “ក” ដាក់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀតឱ្យទៅប្រធាន គ.ក.រ ដើម្បីអនុវត្តការរាប់សន្លឹកឆ្នោត។ ប្រធាន គ.ក.រ ត្រូវ៖

៨.២៣.៩.១ ពិនិត្យឱ្យប្រាកដថា ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង “ខ” ដែលបានទទួល ពុំត្រូវបានគេរុះរើឡើយ។

៨.២៣.៩.២ កាត់ផ្តាច់សោឃ្លុំស្បោង “ខ” និងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតខាងក្នុង ដោយផ្ទៀងផ្ទាត់ទៅនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧)។

៨.២៣.១០ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតខាងលើ រាល់បទប្បញ្ញត្តិដូចមានចែងក្នុងប្រការ ៨.១៨ រហូតដល់ប្រការ ៨.២០ និងប្រការ ៨.២២ ខាងលើនេះ ត្រូវតែបានអនុវត្ត។ ដោយសារការរាប់សន្លឹកឆ្នោតនេះ ត្រូវបានធ្វើនៅ លគធ.ឧប នីតិវិធីពាក់ព័ន្ធមួយចំនួនត្រូវបានកំណត់ឱ្យអនុវត្តដោយឡែក ដែលក្នុងនោះប្រធាន គ.ក.រ ត្រូវ៖

៨.២៣.១០.១ ទទួលខុសត្រូវនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) មួយ ១ (មួយ) ច្បាប់ ទៅបិទផ្សាយនៅខាងមុខទីតាំងការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

៨.២៣.១០.២ បង្គាប់សមាជិកទី២ ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ នៅខាងមុខ លគធ.ខប ព្រមទាំងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន។

៨.២៣.១០.៣ ធានាថា បន្ទាប់ពីការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ រាល់សម្ភារ ឯកសារបោះឆ្នោតត្រូវបានវេចខ្ចប់ក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រ និងដាក់ក្នុងកញ្ចប់សុវត្ថិភាព "ក" រួចបិទភ្ជិតដោយការសុវត្ថិភាពបម្រុងស្រាប់។ បន្ទាប់មកស្បោង "ខ" ត្រូវបានវេចខ្ចប់ជាថ្មី ដោយដាក់សម្ភារ ឯកសារបោះឆ្នោតតាមលំនាំដូចមានចែងក្នុងចំណុច ៨.២០.៦ នៃ ប.ន.ព.ស នេះ រួចចងមាត់ស្បោងឡើងវិញ ហើយត្រូវប្រគល់ជូន គធ.ខប ដោយផ្ទាល់នៅបន្ទប់រាប់សន្លឹកឆ្នោតនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។

៨.២៣.១០.៤ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវបានបំពេញ និងប្រើប្រាស់ក្នុងការប្រគល់ ទទួល ស្របតាមការកំណត់របស់ គ.ជ.ប។

៨.២៣.១១ នៅពេលបានទទួលស្បោង "ខ" ដូចមានចែងក្នុងចំណុច ៨.២៣.១០.៣ ខាងលើនេះ គធ.ខប ត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៨.២២.៤ និងចំណុច ៨.២២.៥ ខាងលើនេះ។

## ការដាក់ពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅ គធ.ខប

### ប្រការ៨.២៤.-

ភ្នាក់ងារគណបក្សនយោបាយដែលមិនសុខចិត្តនឹងការសម្រេចរបស់ គ.ក.ប/គ.ក.រ ពាក់ព័ន្ធនឹងការជំទាស់ ឬការតវ៉ា ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយនៅក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៦.២៣ នៃ ប.ន.ព.ស នេះ ឬ/និងក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ៨.១៨.៧ និងប្រការ ៨.២៣ នៃ ប.ន.ព.ស នេះ អាចបំពេញបែបបទសម្រាប់ប្ដឹងទៅ គធ.ខប។

ការដាក់ពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត ត្រូវធ្វើឡើងជាបន្ទាន់ស្របពេលនឹងការបញ្ជូនស្បោង "ខ" និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅ គធ.ខប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។ ប្រសិនបើនៅក្នុងរយៈពេល

កំណត់ខាងលើនេះ គជ.ខប មិនបានទទួលពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថា គ្មានការប្ដឹងតវ៉ា ឬប្ដឹងជំទាស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

៨.២៥.១ ភ្នាក់ងារគណបក្សនយោបាយដែលមានបំណងប្ដឹងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ដិតមេដៃលើពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្ដល់ព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

៨.២៥.១.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង។

៨.២៥.១.២ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត។

៨.២៥.១.៣ ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី។

៨.២៥.១.៤ កម្មវត្ថុនៃពាក្យបណ្ដឹង។

៨.២៥.១.៥ បើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ព.ស ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬប្រការនៃ ប.ន.ព.ស ដែលត្រូវបានរំលោភ។

៨.២៥.១.៦ មនុស្សដែលពាក់ព័ន្ធក្នុងភាពមិនប្រក្រតី។

៨.២៥.១.៧ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)។

៨.២៥.១.៨ សេចក្ដីអះអាងគាំទ្រ ឬភស្ដុតាងផ្សេងៗទៀត (ប្រសិនបើមាន)។

៨.២៥.១.៩ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង (ប្រសិនបើមាន)។

៨.២៥.២ នៅពេលបានទទួលពាក្យបណ្ដឹង សមាជិក គជ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង ទី២ កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់យ៉ាងយូរម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

៨.២៥.៣ បន្ទាប់មកសមាជិក គជ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់រួចឱ្យអ្នកប្ដឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខា សមាជិក គជ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។

៨.២៥.៤ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹងនិងកំណត់ហេតុសាកសួរ ហើយឃើញថា៖

៨.២៤.៤.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់ដូចមានចែងក្នុងប្រការ ៨.២៤ ខាងលើនេះ ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធ លើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់ពីមូលហេតុ ហើយ ចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាងវិញ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងប្រាប់អ្នកប្តឹង ឬតំណាងថា ពាក្យបណ្តឹងរបស់គាត់ ដែលបានដាក់នៅក្រោយពេលកំណត់ គធ.ខប មិនអាច ទទួលយកមកដោះស្រាយបានទេ។

៨.២៤.៤.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុង ចំណុច ៨.២៤.១ ខាងលើនេះ សមាជិក គធ.ខប ដែលជា ប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុច ខ្វះខាតមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវ ចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែល បានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើ ពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់ពីមូលហេតុ ហើយចុះ ហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួច ផ្ញើជូនអ្នកប្តឹង ឬតំណាង វិញ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.២៤.៤.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ដូចមានចែងក្នុងប្រការ ៨.២៤ ខាងលើនេះ និងមានបញ្ជាក់ព័ត៌មានចាំបាច់ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និង សន្តិសុខបោះឆ្នោត ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយ ចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្តឹង គ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាងវិញ ១(មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅ លគធ.ខប ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់ សម្រាប់ គធ.ខប ប្រើក្នុងពេលប្រជុំ

សម្រេច។ សមាជិក គជ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវជម្រាបអ្នកប្តឹងថា គជ.ខបនឹងធ្វើការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ឡើងវិញព្រមទាំង ប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធក្នុងអំឡុងពេលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យ បោះឆ្នោតនានាក្នុងរាជធានី ខេត្ត។

៨.២៩.៥ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់មានភស្តុតាងបញ្ជាក់អាចឱ្យជឿថា មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គជ.ខប ត្រូវ៖

៨.២៩.៥.១ ចាត់ចែងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹង។

៨.២៩.៥.២ បើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតដូចមានចែងក្នុងប្រការ ៨.២៩ នៃ ប.ន.ព.ស នេះ។

៨.២៩.៥.៣ អនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ចូលរួមសង្កេតមើលក្នុងការអនុវត្តនីតិវិធីចំណុច ៨.២៩.៥.១ និងចំណុច ៨.២៩.៥.២ ខាងលើនេះ។

៨.២៩.៦ ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញដូចមានចែងក្នុងចំណុច ៨.២៩.៥.១ និងចំណុច ៨.២៩.៥.២ ខាងលើនេះ គជ.ខប មិនឃើញមានភស្តុតាងបញ្ជាក់ថាមានកំហុសណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គជ.ខប ត្រូវប្រជុំសម្រេចបដិសេធលើពាក្យបណ្តឹង ប្រធាន គជ.ខប ត្រូវ៖

៨.២៩.៦.១ ចាត់មន្ត្រី លគជ.ខប ឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ ហើយត្រូវចុះហត្ថលេខាឈ្មោះ ដោយមន្ត្រី លគជ.ខប និងប្រធាន គជ.ខប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គជ.ខប។

៨.២៤.៦.២ ប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.២៤.៦.៣ ជម្រាបអ្នកប្តឹង ឬតំណាងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ឃប ទៅ គ.ជ.ប ក្នុងរយៈពេល ២ (ពីរ) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

៨.២៤.៦.៤ ប្រគល់ជូនអ្នកប្តឹង ឬតំណាងនូវពាក្យបណ្តឹង (ទ.១២០២) សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ចំនួន ៣ (បី) ច្បាប់ (ប្រសិនបើគាត់ស្នើសុំ)។

៨.២៤.៧ ប្រសិនបើក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញដូចមានចែងក្នុងចំណុច ៨.២៤.៥.១ និងចំណុច ៨.២៤.៥.២ ខាងលើនេះ គធ.ឃប បានរកឃើញភស្តុតាងបញ្ជាក់ថា មានកំហុសណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ គធ.ឃប ត្រូវប្រជុំសម្រេច យល់ព្រមតាមពាក្យបណ្តឹង ប្រធាន គធ.ឃប ត្រូវ៖

៨.២៤.៧.១ ចាត់មន្ត្រី លគធ.ឃប ឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ (បី) ច្បាប់ ហើយត្រូវចុះហត្ថលេខា ឈ្មោះ ដោយមន្ត្រី លគធ.ឃប និងប្រធាន គធ.ឃប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គធ.ឃប។

៨.២៤.៧.២ ប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងជម្រាបអ្នកប្តឹង ឬតំណាងថា គធ.ឃប នឹងលើកសំណើសុំព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ ព្រមទាំងវេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធដោយឡែក បញ្ជូនទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង បន្ទាប់ពី គធ.ឃប សម្រេចយល់ព្រមតាមពាក្យបណ្តឹង ដើម្បី គ.ជ.ប ពិនិត្យ សម្រេច។

## ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីនៅ ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត នៅ គធ.ខប

**ប្រការ៨.២៥.-**

នីតិវិធីដូចបានចែងក្នុងប្រការ ៨.២៤ ខាងលើនេះ ក៏មានសុពលភាពផងដែរសម្រាប់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ដែលបានកើតមានឡើងនៅក្នុងតំបន់បោះឆ្នោតណាមួយនៅ ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត។

៨.២៥.១ អំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដូចបញ្ជាក់ក្នុងប្រការ ៨.២៥ ខាងលើនេះ ត្រូវបានកំណត់ជាក់ស្តែងតាមរយៈកិច្ចសង្កេតការណ៍ ឬការរាយការណ៍ ឬការចោទប្រកាន់ដោយមានភស្តុតាងគ្រប់គ្រាន់ ដែលរួមមានប្រភេទបទរំលោភដូចខាងក្រោម៖

៨.២៥.១.១ ការប្រើកម្លាំងដកហូតឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតពីអ្នកបោះឆ្នោត។

៨.២៥.១.២ ការប្រើកម្លាំង ឬអំពើហិង្សា ឬការគំរាមកំហែង ដើម្បីរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

៨.២៥.១.៣ ការគាបសង្កត់ ឬការគំរាមកំហែង ឬបង្ខំអ្នកបោះឆ្នោតឱ្យស្បថថានឹងបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ។

៨.២៥.១.៤ ការធ្វើឱ្យខូចរបៀបរៀបរយ ឬការអុកឡុករំខានកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតមិនឱ្យដំណើរការបាន។

៨.២៥.១.៥ ការញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង ឬអំពើហិង្សាទៅលើបេក្ខជននៃគណបក្សនយោបាយណាមួយ។

៨.២៥.១.៦ ការប្រើកម្លាំង ឬអំពើហិង្សា ឬការបំភិតបំភ័យដែលបង្កឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ភាពច្របូកច្របល់ និងការបាត់ទំនុកចិត្តលើការបោះឆ្នោត ឬលើការសម្ងាត់នៃការបោះឆ្នោត។

៨.២៥.១.៧ ការបោកបញ្ឆោត ឬការលួងលោមទិញសន្លឹកឆ្នោតដោយសម្ភារ ឬប្រាក់កាស។

៨.២៥.២ ការបំភិតបំភ័យ ការគាបសង្កត់ ការគំរាមកំហែង ការប្រើកម្លាំង ឬអំពើហិង្សា ការរំលោភបំពាន ឬការគំរាមកំហែងដោយហិង្សា ត្រូវបានកំណត់តាមរយៈ

ការស្តែងឡើងតាមគ្រប់មធ្យោបាយដោយពាក្យសម្តី ជាលាយលក្ខណ៍អក្សរ ឬដោយរូបភាព ឬដោយវីដេអូ ឬដោយកាយវិការដូចខាងក្រោម៖

៨.២៥.២.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬដោយការសរសេរជាលាយលក្ខណ៍អក្សរ ឬរូបភាព ឬវីដេអូ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ។

៨.២៥.២.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យថានឹងធ្វើទារុណកម្ម។

៨.២៥.២.៣ ការវាយតប់បន្តិចបន្តួច ឬធ្វន់ធ្ងរលើបុគ្គលណាម្នាក់។

៨.២៥.២.៤ ការរំលោភដោយពាក្យសម្តីថា នឹងធ្វើទុក្ខទោសដល់រាងកាយ។

៨.២៥.២.៥ ការបង្ហាញ ឬការប្រើប្រាស់នូវគ្រឿងសព្វាវុធ ឬវត្ថុដែលមានគ្រោះថ្នាក់ផ្សេងៗ ដើម្បីបំភិតបំភ័យ។

៨.២៥.២.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលយោងទៅលើព្រឹត្តការណ៍ពីអតីតកាលដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់។

៨.២៥.២.៧ ការបាញ់ដោយកាំភ្លើងបង្ហើរពីលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ។

៨.២៥.២.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ដែលអាចធ្វើឱ្យជននោះ មានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន។

៨.២៥.២.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះ មានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសារគាត់។

៨.២៥.២.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ឬការដកហូតមុខតំណែង ការដកហូតដីធ្លី ផ្ទះសម្បែង ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត។

## ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

### ប្រការ៨.២៦.-

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន តាមប្រមាណវិធីដោយដៃ និងតាមកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោតកំណត់ដោយ គ.ជ.ប ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យ សម្រេច។

៨.២៦.១ មជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ត្រូវមានទីតាំងនៅ លគធ.ខប ឬនៅអគារមួយផ្សេង ឬផ្នែកណាមួយដែលមានទំហំទូលាយល្មមអាចរៀបចំមានកន្លែងបម្រុងដូចខាងក្រោម៖

៨.២៦.១.១ កន្លែងសម្រាប់ទទួលស្បោង “ខ” និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ពីគ្រប់ការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្តពាក់ព័ន្ធ។

៨.២៦.១.២ បន្ទប់ធំទូលាយមួយ ដែលមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងពេលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៨.២៦.១.៣ បន្ទប់ស្អាតតូចមួយ (ប្រសិនបើមាន) សម្រាប់ដាក់គ្រឿងបរិក្ខារកុំព្យូទ័រដែលមានភ្ជាប់អ៊ីនធឺណិត និងកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោតដែលរៀបចំដោយ គ.ជ.ប។

៨.២៦.២ គធ.ខប ត្រូវធានាអំពីសន្តិសុខ សុវត្ថិភាពនៃអគារមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន។ ទ្វារ និងបង្អួចទាំងអស់ត្រូវបិទ និងចាក់សោយ៉ាងត្រឹមត្រូវ នៅពេលផុតម៉ោងធ្វើការងារ។ នៅក្នុងដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត គធ.ខប ត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ទទួលបន្ទុកសណ្ដាប់ធ្នាប់ក្នុងមជ្ឈមណ្ឌល និងមានមន្ត្រីម្នាក់ប្រចាំការនៅមាត់ទ្វារចេញចូលដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន គធ.ខប។

៨.២៦.៣ គធ.ខប ត្រូវតែរៀបចំឱ្យមានបរិវេណសន្តិសុខមួយនៅអគារមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ដោយនៅបរិវេណខាងក្រៅ ត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីចាត់កម្លាំងការពារ និងនៅបរិវេណខាងក្នុងត្រូវរៀបចំចាត់កម្លាំងសន្តិសុខផ្ទាល់របស់ គធ.ខប ដើម្បីការពារ។

៨.២៦.៤ គធ.ខប ត្រូវទទួលបន្ទុកគ្រប់គ្រងការចេញចូលមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប និងមានសិទ្ធិអំណាចចេញចូលមជ្ឈមណ្ឌលនេះ។ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងបរិវេណសន្តិសុខ និងក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គធ.ខប។

៨.២៦.៥ ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងមជ្ឈមណ្ឌលនេះនូវជនទាំងឡាយដូចខាងក្រោម៖

៨.២៦.៥.១ ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ដែលបានទទួលការចាត់តាំង។

៨.២៦.៥.២ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្ដឹង ឬតំណាង។

៨.២៦.៥.៣ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន គធ.ខប ឬតំណាង គធ.ខប សំណូមពរក្នុងករណីចាំបាច់។

៨.២៦.៥.៤ មន្ត្រីនៃ គ.ជ.ប ដែលកំពុងបំពេញភារកិច្ចស៊ើបអង្កេតអំពើល្មើសដែលគេបានចោទប្រកាន់ចំពោះសមាជិក ឬមន្ត្រីនៃ គធ.ខប ដែលចាត់ឱ្យជួយក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។

៨.២៦.៦ សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងមជ្ឈមណ្ឌលត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប៖

៨.២៦.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.២៦.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពល ធ្វើឱ្យមន្ត្រីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ឬ/និងមន្ត្រីបូកសរុបលទ្ធផលនៃ គធ.ខប បំពេញចិត្ត ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៨.២៦.៧ គជ.ខប ត្រូវចាត់តាំងក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គជ.ខប ចំនួន ១ (មួយ) ក្រុម។

៨.២៦.៧.១ សមាសភាពនៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គជ.ខប ត្រូវចាត់តាំងពីក្នុងចំណោមសមាសភាពអនុគណៈកម្មការបច្ចេកទេសនៃ គជ.ខប និងមន្ត្រី លគជ.ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ ចំពោះមន្ត្រីណាដែលពេលនោះមិនសូវមានការងារមមាញឹក។

៨.២៦.៧.២ សមាសភាពក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គជ.ខប ត្រូវមាន ៤ (បួន) រូប ដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលជាសមាជិកអនុគណៈកម្មការបច្ចេកទេសនៃ គជ.ខប ឬជាមន្ត្រី លគជ.ខប និងមានអនុប្រធាន ១(មួយ) រូប លេខាធិការ ១ (មួយ) រូប និងជំនួយការ ១ (មួយ) រូប។

៨.២៦.៧.៣ ក្រុមនេះ ត្រូវរាយការណ៍ជាប្រចាំជូន គជ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស។

៨.២៦.៨ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គជ.ខប មានភារកិច្ចត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ទៅតាមករណីដោយឡែកពីគ្នា និងតាមការណែនាំរបស់ គជ.ខប ដោយផ្អែកលើៈ

៨.២៦.៨.១ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គជ.ខប។

៨.២៦.៨.២ ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គជ.ខប ដូចមានចែងក្នុងប្រការ ៨.២៤ និងប្រការ ៨.២៥ ខាងលើនេះ (ប្រសិនបើមាន)។

៨.២៦.៨.៣ លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ គជ.ខប (ប្រសិនបើ គជ.ខប សម្រេចឱ្យធ្វើដូច្នេះ)។

៨.២៦.៩ ផ្អែកតាមការណែនាំរបស់ គជ.ខប ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គជ.ខប ត្រូវអនុវត្តការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតចំណុះ

រាជធានី ខេត្ត ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់ និងតាមលំដាប់លំដោយនៃករណីជាក់ស្តែងនីមួយៗដូចខាងក្រោម៖

៨.២៦.៩.១ ករណីការិយាល័យបោះឆ្នោតណាដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ.ខប។

៨.២៦.៩.២ ករណីការិយាល័យបោះឆ្នោតណាដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប។

៨.២៦.១០ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ បរិក្ខារកុំព្យូទ័រ និងសម្ភារចាំបាច់ផ្សេងទៀតដល់ គធ.ខប សម្រាប់ប្រើប្រាស់ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៨.២៦.១០.១ អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវផ្តល់ការគាំទ្រដល់ គធ.ខប អំពីការអនុវត្តកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត និងការប្រើប្រាស់អ៊ីនធឺណិត។

៨.២៦.១០.២ គធ.ខប ត្រូវប្រើប្រាស់អ៊ីនធឺណិតសម្រាប់តែការបញ្ជូនសារលិខិតស្នាម ព័ត៌មានបន្ទាន់ និងទិន្នន័យបច្ចេកទេសក្នុងការបោះឆ្នោតប៉ុណ្ណោះ។

## កិច្ចប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

**ប្រការ៨.២៧.-**

បន្ទាប់ពីបានទទួលស្បោង "ខ" ដែលមានកញ្ចប់សុវត្ថិភាព "ក" ដាក់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធពីគ្រប់ការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត ដូចមានចែងក្នុងចំណុច ៨.២២.៤ និងចំណុច ៨.២៣.១០.៣ នៃ ប.ន.ព.ស នេះ គធ.ខប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្តបញ្ចូលគ្នាឱ្យរួចរាល់ឆាប់រហ័សតាមដែលអាចធ្វើបាន។

គធ.ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ ចុះហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប ជាផ្លូវការ ហើយកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ត្រូវបានបិទផ្សាយជាសាធារណៈ នាពេលល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

៨.២៧.១ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតចំណុះរាជធានី ខេត្ត។

៨.២៧.១.១ គណបក្សនយោបាយនីមួយៗប្រចាំការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្ត ឬសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោតនីមួយៗត្រូវជ្រើសតាំងឱ្យមានតំណាងរបស់ខ្លួនម្នាក់ និងតំណាងបម្រុងម្នាក់សម្រាប់ចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។

៨.២៧.១.២ តំណាងគណបក្សនយោបាយ ឬសមាគម និងអង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះឆ្នោតនីមួយៗដែលត្រូវចូលរួមសង្កេតមើលដំណើរការនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តខាងលើ អាចផ្លាស់ប្តូរភ្នាក់ងារបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួនបាន។

៨.២៧.១.៣ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត។

៨.២៧.១.៤ តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចថតយករូបភាពនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ។

៨.២៧.២ កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតចំពោះការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្ត ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនត្រូវឈប់សម្រាកឡើយ។ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត ដោយរួម

បញ្ចូលទាំងលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតដែលត្រូវបានរាប់នៅ លគឃ.ខប ឬទីតាំងសុវត្ថិភាពណាមួយ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន រួមនឹងការិយាល័យបោះឆ្នោតដែលត្រូវបាន គឃ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយផ្អែកលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទៅនឹងភាពមិនប្រក្រតីដែលកើតមានឡើង (ប្រសិនបើមាន)។

៨.២៧.៣ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គឃ.ខប ត្រូវបើកកិច្ចប្រតិបត្តិការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ចំណុះរាជធានី ខេត្ត នៅបន្ទប់ធំទូលាយមួយ។ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវរៀបចំបន្ទប់តាមលំនាំគំរូប្លង់ការិយាល័យរាប់សន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ៨.១៨.១.១ នៃ ប.ន.ព.ស នេះ និងត្រូវមានសម្ភារ ឯកសារបោះឆ្នោត និងទម្រង់បែបបទគ្រប់គ្រាន់សម្រាប់បំពេញការងារ។

៨.២៧.៣.១ ប្រធានក្រុមត្រូវត្រៀមនៅក្បែរខ្លួនគាត់នូវពាក្យបណ្តឹង (ទ.១២០២) សម្រាប់ប្រគល់ជូនតំណាងគណបក្សនយោបាយដើម្បីបំពេញពាក្យបណ្តឹង ប្រសិនបើមានការស្នើសុំ និងរាល់ទម្រង់បែបបទចាំបាច់ផ្សេងទៀត និងម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៨.២៧.៣.២ ប្រធានក្រុមត្រូវចាត់ចែងឱ្យលេខាធិការរៀបចំដំឡើងកុំព្យូទ័រ និងភ្ជាប់អ៊ីនធឺណិត ដើម្បីទាញយកទិន្នន័យ និងរូបភាពកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីសេវ្វបករណ៍ (Server) គ.ជ.ប ដែលបានបញ្ចូល និងបញ្ជូនទៅ គ.ជ.ប សម្រាប់ផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត។

**ប្រការ៨.២៨.-**

ក្នុងករណីការិយាល័យបោះឆ្នោតណាគ្មានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ ឬមានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ដែលបានដាក់ក្រោយពេលវេលាកំណត់ ឬមានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ ដែលគ្មានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីធ្ងន់ធ្ងរនាំឱ្យ

ប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយទេនោះ គធ.ខប មិនអាចបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតបានឡើយ។ ក្នុងករណីនេះ គធ.ខប ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ឱ្យត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ចំណុះរាជធានី ខេត្តបញ្ចូលគ្នា។

៨.២៨.១ ក្នុងដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ចំពោះករណីដូចមានចែងក្នុងប្រការ ៨.២៨ ខាងលើនេះ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប គ្រាន់តែត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងគណនាដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ប៉ុណ្ណោះ។ ប្រធានក្រុមត្រូវ៖

៨.២៨.១.១ បង្គាប់ជំនួយការឱ្យនាំយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតម្តងមួយៗពីកន្លែងរក្សាទុក មកដាក់នៅលើតុចំមុខប្រធានក្រុម។

៨.២៨.១.២ បង្គាប់ឱ្យលេខាធិការបញ្ជាប់ចូល (Login) ក្នុងកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត ដើម្បីទាញយកទិន្នន័យពីសេវ្របករណ៍ (Server) គ.ជ.ប សម្រាប់បង្ហាញលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗលើឧបទស្សន៍កុំព្យូទ័រ (Monitor) ជូនភាគីពាក់ព័ន្ធដែលមានវត្តមានបានមើលឃើញទាំងអស់គ្នា។

៨.២៨.១.៣ បង្គាប់ឱ្យលេខាធិការបោះពុម្ពកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីប្រព័ន្ធកុំព្យូទ័រ ១ (មួយ) ច្បាប់ រួចបោះត្រា គធ.ខប រួចប្រគល់ឱ្យជំនួយការ យកទៅបិទផ្សាយនៅខាងមុខ លគធ.ខប។

៨.២៨.១.៤ ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបតួលេខដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) នៃការិយាល័យបោះឆ្នោតនីមួយៗ រួចធ្វើការប្រៀបធៀបលទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធដែលមានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដើម្បីឱ្យដឹង

ប្រាកដថា លទ្ធផលដែលបានកត់ត្រាក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុងការគណនាលេខណាមួយ។

៨.២៨.១.៥ សម្រេចកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ប្រសិនបើបានរកឃើញថា គ.ក.រ មានកំហុសក្នុងការគណនាលេខ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវគូសរង្វង់លើតួលេខដែលខុស តែមិនត្រូវធ្វើឱ្យបាត់លក្ខណៈសម្គាល់នៃតួលេខដើមនោះទេ រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ខ្លួនផង។ ករណីនេះ ប្រធានក្រុមត្រូវចាត់ឱ្យលេខាធិការកត់ត្រាបញ្ហានេះទៅក្នុងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១)ក្នុងប្រព័ន្ធកុំព្យូទ័រផង។តំណាងគណបក្សនយោបាយមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ក្នុងករណីមិនពេញចិត្តនឹងការកែតម្រូវរបស់ប្រធានក្រុម។

៨.២៨.១.៦ ចាត់ឱ្យលេខាធិការស្តែនទម្រង់បែបបទទាំងឡាយណាដែលមានការកែតម្រូវ។

៨.២៨.១.៧ ណែនាំលេខាធិការឱ្យកែតម្រូវទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រដែលបានទាញយកពីសេវ្របករណ៍ (Server) គ.ជ.ប ក្នុងករណីមានការកែតម្រូវទិន្នន័យនៃទម្រង់បែបបទណាមួយដូចមានចែងក្នុងចំណុច ៨.២៨.១.៥ ខាងលើនេះ។

៨.២៨.១.៨ ណែនាំលេខាធិការឱ្យផ្ទេរទិន្នន័យពីកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) បញ្ចូលទៅតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០)។

៨.២៨.១.៩ ធានាថារាល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតដែលបានប្រើប្រាស់ក្នុងដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង

បូកសរុបលទ្ធផលខាងលើនេះរួច ត្រូវតែបានដាក់ទៅក្នុងស្រោមសំបុត្រដែលមានកាខ្នង "កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប" ដើម្បីត្រៀមផ្ញើជូន គ.ជ.ប និងបោះពុម្ព ១ (មួយ) មុខ ១ (មួយ) ច្បាប់ ទុកជាឯកសាររបស់ គធ.ខប។

៨.២៨.២ ប្រធានក្រុមត្រូវធានាថា នីតិវិធីទាំងឡាយដូចមានចែងក្នុងចំណុច ៨.២៨.១ ខាងលើនេះ ត្រូវតែបានអនុវត្តដូចគ្នាសម្រាប់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) របស់ការិយាល័យបោះឆ្នោតម្តងមួយៗ រហូតដល់អស់ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្ត។

៨.២៨.៣ ក្រោយពីបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្តរួចរាល់ហើយ ប្រធានក្រុមត្រូវចាត់ឱ្យលេខាធិការបោះពុម្ពតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ២ (ពីរ) ច្បាប់ បន្ទាប់មកប្រគល់ជូនអនុប្រធានក្រុម លេខាធិការ និងជំនួយការដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់បន្ថែមដោយប្រើប្រមាណវិធីដោយដៃផង និងប្រើម៉ាស៊ីនគិតលេខផង។ តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ត្រូវតែបានពិនិត្យផ្ទៀងផ្ទាត់ឡើងវិញឱ្យបានត្រឹមត្រូវ និងបានចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ហើយប្រធានក្រុមត្រូវ៖

៨.២៨.៣.១ ចាត់ចែងលេខាធិការផ្ទេរទិន្នន័យលទ្ធផលពីតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ទៅក្នុងកំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៩)។

៨.២៨.៣.២ ចាត់ចែងឱ្យលេខាធិការបោះពុម្ពកំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ចំនួន

៣ (បី) ច្បាប់ និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៥) ចំនួន ៣ (បី) ច្បាប់។

៨.២៨.៣.៣ ផ្ទៀងផ្ទាត់តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត រវាងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០)។

៨.២៨.៣.៤ ផ្ទៀងផ្ទាត់តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត រវាងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៥) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០)។

៨.២៨.៣.៥ ធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ២ (ពីរ) ច្បាប់ ដែលបានបោះពុម្ព និងផ្ទៀងផ្ទាត់រួចត្រូវបានចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៨.២៨.៣.៦ ធានាថា កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ចំនួន ៣ (បី) ច្បាប់ ដែលបានបោះពុម្ព និងផ្ទៀងផ្ទាត់រួច ត្រូវបានចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៨.២៨.៣.៧ ធានាថា ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៥) ចំនួន ២ (ពីរ) ច្បាប់ ដែលបានបោះពុម្ព និងផ្ទៀងផ្ទាត់រួច ត្រូវបានចុះហត្ថលេខាសង្ខេបដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

៨.២៨.៣.៨ ធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ២ (ពីរ) ច្បាប់ ដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ចំនួន ៣ (បី) ច្បាប់ ដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៥) ចំនួន ៣ (បី) ច្បាប់

ដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវ ត្រូវបានដាក់ភ្ជាប់ទៅនឹងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដាក់ជូន គជ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដើម្បីពិនិត្យ សម្រេច។

៨.២៨.៤ ប្រធាន គជ.ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ដែលបានចុះហត្ថលេខា និងបោះត្រា គជ.ខប រួចត្រូវបានស្កេនបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ប្រការ៨.២៩.-**

ក្នុងករណីការិយាល័យបោះឆ្នោតណាមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែលត្រូវបានដាក់ក្នុងអំឡុងពេលដូចមានចែងក្នុងប្រការ ៨.២៤ និងប្រការ ៨.២៥ នៃ ប.ន.ព.ស នេះ គជ.ខប ក៏ត្រូវធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ចំណុះរាជធានី ខេត្តបញ្ចូលគ្នាជាលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានីខេត្តផងដែរ ដោយត្រូវអនុវត្តតាមនីតិវិធីចាប់ពីចំណុច ៨.២៨.១ រហូតដល់ចំណុច ៨.២៨.៣ ខាងលើនេះ។

៨.២៩.១ ប្រសិនបើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់មានភស្ដុតាងបញ្ជាក់ថាមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន គជ.ខប អាចបើកកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។ ក្នុងករណីនេះ នៅពេលកំពុងអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៨.២៨.១ ខាងលើនេះ ប្រធានក្រុមត្រូវៈ

៨.២៩.១.១ បង្គាប់ជំនួយការឱ្យទៅនាំយកស្បោង “ខ” នៃការិយាល័យបោះឆ្នោតមានពាក្យបណ្ដឹងពាក់ព័ន្ធ មកដាក់នៅលើតុចំពីមុខប្រធានក្រុម។

៨.២៩.១.២ ស្រាយមាត់ស្បោង “ខ” នោះ ដកយកកញ្ចប់សុវត្ថិភាព “ក” មកដាក់នៅលើតុ។

៨.២៩.១.៣ បើកកញ្ចប់សុវត្ថិភាព “ក” រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុងមកដាក់ដោយឡែកពីគ្នានៅលើតុមុខគាត់។

៨.២៩.១.៤ ប្រគល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប ឱ្យទៅលេខាធិការសម្រាប់តាមដានពិនិត្យ និងប្រៀបធៀបទៅនឹងលទ្ធផលនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត។

៨.២៩.១.៥ បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់តាមនីតិវិធីដូចមានចែងក្នុងចំណុច ៨.២៩.២ ខាងក្រោមនេះ។

៨.២៩.២ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់ចំនួនហើយ ប្រធានក្រុមត្រូវចាត់ចែងឱ្យត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះ (តែមិនត្រូវផ្តល់សុពលភាពជាសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការឡើងវិញទេ) ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ និងបញ្ហាជារួមដូចខាងក្រោមៈ

៨.២៩.២.១ ពិនិត្យ ផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត។

៨.២៩.២.២ ពិនិត្យ ផ្ទៀងផ្ទាត់ត្រាសម្ងាត់ដែលប្រើសម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ។

៨.២៩.២.៣ ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតដែលបានមកបោះឆ្នោត។

៨.២៩.២.៤ ពិនិត្យ ផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោត ដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ។

៨.២៩.២.៥ រាប់ចំនួនសន្លឹកឆ្នោតខូច (ប្រសិនបើមាន)។

៨.២៩.២.៦ រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ។

៨.២៩.២.៧ ពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ។

៨.២៩.២.៨ ពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ។

៨.២៩.២.៩ ពិនិត្យមើលថា តើនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)

មានចុះអំពីភាពមិនប្រក្រតីដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតដែរឬទេ។

៨.២៩.២.១០ ពិនិត្យមើលថា តើនៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ភ្នាក់ងារគណបក្សនយោបាយបានចុះហត្ថលេខាជាសាក្សីដែរឬទេ។

៨.២៩.៣ បន្ទាប់ពីអនុវត្តការបើកកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតណាមួយ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតដូចមានចែងក្នុងចំណុច ៨.២៩.២ ខាងលើនេះរួចរាល់ហើយ ប្រធានក្រុមត្រូវចាត់ចែងអនុវត្តដូចខាងក្រោម៖

៨.២៩.៣.១ ធ្វើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គជ.ខប។ ក្នុងរបាយការណ៍នេះ ត្រូវតែមានលើកយោបល់ស្នើសុំ គជ.ខប ពិនិត្យ សម្រេច៖

- យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ
- កែតម្រូវតួលេខលទ្ធផល ក្នុងករណីមានកំហុសក្នុងការគណនា ឬ
- ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

៨.២៩.៣.២ ដាក់របាយការណ៍ដូចមានចែងក្នុងចំណុច ៨.២៩.៣.១ ខាងលើនេះ ចំនួន ១ (មួយ) ច្បាប់ ភ្ជាប់ទៅនឹងតារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារពាក់ព័ន្ធដែលក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គជ.ខប ត្រូវដាក់ជូន គជ.ខប តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដើម្បីពិនិត្យ សម្រេច។

៨.២៩.៣.៣ ដាក់សម្ភារ ឯកសារបោះឆ្នោតទៅក្នុងស្បោងប្លាស្ទិក និងស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ចប់ក្នុងកញ្ចប់សុវត្ថិភាព “ក” ឡើងវិញតាមលំនាំដើម ដូចមានចែងក្នុងចំណុច ៨.២០.២ នៃ ប.ន.ព.ស នេះ។

៨.២៩.៣.៤ វេចខ្ចប់ស្បោង "ខ" ឡើងវិញ ដោយមានតែកញ្ចប់សុវត្ថិភាព "ក" និងស្រោមសំបុត្រដាក់ត្រា គ.ក.ប រួចនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់វេចខ្ចប់ និងបញ្ជូនទៅ គ.ជ.ប។

៨.២៩.៤ ផ្អែកលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ដូចមានចែងក្នុងចំណុច ៨.២៩.៣.២ ខាងលើនេះ ព្រមទាំងផ្អែកលើពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ដែល គធ.ខប បានទទួល គធ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹងពាក់ព័ន្ធ ដោយត្រូវអនុវត្តតាមចំណុច ៨.២៩.៨ រហូតដល់ចំណុច ៨.២៩.១១ ខាងក្រោមនេះ។

៨.២៩.៥ ក្នុងករណីពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដូចមានចែងក្នុងចំណុច ៨.២៤.៤.៣ នៃ ប.ន.ព.ស នេះ ត្រូវបានដាក់នៅ គធ.ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប បានបញ្ចប់ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះដូចមានចែងក្នុងប្រការ ៨.២៩ ខាងលើនេះ គធ.ខប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់រួចហើយនោះ ដើម្បីប្រជុំសម្រេចលើពាក្យបណ្ដឹងពាក់ព័ន្ធ។

៨.២៩.៦ ក្នុងករណីពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដូចមានចែងក្នុងចំណុច ៨.២៤.៤.៣ នៃ ប.ន.ព.ស នេះ ត្រូវបានដាក់នៅ គធ.ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តពាក់ព័ន្ធនឹងពាក្យបណ្ដឹងដូចមានចែងក្នុងប្រការ ៨.២៩ ខាងលើនេះ គធ.ខប ត្រូវធានាថា រាល់នីតិវិធីដូចមានចែងក្នុងចំណុច ៨.២៩.១ រហូតដល់ចំណុច ៨.២៩.៤ ខាងលើនេះ ត្រូវតែបានអនុវត្តនៅមុនពេល គធ.ខប ប្រជុំសម្រេចលើពាក្យបណ្ដឹង។

៨.២៩.៧ ក្នុងករណីពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដូចមានចែងក្នុងចំណុច ៨.២៤.៤.៣ នៃ ប.ន.ព.ស នេះ ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតដែលមិនទាន់ត្រូវបានត្រួតពិនិត្យ គធ.ខប ត្រូវធានាថារាល់នីតិវិធីដូចមានចែងក្នុងចំណុច ៨.២៨.១ ចំណុច ៨.២៨.៤ និងចំណុច ៨.២៩.១ រហូតដល់ចំណុច ៨.២៩.៤ ខាងលើនេះ ត្រូវតែបានអនុវត្តនៅមុនពេល គធ.ខប ប្រជុំសម្រេចលើពាក្យបណ្ដឹង។

## ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់

៨.២៩.៨ ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គធ.ខប ត្រូវបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គធ.ខប។ ប្រធាន គធ.ខប ត្រូវៈ

៨.២៩.៨.១ ចារយល់ព្រមលើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃ គធ.ខប រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប ព្រមទាំងដាក់បង្ហាញចំពោះមុខអ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

៨.២៩.៨.២ ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងត្រូវបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលដាក់នៅ គធ.ខប ដោយបញ្ជាក់ច្បាស់ពីមូលហេតុ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រី លគធ.ខប និងប្រធាន គធ.ខប ចុះកាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប។

៨.២៩.៨.៣ ប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលើពាក្យបណ្តឹង ដោយយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.២៩.៨.៤ ជម្រាបអ្នកប្តឹង ឬតំណាងថា គាត់មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងការសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។

៨.២៩.៨.៥ ប្រគល់ពាក្យបណ្តឹង (ទ.១២០២) សម្រាប់បំពេញពាក្យបណ្តឹងចំនួន ៣ (បី) ច្បាប់ ជូនអ្នកប្តឹងឬតំណាងប្រសិនបើគាត់ស្នើសុំ។

៨.២៩.៨.៦ ប្រគល់រាល់ឯកសារដូចមានចែងក្នុងចំណុច ៨.២៩.៨.១ និងចំណុច ៨.២៩.៨.៣ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប រក្សាទុកជាឯកសារនៅ គធ.ខប។

៨.២៩.៩ ប្រសិនបើ គធ.ខប សម្រេចយល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ គធ.ខប ត្រូវចារយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែលបានដាក់នៅ គធ.ខប។ ក្នុងករណីនេះ ប្រធាន គធ.ខប ត្រូវ៖

៨.២៩.៩.១ ចារយល់ព្រមលើរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ដែលបានដាក់ជូន គធ.ខប ពិនិត្យ សម្រេចដូចមានចែងក្នុងចំណុច ៨.២៩.៣.១ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប ព្រមទាំងដាក់បង្ហាញនៅចំពោះមុខអ្នកប្ដឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

៨.២៩.៩.២ ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) យល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុ ហើយត្រូវចុះហត្ថលេខា ឈ្មោះ ដោយមន្ត្រី លគធ.ខប និងប្រធាន គធ.ខប ចុះកាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប។

៨.២៩.៩.៣ ប្រគល់សម្រង់សេចក្ដីសម្រេច (ទ.១២០៣) ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.២៩.៩.៤ ជម្រាបអ្នកប្ដឹង ឬតំណាងថា គធ.ខប យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោត។

៨.២៩.៩.៥ ប្រគល់រាល់ឯកសារដូចមានចែងក្នុងចំណុច ៨.២៩.៩.១ និងចំណុច ៨.២៩.៩.៣ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប រក្សាទុកជាឯកសារនៅ គធ.ខប។

៨.២៩.១០ ប្រសិនបើ គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ គធ.ខប ត្រូវយល់ព្រមតាមពាក្យបណ្ដឹង និងត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ។ ក្នុងករណីនេះ ប្រធាន គធ.ខប ត្រូវ៖

៨.២៩.១០.១ ចារយល់ព្រមលើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ដែលបានដាក់ជូន គធ.ខប ពិនិត្យ សម្រេចដូចមានចែងក្នុងចំណុច ៨.២៩.៣.១ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា គធ.ខប ព្រមទាំងដាក់បង្ហាញនៅចំពោះមុខអ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

៨.២៩.១០.២ ចាត់មន្ត្រី លគធ.ខប ឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដោយបញ្ជាក់ច្បាស់ពីមូលហេតុ ហើយត្រូវចុះហត្ថលេខា និងឈ្មោះដោយមន្ត្រី លគធ.ខប និងប្រធាន គធ.ខប ចុះកាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប។

៨.២៩.១០.៣ ប្រគល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.២៩.១០.៤ ប្រកាសថា លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តនោះ ត្រូវបានបដិសេធដោយ គធ.ខប ហើយសេចក្តីសម្រេចនេះស្ថិតក្រោមការត្រួតពិនិត្យឡើងវិញដោយ គ.ជ.ប។

៨.២៩.១០.៥ ធានាថា មន្ត្រី លគធ.ខប បានដាក់ទៅក្នុងស្រោមសំបុត្រដោយឡែកពីគ្នា សម្រាប់ផ្ញើជូន គ.ជ.ប នូវសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ១ (មួយ) ច្បាប់ ព្រមទាំងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផល ១ (មួយ) ច្បាប់។

៨.២៩.១០.៦ ប្រគល់រាល់ឯកសារដូចមានចែងក្នុងចំណុច ៨.២៩.១០.១ និងចំណុច ៨.២៩.១០.៣ ខាងលើនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប រក្សាទុកជាឯកសារនៅ គធ.ខប និងត្រៀមឯកសារនេះ ក្នុងមួយមុខ ១ (មួយ) ច្បាប់ សម្រាប់ផ្ញើជូន គ.ជ.ប។

៨.២៩.១១ ក្នុងករណី គធ.ខប សម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត នៅក្នុងការិយាល័យបោះឆ្នោតណាមួយ ប្រធាន គធ.ខប ត្រូវបញ្ជូនសម្រង់សេចក្ដីសម្រេច (ទ.១២០៣) យល់ព្រមតាមពាក្យបណ្ដឹង និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធជូន គ.ជ.ប មិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលចេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។ ប្រធាន គធ.ខប ត្រូវធានាថា សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ត្រូវបានវេចខ្ចប់ដូចខាងក្រោមសម្រាប់បញ្ជូនទៅ គ.ជ.ប។

៨.២៩.១១.១ ដាក់ទៅក្នុងស្រោមសំបុត្រធំមួយនូវរាល់ស្រោមសំបុត្រដាក់ឯកសារ និងទម្រង់បែបបទនានាដូចមានចែងក្នុងចំណុច ៨.២៩.១០.៦ ខាងលើនេះ ដែលត្រូវផ្ញើជូន គ.ជ.ប ហើយត្រូវសរសេរសម្គាល់ពីក្រៅថា "សេចក្ដីសម្រេចព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតលេខ..."។

៨.២៩.១១.២ ដាក់រាល់ស្បោង "ខ" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោង "ឃ" ទៅតាមចំនួនដែលអាចដាក់ឱ្យអស់ស្បោង "ខ" រួចចងភ្ជិត និងចាក់សោឃ្លុំ និងត្រូវសរសេរសម្គាល់ពីក្រៅស្បោង "ឃ" ថា "ព្យួរលទ្ធផលការិយាល័យបោះឆ្នោតលេខ..."។

៨.២៩.១១.៣ ចាត់ចែងបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយរាយមុខសម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងស្រោមសំបុត្រធំ និងក្នុងស្បោង "ឃ ព្យួរលទ្ធផល"។

៨.២៩.១១.៤ ដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្រធំដូចមានចែងក្នុងចំណុច ៨.២៩.១១.១ ខាងលើនេះ រួចកិបភ្ជាប់ ១ (មួយ) ច្បាប់ទៅនឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំនេះ និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលនៅ គ.ជ.ប។

## ការពិនិត្យ និងចុះហត្ថលេខាលើលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

**ប្រការ៨.៣០.-**

បន្ទាប់ពីបានត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរួចរាល់ហើយ ប្រធាន គធ.ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១)

និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ត្រូវតែបានចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងប្រធាន គធ.ខប កាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប រួចបញ្ជូនដោយវេចខ្ចប់អមជាមួយនូវសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

៨.៣០.១ តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ចំនួន ២ (ពីរ) ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវរួចហើយ ដូចបានបញ្ជាក់ក្នុងចំណុច ៨.២៨.៣.៥ ខាងលើនេះ ត្រូវចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងប្រធាន គធ.ខប កាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប រួចដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ខាងលើនេះ ដូចខាងក្រោម៖

៨.៣០.១.១ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់ក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្នងថា “តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត... ផ្ញើជូន គ.ជ.ប”។

៨.៣០.១.២ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣០.២ កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ចំនួន ៣ (បី) ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវរួចហើយ ដូចបានបញ្ជាក់ក្នុងចំណុច ៨.២៨.៣.៦ ខាងលើនេះ ត្រូវចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងប្រធាន គធ.ខប កាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប រួចដាក់បង្ហាញនៅចំពោះមុខតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ។

៨.៣០.២.១ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១)។

៨.៣០.២.២ ការមិនព្រមចុះហត្ថលេខាពីតំណាងគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនូវកំណត់ហេតុនេះបានទេ។

៨.៣០.៣ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ខាងលើនេះ ដូចខាងក្រោម៖

៨.៣០.៣.១ បិទផ្សាយនៅ លគធ.ខប ១ (មួយ) ច្បាប់ នៅពេលល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ដោយត្រូវធ្វើកំណត់ហេតុស្តីពីការបិទផ្សាយ ដែលមានបញ្ជាក់ពេលវេលា និងកាលបរិច្ឆេទនៃការបិទផ្សាយផង។

៨.៣០.៣.២ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់ក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្ទងថា "កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត... ផ្ញើជូន គ.ជ.ប" ដោយភ្ជាប់ទៅជាមួយនូវកំណត់ហេតុស្តីពីការបិទផ្សាយ ១ (មួយ) ច្បាប់ផង។

៨.៣០.៣.៣ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ជាមួយនឹងកំណត់ហេតុស្តីពីការបិទផ្សាយ ១ (មួយ) ច្បាប់។

៨.៣០.៤ ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ចំនួន ៣ (បី) ច្បាប់ ដែលបានបោះពុម្ព និងពិនិត្យត្រឹមត្រូវរួចហើយដូចបានបញ្ជាក់ក្នុងចំណុច ៨.២៨.៣.៧ ខាងលើនេះ ត្រូវចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងប្រធាន គធ.ខប កាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គធ.ខប រួចដាក់បង្ហាញចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ។

៨.៣០.៥ ប្រធាន គធ.ខប ត្រូវចាត់ចែង និងប្រើប្រាស់ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ដូចខាងក្រោម៖

៨.៣០.៥.១ បិទផ្សាយ ១ (មួយ) ច្បាប់ នៅ លគធ.ខប នៅពេលល្ងាចនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

៨.៣០.៥.២ ផ្ញើ ១ (មួយ) ច្បាប់ជូន គ.ជ.ប ដែលត្រូវដាក់ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ទងថា "ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត...ផ្ញើជូន គ.ជ.ប"។

៨.៣០.៥.៣ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣០.៦ តំណាងគណបក្សនយោបាយឈរឈ្មោះក្នុងភូមិភាគពាក់ព័ន្ធ អាចស្នើសុំថតចម្លងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤)។

៨.៣០.៧ ប្រធាន គធ.ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ដូចមានចែងក្នុងចំណុច ៨.៣០.១.១ ខាងលើនេះ កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងកំណត់ហេតុស្តីពីការបិទផ្សាយដូចមានចែងក្នុងចំណុច ៨.៣០.៣.២ ខាងលើនេះ និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ដូចមានចែងក្នុងចំណុច ៨.៣០.៥.២ ខាងលើនេះ ត្រូវបានដាក់ក្នុងស្រោមសំបុត្រធំតែមួយ ត្រៀមសម្រាប់ផ្ញើជូន គ.ជ.ប។

៨.៣០.៨ ប្រធាន គធ.ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៥) ដែលបានចុះហត្ថលេខា និងបោះត្រា គធ.ខប រួចត្រូវបានស្កែនបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ រួចត្រូវបញ្ជូនទិន្នន័យ និងរូបភាពទាំងនេះទៅ គ.ជ.ប តាមអ៊ីនធឺណិត។

## ការវេចខ្ចប់ និងបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាល់សម្ភារ ឯកសារបោះឆ្នោត ទៅ គ.ជ.ប

### ប្រការ៨.៣១.-

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចមានចែងក្នុងប្រការ ៨.២៨ រហូតដល់ប្រការ ៨.៣០ ខាងលើនេះ គធ.ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៥) និងរាល់ស្បោង "ខ" ដាក់រាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៃការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ "ឃ ពិសេស" និងស្បោង "ឃ" បញ្ជូន និងប្រគល់ជូន គ.ជ.ប ឱ្យទាន់ពេលវេលានៅថ្ងៃទីពីរ បន្ទាប់ពីថ្ងៃបោះឆ្នោត។ ក្នុងករណីមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ពាក់ព័ន្ធក្នុងការិយាល័យបោះឆ្នោតមួយ ឬច្រើនត្រូវបានដាក់នៅ គធ.ខប ប្រធាន គធ.ខប អាចចាត់ចែងវេចខ្ចប់រាល់ក្រដាសលទ្ធផល និងសម្ភារ ឯកសារបោះឆ្នោតដូចមានបញ្ជាក់ខាងលើ ដើម្បីបញ្ជូន និងប្រគល់ជូន គ.ជ.ប នៅក្រោយពេលដែល គធ.ខប ដោះស្រាយពាក្យបណ្ដឹងចប់សព្វគ្រប់ ស្របតាម ច.ប.ព.ស និង ប.ន.ព.ស នេះ។

៨.៣១.១ ប្រធាន គធ.ខប ត្រូវធានាថា សម្រង់សេចក្ដីសម្រេច (ទ.១២០៣) យល់ព្រមតាមពាក្យបណ្ដឹង និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតដែលត្រូវបានសម្រេចស្នើសុំ គ.ជ.ប ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតដូចបានបញ្ជាក់ក្នុងចំណុច ៨.២៩.១០ ខាងលើនេះ ត្រូវតែបានវេចខ្ចប់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗ និងបញ្ជូនទៅ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.២៩.១១ ខាងលើនេះ។

៨.៣១.២ ចំពោះករណីការិយាល័យបោះឆ្នោតទាំងឡាយណាដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងនោះ ត្រូវបាន គធ.ខប សម្រេចយល់ព្រម ប្រធាន គធ.ខប ត្រូវត្រៀមកញ្ចប់ "ឃ ពិសេស" មួយសម្រាប់ដាក់រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតដែលនឹងត្រូវផ្ញើជូន គ.ជ.ប និងត្រូវធានាថា រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតទាំងនោះ ត្រូវតែបាន

ត្រួតពិនិត្យឡើងវិញ និងរៀបចំចងជាបាច់ដោយឡែកពីគ្នាទៅតាមប្រភេទឯកសារក្នុងស្រោមសំបុត្រ។ នៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនីមួយៗ ប្រធាន គធ.ខប ត្រូវប្រមូល និងរៀបចំដាក់ទៅក្នុងកញ្ចប់ "ឃ ពិសេស" នូវ៖

៨.៣១.២.១ រាល់ស្រោមសំបុត្រដាក់តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ១ (មួយ) ច្បាប់ កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ១ (មួយ) ច្បាប់ និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប។

៨.៣១.២.២ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ផ្ញើជូន គ.ជ.ប។

៨.៣១.២.៣ រាល់របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដែលមានការស្នើសុំ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ (ប្រសិនបើមាន) ដូចមានចែងក្នុងចំណុច ៨.២៩.៨.១ ខាងលើនេះ។

៨.៣១.២.៤ រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រមួយ និងកាខ្ទងផ្ញើជូន គ.ជ.ប។

៨.៣១.២.៥ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់។

៨.៣១.៣ ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយមានសរសេររាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងកញ្ចប់ "ឃ ពិសេស" ខាងលើ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងកញ្ចប់ "ឃ ពិសេស" ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ "ឃ ពិសេស" និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប។

៨.៣១.៤ ប្រធាន គធ.ខប ត្រូវបិទភ្ជិតកញ្ចប់ “ឃ ពិសេស” រួចហើយត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្តរបស់ខ្លួននៅលើផ្ទៃកខាងក្រៅនៃកញ្ចប់ “ឃ ពិសេស” ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ។

៨.៣១.៥ បន្ទាប់មកប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យវេចខ្ចប់ស្បោង “ខ” នៃការិយាល័យបោះឆ្នោតដែលគ្មាន ឬមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ ប៉ុន្តែគ្មានការបើកកញ្ចប់សុវត្ថិភាព “ក” ហើយដែលបានត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ដូចមានចែងក្នុងប្រការ ៨.២៨ ខាងលើនេះ ដោយដាក់ទៅក្នុងស្បោង “ឃ” តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង “ខ” នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។ ក្នុងការវេចខ្ចប់នេះ គធ.ខប ត្រូវ៖

៨.៣១.៥.១ ដាក់ស្បោង “ខ” តាមលំដាប់លេខរៀងនៃលេខកូដការិយាល័យបោះឆ្នោត ប្រសិនបើអាចទៅក្នុងស្បោង “ឃ” នីមួយៗ។

៨.៣១.៥.២ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារៈឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញដោយមានរាយមុខសម្ភារ ឯកសារបោះឆ្នោត ដែលបានដាក់ក្នុងស្បោង “ឃ” នីមួយៗ ហើយត្រូវបានដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង “ឃ” ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅនៃស្បោង “ឃ” និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប។

៨.៣១.៥.៣ ចងភ្ជិតស្បោង “ឃ” នីមួយៗ និងចាក់សោឃ្លុំមានលេខ រួចសរសេរសម្គាល់ពីក្រៅស្បោង “ឃ” នីមួយៗ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះនូវលេខកូដរាជធានី ខេត្តពាក់ព័ន្ធ លេខកូដការិយាល័យបោះឆ្នោតពីលេខប៉ុន្មាន ដល់លេខប៉ុន្មាន និងពាក្យថា “ពិនិត្យរួច”។

៨.៣១.៦ ប្រសិនបើក្នុងរាជធានី ខេត្ត មានការិយាល័យបោះឆ្នោតមួយចំនួនមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដែលតម្រូវឱ្យមានការបើកកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតមួយ ឬច្រើន ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ប្រធាន គធ.ខប ត្រូវធានាថា រាល់ស្បោង “ខ” មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទាំងនោះ ត្រូវតែបានវេចខ្ចប់ក្នុងស្បោង “ឃ” ដោយឡែក។ ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់ស្បោង “ខ” មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព “ក” នៃរាជធានី ខេត្ត ហើយដែលបានត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង

បូកសរុបលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងប្រការ ៨.២៩ ខាងលើនេះ ហើយដែល គធ.ខប យល់ព្រមទទួលយកលទ្ធផលបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងនោះ ដោយដាក់ទៅក្នុងស្បោង "ឃ" ដោយឡែក តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង ("ខ" មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក") ពាក់ព័ន្ធនៃរាជធានី ខេត្តនោះ។ ក្នុងការវេចខ្ចប់នេះ គធ.ខប ត្រូវៈ

៨.៣១.៦.១ ដាក់រាល់ស្បោង ("ខ" មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក") នៃរាជធានី ខេត្តពាក់ព័ន្ធ ដែលមានការបើកកញ្ចប់សុវត្ថិភាព "ក" ទៅក្នុងស្បោង "ឃ" ដោយឡែក។

៨.៣១.៦.២ ធានាថាលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញ ដោយមានរាយមុខសម្ភារ ឯកសារបោះឆ្នោតដែលបានដាក់ក្នុងស្បោង "ឃ" ពាក់ព័ន្ធ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង "ឃ" ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅនៃស្បោង "ឃ" និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប។

៨.៣១.៦.៣ ចងភ្ជិតស្បោង "ឃ" និងចាក់សោឃ្លុំមានលេខ រួចសរសេរសម្គាល់ពីក្រៅស្បោង "ឃ" ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះនូវលេខកូដរាជធានី ខេត្ត លេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ និងពាក្យថា (មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក")។

៨.៣១.៧ ក្នុងករណីមានស្បោង "ឃ" ដូចមានចែងក្នុងចំណុច ៨.៣១.៥ ឬ/និងចំណុច ៨.៣១.៦ ខាងលើនេះ សរុបលើសពីមួយ ប្រធាន គធ.ខប ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង "ឃ" ទាំងនោះ នូវលេខរៀងនៃស្បោង "ឃ" នីមួយៗ។ ប្រសិនបើមានស្បោង "ឃ" សរុបចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀង ១/៣ ២/៣ និង ៣/៣។

៨.៣១.៨ ប្រធាន គធ.ខប ត្រូវប្រកាសអញ្ជើញតំណាងគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងអ្នកសារព័ត៌មាន ដែលមានវត្តមានឱ្យចូលរួមជាសាក្សីក្នុងការបញ្ជូន និងការប្រគល់ ទទួលកញ្ចប់ "ឃ ពិសេស" និងរាល់ស្បោង "ឃ" ឬ/និងស្បោង ("ឃ" មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក") ខាងលើនេះ ហើយត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរនៃការបញ្ជូន ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ ទទួលនៅទីស្ដីការ គ.ជ.ប។

៨.៣១.៩ ប្រធាន គធ.ខប ត្រូវធានាថា រាល់កញ្ចប់សន្លឹកឆ្នោតត្រៀមបម្រុងសម្រាប់រាជធានី ខេត្តនីមួយៗ (ប្រសិនបើមាន) ដែលមិនត្រូវបានប្រើប្រាស់ ត្រូវតែបានវេចខ្ចប់ដោយឡែក និងមិនត្រូវដាក់ក្នុងស្បោង “ឃ” ហើយត្រូវបញ្ជូន និងប្រគល់ជូន គ.ជ.ប ស្របពេលជាមួយនឹងការបញ្ជូនកញ្ចប់ “ឃ ពិសេស” និងស្បោង “ឃ” ឬ/និងស្បោង “ឃ” មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព “ក” នៅក្នុងការវេចខ្ចប់បញ្ជូន និងប្រគល់ទទួលសន្លឹកឆ្នោតត្រៀមបម្រុង ប្រធាន គធ.ខប ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវបានបំពេញ និងប្រើប្រាស់តាមការកំណត់ក្នុងការបញ្ជូន និងការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត។

៨.៣១.១០ ប្រធាន គធ.ខប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែលបានទទួលពី គ.ក.ប ចំណុះរាជធានី ខេត្ត ឬ/និងមាននៅ លគធ.ខប ត្រូវតែបានវេចខ្ចប់ និងបញ្ជូនដោយឡែកទៅ គ.ជ.ប នៅពេលក្រោយ។ នៅក្នុងការវេចខ្ចប់បញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅសល់ ប្រធាន គធ.ខប ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវតែបានបំពេញ និងប្រើប្រាស់តាមគោលការណ៍នៃការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត។

## ការដាក់ពាក្យបណ្តឹងតវ៉ានឹងការសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប

### ប្រការ៨.៣២.-

តំណាងគណបក្សនយោបាយ អ្នកប្តឹងតវ៉ា ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់របស់គាត់ពាក់ព័ន្ធនឹងការបោះឆ្នោត ឬ/និងការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើនក្នុងរាជធានី ខេត្ត ឬអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.២៩.៨.២ ខាងលើនេះ មានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប បដិសេធលើពាក្យបណ្តឹង។

៨.៣២.១ អ្នកប្តឹងតវ៉ា ឬតំណាងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់។

៨.៣២.២ ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងតវ៉ាណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថា គ្មានការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកំហុសឆ្គងក្នុងប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬ/និងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត។

៨.៣២.៣ នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង ទី២ កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឧប។

៨.៣២.៤ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

៨.៣២.៥ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថាៈ

- ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឧប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៨.៣១.៣ ខាងលើនេះ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុច ខ្វះខាត ដោយមិនឱ្យហួសពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុច ខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងនោះដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឧប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឧប និងមានព័ត៌មានចាំបាច់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះលើពាក្យបណ្តឹង

គ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលប្រជុំសម្រេច ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។ ជម្រាបអ្នកប្ដឹង ឬតំណាងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្ដឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះ។

៨.៣២.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប អំពីករណីនៃពាក្យបណ្ដឹង ដោយភ្ជាប់ពាក្យបណ្ដឹងតវ៉ាដែលបានទទួល និងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប បដិសេធលើពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ដូចមានចែងក្នុងចំណុច ៨.២៩.៨.២ ខាងលើនេះ ដែលត្រូវដកចេញពីកញ្ចប់ "ឃ ពិសេស" និងដើម្បីសុំការណែនាំរបស់ គ.ជ.ប អំពីករណីនៃការត្រួតពិនិត្យលទ្ធផល និងអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញ។ ផ្អែកតាមការណែនាំខាងលើនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធនឹងពាក្យបណ្ដឹងនោះ នៅចំពោះមុខអ្នកប្ដឹង ឬតំណាង តំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍។

## ការបង្កើតក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណសម្បត្តិបម្រើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនីមួយៗ

### ប្រការ៨.៣៣.-

ក្នុងគោលបំណងត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា គ.ជ.ប ត្រូវបង្កើតក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោត ១ (មួយ) ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតមួយចំនួនតាមការចាំបាច់ និងក្រុមកំណត់បែងចែកអាសនៈ ១ (មួយ) ព្រមទាំងត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីបម្រើឱ្យការងារត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនីមួយៗ។

៨.៣៣.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតមួយត្រូវបានបង្កើតឡើងនៅ គ.ជ.ប ដើម្បីធានាការទទួលកញ្ចប់ "ឃ ពិសេស" ស្បោង "ឃ" ឬ/និងស្បោង ("ឃ" មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក") កញ្ចប់ដាក់សន្លឹកឆ្នោតបម្រុងដែលមិនទាន់ប្រើប្រាស់ និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធដែល គធ.ខប បានបញ្ជូន និងប្រគល់ជូន គ.ជ.ប ព្រមទាំងធានាការបែងចែកនិងរក្សាទុកសម្ភារ ឯកសារបោះឆ្នោតទាំងនោះ នៅបន្ទប់ស្ដុកតាមភូមិភាគនីមួយៗ។

៨.៣៣.១.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវដឹកនាំដោយប្រធាននាយកដ្ឋានរដ្ឋបាល និងមានមន្ត្រីនាយកដ្ឋានប្រតិបត្តិការ មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងមន្ត្រីលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប មួយចំនួនជាសមាជិក។

៨.៣៣.១.២ ក្រុមនេះ ត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប។

៨.៣៣.២ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប មួយចំនួន ត្រូវបានបង្កើតឡើង ដើម្បីអនុវត្តការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគទាំង៨ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប នីមួយៗរួមមានសមាសភាពដែលត្រូវបានចាត់តាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋាននានាចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ប និងត្រូវបានបែងចែកឱ្យទទួលបន្ទុកត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគមួយ ឬច្រើន។

៨.៣៣.២.១ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប នីមួយៗ ត្រូវមានសមាសភាព ៤ (បួន) រូប ដែលដឹកនាំដោយប្រធាន ១ (មួយ) រូប អនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងជំនួយការ ១ (មួយ) រូប។

៨.៣៣.២.២ ក្រុមនេះ ត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប។

៨.៣៣.៣ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប នីមួយៗ មានភារកិច្ចត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនីមួយៗដោយឡែកពីគ្នា រួចត្រូវបោះពុម្ពតារាងត្រួតពិនិត្យ និងបូក

សរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គព)។ ក្នុងករណីការិយាល័យបោះឆ្នោតមានពាក្យបណ្តឹងតវ៉ាត្រូវបានដាក់នៅ គ.ជ.ប ឬលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតត្រូវបាន គធ.ខប ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវអនុវត្តបន្ថែមដោយធ្វើរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត។ ប្រធានក្រុមត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផល និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គព) ឬ/និងរបាយការណ៍ខាងលើនេះ ត្រូវបានចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមពាក់ព័ន្ធ និងត្រូវដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។ បន្ទាប់មក គ.ជ.ប ត្រូវប្រគល់សំណុំឯកសារដែលបានសម្រេចរួចនេះ តាមរយៈអគ្គលេខាធិការ គ.ជ.ប ឱ្យទៅក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីមុខការបន្ត។ ការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនេះ ត្រូវអនុវត្តដោយផ្អែកលើ៖

៨.៣៣.៣.១ តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤)។

៨.៣៣.៣.២ កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅតាមការិយាល័យបោះឆ្នោត។

៨.៣៣.៣.៣ របាយការណ៍ស្តីពីលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ គធ.ខប (ប្រសិនបើមាន)។

៨.៣៣.៣.៤ សម្រង់សេចក្តីសម្រេចរបស់ គធ.ខប យល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (ប្រសិនបើមាន)។

៨.៣៣.៣.៥ ពាក្យបណ្តឹងដែលបានដាក់នៅ គ.ជ.ប ដូចមានចែងក្នុងប្រការ ៨.៣២ ខាងលើនេះ (ប្រសិនបើមាន)។

៨.៣៣.៣.៦ លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ (ប្រសិនបើ គ.ជ.ប សម្រេចឱ្យធ្វើដូច្នេះ)។

៨.៣៣.៤ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបានបង្កើតឡើង ដើម្បីទាញទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនីមួយៗចំណុះភូមិភាគពាក់ព័ន្ធនៅក្នុងប្រព័ន្ធកុំព្យូទ័រ រួចធ្វើការផ្ទៀងផ្ទាត់លទ្ធផលដែលបូកសរុបឃើញជាមួយនឹងតួលេខលទ្ធផលដែលមានក្នុងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧តព) ដែល គ.ជ.ប បានយល់ព្រមទទួលយកលទ្ធផលនោះរួចហើយ។ ប្រសិនបើការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតគ្រប់ភូមិភាគទូទាំងប្រទេស ឃើញត្រឹមត្រូវហើយ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបោះពុម្ពសេចក្ដីព្រាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច និងផ្សព្វផ្សាយ។ ក្នុងករណីគ្មានពាក្យបណ្ដឹងតវ៉ា ឬរាល់ពាក្យបណ្ដឹងតវ៉ាត្រូវបានដោះស្រាយចប់ជាស្ថាពរ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវរៀបចំសេចក្ដីព្រាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងសេចក្ដីព្រាងតារាងលទ្ធផលនៃការបែងចែកអាសនៈ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេចជាផ្លូវការ។

៨.៣៣.៤.១ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវមានសមាសភាពមួយចំនួនតាមការចាំបាច់ ដែលត្រូវបានចាត់តាំងពីក្នុងចំណោមថ្នាក់ដឹកនាំអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ប្រធាននាយកដ្ឋានប្រតិបត្តិការ និងប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម។

៨.៣៣.៤.២ ក្រុមនេះ ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលជាអគ្គនាយកនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស អនុប្រធាន ១ (មួយ) រូប ដែលជាអគ្គនាយករងនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស សមាជិក ៣ (បី) រូប ដែលជាអគ្គនាយករងនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ប្រធាននាយកដ្ឋានប្រតិបត្តិការ និងប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងមានក្រុមជំនួយការមួយចំនួនតាមការចាំបាច់។

៨.៣៣.៤.៣ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប។

៨.៣៣.៥ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួននៅបន្ទប់កុំព្យូទ័រនៃនាយកដ្ឋានប្រតិបត្តិការ និងត្រូវមានភារទទួលខុសត្រូវ និងភារកិច្ចដូចខាងក្រោម៖

៨.៣៣.៥.១ បោះពុម្ពតារាងលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនីមួយៗ ដោយផ្អែកតាមតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) នោះ ឬទាំងនោះ ដែល គធ.ខប បានបញ្ជូនមកសេវូបករណ៍ (Server) គ.ជ.ប។ បន្ទាប់មកកែតម្រូវ និងផ្ទៀងផ្ទាត់លទ្ធផលដែលបានបូកសរុបទៅនឹងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៩) និងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) ដែល គ.ជ.ប បានពិនិត្យ សម្រេចរួចហើយ។

៨.៣៣.៥.២ ដាក់សេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាជូនគ.ជ.បតាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច និងផ្សព្វផ្សាយជាសាធារណៈ។

៨.៣៣.៥.៣ កែតម្រូវតួលេខលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា យោងតាមសេចក្តីសម្រេចរបស់ គ.ជ.ប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញលើពាក្យបណ្តឹងតវ៉ា (ប្រសិនបើមាន) និងរៀបចំបោះពុម្ពសេចក្តីព្រាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យសម្រេចជាផ្លូវការ និងផ្សព្វផ្សាយជាសាធារណៈ។

៨.៣៣.៥.៤ កំណត់បែងចែកអាសនៈតាមរូបមន្តដែលកំណត់ដោយច្បាប់ ដោយគណនាតាមការធ្វើប្រមាណវិធីដោយដៃដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ស្តីពីការបែងចែកអាសនៈ និងដោយប្រើកម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត យោងតាមតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៨.៣៣.៥.៥ បោះពុម្ពតារាងលទ្ធផលនៃការបែងចែកអាសនៈតាមភូមិភាគដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបាន រួចផ្ទៀងផ្ទាត់ និងទាញឈ្មោះបេក្ខជនជាប់ឆ្នោតតាមចំនួនអាសនៈ និងលំដាប់លេខរៀងពីក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈទៅក្នុងសេចក្តីព្រាងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា។

៨.៣៣.៥.៦ រៀបចំតារាងលទ្ធផលនៃការបែងចែកអាសនៈ និងសេចក្តីព្រាង សេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា រួច ដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេចជាផ្លូវការ។

៨.៣៣.៦ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំ និងចាត់ចែងក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប និងក្រុមកំណត់បែងចែក អាសនៈនៃ គ.ជ.ប នៅក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នូវ លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងកិច្ចប្រតិបត្តិការ បែងចែកអាសនៈតាមភូមិភាគ។ អគ្គលេខាធិការ គ.ជ.ប ត្រូវពិនិត្យរាល់សំណុំ ឯកសាររបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត នៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

៨.៣៣.៧ អគ្គលេខាធិការ គ.ជ.ប ត្រូវត្រៀមបន្ទប់មួយចំនួននៃអគារទីស្តីការ គ.ជ.ប សម្រាប់ធ្វើជាកន្លែងស្តុកស្រោមសំបុត្រធំ កញ្ចប់ “ឃ ពិសេស” ដាក់សំណុំ ឯកសារលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងស្បោង “ឃ” ឬ/និង ស្បោង (“ឃ” មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព “ក”) ឬ/និងស្បោង “ឃ ព្យួរលទ្ធផល” ដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ។ ក្នុងនោះត្រូវៈ

៨.៣៣.៧.១ ត្រៀមបន្ទប់មួយដោយឡែកសម្រាប់រក្សាទុករាល់ស្រោម សំបុត្រធំដាក់ឯកសារបោះឆ្នោត ព្យួរជាបណ្តោះអាសន្ននូវ លទ្ធផលនៃការបោះឆ្នោត និងរាល់ស្បោង “ឃ ព្យួរលទ្ធផល” និងរាល់ស្បោង (“ឃ” មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព “ក”) ដាក់ស្បោង “ខ” នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

៨.៣៣.៧.២ ត្រៀមបន្ទប់មួយដោយឡែកសម្រាប់ដាក់រាល់កញ្ចប់ “ឃ ពិសេស” នៃ គធ.ខប ទាំងអស់។

៨.៣៣.៧.៣ ត្រៀមបន្ទប់មួយចំនួនសម្រាប់ស្តុកស្បោង “ឃ” ដែលមាន ដាក់ស្បោង “ខ” ហើយដែលត្រូវដាក់ដោយឡែកពីគ្នាទៅ តាមរាជធានី ខេត្ត និងភូមិភាគនីមួយៗ។

៨.៣៣.៨ អគ្គលេខាធិការ គ.ជ.ប ត្រូវត្រៀមបន្ទប់ធំទូលាយមួយចំនួន ឬបន្ទប់តូចៗ ច្រើនដែលអាចឱ្យក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការ បោះឆ្នោតនៃ គ.ជ.ប បំពេញការងាររបស់ខ្លួនបានល្អ។

៨.៣៣.៨.១ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ២ (ពីរ) ឬច្រើនអាចបំពេញការងាររបស់ខ្លួននៅជុំគ្នាក្នុងបន្ទប់តែមួយ ឬនៅបន្ទប់ដោយឡែកពីគ្នា ដោយផ្អែកតាមលទ្ធភាពជាក់ស្តែង។

៨.៣៣.៨.២ សេចក្តីជូនដំណឹងស្តីពីពេលវេលា កាលបរិច្ឆេទ ទីកន្លែង ឈ្មោះភូមិភាគ លេខកូដ និងឈ្មោះរាជធានី ខេត្ត និងលេខកូដការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ ព្រមទាំងលេខរៀងក្រុម និងឈ្មោះប្រធានក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតដែលទទួលបន្ទុក ត្រូវតែបានផ្សព្វផ្សាយ និងបិទផ្សាយជាសាធារណៈនៅទីស្តីការ គ.ជ.ប ដើម្បីជាដំណឹងដល់អ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ ព្រមទាំងអ្នកសារព័ត៌មានដែលបានទទួលការអនុញ្ញាតឱ្យចូលរួមសង្កេតមើលក្នុងដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនេះ។

៨.៣៣.៩ ក្នុងអំឡុងពេលនៃដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅ គ.ជ.ប លក្ខខណ្ឌសន្តិសុខនៅជុំវិញបរិវេណ និងក្នុងទីស្តីការ គ.ជ.ប ព្រមទាំងសណ្តាប់ធ្នាប់ និងរបៀបរៀបរយត្រូវតែបានពង្រឹងតាមវិធានការរដ្ឋបាល ដែលគ្រប់គ្រង និងចាត់ចែងដោយអគ្គលេខាធិការ គ.ជ.ប។

៨.៣៣.៩.១ អ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ព្រមទាំងអ្នកសារព័ត៌មានដែលទទួលបានការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៅទីស្តីការ គ.ជ.ប ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់អគ្គលេខាធិការ គ.ជ.ប ឬមន្ត្រីដែលត្រូវបានប្រគល់សិទ្ធិ។

៨.៣៣.៩.២ អ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ព្រមទាំងអ្នកសារព័ត៌មានដែលទទួលបានការអនុញ្ញាតឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៅទីស្តីការ គ.ជ.ប ត្រូវគោរពក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត

ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោត និង ប.ន.ព.ស នេះ ហើយមិនត្រូវធ្វើសកម្មភាព ឬអំពើអ្វីមួយដែលរំខាន ឬអុកឡុក ឬរារាំង ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ឬបំពានលើសិទ្ធិអំណាច និងឯករាជ្យភាពរបស់ គ.ជ.ប ឡើយ។

៨.៣៣.១០ ហាមជនគ្រប់រូបចូលក្នុងបន្ទប់ដែលក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប កំពុងត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលខាងលើនេះនូវជនទាំងឡាយដូចខាងក្រោម៖

៨.៣៣.១០.១ មន្ត្រីក្នុងក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដែលបានទទួលការចាត់តាំងពី គ.ជ.ប។

៨.៣៣.១០.២ អ្នកប្ដឹង ឬតំណាង តំណាងគណបក្សនយោបាយដែលបានឈរឈ្មោះក្នុងភូមិភាគពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ព្រមទាំងអ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្ដល់ឱ្យដោយ គ.ជ.ប។

៨.៣៣.១០.៣ ប្រធាន អនុប្រធាន សមាជិក គ.ជ.ប និងអគ្គលេខាធិការ គ.ជ.ប ឬមន្ត្រីដែលត្រូវបានប្រគល់សិទ្ធិ ដែលមានបំណងត្រួតពិនិត្យ តាមដានក្នុងដំណើរការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតរបស់ក្រុមនីមួយៗ។

## ការប្រគល់ និងការទទួលកញ្ចប់ "ឃ ពិសេស" និងស្បោង "ឃ ព្យួរលទ្ធផល" ឬ/និងស្បោង "ឃ" ឬ/និងស្បោង ("ឃ" មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក") និងសម្ភារៈ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្ដីការ គ.ជ.ប

## ប្រការ៨.៣៤.-

សមាសភាពក្រុមទទួលសម្ភារៈ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដែលបានចាត់តាំងក្នុងចំណុច ៨.៣៣.១ ខាងលើនេះ ត្រូវមានវត្តមានជាប្រចាំនៅទីស្ដីការ គ.ជ.ប ចាប់ពីពេលដែល គធ.ខប ចាប់ផ្ដើមធ្វើការត្រួតពិនិត្យ និងបូកសរុបលទ្ធផល ដើម្បីរង់ចាំទទួលសម្ភារៈ ឯកសារបោះឆ្នោតដែល គធ.ខប ត្រូវបញ្ជូន និងប្រគល់ជូន គ.ជ.ប។

៨.៣៩.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីទទួលសម្ភារ ឯកសារបោះឆ្នោត ដោយផ្អែកតាមករណីដោយឡែកនៃរាជធានី ខេត្តនីមួយៗ ដែល គធ.ខប ពាក់ព័ន្ធអាចវេចខ្ចប់ និងបញ្ជូនសម្ភារ ឯកសារបោះឆ្នោតជូន គ.ជ.ប ជា ៤ (បួន) ផ្អែកដូចខាងក្រោម៖

៨.៣៩.១.១ រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមតាមពាក្យបណ្តឹងនៅរាជធានី ខេត្ត ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្ត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោត ដែលត្រូវបាន គធ.ខប ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៣១.១ នៃ ប.ន.ព.ស នេះ។

៨.៣៩.១.២ រាល់កញ្ចប់ "ឃ ពិសេស" និងស្បោង "ឃ" ដាក់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតត្រូវបាន គធ.ខប សម្រេចយល់ព្រមដូចមានចែងក្នុងចំណុច ៨.៣១.២ ចំណុច ៨.៣១.៥ និងចំណុច ៨.៣១.៦ នៃ ប.ន.ព.ស នេះ។

៨.៣៩.១.៣ រាល់កញ្ចប់សន្លឹកឆ្នោតបម្រុងសម្រាប់រាជធានី ខេត្តដែលនៅសល់មិនបានប្រើប្រាស់។

៨.៣៩.១.៤ រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ដែលត្រូវបានវេចខ្ចប់ និងបញ្ជូនដោយឡែកមក គ.ជ.ប នៅពេលក្រោយដូចមានចែងក្នុងចំណុច ៨.៣១.១០ នៃ ប.ន.ព.ស នេះ។

៨.៣៩.២ ក្នុងករណីមន្ត្រី លគធ.ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៣៩.១.១ ខាងលើនេះ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងស្រោមសំបុត្រធំ និងរាល់ស្បោង "ឃ ព្យួរលទ្ធផល" ដាក់ស្បោង "ខ" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត។ ក្នុងការត្រួតពិនិត្យនេះ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ ដែល ១ (មួយ) ច្បាប់នៅក្នុងស្រោមសំបុត្រធំ ១ (មួយ) ច្បាប់ កិបជាប់នឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំ និង ១ (មួយ) ច្បាប់ នៅនឹងមន្ត្រី លគធ.ខប ដែលបញ្ជូនសម្ភារ ឯកសារបោះឆ្នោតមក។

៨.៣៥.២.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវកត់ត្រាមុខសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលទាំងអស់ ចូលក្នុងបញ្ជីរបស់ខ្លួន ប្រសិនបើគ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា "គ្រប់ចំនួន"។

៨.៣៥.២.២ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដូចមានចែងក្នុងចំណុច ៨.៣៥.២ ខាងលើនេះ រួចប្រគល់ ១ (មួយ) ច្បាប់ ជូនមន្ត្រី លគធ.ខប ទទួលបន្ទុកការបញ្ជូន រក្សាទុក ១ (មួយ) ច្បាប់ ភ្ជាប់ទៅនឹងស្រោមសំបុត្រធំ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣៥.២.៣ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវនាំយកស្រោមសំបុត្រធំ និងស្បោង "ឃ ព្យួរលទ្ធផល" ដាក់រាល់ស្បោង "ខ" នៃការិយាល័យបោះឆ្នោតដែលត្រូវបាន គធ.ខប ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនោះទៅរក្សាទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុក ដូចមានចែងក្នុងចំណុច ៨.៣៣.៧.១ ខាងលើនេះ និងត្រូវសរសេរសម្គាល់លេខកូដការិយាល័យបោះឆ្នោត និងរាជធានី ខេត្តពាក់ព័ន្ធផង។

៨.៣៥.២.៤ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប នូវលេខកូដការិយាល័យបោះឆ្នោត និងលេខកូដ និងឈ្មោះរាជធានី ខេត្ត ដែលត្រូវ គធ.ខប ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនោះ ដោយដាក់អមទៅជាមួយនូវស្រោមសំបុត្រធំពាក់ព័ន្ធផង។

៨.៣៥.៣ ក្នុងករណីមន្ត្រី លគធ.ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៣៥.១.២ ខាងលើនេះ មកដល់ទីស្ដីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងកញ្ចប់ "ឃ ពិសេស" និងរាល់ "ស្បោង "ឃ ពិនិត្យរួច" ឬ/និងស្បោង ("ឃ" មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក") ដាក់ស្បោង "ខ" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធទាំងអស់ ដែលលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តទាំងនោះ ត្រូវបាន គធ.ខប សម្រេចយល់ព្រម។ ក្នុងការត្រួតពិនិត្យនេះ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវ

ផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ ដោយឡែកពីគ្នាដែល ១ (មួយ) ច្បាប់ នៅក្នុងកញ្ចប់ "ឃ ពិសេស" និងស្បោង "ឃ" ឬ/និងស្បោង ("ឃ មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព "ក") ១ (មួយ) ច្បាប់ នៅក្នុងហោប៉ៅនៃកញ្ចប់ "ឃ ពិសេស" និងស្បោង "ឃ" ឬ/និងស្បោង ("ឃ" មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព "ក") និង ១ (មួយ) ច្បាប់ នៅនឹងមន្ត្រី លគធ.ខប ដែលបញ្ជូនសម្ភារ ឯកសារបោះឆ្នោតមក។

៨.៣៩.៣.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវកត់ត្រាមុខសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួនដែលប្រសិនបើគ្រប់គ្រាន់ហើយត្រូវចារសម្គាល់ថា "គ្រប់ចំនួន"។

៨.៣៩.៣.២ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដូចមានចែងក្នុងចំណុច ៨.៣៩.៣ ខាងលើនេះ រួចប្រគល់ ១ (មួយ) ច្បាប់ ជូនមន្ត្រី លគធ.ខប ទទួលបន្ទុកការបញ្ជូន និងដាក់ ១ (មួយ) ច្បាប់ ក្នុងហោប៉ៅកញ្ចប់ "ឃ ពិសេស" និងស្បោង "ឃ" ឬ/និងស្បោង ("ឃ" មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព "ក") វិញ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣៩.៣.៣ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវនាំយកកញ្ចប់ "ឃ ពិសេស" និងស្បោង ("ឃ" មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព "ក") នៃរាជធានី ខេត្តពាក់ព័ន្ធ ទៅរក្សាទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុកដូចមានចែងក្នុងចំណុច ៨.៣៣.៧.២ ខាងលើនេះ ដោយត្រូវដាក់តាមលំដាប់លេខរៀងនៃលេខកូដរាជធានី ខេត្តនីមួយៗ។

៨.៣៩.៣.៤ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវនាំយករាល់ស្បោង "ឃ" ដាក់ស្បោង "ខ" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងនោះ ត្រូវបាន គធ.ខប សម្រេចយល់ព្រមទៅរក្សាទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុកដូចមានចែងក្នុងចំណុច ៨.៣៣.៧.៣ ខាងលើនេះ និងត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្តពាក់ព័ន្ធផង។

៨.៣៥.៣.៥ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប នូវរាជធានី ខេត្តដែលបានប្រគល់កញ្ចប់ "ឃ ពិសេស" និងរាល់ស្បោង "ឃ" ឬ/និងស្បោង ("ឃ" មានពាក្យបណ្តឹង/បើកកញ្ចប់សុវត្ថិភាព "ក") ដាក់ស្បោង "ខ" នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងនោះ ត្រូវបាន គធ.ឧប សម្រេចយល់ព្រម។ ប្រសិនបើក្នុងរាជធានី ខេត្តពាក់ព័ន្ធមានការិយាល័យបោះឆ្នោតណាដែលមានពាក្យបណ្តឹង ត្រូវបានដាក់នៅ គធ.ឧប និងដែលមានកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើនត្រូវបានបើក ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបញ្ជាក់បន្ថែមក្នុងរបាយការណ៍ខាងលើផងដែរនូវលេខកូដការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្តឹងទាំងនោះ និងត្រូវដកយករាល់ស្រោមសំបុត្រដាក់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឧប ពាក់ព័ន្ធ ពីក្នុងកញ្ចប់ "ឃ ពិសេស" ដាក់អមទៅជាមួយផង។

៨.៣៥.៤ ក្នុងករណីមន្ត្រី លគធ.ឧប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោតនៅសល់ ដូចបញ្ជាក់ក្នុងចំណុច ៨.៣៥.១.២ ខាងលើនេះ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើកកញ្ចប់ និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលបានប្រគល់ជូន គ.ជ.ប។ ក្នុងការត្រួតពិនិត្យនេះ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដែលប្រសិនបើត្រឹមត្រូវគ្រប់ចំនួនហើយ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) នោះរួចប្រគល់ជូនមន្ត្រី លគធ.ឧប ទទួលបន្ទុកការបញ្ជូន ១ (មួយ) ច្បាប់។ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទេររាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ដែលបានទទួលខាងលើ ដោយភ្ជាប់ជាមួយលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ទៅឱ្យនាយកដ្ឋានប្រតិបត្តិការនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេសទទួលគ្រប់គ្រង និងរក្សាទុកនៅឃ្លាំង គ.ជ.ប ឬបន្ទប់ស្តុកដែលបានកំណត់។

## កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប

**ប្រការ៨.៣៥.-**

ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប មានភារកិច្ចត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តមួយ ឬច្រើនចំណុះភូមិភាគ បញ្ចូលគ្នាជាលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ក្នុងគោលបំណងបញ្ជាក់ជាចុងក្រោយអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់រាជធានី ខេត្តក្នុងភូមិភាគ។

ប្រសិនបើក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប យល់ព្រមតាមកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ទាំងអស់ចំណុះភូមិភាគ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវបោះពុម្ពតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) ហើយដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនោះ គ.ជ.ប ត្រូវប្រគល់តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) និងសំណុំឯកសារពាក់ព័ន្ធតាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដែលត្រូវទាញទិន្នន័យពីប្រព័ន្ធកុំព្យូទ័រ និងរៀបចំជាសេចក្ដីព្រាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យសម្រេច និងប្រកាសផ្សព្វផ្សាយជាលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៨.៣៥.១ នៅពេលដែល គ.ជ.ប បានទទួលតាមរយៈអគ្គលេខាធិការ គ.ជ.ប នូវរបាយការណ៍ពីក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៤.២.៤ និងចំណុច ៨.៣៤.៣.៥ ខាងលើនេះ និងពីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ដូចមានចែងក្នុងចំណុច ៨.៣២.៥ នៃ ប.ន.ព.ស នេះ គ.ជ.ប ត្រូវសម្រេចកំណត់អំពីករណីដែលនឹងត្រូវធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ និងត្រូវសម្រេចអំពីភាពមិនចាំបាច់ ឬភាពចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព“ក”ដើម្បីពិនិត្យផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ប្រសិនបើលក្ខខណ្ឌតម្រូវឱ្យធ្វើ។

៨.៣៥.២ ផ្អែកតាមការកំណត់ និងសម្រេចរបស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៥.១ ខាងលើនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវចាត់ចែងក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់

និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ឱ្យត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំណុះភូមិភាគនីមួយៗដែលក្រុមទទួលបន្ទុក។ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់ និងតាមករណីជាក់ស្តែងនៃរាជធានី ខេត្តចំណុះភូមិភាគនីមួយៗដូចខាងក្រោម៖

៨.៣៥.២.១ ករណីរាជធានី ខេត្តចំណុះភូមិភាគដែលមានលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ត្រូវបាន គធ.ខប ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ហើយដែលបានបញ្ជូនមក គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.២៩.១១ នៃ ប.ន.ព.ស នេះ ដើម្បីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ។

៨.៣៥.២.២ ករណីរាជធានី ខេត្តចំណុះភូមិភាគដែលគ្មានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងការិយាល័យបោះឆ្នោតមួយ ឬច្រើនត្រូវបានដាក់នៅ គធ.ខប ឬ/និង គ.ជ.ប ហើយ គធ.ខប បានសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ។

៨.៣៥.២.៣ ករណីរាជធានី ខេត្តចំណុះភូមិភាគដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ឬ/និង នៅ គ.ជ.ប ហើយដែលមានកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតមួយ ឬច្រើនត្រូវបានបើក ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅ គធ.ខប ប៉ុន្តែ គធ.ខប បានសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ។

៨.៣៥.៣ អ្នកប្តឹង ឬតំណាង តំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ព្រមទាំងអ្នកសារព័ត៌មានដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប មានសិទ្ធិចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានៅទីស្តីការ គ.ជ.ប។ ប្រសិនបើបន្ទប់ចង្អៀត ការចូលរួមសង្កេតមើលរបស់តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ ជាអាទិ៍ដែលមានចែងក្នុងចំណុចនេះ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ប្រធានក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ឬប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប តាមរបៀបផ្លាស់ប្តូរវេនគ្នា។

៨.៣៥.៤ កិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅភូមិភាគណាមួយ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ។

៨.៣៥.៥ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវបើកកិច្ចប្រតិបត្តិការ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ ដែលខ្លួនទទួលបន្ទុកម្តងមួយភូមិភាគៗ នៅបន្ទប់ធំទូលាយណាមួយ ឬបន្ទប់តូចៗដោយឡែកពីគ្នា ដែលបានត្រៀមបម្រុងដូចមានចែងក្នុងចំណុច ៨.៣៣.៨ ខាងលើនេះ។ ក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតខាងលើនេះ ប្រធានក្រុមត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង និងទម្រង់បែបបទសម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផល និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) ព្រមទាំងរាល់សំណុំឯកសារយោងដូចមានចែងចាប់ពីចំណុច ៨.៣៣.៣.១ រហូតដល់ចំណុច ៨.៣៣.៣.៦ ខាងលើនេះ។

៨.៣៥.៦ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបើកកិច្ចប្រតិបត្តិការ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាម្តងមួយភូមិភាគៗ បន្ទាប់ពីបានទទួលតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) ដែល គ.ជ.ប បានពិនិត្យ សម្រេចរួច។

## ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើននៃរាជធានី ខេត្ត ចំណុះភូមិភាគ ដែល គធ.ខប បានសម្រេចព្យួរជាបណ្តោះអាសន្ន

## ប្រការ៨.៣៦.-

អនុលោមតាមការសម្រេចរបស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៥.១ ខាងលើនេះ បានតម្រូវឱ្យក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ពិនិត្យ ផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើននៃរាជធានី ខេត្តចំណុះភូមិភាគដែល គធ.ខប បានសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៣៥.២.១ ខាងលើនេះ។ ចំពោះករណីនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ដែលទទួលបន្ទុកតាមភូមិភាគឱ្យអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

៨.៣៦.១ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវធានាថា ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើនចំណុះរាជធានី ខេត្ត ដែល គធ.ខប បានសម្រេចព្យួរជាបណ្ដោះអាសន្ន ត្រូវតែបានអនុវត្តយ៉ាងរួសរាន់ និងដាក់ជូន គ.ជ.ប ពិនិត្យ សម្រេចក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែល គ.ជ.ប បានទទួលស្បោង "ឃ ព្យួរលទ្ធផល" ដាក់សំណុំឯកសារនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ដែលបានព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនោះ ឬទាំងនោះ។

៨.៣៦.២ ក្នុងករណី គ.ជ.ប សម្រេចមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោតឡើងវិញទេ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផល ដោយគ្រាន់តែផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធដូចមានចែងក្នុងចំណុច ៨.២៩.១១.១ នៃ ប.ន.ព.ស នេះប៉ុណ្ណោះ។

៨.៣៦.៣ ក្នុងករណី គ.ជ.ប សម្រេចតម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យ ដោយផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំដាក់ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធដូចមានចែងក្នុងចំណុច ៨.២៩.១១.១ នៃ ប.ន.ព.ស នេះផង និងត្រូវអនុវត្តបន្ថែមការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញតាមលក្ខខណ្ឌ និងនីតិវិធីទាំងឡាយដូចខាងក្រោម៖

៨.៣៦.៣.១ បង្គាប់ជំនួយការឱ្យទៅនាំយកស្បោង ("ឃ" មានពាក្យបណ្ដឹង/បើកកញ្ចប់សុវត្ថិភាព "ក") នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធពីបន្ទប់រក្សាស្ដុក មកដាក់នៅលើតុចំពីមុខប្រធានក្រុម។

៨.៣៦.៣.២ បើកស្បោង "ឃ" នោះ ដកយកស្បោង "ខ" ចេញមកក្រៅ រួចបើក និងដកយកកញ្ចប់សុវត្ថិភាព "ក" មកដាក់នៅលើតុ។

៨.៣៦.៣.៣ បើកកញ្ចប់សុវត្ថិភាព "ក" រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុង មកដាក់ដោយឡែកពីគ្នា នៅលើតុខាងមុខគាត់។

៨.៣៦.៣.៤ ប្រគល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ឱ្យទៅលេខាធិការ សម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព “ក” ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ។

៨.៣៦.៣.៥ បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្ដងមួយៗ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់តាមនីតិវិធីដូចមានចែងក្នុងចំណុច ៨.៣៦.៤ ខាងក្រោមនេះ។

៨.៣៦.៤ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធានក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវចាត់ចែងត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះឡើងវិញ តាមលំនាំនីតិវិធីដូចមានចែងក្នុងចំណុច ៨.១៨.៦.១ រហូតដល់ចំណុច ៨.១៨.១២ នៃ ប.ន.ព.ស នេះ។

៨.៣៦.៥ ក្នុងករណី គ.ជ.ប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតលើសពីមួយក្នុងរាជធានី ខេត្ត ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវអនុវត្តតាមលំនាំនីតិវិធីដដែលដូចមានចែងក្នុងចំណុច ៨.៣៦.៣ និងចំណុច ៨.៣៦.៤ ខាងលើនេះ សម្រាប់កញ្ចប់សុវត្ថិភាព “ក” នីមួយៗ រហូតដល់អស់កញ្ចប់សុវត្ថិភាព “ក” នៃការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ ដែលត្រូវសម្រេចឱ្យបើក។

៨.៣៦.៦ បន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ តាមនីតិវិធីដូចមានចែងក្នុងចំណុច ៨.៣៦.២ រហូតដល់ចំណុច ៨.៣៦.៥ ខាងលើនេះ ប្រធានក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវធានាថា របាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព “ក” ១ (មួយ) ច្បាប់ តារាងត្រួតពិនិត្យនិងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅភូមិភាគ (ទ.១១១៧គព) នោះ ចំនួន ១ (មួយ) ច្បាប់ និងរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោត ចំនួន១ (មួយ) ច្បាប់

ត្រូវតែបានធ្វើ និងចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

៨.៣៦.៧ អគ្គលេខាធិការ គ.ជ.ប ត្រូវចារយោបល់លើតារាងត្រួតពិនិត្យ និងលទ្ធផល និងរបាយការណ៍ដែលបានដាក់ជូនពិនិត្យដូចមានចែងក្នុងចំណុច ៨.៣៦.៦ ខាងលើនេះ រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ដើម្បីពិនិត្យ សម្រេច។ អគ្គលេខាធិការ គ.ជ.ប ត្រូវ៖

៨.៣៦.៧.១ លើកយោបល់ស្នើសុំការយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ដែលព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្ត ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្ត ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ឬ

៨.៣៦.៧.២ លើកយោបល់ស្នើសុំការបដិសេធសេចក្ដីសម្រេចរបស់ គធ.ខប ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ដោយត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្ត ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ប្រសិនបើកម្រិតនៃភាពមិនប្រក្រតីមិននាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តទេ។

៨.៣៦.៨ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ហើយដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

៨.៣៦.៨.១ ចារយល់ព្រមលើសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលបានយល់ព្រមតាមពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់នៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៦.៨.២ ចារយល់ព្រមលើរបាយការណ៍លើកស្នើយោបល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត

នៃ គ.ជ.ប និងចារបដិសេធលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) ដូចមានចែងក្នុងចំណុច ៨.៣៦.៧ និងចំណុច ៨.៣៦.៧.១ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៦.៨.៣ ចាត់មន្ត្រីជំនាញឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ (ទ.១២០៣) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការយល់ព្រមផង ហើយដែលត្រូវចុះហត្ថលេខាដោយមន្ត្រីជំនាញ និងប្រធាន គ.ជ.ប ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៦.៨.៤ ធានាថា សម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធខាងលើត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនអ្នកប្តឹងឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣៦.៨.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តនោះ ជាសេចក្តីសម្រេចចុងក្រោយ ហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់នៃរាជធានី ខេត្តនោះ ក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចបដិសេធ។

៨.៣៦.៨.៦ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផល សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តនោះ មួយមុខ ១ (មួយ) ច្បាប់ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ទទួលបន្ទុកដាក់ក្នុងស្រោមសំបុត្រធំ រួចដាក់ទៅក្នុងកញ្ចប់ "ឃ ពិសេស" នៃរាជធានី ខេត្តពាក់ព័ន្ធ។

៨.៣៦.៨.៧ ធានាថា ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប បានវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ពាក់ព័ន្ធ ដាក់ក្នុងស្បោង "ខ" រួចចងភ្ជិត និងដាក់ស្បោង "ខ" ទៅក្នុងស្បោង "ឃ" នៃរាជធានី ខេត្តនោះ តាមលំនាំដើម ដោយចាក់សោឃ្លុំមានលេខផង រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

៨.៣៦.៩ យោងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គ.ជ.ប យល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ដែលបានព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៣៦.៨.៣ ខាងលើនេះ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្តពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតទាំងនោះ ត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៨.១៣ នៃ ប.ន.ព.ស នេះ។ ការបោះឆ្នោតសាជាថ្មីនេះត្រូវអនុវត្តដោយផ្អែកលើបញ្ជីបោះឆ្នោតដដែល បញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយក្នុងភូមិភាគដដែល និងសន្លឹកឆ្នោតដែលមានទម្រង់ និងខ្លឹមសារដដែល ប៉ុន្តែត្រូវបោះពុម្ពថ្មីលើក្រដាសពណ៌ផ្សេង។

៨.៣៦.១០ ប្រសិនបើ គ.ជ.ប សម្រេចមិនយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ដែលព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ដោយបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

៨.៣៦.១០.១ ចារបដិសេធលើសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលបានព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ រួចចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៦.១០.២ ចារយល់ព្រមលើរបាយការណ៍លើកស្នើយោបល់របស់ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប និងចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គព)

ដូចមានចែងក្នុងចំណុច ៨.៣៦.៧ និងចំណុច ៨.៣៦.៧.២ ខាងលើនេះ រួចចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៦.១០.៣ ចាត់មន្ត្រីជំនាញឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធរបស់ គ.ជ.ប ចំពោះសេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតរបស់ គធ.ខប ហើយដែលត្រូវចុះហត្ថលេខា ដោយមន្ត្រីជំនាញ និងប្រធាន គ.ជ.ប ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៦.១០.៤ ធានាថា សម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមខាងលើត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ)ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣៦.១០.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបដិសេធសេចក្តីសម្រេចរបស់ គធ.ខប និងយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តនោះ ជាសេចក្តីសម្រេចចុងក្រោយ។

៨.៣៦.១០.៦ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផល សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលមានចំណាររបស់ប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តនោះ មួយមុខ ១ (មួយ) ច្បាប់ ព្រមទាំងឯកសារក្នុងស្រោមសំបុត្រធំ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីមុខការ។

៨.៣៦.១០.៧ ធានាថា ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប បានវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ពាក់ព័ន្ធដាក់ក្នុងស្បោង "ខ" រួចចងភ្ជិត និងដាក់ស្បោង "ខ" ទៅក្នុងស្បោង "ឃ" នៃរាជធានី ខេត្តតាមលំនាំដើម ដោយចាក់សោឃ្លុំមានលេខផង រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារឯកសារបោះឆ្នោតនៃ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

**ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំណុះភូមិភាគ ដែលគ្មានពាក្យបណ្តឹងតវ៉ាត្រូវបានដាក់នៅ គធ.ខប ឬ/និង គ.ជ.ប**

**ប្រការ៨.៣៧.-**

អនុលោមតាមការសម្រេចរបស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៥.១ ខាងលើនេះ ប្រសិនបើរាជធានី ខេត្តចំណុះភូមិភាគ ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីរាជធានី ខេត្តដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ឬ/និង គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៥.២.២ ខាងលើនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមនីតិវិធីដូចខាងក្រោម៖

៨.៣៧.១ ក្នុងករណីខាងលើនេះ ផ្អែកតាមការណែនាំរបស់អគ្គលេខាធិការ គ.ជ.ប ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តពាក់ព័ន្ធចំណុះភូមិភាគ ដែលក្រុមទទួលបន្ទុកដោយឡែកពីគ្នាម្តងមួយរាជធានី ខេត្ត ដោយផ្អែកលើរាល់ឯកសារពាក់ព័ន្ធដែលមាននៅក្នុងកញ្ចប់ “ឃ ពិសេស” ប៉ុណ្ណោះ និងមិនត្រូវបើកកញ្ចប់សុវត្ថិភាព “ក” ណាមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ។ ក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តចំណុះភូមិភាគណាមួយប្រធានក្រុមត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវ៖

៨.៣៧.១.១ ចាត់សមាជិកក្រុមឱ្យទៅនាំយកកញ្ចប់ ‘ឃ ពិសេស’ នៃរាជធានី ខេត្តចំណុះភូមិភាគ ដែលក្រុមទទួលបន្ទុកម្តងមួយរាជធានី ខេត្ត ពីកន្លែងរក្សាស្តុកមកដាក់នៅលើតុចំពីមុខប្រធាន។

៨.៣៧.១.២ ចាត់លេខាធិការឱ្យបញ្ជាប់ចូល (Login) ទៅក្នុងប្រព័ន្ធ ដើម្បីទាញយកទិន្នន័យដែល គធ.ខប បានបញ្ជូនមកសេវ្របករណ៍ (Server) របស់ គ.ជ.ប ដើម្បីបង្ហាញលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តលើឧបទស្សន៍កុំព្យូទ័រ (Monitor) ដើម្បីឱ្យភាគីពាក់ព័ន្ធដែលមានវត្តមានបានមើលឃើញទាំងអស់គ្នា។

៨.៣៧.១.៣ បើកកញ្ចប់ “ឃ ពិសេស” រួចដកយករាល់ស្រោមសំបុត្រដាក់តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) មកដាក់នៅលើតុ។

៨.៣៧.១.៤ ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តនីមួយៗ ដោយផ្អែកលើសំណុំឯកសារលទ្ធផលនៃការបោះឆ្នោតតាមរាជធានី ខេត្ត ដូចមានចែងក្នុងចំណុច ៨.៣៧.១.២ ខាងលើនេះ ធៀបនឹងទិន្នន័យដែលមានក្នុងប្រព័ន្ធកុំព្យូទ័រ។

៨.៣៧.១.៥ ធានាថា របាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យខាងលើនេះ ចំនួន ១ (មួយ) ច្បាប់ សម្រាប់រាជធានី ខេត្តនីមួយៗ ត្រូវបានបំពេញ និងចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ដោយត្រូវបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោម ប្រសិនបើបានរកឃើញថា៖

- តួលេខនៃលទ្ធផលដែលបានត្រួតពិនិត្យ មានភាពត្រឹមត្រូវ
- គធ.ខប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ហើយកំហុសនោះ ត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវគូសរង្វង់លើតួលេខដែលខុស ដោយរក្សាឱ្យឃើញតួលេខដែលខុសរួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានហត្ថលេខារបស់ប្រធានក្រុមផង។

៨.៣៧.១.៦ ធានាថា តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧តព) ចំនួន ១ (មួយ) ច្បាប់ ត្រូវបានបោះពុម្ពដោយមានបញ្ជាក់ច្បាស់នូវឈ្មោះភូមិភាគពាក់ព័ន្ធ និងត្រូវចុះហត្ថលេខា ដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប។

៨.៣៧.១.៧ ធានាថារបាយការណ៍ និងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧តព) ដូចបញ្ជាក់ក្នុងចំណុច ៨.៣៧.១.៥ និងចំណុច ៨.៣៧.១.៦ ខាងលើនេះ ដែលអមដោយសំណុំឯកសារ ដូចមានចែងក្នុងចំណុច ៨.៣៧.១.២ ខាងលើនេះ ត្រូវបានដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

៨.៣៧.២ ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ដែលគ្មានបណ្ដឹងទាំងអស់ចំណុះរាជធានី ខេត្ត ដោយត្រូវត្រួតពិនិត្យម្ដងមួយរាជធានី ខេត្ត រហូតដល់អស់ និងត្រូវអនុវត្តតាមនីតិវិធីដូចមានចែងចាប់ពីចំណុច ៨.៣៧.១.១ រហូតដល់ចំណុច ៨.៣៧.១.៧ ខាងលើនេះ។

៨.៣៧.៣ អគ្គលេខាធិការ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យ និងសំណុំឯកសារភ្ជាប់ជាមួយដែលបានដាក់ជូនដូចមានចែងក្នុងចំណុច ៨.៣៧.១.៧ ខាងលើនេះ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ អគ្គលេខាធិការ គ.ជ.ប ត្រូវលើកយោបល់ស្នើសុំការយល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា កាលបរិច្ឆេទ លើរបាយការណ៍ស្ដីពីលទ្ធផលនៃការត្រួតពិនិត្យ និងលើតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) និងដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

៨.៣៧.៤ ប្រសិនបើ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅភូមិភាគ ប្រធាន គ.ជ.ប ត្រូវចារយល់ព្រមលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលដូចមានចែងក្នុងចំណុច ៨.៣៧.៣ ខាងលើនេះ រួចចុះហត្ថលេខា ចុះកាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គ.ជ.ប បន្ទាប់មកប្រគល់របាយការណ៍ និងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយតាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីមុខការ។

## ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំណុះភូមិភាគដែលមានពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់ត្រូវបានដាក់នៅ គធ.ខប ឬ/និង គ.ជ.ប ហើយដែលមានកញ្ចប់សុវត្ថិភាព "ក" មួយ ឬច្រើនត្រូវបានបើក

**ប្រការ៨.៣៨.–**

អនុលោមតាមការសម្រេចរបស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៥.១ ខាងលើនេះ ប្រសិនបើរាជធានី ខេត្តចំណុះភូមិភាគ ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីរាជធានី ខេត្ត ដូចមានចែងក្នុងចំណុច ៨.៣៥.២.៣ នៃ ប.ន.ព.ស នេះ អគ្គលេខាធិការ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ទទួលបន្ទុកឱ្យធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលតាមនីតិវិធីដូចខាងក្រោម៖

៨.៣៨.១ ផ្អែកតាមការសម្រេចរបស់ គ.ជ.ប មិនឱ្យបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ

ប្រធានក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតទទួលបន្ទុក ត្រូវពិនិត្យជាមុននូវសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ឌប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ និងត្រូវធានាថា ផ្អែកលើរាល់ឯកសារដែលមាននៅក្នុងកញ្ចប់ "ឃ ពិសេស" ដូចបញ្ជាក់ក្នុងចំណុច ៨.៣១.២ នៃ ប.ន.ព.ស នេះ នីតិវិធីក្នុងជំពូកនេះ ចាប់ពីចំណុច ៨.៣៧.១.១ រហូតដល់ចំណុច ៨.៣៧.១.៧ ខាងលើនេះ ត្រូវតែបានអនុវត្ត។

៨.៣៨.២ បន្ទាប់ពីបានអនុវត្តរាល់នីតិវិធីដូចបញ្ជាក់ក្នុងចំណុច ៨.៣៨.១ ខាងលើនេះរួច អគ្គលេខាធិការ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារភ្ជាប់ជាមួយ ដែលក្រុមត្រួតពិនិត្យបានដាក់ជូនដូចមានចែងក្នុងចំណុច ៨.៣៧.១.៧ ខាងលើនេះ។ ប្រសិនបើពិនិត្យឃើញថា ត្រឹមត្រូវហើយ អគ្គលេខាធិការ គ.ជ.ប ត្រូវចារលើកយោបល់ស្នើសុំការយល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាអគ្គលេខាធិការដ្ឋាន គ.ជ.ប លើរបាយការណ៍ និងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) ហើយដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។

៨.៣៨.៣ ផ្អែកលើរបាយការណ៍ និងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយ ដូចមានចែងក្នុងចំណុច ៨.៣៨.២ ខាងលើនេះ ទោះបីមានពាក្យបណ្ដឹងដាក់នៅ គធ.ឌប ក្ដី ប៉ុន្តែគ្មានពាក្យបណ្ដឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវពិនិត្យសម្រេចយល់ព្រមតាមយោបល់របស់អគ្គលេខាធិការ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៧.២ ខាងលើនេះ។ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

៨.៣៨.៣.១ ចារយល់ព្រមលើសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ឌប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តនោះ រួចចុះហត្ថលេខា ចុះកាលបរិច្ឆេទ ឈ្មោះ និងបោះត្រា គ.ជ.ប។

៨.៣៨.៣.២ ចារយល់ព្រមលើរបាយការណ៍ស្ដីពីលទ្ធផលនៃការត្រួតពិនិត្យ និងតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គ៣) រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៨.៣.៣ ចាត់មន្ត្រីជំនាញឱ្យបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យ

បោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ហើយដែលត្រូវចុះហត្ថលេខា ដោយមន្ត្រីជំនាញ និងប្រធាន គ.ជ.ប ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៨.៣.៤ ធានាថា សម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមខាងលើនេះ ត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ (សម្រាប់ពាក្យបណ្ដឹងដាក់នៅ គ.ជ.ប) ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣៨.៣.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តនោះ ជាសេចក្តីសម្រេចចុងក្រោយ។

៨.៣៨.៣.៦ ប្រគល់របាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលមានចំណារយល់ព្រមរបស់ប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្ត មួយមុខ ១ (មួយ) ច្បាប់ ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីមុខការ។

៨.៣៨.៤ ប្រសិនបើផ្អែកតាមកម្រិតនៃភាពមិនប្រក្រតីពាក់ព័ន្ធនឹងពាក្យបណ្ដឹង ដែលអាចនាំឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ គ.ជ.ប បានសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព “ក” មួយ ឬច្រើន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ប្រធានក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតទទួលបន្ទុក ត្រូវពិនិត្យជាមុននូវពាក្យបណ្ដឹងពាក់ព័ន្ធដែលបានដាក់នៅ គ.ជ.ប និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ហើយផ្អែកលើរាល់ឯកសារដែលមាននៅក្នុងកញ្ចប់ “ឃ ពិសេស” និងស្បោង “ឃ” ពាក់ព័ន្ធ ដូចបានបញ្ជាក់ក្នុងចំណុច ៨.៣០.២ ចំណុច ៨.៣០.៥ និងចំណុច ៨.៣០.៦ នៃ ប.ន.ព.ស នេះ ត្រូវគួបផ្សំអនុវត្តឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយតាមលំនាំនីតិវិធីដូចមានចែងក្នុងជំពូកនេះ ចាប់ពីចំណុច ៨.៣៦.៣ រហូតដល់ចំណុច ៨.៣៦.៥ និងពីចំណុច ៨.៣៧.១.១ រហូតដល់ចំណុច ៨.៣៧.១.៧ ខាងលើនេះ។

៨.៣៨.៥ បន្ទាប់ពីបញ្ចប់ការអនុវត្តចំណុច ៨.៣៨.៤ ខាងលើនេះ អគ្គលេខាធិការ គ.ជ.ប ត្រូវពិនិត្យ និងលើកយោបល់លើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដូចមានចែងក្នុងចំណុច ៨.៣៧.១.៧ ខាងលើនេះ និងរបាយការណ៍ស្ដីពីការបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ដូចមានចែងក្នុងចំណុច ៨.៣៦.៥ ខាងលើនេះ ដែលក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតបានដាក់ជូន រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ពិនិត្យ សម្រេច។ អគ្គលេខាធិការ គ.ជ.ប ត្រូវ៖

៨.៣៨.៥.១ លើកយោបល់ស្នើសុំបដិសេធសម្រង់សេចក្ដីសម្រេច (ទ.១២០៣) យល់ព្រមទទួលយកលទ្ធផលរបស់ គធ.ខប និងសុំការយល់ព្រមតាមពាក្យបណ្ដឹងដាក់នៅ គ.ជ.ប ដោយត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្ត ប្រសិនបើមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលនាំឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ឬ

៨.៣៨.៥.២ លើកយោបល់ស្នើសុំយល់ព្រមតាមសម្រង់សេចក្ដីសម្រេច (ទ.១២០៣) យល់ព្រមរបស់ គធ.ខប និងសុំបដិសេធពាក្យបណ្ដឹងដាក់នៅ គ.ជ.ប ដោយត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ប្រសិនបើកម្រិតនៃភាពមិនប្រក្រតីមិននាំឱ្យផ្លាស់ប្ដូរលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតទេ។

៨.៣៨.៦ ផ្អែកលើសំណុំឯកសារដូចមានចែងក្នុងចំណុច ៨.៣៨.៥ ខាងលើនេះ ករណីមានពាក្យបណ្ដឹងដាក់នៅ គធ.ខប ផង និងមានពាក្យបណ្ដឹងដាក់នៅ គ.ជ.ប ផងនោះ គ.ជ.ប ត្រូវពិនិត្យ សម្រេចដោយផ្អែកលើសំណើរបស់អគ្គលេខាធិការ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៨.៥ ខាងលើនេះ។ ក្នុងករណីមានពាក្យបណ្ដឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវប្រជុំសម្រេចលើពាក្យបណ្ដឹងពាក់ព័ន្ធ។ ប្រសិនបើ គ.ជ.ប សម្រេចបដិសេធសេចក្ដីសម្រេចយល់ព្រមរបស់ គធ.ខប និងយល់ព្រមតាមពាក្យបណ្ដឹងដាក់នៅ គ.ជ.ប ដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ៖

៨.៣៨.៦.១ ចារបដិសេធលើសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ។

៨.៣៨.៦.២ ចាត់មន្ត្រីជំនាញឱ្យបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការបដិសេធផង ហើយដែលត្រូវចុះហត្ថលេខាដោយប្រធាន គ.ជ.ប កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៣៨.៦.៣ ធានាថា សម្រង់សេចក្ដីសម្រេច (ទ.១២០៣) បដិសេធខាងលើត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់សម្រាប់ប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ (សម្រាប់ពាក្យបណ្ដឹងដាក់នៅ គ.ជ.ប) ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៨.៣៨.៦.៤ ប្រកាសថា សេចក្ដីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្ត ជាសេចក្ដីសម្រេចចុងក្រោយហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់នៃរាជធានី ខេត្តនោះ ក្នុងរយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃបន្ទាប់ពីថ្ងៃចេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) នេះ ។

៨.៣៨.៦.៥ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងភូមិភាគ(ទ.១១១៧គ១) និងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គធ.ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តនោះមួយមុខ ១ (មួយ) ច្បាប់ តាមរយៈអគ្គលេខាធិការ គ.ជ.ប ទៅឱ្យក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប ដែលត្រូវដាក់ទៅក្នុងកញ្ចប់ “ឃ ពិសេស” នៃរាជធានី ខេត្តពាក់ព័ន្ធ។

៨.៣៨.៦.៦ ធានាថា ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប បានវេចខ្ចប់កញ្ចប់សុវត្ថិភាព “ក” ពាក់ព័ន្ធ ដោយចាក់សោឃ្លុំមានលេខ ដាក់ក្នុងស្បោង “ខ” និងក្នុងស្បោង “ឃ” នៃរាជធានី ខេត្តតាមលំនាំដើម ដោយចាក់សោឃ្លុំមានលេខផង រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

៨.៣៨.៧ យោងសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធរបស់ គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៨.៦.២ ខាងលើនេះ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់ក្នុងរាជធានី ខេត្តពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតទាំងនោះ ត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៨.១៣ នៃ ប.ន.ព.ស នេះ។ ការបោះឆ្នោតសាជាថ្មីនេះត្រូវអនុវត្តដោយផ្អែកលើបញ្ជីបោះឆ្នោតដដែល បញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយក្នុងភូមិភាគដដែល និងសន្លឹកឆ្នោតដែលមានទម្រង់និងខ្លឹមសារដដែល ប៉ុន្តែត្រូវបោះពុម្ពថ្មីលើក្រដាសពណ៌ផ្សេង។

៨.៣៨.៨ ផ្អែកលើសំណុំឯកសារត្រួតពិនិត្យលទ្ធផលដូចមានចែងក្នុងចំណុច ៨.៣៨.៥ ខាងលើនេះ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្តីសម្រេចរបស់ គធ.ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងរាជធានី ខេត្តពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវធានាថា បញ្ញត្តិ និងនីតិវិធីដូចមានចែងក្នុងចំណុច ៨.៣៨.៣ ខាងលើនេះ ត្រូវតែបានអនុវត្ត។

៨.៣៨.៩ ក្នុងការអនុវត្តចំណុច ៨.៣៨.៨ ខាងលើនេះ និងនៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលដែលមានចំណារប្រធាន គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៨.៣.៦ ខាងលើនេះ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងចំណុច ៨.៣៣.៥ នៃ ប.ន.ព.ស នេះ និងត្រូវធានាថា រាល់នីតិវិធី ដូចមានចែងចាប់ពីចំណុច ៨.៣៩.១ រហូតដល់ចំណុច ៨.៣៩.៤ ខាងក្រោមនេះ ត្រូវតែបានអនុវត្ត។

៨.៣៨.១០ នៅពេលដែលក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គធ.ខប ឬ/និង គ.ជ.ប ហើយដែលត្រូវបាន គ.ជ.ប សម្រេចបដិសេធ ឬយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាទាំងនោះរួចហើយ អគ្គលេខាធិការ គ.ជ.ប ត្រូវធានាថា ក្រុមត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតទទួលបន្ទុកតាមរាជធានី ខេត្តនីមួយៗ និង

ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានរៀបចំទុកដាក់រាល់របាយការណ៍ ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធ ដែលបានប្រើក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ខាងលើ ដោយត្រូវច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ "ឃ ពិសេស" ឬ/និងក្នុងកញ្ចប់សុវត្ថិភាព "ក" ស្បោង "ខ" និងស្បោង "ឃ" តាមលំនាំដូចដើមរួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារឯកសារបោះឆ្នោតនៃ គ.ជ.ប ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

## ការទាញទិន្នន័យ និងការផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគក្នុងប្រព័ន្ធកុំព្យូទ័រ និងការកំណត់បែងចែកអាសនៈតាមភូមិភាគនីមួយៗ

**ប្រការ៨.៣៩.-**

នៅពេលបានទទួលតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧គព) របាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំណុះភូមិភាគ ព្រមទាំងសំណុំឯកសារបោះឆ្នោតផ្សេងទៀតភ្ជាប់ជាមួយដែលត្រូវបាន គ.ជ.ប ចារយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគរួចហើយ ដូចមានចែងក្នុងចំណុច ៨.៣៦.១០.៦ ចំណុច ៨.៣៧.៤ និងចំណុច ៨.៣៨.៣.៦ ខាងលើនេះ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តភារកិច្ចរបស់ខ្លួនដែលបានកំណត់ដូចមានចែងក្នុងចំណុច ៨.៣៣.៤ និងចំណុច ៨.៣៣.៥ នៃ ប.ន.ព.ស នេះ ដើម្បីរៀបចំសេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សេចក្តីព្រាងតារាងលទ្ធផលនៃការបែងចែកអាសនៈដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមភូមិភាគត្រូវបានទទួល និងសេចក្តីព្រាងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា ដែលត្រូវដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

៨.៣៩.១ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួននៅបន្ទប់កុំព្យូទ័រនៃនាយកដ្ឋានប្រតិបត្តិការដែលមានកុំព្យូទ័រ និងបណ្តាញបរិក្ខារអេឡិចត្រូនិកគ្រប់គ្រាន់ ហើយដែលត្រូវបានបំពាក់កម្មវិធីគ្រប់គ្រងលទ្ធផលនៃការបោះឆ្នោត ដែលមានកម្មវិធីប្រតិបត្តិការបែងចែកអាសនៈដែលផ្អែកតាមរូបមន្ត និងនីតិវិធីដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ស្តីពីការបែងចែកអាសនៈ និងមានរក្សាទុកទិន្នន័យបញ្ជីបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមភូមិភាគទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

៨.៣៩.២ ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មដែលជាសមាជិកក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវធានាឱ្យមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមភូមិភាគទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា (បញ្ជីផ្លូវការ) ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការផ្ទៀងផ្ទាត់ និងស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយដែលត្រូវជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា។

៨.៣៩.៣ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងសមាជិករបស់ខ្លួនឱ្យទាញយកទិន្នន័យលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគទាំងអស់ ដោយផ្អែកតាមតារាងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ (ទ.១១១៧តព) នីមួយៗ និងរបាយការណ៍ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលត្រូវបាន គ.ជ.ប ចារយល់ព្រមរួចហើយ ព្រមទាំងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ដែល គធ.ខប បានផ្ញើជូនជាឯកសារផ្លូវការ ឬ/និងតាមអ៊ីនធឺណិត។

៨.៣៩.៤ បន្ទាប់ពីបានទាញ និងផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតពីគ្រប់រាជធានី ខេត្តចំណុះភូមិភាគទាំងអស់រួចរាល់ហើយ ប្រធានក្រុមត្រូវធានាថា សេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវតែបានផ្ទៀងផ្ទាត់ឡើងវិញ ដោយប្រៀបធៀបទៅនឹងតួលេខលទ្ធផលដែលមានក្នុងតារាងបូកសរុបលទ្ធផល និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តទាំង២៥ ចំណុះភូមិភាគទាំង៨ ដើម្បីឱ្យដឹងប្រាកដថា មានលក្ខណៈត្រឹមត្រូវហើយ។

៨.៣៩.៤.១ ប្រធានក្រុមត្រូវធានាថា សេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវបានបោះពុម្ពរួចចារបញ្ជាក់ថា ត្រឹមត្រូវ និងចុះហត្ថលេខាដោយលេខាធិការ អនុប្រធាន និងប្រធានក្រុម ដែលត្រូវដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

៨.៣៩.៤.២ ប្រធានក្រុមត្រូវបោះពុម្ពសេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាខាងលើចំនួន ៥ (ប្រាំ) ច្បាប់ ដែលត្រូវចុះហត្ថលេខាសង្ខេបដោយសមាសភាពទាំងអស់នៃក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងដាក់ភ្ជាប់ជាមួយសេចក្តីព្រាងលទ្ធផល ដូចបានចែងក្នុងចំណុច ៨.៣៩.៤.១ ខាងលើនេះ ជូនប្រធាន គ.ជ.ប ចុះហត្ថលេខា និងបោះត្រា គ.ជ.ប។

៨.៣៩.៥ នៅពេលក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានបញ្ចប់ការងាររបស់ខ្លួន ប្រធានក្រុមត្រូវធានាថា រាល់តារាងត្រួតពិនិត្យ របាយការណ៍ កំណត់ហេតុ តារាងលទ្ធផល និងឯកសារពាក់ព័ន្ធ ដែលបានប្រើក្នុងការបញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោត និងក្នុងការគណនាបែងចែកអាសនៈដូចមានចែងក្នុង

ប្រការ ៨.៣៩ ខាងលើនេះ ត្រូវតែបានច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ "ឃ ពិសេស" នៃរាជធានី ខេត្តពាក់ព័ន្ធតាមលំនាំដូចដើម រួចប្រគល់ឱ្យក្រុមទទួលសម្ភារឯកសារបោះឆ្នោតនៅ គ.ជ.ប រក្សាទុកក្នុងបន្ទប់ស្តុកវិញ។

៨.៣៩.៦ ផ្អែកលើសេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដូចមានចែងក្នុងចំណុច ៨.៣៩.៤ ខាងលើនេះ ប្រសិនបើ គ.ជ.ប បានពិនិត្យឃើញថា លទ្ធផលទាំងនោះមានលក្ខណៈត្រឹមត្រូវហើយ ប្រធាន គ.ជ.ប ត្រូវចារឯកភាព និងចុះហត្ថលេខាលើសេចក្តីព្រាងលទ្ធផល ដូចមានចែងក្នុងចំណុច ៨.៣៩.៤.១ ខាងលើនេះ ហើយត្រូវចុះហត្ថលេខា និងបោះត្រា គ.ជ.ប ផ្តល់សុពលភាពលើតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដូចមានចែងក្នុងចំណុច ៨.៣៩.៤.២ ខាងលើនេះជាផ្លូវការ។

៨.៣៩.៧ គ.ជ.ប ត្រូវចាត់ចែងឱ្យបិទផ្សាយតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដូចមានចែងក្នុងចំណុច ៨.៣៩.៤.២ ខាងលើនេះ ១ (មួយ) ច្បាប់ នៅទីស្តីការ គ.ជ.ប និងឱ្យផ្សព្វផ្សាយតារាងលទ្ធផលនេះជាសាធារណៈតាមគ្រប់រូបភាព។ ទន្ទឹមនឹងនេះ គ.ជ.ប ត្រូវចាត់ចែង និងប្រើប្រាស់តារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដូចខាងក្រោម៖

៨.៣៩.៧.១ ទូលថ្វាយព្រះមហាក្សត្រ ច្បាប់ដើម ១ (មួយ) ច្បាប់។

៨.៣៩.៧.២ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ដើម ១ (មួយ) ច្បាប់។

៨.៣៩.៧.៣ ផ្ញើជូនព្រឹទ្ធសភា ច្បាប់ចម្លង ១ (មួយ) ច្បាប់។

៨.៣៩.៧.៤ ផ្ញើជូនរដ្ឋសភា ច្បាប់ចម្លង ១ (មួយ) ច្បាប់។

៨.៣៩.៧.៥ ផ្ញើជូនរាជរដ្ឋាភិបាល ច្បាប់ចម្លង ១ (មួយ) ច្បាប់។

៨.៣៩.៧.៦ ថតចម្លង និងផ្ញើជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ១ (មួយ) ច្បាប់។

៨.៣៩.៧.៧ រក្សាទុកជាឯកសារ និងប្រើប្រាស់នៅ គ.ជ.ប ច្បាប់ដើម ២ (ពីរ) ច្បាប់។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតទៅ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ

### ប្រការ៨.៤០.-

គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាមួយផ្នែក ឬ

លទ្ធផលទាំងអស់នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដោយត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរនៅ គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៣៩.៧ ខាងលើនេះ។

៨.៤០.១ ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញមិនបានទទួលពាក្យបណ្តឹងតវ៉ាណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានការប្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាទេ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

៨.៤០.២ គណបក្សនយោបាយ ឬតំណាងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់។

៨.៤០.៣ នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង ទី២ កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់ ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

៨.៤០.៤ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

៨.៤០.៥ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថាៈ

- ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ ចុះកាលបរិច្ឆេទ និងបោះត្រា គ.ជ.ប រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

- ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៨.២៣.១ នៃ ប.ន.ព.ស នេះ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងនោះដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់
- ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងមានព័ត៌មានចាំបាច់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងការដោះស្រាយពាក្យបណ្តឹង ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

៨.៤០.៦ ចំពោះពាក្យបណ្តឹងតវ៉ាមានឯកសារ ឬភស្តុតាងគ្រប់គ្រាន់ដែលបានដាក់ប្តឹងនៅ គ.ជ.ប ស្របតាមរយៈពេលកំណត់ដូចមានចែងក្នុងប្រការ ៨.៤០ ខាងលើនេះ គ.ជ.ប ត្រូវបើកសវនាការដោះស្រាយលើពាក្យបណ្តឹងតវ៉ានោះ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។ នីតិវិធីសម្រាប់ការបើកសវនាការដោះស្រាយពាក្យបណ្តឹងតវ៉ា ដែលបានដាក់នៅ គ.ជ.ប ត្រូវបានកំណត់ដោយយោងតាមសិទ្ធិអំណាចរបស់ គ.ជ.ប និងការកំណត់ក្នុង ប.ន.ព.ស នេះ។

៨.៤០.៦.១ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមបណ្តឹងតវ៉ាដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន និងត្រូវចាត់ចែងរៀបចំឱ្យមានការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ។

៨.៤០.៦.២ ប្រសិនបើ គ.ជ.ប សម្រេចបដិសេធបណ្តឹងតវ៉ាដែលត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យ

បោះឆ្នោតនោះ ឬទាំងនោះ អ្នកប្ដឹងតវ៉ា ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាជំទាស់នឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីពេលបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) បដិសេធលើពាក្យបណ្ដឹង។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ការដាក់ ការទទួលពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៨.៥០.៧ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគ ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាទៅនឹងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ន ឬអ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) របស់ គ.ជ.ប។

៨.៥០.៨ ការដាក់ និងការទទួលពាក្យបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ការដោះស្រាយពាក្យបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៨.៥០.៩ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្ដឹងតវ៉ាក្នុងរយៈពេលពី ១០ (ដប់) ថ្ងៃ ទៅ ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង។

៨.៥០.១០ ការដោះស្រាយពាក្យបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

៨.៥០.១១ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមលើបណ្ដឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្ដីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

៨.៥០.១២ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

៨.៥០.១៣ បន្ទាប់ពីរាល់ពាក្យបណ្ដឹងតវ៉ាដែលបានដាក់នៅ គ.ជ.ប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរ គ.ជ.ប ត្រូវណែនាំក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ឱ្យកែតម្រូវតួលេខលទ្ធផល ឬ/និងណែនាំអគ្គលេខាធិការ គ.ជ.ប ឱ្យចាត់ចែងរៀបចំការបោះឆ្នោតសាជាថ្មី (ប្រសិនបើមាន) ដោយផ្អែកតាមសេចក្ដីសម្រេចស្ថាពររបស់ គ.ជ.ប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញ។ បន្ទាប់ពីបានកែតម្រូវតារាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងពិនិត្យ ផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ គ.ជ.ប ត្រូវផ្ដល់

សុពលភាពតារាងលទ្ធផលបណ្ដោះអាសន្ន ទៅជាតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៨.៤០.១៣.១ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវធានាថា សេចក្ដីព្រាងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលបានត្រួតពិនិត្យ ផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ត្រូវបានបោះពុម្ព និងចុះហត្ថលេខា ដោយលេខាធិការ អនុប្រធាន និងប្រធានក្រុម និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

៨.៤០.១៣.២ ប្រធានក្រុមត្រូវបោះពុម្ពសេចក្ដីព្រាងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាខាងលើចំនួន ៥ (ប្រាំ) ច្បាប់ ដែលត្រូវចុះហត្ថលេខាសង្ខេប ដោយសមាសភាពទាំងអស់នៃក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងដាក់ភ្ជាប់ជាមួយសេចក្ដីព្រាងតារាងលទ្ធផលដូចមានចែងក្នុងចំណុច ៨.៤០.១៣.១ ខាងលើនេះ ជូនប្រធាន គ.ជ.ប ចុះហត្ថលេខា និងបោះត្រា គ.ជ.ប ជាផ្លូវការ។

៨.៤០.១៤ ផ្អែកតាមលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដូចមានចែងក្នុងចំណុច ៨.៤០.១៣ ខាងលើនេះ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវធានាថា គាត់បានចាត់ចែងសមាជិកក្រុមឱ្យទាញយកតួលេខលទ្ធផលសំឡេងឆ្នោតគាំទ្រគណបក្សនយោបាយនីមួយៗដែលឈរឈ្មោះបោះឆ្នោតតាមភូមិភាគ ទៅក្នុងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ឬ/និងឱ្យគណនាតាមការធ្វើប្រមាណវិធីដោយដៃ ដោយផ្អែកតាមរូបមន្តក្នុងការកំណត់បែងចែកអាសនៈ ដែលកំណត់ដោយច្បាប់ និងដូចមានចែងក្នុងឧបសម្ព័ន្ធទី១ ស្ដីពីការបែងចែកអាសនៈ។ ប្រធានក្រុមត្រូវពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបែងចែកអាសនៈខាងលើរវាងការគណនាដោយដៃ និងការគណនាដោយប្រើកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ដើម្បីឱ្យដឹងប្រាកដថា លទ្ធផលនៃការគណនាទាំងពីររបៀប មានលក្ខណៈដូចគ្នា និងត្រឹមត្រូវ។

៨.៤០.១៤.១ ប្រធានក្រុមត្រូវធានាថាតារាងលទ្ធផលនៃការបែងចែកអាសនៈដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមភូមិភាគបានទទួល និងដែលបានពិនិត្យ ផ្ទៀងផ្ទាត់ត្រឹមត្រូវហើយ ត្រូវបានបោះពុម្ព និងចុះហត្ថលេខា ដោយលេខាធិការ អនុប្រធាន និងប្រធានក្រុម និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច។

៨.៤០.១៤.២ ប្រធានក្រុមត្រូវបោះពុម្ពសេចក្ដីព្រាងតារាងលទ្ធផលនៃការបែងចែកអាសនៈខាងលើចំនួន ៥ (ប្រាំ) ច្បាប់ ដែលត្រូវចុះហត្ថលេខាសង្ខេប ដោយសមាសភាពទាំងអស់នៃក្រុមកំណត់បែងចែកអាសនៈ និងដាក់ភ្ជាប់ជាមួយតារាងលទ្ធផលនៃការបែងចែកអាសនៈ ដូចបានចែងក្នុងចំណុច ៨.៤០.១៤.១ ខាងលើនេះជូនប្រធាន គ.ជ.ប ចុះហត្ថលេខា និងបោះត្រា គ.ជ.ប ជាផ្លូវការ។

៨.៤០.១៥ ផ្អែកតាមតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងតារាងលទ្ធផលនៃការបែងចែកអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមភូមិភាគត្រូវបានទទួល ប្រធានក្រុមកំណត់បែងចែកអាសនៈរួមជាមួយអនុប្រធានក្រុមត្រូវផ្ទៀងផ្ទាត់ និងស្រង់ឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតដែលត្រូវជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា និងត្រូវរៀបចំសេចក្ដីព្រាងសេចក្ដីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាចំនួន ៥ (ប្រាំ) ច្បាប់ ដែលត្រូវចុះហត្ថលេខាសង្ខេបដោយសមាសភាពទាំងអស់នៃក្រុមកំណត់បែងចែកអាសនៈរួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ដើម្បីពិនិត្យ សម្រេច ព្រមទាំងចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប។

៨.៤០.១៦ គ.ជ.ប ត្រូវចាត់ចែងឱ្យបិទផ្សាយនូវតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តារាងលទ្ធផលនៃការបែងចែកអាសនៈ និងសេចក្ដីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា ១ (មួយ) ច្បាប់ នៅទីស្ដីការ គ.ជ.ប និងឱ្យផ្សព្វផ្សាយជាសាធារណៈតាមគ្រប់រូបភាព។ ទន្ទឹមនឹងនេះ គ.ជ.ប ត្រូវចាត់ចែង និងប្រើប្រាស់តារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា តារាងលទ្ធផលនៃការបែងចែកអាសនៈ និងសេចក្ដីប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាដូចខាងក្រោម៖

៨.៤០.១៦.១ ទូលថ្វាយព្រះមហាក្សត្រ ច្បាប់ដើម ១ (មួយ) ច្បាប់។

៨.៤០.១៦.២ ផ្ញើជូនព្រឹទ្ធសភា ច្បាប់ចម្លង ១ (មួយ) ច្បាប់។

៨.៤០.១៦.៣ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ដើម ១ (មួយ) ច្បាប់។

៨.៤០.១៦.៤ ផ្ញើជូនរដ្ឋសភា ច្បាប់ចម្លង ១ (មួយ) ច្បាប់។

៨.៤០.១៦.៥ ផ្ញើជូនរាជរដ្ឋាភិបាល ច្បាប់ចម្លង ១ (មួយ) ច្បាប់។

៨.៤០.១៦.៦ ថតចម្លង និងផ្ញើជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ១ (មួយ) ច្បាប់។

៨.៤០.១៦.៧ ផ្ញើជូនបណ្ណសារដ្ឋានជាតិ ច្បាប់ចម្លង ១ (មួយ) ច្បាប់។

៨.៤០.១៦.៨ រក្សាទុកជាឯកសារ និងប្រើប្រាស់នៅ គ.ជ.ប ច្បាប់ដើម ២ (ពីរ) ច្បាប់។

# ជំពូកទី៩
# សមត្ថកិច្ចដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត
## ផ្នែកទី១
## សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង

### សមត្ថកិច្ចដោះស្រាយពាក្យបណ្តឹងក្នុងការបោះឆ្នោត

**ប្រការ៩.១.-**

គធ.ខប គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ គធ.ខប បើកការប្រជុំផ្សះផ្សា ឬ/និង បើកសវនាការ និង គ.ជ.ប ពិនិត្យសម្រេច ឬបើកសវនាការលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែពាក្យបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ។

៩.១.១ នីតិវិធីប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹងដូចមានចែងក្នុងផ្នែកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរួមមានដំណាក់កាលចុះឈ្មោះបោះឆ្នោត ដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដំណាក់កាលឃោសនាបោះឆ្នោត ដំណាក់កាលនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត។

៩.១.២ ការរាប់ចំនួនថ្ងៃតវ៉ា ឬថ្ងៃជំទាស់ និងការសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ។

៩.១.៣ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

### សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ

**ប្រការ៩.២.-**

ការប្រជុំផ្សះផ្សា ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គធ.ខប ឬ គ.ជ.ប។

៩.២.១ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គធ.ខប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬសវនាការ និងការសម្រេចរបស់ខ្លួនស្របតាមនីតិវិធីដោះស្រាយពាក្យបណ្តឹងដូចមានចែងក្នុងប្រការ ៩.៨ នៃ ប.ន.ព.ស នេះ។

៩.២.២ ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សា ហៅថា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមសវនាការ ហៅថា ក្រុមប្រឹក្សាជំនុំជម្រះ។

៩.២.២.១ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប រួមមាន៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គធ.ខប ជាសមាជិក
- មន្ត្រី លគធ.ខប ដែលត្រូវបានចាត់តាំង ជាលេខាធិការ។

៩.២.២.២ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិក គធ.ខប ទាំងមូល។

៩.២.២.៣ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មិនត្រូវមានសំឡេងអនុបវាទឡើយ។

៩.២.២.៤ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មានសិទ្ធិអំណាចកោះហៅគូភាគីឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬជំនុំជម្រះ។ ដោយឡែកសវនាការ អាចកោះហៅសាក្សីបាន។

៩.២.៣ សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គ.ជ.ប ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប អនុលោមតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

៩.២.៤ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការ ដោះស្រាយពាក្យបណ្តឹងហៅថា ក្រុមប្រឹក្សាជំនុំជម្រះ។

៩.២.៤.១ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានតែងតាំងជាគណៈលេខាធិការសវនាការ។

៩.២.៤.២ លក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃ ច.គ.ជ.ប និង បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

៩.២.៤.៣ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មិនត្រូវមានសំឡេងអនុបវាទឡើយ។

៩.២.៤.៤ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅគូភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ។

## ការប្តឹងតវ៉ា ឬការប្តឹងជំទាស់

### ប្រការ៩.៣.-

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់តាមឋានានុក្រមទៅ គធ.ឃប ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញអំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថា មានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃ ច.ប.ព.ស ច.ប.គ.រ ច.វ.ច.ប និង ប.ន.ព.ស នេះ ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែការប្តឹងតវ៉ា និងការប្តឹងជំទាស់ទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះដែលត្រូវប្តឹងដោយសាមីគណបក្សនយោបាយ ឬសាមីបេក្ខជន និងការប្តឹងទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវប្តឹងដោយមន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដែលត្រូវប្តឹងដោយគណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត។

៩.៣.១ ពាក្យបណ្តឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

៩.៣.២ ពាក្យបណ្តឹងប្តឹងពីអញ្ញាតជន ត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គធ.ឃប ឬ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងទៅអ្នកប្តឹងវិញអំពីករណីនេះ ក្នុងរយៈពេលសមស្រប។

៩.៣.៣ ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ចំពោះពាក្យបណ្តឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ចំពោះពាក្យបណ្តឹងជំទាស់)។ អ្នកប្តឹងដំបូងអាចថតចម្លងពាក្យបណ្តឹង (ទ.១២០២)

ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះ ដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជំនួសខ្លួនបាន។

៩.៣.៤ មន្ត្រីបោះឆ្នោតត្រូវប្រគល់ពាក្យបណ្តឹង (ទ.១២០២) ដល់អ្នកប្តឹង ដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ។

៩.៣.៥ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- កម្មវត្ថុនៃពាក្យបណ្តឹង
- ប្រភេទនៃអំពើល្មើស
- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង
- បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោត ដែលត្រូវបានរំលោភ
- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី (ប្រសិនបើមាន)
- ភស្តុតាងផ្សេងៗទៀត (ប្រសិនបើមាន)។

៩.៣.៦ ពាក្យបណ្តឹង (ទ.១២០២) ត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ហើយជាបន្ទាន់។

៩.៣.៧ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

## ការដកពាក្យបណ្តឹង

### ប្រការ៩.៤.-

ដើមបណ្តឹងអាចដកពាក្យបណ្តឹងទាំងមូល ឬមួយផ្នែកបាន រហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ.ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា។

៩.៤.១ ការដកពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គធ.ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងសវនាការ នោះការដកពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន។

៩.៤.២ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹង ធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ឬសវនាការ គធ.ខប ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្តឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ។

៩.៤.៣ ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្ដឹងដកពាក្យបណ្ដឹង ហើយពាក្យបណ្ដឹងនោះត្រូវបានលើកចោលតាមការស្នើសុំ។

៩.៤.៤ ប្រសិនបើដើមបណ្ដឹងដកពាក្យបណ្ដឹង ធ្វើឡើងនៅពេលកំពុងសវនាការ ក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្ដឹងចោល ដោយចេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

**ការរួមបញ្ចូលរឿងក្ដី**

**ប្រការ៩.៥.-**

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប អាចបញ្ចូលរឿងក្ដី ក្នុងករណីដែលមានពាក្យបណ្ដឹងច្រើន ប៉ុន្តែកម្មវត្ថុនៃពាក្យបណ្ដឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្ដឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ។ ប៉ុន្តែក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្ដីសម្រេចជាស្ថាពរ អ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅតែប្រព្រឹត្តល្មើសដដែលបន្តទៀត ហើយបើមានពាក្យបណ្ដឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវលើកយកមកដោះស្រាយដោយចាត់ទុកជាករណីថ្មីទៀត។

**សិទ្ធិ និងភារកិច្ចរបស់គូភាគី ដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាង**

**ប្រការ៩.៦.-**

ក្នុងករណីគូភាគីមានមេធាវី ឬតំណាងដើម្បីធ្វើជាតំណាង ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងពាក្យបណ្ដឹងដែលត្រូវចូលរួមបំភ្លឺក្នុងសវនាការនោះ ត្រូវសុំការអនុញ្ញាតជាមុនពី ប្រធានក្រុមប្រឹក្សាជំនុំជម្រះ មុនពេលបើកសវនាការ។ ចំពោះការប្រជុំផ្សះផ្សា គូភាគីអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិ តែមិនតម្រូវឱ្យមានសាក្សីទេ។

៩.៦.១ គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាងដោយមានចុះហត្ថលេខា ឬផ្ដិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃតំណាងនោះ។ តំណាងត្រូវតែជានីតិជន។

៩.៦.២ លិខិតប្រគល់សិទ្ធិត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ យ៉ាងតិច ២ (ពីរ) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ឬបើកសវនាការ។

៩.៦.៣ មេធាវី ឬតំណាងមិនអាចប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងដទៃទៀត ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ។

៩.៦.៤ ដើមបណ្តឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ។

៩.៦.៥ ដើមបណ្តឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងក្នុងរឿងក្តីរបស់ខ្លួន។

៩.៦.៦ ដើមបណ្តឹង ឬ/និងជនរងគ្រោះមានវិសមិតភាពរវាងឋានៈជាដើមបណ្តឹង ឬជនរងគ្រោះនិងឋានៈជាសាក្សី។ ដើមបណ្តឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្តល់ចម្លើយក្នុងឋានៈជាសាក្សីបានទេ។

៩.៦.៧ ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានា ដែលទាក់ទងនឹងពាក្យបណ្តឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ។

៩.៦.៨ ចុងចម្លើយត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សី ដើម្បីជាសំអាងការពាររឿងក្តីរបស់ខ្លួន។

៩.៦.៩ ចុងចម្លើយអាចបង្ហាញភស្តុតាងជាទឡ្ហីករណ៍ចុងក្រោយរបស់ខ្លួន ដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដើម្បីឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ដើមបណ្តឹង។

៩.៦.១០ មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជំនុំជម្រះក្តីក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា ឬសវនាការនេះ។ ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរពតាម ច.ប.ព.ស ច.ប.ត.រ ច.រ.ច.ប និង ប.ន.ព.ស នេះ។

៩.៦.១១ ជនណាបានប្រព្រឹត្តអំពើក្លែងលិខិត ឬឯកសារដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារក្លែងនោះ ជននោះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

៩.៦.១២ ដើមបណ្តឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ។

៩.៦.១៣ នៅក្នុងនីតិវិធីសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្តឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយ។ ចុងចម្លើយក៏អាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹង។

៩.៦.១៤ មុនពេលក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា គូភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថា មានប្រយោជន៍ដល់ខ្លួនជូនទៅក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា។

៩.៦.១៥ គូភាគីមានសិទ្ធិប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះតាមការកំណត់ក្នុង ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ។

៩.៦.១៦ ដើមបណ្ដឹង ឬចុងចម្លើយ ឬមេធាវី ឬតំណាងរបស់ភាគីអាចស្នើសុំឱ្យ គធ.ខប ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួន ដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។ ការថតចម្លងត្រូវធ្វើដោយមន្ត្រីបោះឆ្នោតដែលត្រូវបានចាត់តាំង។

## សិទ្ធិ និងភារកិច្ចរបស់សាក្សី

### ប្រការ៩.៧.-

សាក្សីត្រូវធ្វើសម្បថជាមុនហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាជំនុំជម្រះ នៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់អំពីការផ្ដន្ទាទោសចំពោះការផ្ដល់សក្ខីកម្មភូតកុហក ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត។ ទម្រង់នៃសម្បថត្រូវធ្វើដូចមានកំណត់នៅក្នុងនីតិវិធី និងខ្លឹមសារនៃសម្បថ។

៩.៧.១ សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំ ដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

៩.៧.២ សាក្សីដើមបណ្ដឹង និងសាក្សីចុងចម្លើយត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យមកបំភ្លឺដោយក្រុមប្រឹក្សាជំនុំជម្រះ។

៩.៧.៣ សាក្សីដើមបណ្ដឹង និងសាក្សីចុងចម្លើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នាទោះតាមមធ្យោបាយណាក៏ដោយ ក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមសវនាការ។

៩.៧.៤ សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្ដាប់ការសួរដេញដោលនៅក្នុងបន្ទប់សវនាការឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## នីតិវិធីប្រជុំផ្សះផ្សា ឬនីតិវិធីសវនាការ

### ប្រការ៩.៨.-

ដំណើរការប្រជុំផ្សះផ្សា ឬសវនាការត្រូវដឹកនាំ និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬសវនាការ

ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹងដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការដោះស្រាយពាក្យបណ្តឹង។

## ប្រភេទសវនាការ

៩.៨.១ ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬសវនាការតទល់ ឬសវនាការសួរដេញដោល។

៩.៨.១.១ សវនាការសង្ខេប ជាសវនាការដែលគ្មានទម្រង់ការច្រើន។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថា មានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ។

៩.៨.១.២ សវនាការតទល់ ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងពាក្យបណ្តឹង។ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាង ដើម្បីដាក់ជូនសវនាការ។

៩.៨.១.៣ សវនាការសួរដេញដោល ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផលក្នុងរឿងក្តី។ ក្នុងសវនាការប្រភេទនេះទាំងក្រុមប្រឹក្សាជំនុំជម្រះទាំងគូក្តី ជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗ ដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវសំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះ អាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

## ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬសវនាការ

៩.៨.២ ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬសវនាការគឺភាសាខ្មែរ។ ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង។

## ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ

៩.៨.៣ នៅថ្ងៃប្រជុំផ្សះផ្សា ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែង ដែលបានរៀបចំទុក។ ប្រធានអង្គុយនៅកណ្ដាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្តាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ។

៩.៨.៣.១ ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវ៖

- ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ
- ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ឬសវនាការ
- បង្គាប់លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការឱ្យរាយការណ៍អំពីវត្តមានដើមបណ្ដឹង ចុងចម្លើយ និងសាក្សី (ករណីសវនាការ)។

៩.៨.៣.២ មុននឹងចាប់ផ្ដើមផ្សះផ្សា ឬសួរដេញដោលប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរទៅដើមបណ្ដឹងថាតើលោក ឬលោកស្រីនៅតែបន្តប្ដឹងដូចមានចែងក្នុងកម្មវត្ថុនៃពាក្យបណ្ដឹង ឬមានការកែប្រែឬទេ? ប្រសិនបើ៖

- ដើមបណ្ដឹងឆ្លើយថា ខ្លួនដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបង្គាប់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ឱ្យកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្ដឹងផ្ដិតមេដៃលើកំណត់ហេតុនោះ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សាអាចផ្សះផ្សារឿងក្ដីផ្សេងទៀត (ប្រសិនបើមាន) ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយទៅពិភាក្សា ពិចារណា ឬបន្តទៅសវនាការរឿងក្ដីផ្សេងទៀត (ប្រសិនបើមាន)
- ដើមបណ្ដឹងនៅតែបន្តប្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាប់ផ្ដើមដំណើរការប្រជុំផ្សះផ្សា ឬសវនាការ។

៩.៨.៣.៣ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរដេញដោលទៅដើមបណ្ដឹងមុនរួចត្រូវសួរទៅចុងចម្លើយ។ បន្ទាប់មក ប្រធានត្រូវសួរសាក្សីដើមបណ្ដឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ រួចឱ្យភាគីដើមបណ្ដឹង និងភាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

៩.៨.៣.៤ ប្រសិនបើមានមេធាវីការពារក្ដី ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្ដល់ពេលវេលាឱ្យមេធាវីនិយាយការពារកូនក្ដី សួរភាគី និងធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ មុនក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា។

៩.៨.៣.៥ ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ឬសវនាការ ប្រសិនបើដើមបណ្ដឹងសុំដកពាក្យបណ្ដឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬសួរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្ដឹងដកពាក្យបណ្ដឹង ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះសួរពេលដំបូងដែរ។

៩.៨.៣.៦ ក្រោយពីបានដំណើរការសវនាការតាមលំដាប់លំដោយរួចហើយ ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវថយទៅពិភាក្សាពិចារណានៅក្នុងបន្ទប់សម្ងាត់។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់។

## ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ

៩.៨.៤ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការមានភារកិច្ចដូចខាងក្រោម៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប
- នាំសាក្សីទៅស្បថ (ករណីសវនាការ)
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ ឱ្យក្រោកឈរនៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្ដឹង ចុងចម្លើយ មេធាវី ឬតំណាងដែលត្រូវចូលរួមប្រជុំផ្សះផ្សា ឬសវនាការ លើកលែងតែសវនាការដែលត្រូវស្រង់វត្តមានសាក្សី

- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ
- ត្រូវសរសេរដោយដៃ ឬដោយវាយកុំព្យូទ័រនូវកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការ ក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការមិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ ពាក្យឆូតលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខារបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ និងភាគីពាក់ព័ន្ធ
- អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការបង្គាប់ពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- រៀបចំសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចចុះហត្ថលេខា ហើយដាក់ជូនប្រធានក្រុមប្រឹក្សាជំនុំជម្រះចុះហត្ថលេខា ឈ្មោះ បោះត្រានិងចុះកាលបរិច្ឆេទ
- អញ្ជើញភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការ ក្នុងករណីដែលភាគីណាមួយមិនព្រមផ្តិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។

## ពេលវេលាដោះស្រាយពាក្យបណ្តឹង

៩.៨.៥ ការប្រជុំផ្សះផ្សា ឬសវនាការអាចធ្វើជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៨:០០ (ប្រាំបី) ព្រឹក ដល់ម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទីព្រឹក និងរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) ដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី ។ ក្នុងករណីចាំបាច់ ការប្រជុំផ្សះផ្សា ឬសវនាការអាចបន្តធ្វើទៅតាមស្ថានភាពជាក់ស្តែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។ ក្នុងកម្មវិធីមួយពេលនៃការបើកប្រជុំផ្សះផ្សា ឬសវនាការលើពាក្យបណ្តឹងអាចកំណត់ធ្វើការប្រជុំផ្សះផ្សា ឬសវនាការច្រើនករណីនៃពាក្យបណ្តឹងបាន។

## ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការ

## ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ខប

៩.៨.៦ គធ.ខប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គធ.ខប ទៅតាមករណីនៃពាក្យបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ព.ស ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ។ លគធ.ខប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកការ

ប្រជុំផ្សះផ្សា ឬបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងប្រជុំផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងបើកសវនាការ។

## ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

៩.៨.៧ គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយពាក្យបណ្ដឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃពាក្យបណ្ដឹង និងទៅតាមរយៈពេលកំណត់ដូចមានចែងនៅក្នុង ច.ប.ព.ស ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវផ្ញើលិខិតអញ្ជើញអំពីការបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោង មុនពេលបើកសវនាការ។

## ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬសវនាការ

៩.៨.៨ ប្រសិនបើភាគីដើមបណ្ដឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេ នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកពាក្យបណ្ដឹងចោលដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្ដឹង។

៩.៨.៩ ប្រសិនបើភាគីដើមបណ្ដឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការទេ នោះក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំបាំងមុខដើមបណ្ដឹង ប៉ុន្តែចាត់ទុកជាចំពោះមុខ ដោយបញ្ជាក់ពីមូលហេតុលើសេចក្ដីសម្រេច។

៩.៨.១០ ប្រសិនបើភាគីដើមបណ្ដឹងស្លាប់នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

៩.៨.១១ ប្រសិនបើភាគីចុងចម្លើយស្លាប់មុនពេលបើកប្រជុំផ្សះផ្សា ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវលុបពាក្យបណ្ដឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្ដឹងឱ្យបានជ្រាប។

៩.៨.១២ ប្រសិនបើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល។

៩.៨.១៣ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននាថ្ងៃសវនាការ ក្រុមប្រឹក្សាជំនុំជម្រះត្រូវចាត់លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ព្រមទាំងស្នើសុំកិច្ចសហការពីអាជ្ញាធរឃុំ សង្កាត់អមដំណើរជាមួយ ដើម្បីបញ្ជូនសម្រង់សេចក្តីសម្រេច (ទ.១២០៣) ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬចុងចម្លើយ ឬទីស្នាក់ការគណបក្សនយោបាយរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធមិនទទួលយកសម្រង់សេចក្តីសម្រេច (ទ.១២០៣) នោះលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ឬមន្ត្រី គ.ជ.ប ត្រូវចារលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ថា "អ្នកប្តឹង ឬតំណាង ឬចុងចម្លើយ ឬតំណាងមិនព្រមទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)" ហើយចុះកាលបរិច្ឆេទ ឈ្មោះ និងហត្ថលេខា ព្រមទាំងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ដែលអមដំណើរទៅជាមួយ ដើម្បីបញ្ជាក់ថាភាគីនៃពាក្យបណ្តឹងពិតជាមិនព្រមទទួលយកសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចបិទសម្រង់សេចក្តីសម្រេច (ទ.១២០៣) នោះ នៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនៃពាក្យបណ្តឹងនោះ ហើយចាត់ទុកថាភាគីនៃពាក្យបណ្តឹងបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) រួចហើយ។

## ការប្រកាសសេចក្តីសម្រេច

៩.៨.១៤ ក្រុមប្រឹក្សាជំនុំជម្រះត្រូវប្រកាសសេចក្តីសម្រេចភ្លាម បន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះរឿងពាក្យបណ្តឹងដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយពាក្យបណ្តឹងឡើយ។ ការប្រកាសសេចក្តីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចចាត់តាំងសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន។

## ការបំពេញ និងប្រើប្រាស់ទម្រង់សម្រង់សេចក្តីសម្រេច (ទ.១២០៣)

៩.៨.១៥ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ។ សេចក្តីសម្រេចនេះ ត្រូវស្រង់ដាក់ក្នុងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ហើយត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួននិងកម្មវត្ថុនៃពាក្យបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។

៩.៨.១៦ ការបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) នៅ គធ.ខប ត្រូវធ្វើជា ៣ (បី) ច្បាប់ សម្រាប់ពាក្យបណ្ដឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្ដឹងជំទាស់ ដើម្បី៖

- ជូន ឬផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្ដឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្ដឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.៨.១៧ ការបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) នៅ គ.ជ.ប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់ពាក្យបណ្ដឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់ពាក្យបណ្ដឹងជំទាស់ ដើម្បី៖

- ជូន ឬផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្ដឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះពាក្យបណ្ដឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

## ការបញ្ជូនសម្រង់សេចក្ដីសម្រេច (ទ.១២០៣)

៩.៨.១៨ គ.ជ.ប ត្រូវចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ១ (មួយ) រូប ឱ្យទទួលបន្ទុកជាមន្ត្រីប្រគល់សម្រង់សេចក្ដីសម្រេច (ទ.១២០៣)។ សម្រង់សេចក្ដីសម្រេច (ទ.១២០៣) ត្រូវប្រគល់ជូនភាគីនៃពាក្យបណ្ដឹងភ្លាមៗ បន្ទាប់ពី គ.ជ.ប បញ្ចប់សវនាការ ហើយការប្រគល់ ទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣) នេះ ត្រូវមានកំណត់ហេតុដែលបញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការប្រគល់ ទទួលឱ្យបានច្បាស់លាស់។ កំណត់ហេតុនេះ ត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្ដីសម្រេច (ទ.១២០៣) នៃ គ.ជ.ប និងហត្ថលេខារបស់អ្នកទទួលជាក់ស្ដែង។ ក្នុងករណី៖

- ភាគីនៃពាក្យបណ្ដឹងណាមួយបដិសេធមិនព្រមទទួលយកសម្រង់សេចក្ដីសម្រេច(ទ.១២០៣)មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្ដីសម្រេច(ទ.១២០៣) នៃ គ.ជ.ប ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមទទួលយកឱ្យបានច្បាស់លាស់
- ក្នុងករណីភាគីនៃពាក្យបណ្ដឹងជាភ្នាក់ងារ ឬតំណាងគណបក្សនយោបាយ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្ដីសម្រេច (ទ.១២០៣) នៃ គ.ជ.ប ត្រូវបញ្ជូនសម្រង់សេចក្ដីសម្រេច (ទ.១២០៣) ដោយមានដីកាអមទៅ

ទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ។ កាលបរិច្ឆេទនៃការទទួលដីកាអម ត្រូវចាត់ទុកជាកាលបរិច្ឆេទទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)។

## ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ឬសវនាការ

៩.៨.១៩ គធ.ខប និង គ.ជ.ប មានទម្រង់បែបបទផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្សះផ្សា ឬសវនាការ មានជាអាទិ៍លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការ កំណត់ហេតុសាកសួរ និងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុសវនាការ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប។

៩.៨.១៩.១ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការ ត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធដែលត្រូវអញ្ជើញឱ្យចូលរួមប្រជុំផ្សះផ្សា ឬសវនាការ រួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់ៗ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.៨.១៩.២ កំណត់ហេតុសាកសួរអាចធ្វើឡើងដោយដៃ ឬដោយវាយកុំព្យូទ័រ។

៩.៨.១៩.៣ កំណត់ហេតុប្រជុំផ្សះផ្សា ត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្សះផ្សា ចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង និងលទ្ធផលនៃការផ្សះផ្សា។

៩.៨.១៩.៤ កំណត់ហេតុសវនាការ ត្រូវបំពេញដោយលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធនឹងពាក្យបណ្តឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។

៩.៨.១៩.៥ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ និងបទបញ្ជា និងនីតិវិធីពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ។ ច្បាប់ចម្លងសេចក្តីសម្រេចនេះអាចផ្តល់ជូនគូភាគីបាន ប្រសិនបើមានការស្នើសុំ។

## ផ្នែកទី២
## នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ)នៃ ច.ប.ព.ស

**ប្រការ៩.៩.-**

បទប្បញ្ញត្តិនៃផ្នែកនេះ កំណត់អំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ព.ស ប.ន.ព.ស នេះ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនជាមន្ត្រីបោះឆ្នោត ឬ/និងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬប្រព្រឹត្តដោយគណបក្សនយោបាយ ដែលអាចនាំឱ្យមានការផាកពិន័យ និងដែលអាចកើតឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា រួមទាំងនៅ ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោត។

### ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

**ប្រការ៩.១០.-**

ជនណាក៏ដោយដែលរងឥទ្ធិពល ឬដែលស្ថិតនៅកន្លែងកើតហេតុ ឬតំណាងមានសិទ្ធិដាក់ពាក្យបណ្តឹងចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ ទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។ ភាគី ឬតំណាងអាចបន្តប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប ឬបុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់ គ.ជ.ប អាចប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប។ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចមានចែងក្នុងចំណុច ៩.៣.៥ នៃ ប.ន.ព.ស នេះ។

### ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

### ការដាក់ ការទទួលពាក្យបណ្តឹងនៅ គធ.ខប

៩.១០.១ អ្នកប្តឹងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៤ (បួន) ច្បាប់។ អ្នកប្តឹងដំបូងអាចថតចម្លងពាក្យបណ្តឹង (ទ.១២០២) ដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជូសខ្លួនបាន។

៩.១០.២ នៅពេលបានទទួលពាក្យបណ្តឹង សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ទី២ កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

៩.១០.៣ បន្ទាប់មកសមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់រួចឱ្យអ្នកប្តឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោតត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។

៩.១០.៤ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថាៈ

៩.១០.៤.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

៩.១០.៤.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៩.៣.៥ នៃ ប.ន.ព.ស នេះ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិក គធ.ខប ដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់។

៩.១០.៤.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ និងមានព័ត៌មានចាំបាច់ សមាជិក គធ.ខប ដែលជាប្រធានផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និង សន្តិសុខបោះឆ្នោតត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះ ហត្ថលេខា ឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្តឹង គ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំ ផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

៩.១០.៥ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គធ.ខប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យ ជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គធ.ខប ពិនិត្យ និងយល់ឃើញថា៖

៩.១០.៥.១ ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិ នៃ ច.ប.ព.ស ឬ ច.ប.គ.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ គធ.ខប ត្រូវ ធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាងដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយ ចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេ ប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សា ទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.៥.២ កម្មវត្ថុ និងមូលហេតុនៃពាក្យបណ្តឹងមានលក្ខណៈជាបទល្មើស ព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើ បទប្បញ្ញត្តិនៃ ច.ប.ព.ស ឬ ច.ប.គ.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិត រដ្ឋបាលទៅអ្នកប្តឹង ឬតំណាងដោយបញ្ជាក់អំពីមូលហេតុ ឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.៦ ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គធ.ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យនិងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុម
- សមាជិក គធ.ខប ១ (មួយ) នាក់ ជាសមាជិក
- មន្ត្រីផ្នែកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត ១ (មួយ) នាក់ ជាលេខាធិការ។

៩.១០.៧ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្តឹង ឬតំណាង។

៩.១០.៨ បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់សព្វគ្រប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើ ច.ប.ព.ស ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.៩ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើ ច.ប.ព.ស ច.ប.ត.រ ច.វ.ច.ប និង ប.ន.ព.ស នេះ គធ.ខប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គធ.ខប។

៩.១០.១០ គធ.ខប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យគូភាគីផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ។

៩.១០.១១ ក្នុងការផ្សះផ្សា ប្រសិនបើគូភាគីទំនាស់៖

៩.១០.១១.១ ព្រមព្រៀងគ្នា គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្តិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុប្រជុំផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប។

៩.១០.១១.២ មិនព្រមព្រៀងគ្នាទេ គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ។ គធ.ខប ត្រូវកំណត់ពេលវេលា និងកាលបរិច្ឆេទបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១ (មួយ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីពេលវេលាកាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្តង។

៩.១០.១២ គធ.ខប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយមានកំណត់ហេតុសវនាការ សេចក្តីសម្រេច និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៤ (បួន) ច្បាប់ ដោយមានការចុះហត្ថលេខារបស់លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១(មួយ) ច្បាប់។

៩.១០.១៣ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី១ ជំពូកទី៩ នៃ ប.ន.ព.ស នេះ។

### ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

### ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

៩.១០.១៤ ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គធ.ខប អាចប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។

៩.១០.១៥ អ្នកប្តឹង ឬតំណាងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៤ (បួន) ច្បាប់។

៩.១០.១៦ នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង ទី២ កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ខប។

៩.១០.១៧ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃ ឬចុះហត្ថលេខា ឈ្មោះលើកំណត់ហេតុសាកសួរនេះ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខា មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនោះ។

៩.១០.១៨ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុសាកសួរ ហើយឃើញថា៖

៩.១០.១៨.១ ពាក្យបណ្តឹងមិនគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គធ.ឃប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឃប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.១៨.២ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចមានចែងក្នុងចំណុច ៩.៣.៥ នៃ ប.ន.ព.ស នេះ ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាតដោយមិនឱ្យហួសពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងនោះគ្រប់ច្បាប់ ដោយបញ្ជាក់អំពីមូលហេតុ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ឃប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.១៨.៣ ពាក្យបណ្តឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬសម្រង់សេចក្តីសម្រេច

(ទ.១២០៣) របស់ គធ.ខប និងមានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា ឈ្មោះ លើពាក្យបណ្ដឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់។

## ការដោះស្រាយពាក្យបណ្ដឹងនៅ គ.ជ.ប

៩.១០.១៩ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្ដឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា៖

៩.១០.១៩.១ ពាក្យបណ្ដឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ព.ស ឬ ច.ប.គ.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.១៩.២ កម្មវត្ថុ និងមូលហេតុនៃពាក្យបណ្ដឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ព.ស ឬ ច.ប.គ.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.១៩.៣ ពាក្យបណ្ដឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នារួចហើយនៅ គធ.ខប គ.ជ.ប ត្រូវពិនិត្យ សម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ។ ក្នុងករណីបដិសេធ គ.ជ.ប

ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្ដឹង ឬតំណាង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.១៩.៤ ពាក្យបណ្ដឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ដូចក្នុងចំណុច ៩.៣.៥ នៃ ប.ន.ព.ស នេះ គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ។

៩.១០.២០ គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ។

៩.១០.២១ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកពាក្យបណ្ដឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថាពាក្យបណ្ដឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្ដឹងដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថា ផ្ទុយពីការអះអាងក្នុងពាក្យបណ្ដឹង។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងបដិសេធតាមបែបបទរដ្ឋបាល ក្នុងរយៈពេលសមស្របមួយទៅអ្នកប្ដឹង ឬតំណាងដើម្បីជូនជ្រាបថា ពាក្យបណ្ដឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយ ហើយចុះហត្ថលេខា ឈ្មោះ បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្ដឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

៩.១០.២២ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញភស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃពាក្យបណ្ដឹង គ.ជ.ប ត្រូវដោះស្រាយពាក្យបណ្ដឹងតាមពេលវេលាសមស្រប ជាបន្ទាន់។

៩.១០.២៣ គ.ជ.ប ត្រូវសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្ដឹងដោយមានកំណត់ហេតុសេចក្ដីសម្រេច និងសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

៩.១០.២៤ សមាសភាព ការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៩ នៃ ប.ន.ព.ស នេះ។

## ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

### ការដាក់ ការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៩.១០.២៥ បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង យ៉ាងយូរ បន្ទាប់ពីបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប។

៩.១០.២៦ ការដាក់ និងការទទួលពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

៩.១០.២៧ ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការជាសាធារណៈដើម្បីពិនិត្យ និងសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ១០ (ដប់) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

៩.១០.២៨ ការដោះស្រាយពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

៩.១០.២៩ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

### ប្រការ៩.១១.-

គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើបំពានលើបទប្បញ្ញត្តិនៃ ច.ប.ព.ស ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្តឹង គ.ក.ប/គ.ក.រ ឬ គធ.ឧប ឬមន្ត្រីបោះឆ្នោត ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

៩.១១.១ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គ.ក.ប/គ.ក.រ ដំបូងត្រូវប្តឹងទៅ គធ.ឧប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងប្រការ ៩.១០ រហូតដល់ចំណុច ៩.១០.២៣ ខាងលើនេះ។

៩.១១.២ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាសភាព គធ.ឧប ឬមន្ត្រី លគធ.ឧប ឬមន្ត្រី គ.ជ.ប ត្រូវប្តឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ៩.១០.១៤ រហូតដល់ចំណុច ៩.១០.២៣ ខាងលើនេះ។

៩.១១.៣ ពាក្យបណ្តឹងពាក់ព័ន្ធនឹងសមាជិក គ.ជ.ប ត្រូវប្តឹងទៅរដ្ឋសភា ដោយអនុលោមតាម ច.គ.ជ.ប។

៩.១១.៤ ពាក្យបណ្តឹងចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្តឹង ដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ និងមិនព្រមដោះស្រាយ ពាក្យបណ្តឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលពាក្យបណ្តឹងរួចហើយ ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។ ក្នុងករណីដែលរកឃើញថា៖

៩.១១.៤.១ សមាជិក ឬមន្ត្រីនោះ ពិតជាបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ព.ស ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មផ្នែកវិន័យ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

៩.១១.៤.២ សមាជិក ឬមន្ត្រីនោះ បានគោរពតាម ច.ប.ព.ស ឬ ច.ប.ត.រ ឬ ច.វ.ច.ប ឬ ប.ន.ព.ស នេះ ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ត្រឹមត្រូវហើយត្រូវបដិសេធពាក្យបណ្តឹងនោះហើយពាក្យបណ្តឹងដែលត្រូវបានបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ។

# បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬសវនាការ
# ដោះស្រាយពាក្យបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ត្រូវគោរព និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងដូចតទៅ៖

១- ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ។

២- ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ ដូចជា៖
- ការដើរឆ្លងកាត់ ឬដើរចេញ ចូលរហោតរហូត ដោយគ្មានការអនុញ្ញាត
- ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ។

៣- ហាមក្មេងអាយុក្រោម១៨ ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ។

៤- ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ។

៥- ហាមថតរូប និងថតសំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ។

៦- ហាមប្រើប្រាស់ទូរសព្ទដៃ វិទ្យុទាក់ទង សម្ភារ បរិក្ខារអេឡិចត្រូនិកដែលអាចថតរូប វីដេអូ និងសំឡេងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ។

៧- ក្នុងករណីជនណាម្នាក់ ឬច្រើននាក់បង្កភាពណាមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់របៀបរៀបរយការប្រជុំផ្សះផ្សា ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះអាចបណ្តេញជននោះ ឬទាំងនោះ ចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់សវនាការ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពវឹកវរក្នុងពេលប្រជុំផ្សះផ្សា ឬសវនាការ ត្រូវទទួលទោសតាមច្បាប់ជាធរមាន។

# នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធានត្រូវដឹកនាំធ្វើឡើងដោយលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុស័ក្តិសិទ្ធិនៅទីកន្លែងបើក សវនាការនីមួយៗ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូបបូជានៅចំពោះមុខវត្ថុស័ក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការសវនាការ ឬសមាជិកគណៈលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗឱ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។

ក្រោយពីធ្វើសម្បថរួច លេខាធិការសវនាការ ឬគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថា បានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណាត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

## ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គជីវ័រវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ដ្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថា ជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់ តាមការណ៍ពិត។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិបំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្រេវហោមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តីបំណងប្រាថ្នា កុំបីអាក់ខានឡើយ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់បរាមុខខ្ញុំឱ្យវិនាសលាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសន្តានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

# ជំពូកទី១០
# ការបាត់បង់អាសនៈនៃព្រឹទ្ធសភា និងការជ្រើសតាំងសមាជិកជំនួស

## ការបាត់បង់អាសនៈបន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតផ្លូវការរួចហើយ

**ប្រការ១០.១.-**

បន្ទាប់ពីដំណើរការនៃការបោះឆ្នោត បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ច.គ.ជ.ប ច.ប.ព.ស និង ច.ប.ត.រ ហើយបន្ទាប់ពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយ គ.ជ.ប រួច គណបក្សនយោបាយណាមួយដែលបានទទួលអាសនៈមួយ ឬច្រើនក្នុងព្រឹទ្ធសភា ត្រូវចាត់ទុកថា បានបោះបង់ចោលអាសនៈរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម៖

១០.១.១ គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមចូលរួមសម័យប្រជុំដំបូង តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។

១០.១.២ គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមចូលរួមប្រជុំព្រឹទ្ធសភាសម្រាប់ការប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ។

១០.១.៣ គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមធ្វើសច្ចាប្រណិធានចូលកាន់តំណែង។

១០.១.៤ ក្នុងករណីដូចមានចែងក្នុងចំណុច ១០.១.១ ចំណុច ១០.១.២ និងចំណុច ១០.១.៣ ខាងលើនេះ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះ ដែលបានប្រកាសថា ជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ។

១០.១.៥ ព្រឹទ្ធសភាត្រូវជូនដំណឹងទៅ គ.ជ.ប ជាបន្ទាន់ ឬក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង។ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីព្រឹទ្ធសភា ទៅឱ្យគណបក្សនយោបាយផ្សេងដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងភូមិភាគជាមួយគ្នា ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបាត់បង់អាសនៈដូចមានចែងក្នុងចំណុច ១០.១.១ ចំណុច ១០.១.២ និងចំណុច ១០.១.៣ ខាងលើនេះ តាមជំហានទាំងឡាយដូចខាងក្រោម៖

## ការរកកូតានៃអាសនៈដែលបោះបង់ចោល

១០.១.៥.១ ជំហានទី១ : កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួល ១ (មួយ) អាសនៈ តាមរូបមន្តដូចខាងក្រោម៖

$$\text{ក'}_{\text{ត}} = \frac{\text{ស'}_{\text{ស}}}{\text{អ'}_{\text{ប}}}$$

ក្នុងនោះ៖

- $\text{ក'}_{\text{ត}}$ : តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក។
- $\text{ស'}_{\text{ស}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យគណបក្សនយោបាយផ្សេងដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ក្នុងការបោះឆ្នោតនៅក្នុងភូមិភាគ ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងភូមិភាគ។
- $\text{អ'}_{\text{ប}}$ : តាងឱ្យអាសនៈដែលបានបោះបង់ចោលនៅក្នុងភូមិភាគ។

## ការកំណត់ចំនួនអាសនៈបឋម

១០.១.៥.២ ជំហានទី២ : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលតាមរូបមន្តដូចខាងក្រោម៖

$$\text{អ'}_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក'}_{\text{ត}}}$$

ក្នុងនោះ៖

- $\text{អ'}_{\text{ទ}}$ : តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងភូមិភាគបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី៣។
- $\text{ស}_{\text{ប}}$ : តាងឱ្យសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយមួយក្នុងភូមិភាគ។
- $\text{ក'}_{\text{ត}}$ : តាងឱ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទី១។

បន្ទាប់ពីបានគណនាក្នុងជំហានទី១ គ្រប់គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងភូមិភាគ លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសនៈក្នុងភូមិភាគ ក្នុងករណីគ្មាននៅសល់អាសនៈ ដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេច ត្រូវកំណត់យកតែម្តង។

ក្នុងករណីគណនាក្នុងជំហានទី២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះ ត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី៣។

## ការបែងចែកអាសនៈនៅសល់ពីការបែងចែកជំហានទី២

១០.១.៥.៣ ជំហានទី៣ : អាសនៈដែលនៅសល់ត្រូវបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម៖

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ទ} + ១}$$

ក្នុងនោះ៖

- $ម'_{ធ}$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត។
- $ស_{ប}$ : តាងឱ្យសន្លឹកឆ្នោតបានការសរុបបោះឱ្យគណបក្សនយោបាយមួយក្នុងភូមិភាគ។
- $អ'_{ទ}$ : តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យទៅគណបក្សនយោបាយមួយ។

ក្នុងករណីដែលនៅសល់អាសនៈចំនួន ១ (មួយ) ដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទី៣ សម្រាប់គណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត។

ក្នុងករណីដែលនៅសល់អាសនៈច្រើនជាង ១ (មួយ) ដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី៣ ហើយអាសនៈចំនួន ១ (មួយ) ត្រូវបែងចែកទៅឱ្យគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត។

បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចមក ត្រូវធ្វើការប្រៀបធៀបគ្នា។ គណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតទាំងចំនួន ២ (ពីរ) ខ្ទង់ក្រោយក្បៀស) នឹងត្រូវទទួលបានអាសនៈ ១ (មួយ)។

បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ $អ'_{ទ}$ ចំនួន១(មួយ)ចំពោះគណបក្សនយោបាយដែលបានទទួលអាសនៈចំនួន ១ (មួយ) ក្នុងការអនុវត្តរូបមន្តលើកទីមួយ។ ដូច្នេះ ចំនួនអាសនៈចំនួន ១ (មួយ) ត្រូវផ្តល់ឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ក្នុងការអនុវត្តរូបមន្តលើកទីពីរ។ ក្នុងករណីនៅសល់អាសនៈ ត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសនៈម្តងមួយអាសនៈជាបន្តបន្ទាប់រហូតដល់អស់អាសនៈដែលនៅសល់។

ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សនយោបាយពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នាដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឱ្យគណបក្សនយោបាយណាមួយបានអាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោត

បានការខ្ពស់ជាងគេ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដោយ គ.ជ.ប ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុច៦ ឧបសម្ព័ន្ធទី១ ស្តីពីការបែងចែកអាសនៈ។

ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ គ.ជ.ប ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅគណបក្សនោះឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៤៨ (សែសិបប្រាំបី) ម៉ោង ក្រោយពីបានទទួលសំណើ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាខាងលើ ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះ បោះបង់ចោលអាសនៈឱ្យនៅទំនេរ។

## ការជ្រើសតាំងជំនួស

## ប្រការ១០.២.-

១០.២.១ សមាជិកព្រឹទ្ធសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម៖

១០.២.១.១ សាមីខ្លួនទទួលមរណភាព។

១០.២.១.២ សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

១០.២.១.៣ សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិកព្រឹទ្ធសភា។

១០.២.១.៤ សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

១០.២.១.៥ សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

១០.២.២ កាលបើសមាជិកព្រឹទ្ធសភាណាម្នាក់ត្រូវបាត់បង់សមាជិកភាពមានរយៈពេល ៦ (ប្រាំមួយ) ខែ យ៉ាងតិចមុនចប់នីតិកាល ស្ថាប័នដែលមានអាសនៈនៅព្រឹទ្ធសភា ឬសាមីគណបក្សនយោបាយនោះអាចស្នើចាត់តាំង ឬជ្រើសតាំងសមាជិកថ្មី ឬជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះ មកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ។

# ឧបសម្ព័ន្ធទី១

## ការបែងចែកអាសនៈ

១- អនុលោមតាម ច.ប.ព.ស ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ និងការបែងចែកអាសនៈតាមភូមិភាគ ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដូចមានចែងក្នុង ច.ប.ត.រ។

២- អាសនៈក្នុងព្រឹទ្ធសភាត្រូវបានបែងចែក ដោយផ្អែកលើចំនួនអាសនៈតាមភូមិភាគ និងលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគ។ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈ និងកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយជាប់ឆ្នោតតាមភូមិភាគនីមួយៗ។

៣- បេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាត្រូវបានប្រកាស ដោយផ្អែកតាមលំដាប់លេខរៀងនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយដែលបានជាប់ឆ្នោតនៅក្នុងភូមិភាគនីមួយៗ។

## ការកំណត់កូតា និងការបែងចែកអាសនៈ

៤- ដើម្បីបែងចែកអាសនៈតាមភូមិភាគនីមួយៗ គ.ជ.ប ត្រូវអនុវត្តតាមករណីដូចតទៅ៖

៤.១ អាសនៈនៅក្នុងភូមិភាគ ត្រូវបានបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតក្នុងភូមិភាគ តាមជំហានទាំងឡាយដូចខាងក្រោម៖

**<u>ជំហានទី១</u> : ការកំណត់កូតា** (Quota)

៤.១.១ កូតា គឺជាចំនួនសន្លឹកឆ្នោតបានការនៅក្នុងមណ្ឌលភូមិភាគនីមួយៗ ដែលកំណត់ឡើង សម្រាប់ឱ្យគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅក្នុងភូមិភាគនោះ ទទួលបាន ១ (មួយ) អាសនៈ។

៤.១.២ ដើម្បីកំណត់កូតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបក្នុងភូមិភាគពាក់ព័ន្ធចែកនឹងចំនួនអាសនៈសរុប ដែលបានកំណត់សម្រាប់ភូមិភាគនោះ។

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ៖

- $ក_{ត}$ : តាងឱ្យកូតា ជាផលចែកដោយមិនគិតសំណល់ចែក។
- $ស_{ស}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងភូមិភាគ។
- $អ_{ស}$ : តាងឱ្យចំនួនអាសនៈសរុបតាមភូមិភាគ។

**<u>ឧទាហរណ៍</u> : ការកំណត់កូតា**

នៅភូមិភាគ A មាន៖

- សន្លឹកឆ្នោតបានការសរុប ($ស_ស$) = ១.៧៦៥ សន្លឹក
- អាសនៈសរុប ($អ_ស$) = ៨ អាសនៈ

អនុវត្តតាមរូបមន្តខាងលើយើងបាន៖

$$ក_ត = \frac{ស_ស}{អ_ស} \quad \frac{១.៧៦៥}{៨} = ២២០$$

កូតាស្មើនឹង ២២០ ($ក_ត$ = ២២០)

**<u>ជំហានទី២</u> : ការកំណត់ចំនួនអាសនៈជាបឋម ឬការបែងចែកអាសនៈលើកទី១**

៤.១.៣ ដើម្បីកំណត់ចំនួនអាសនៈជាបឋមសម្រាប់គណបក្សនយោបាយនីមួយៗ ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលគណបក្សនីមួយៗទទួលបាន មកចែកនឹងកូតា ដោយមិនគិតសំណល់ចែក តាមរូបមន្តដូចខាងក្រោម៖

$$អ_ទ = \frac{ស_ប}{ក_ត}$$

ក្នុងនោះ៖

- $អ_ទ$ : គឺជាផលចែកដោយមិនគិតពីសំណល់ចែក តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ មានសិទ្ធិបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣។
- $ស_ប$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យគណបក្សណាមួយនៅក្នុងភូមិភាគ។
- $ក_ត$ : តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី១។

**<u>ឧទាហរណ៍</u> : ការបែងអាសនៈលើកទី១**

នៅភូមិភាគ A ដដែល មានគណបក្សនយោបាយឈរឈ្មោះចំនួន ៧៖

- គណបក្ស **ក** មានសន្លឹកឆ្នោតបានការ $ស_ប$ក = ១៨៣ សន្លឹក
- គណបក្ស **ខ** មានសន្លឹកឆ្នោតបានការ $ស_ប$ខ = ៣៣១ សន្លឹក
- គណបក្ស **គ** មានសន្លឹកឆ្នោតបានការ $ស_ប$គ = ៩៨ សន្លឹក
- គណបក្ស **ឃ** មានសន្លឹកឆ្នោតបានការ $ស_ប$ឃ = ៥១២ សន្លឹក
- គណបក្ស **ង** មានសន្លឹកឆ្នោតបានការ $ស_ប$ង = ២៨៥ សន្លឹក
- គណបក្ស **ច** មានសន្លឹកឆ្នោតបានការ $ស_ប$ច = ១០៤ សន្លឹក
- គណបក្ស **ឆ** មានសន្លឹកឆ្នោតបានការ $ស_ប$ឆ = ២៥២ សន្លឹក

អនុវត្តតាមរូបមន្តដូចមានចែងក្នុងចំណុច ៤.១.៣ ខាងលើនេះ យើងបាន៖

| | | | | |
|---|---|---|---|---|
| គណបក្ស **ក** | $អ_{ទូ}ក = \frac{១៨៣}{២២០}$ | = ០,៨៣ | ត្រូវជា ០ | អាសនៈ |
| គណបក្ស **ខ** | $អ_{ទូ}ខ = \frac{៣៣១}{២២០}$ | = ១,៥០ | ត្រូវជា **១** | អាសនៈ |
| គណបក្ស **គ** | $អ_{ទូ}គ = \frac{៩៨}{២២០}$ | = ០,៤៤ | ត្រូវជា ០ | អាសនៈ |
| គណបក្ស **ឃ** | $អ_{ទូ}ឃ = \frac{៥១២}{២២០}$ | = ២,៣២ | ត្រូវជា **២** | អាសនៈ |
| គណបក្ស **ង** | $អ_{ទូ}ង = \frac{២៨៥}{២២០}$ | = ១,២៩ | ត្រូវជា **១** | អាសនៈ |
| គណបក្ស **ច** | $អ_{ទូ}ច = \frac{១០៤}{២២០}$ | = ០,៤៧ | ត្រូវជា ០ | អាសនៈ |
| គណបក្ស **ឆ** | $អ_{ទូ}ឆ = \frac{២៥២}{២២០}$ | = ១,១៤ | ត្រូវជា **១** | អាសនៈ |

៤.១.៤ បន្ទាប់ពីបានគណនាបែងចែកអាសនៈ គ្រប់គណបក្សនយោបាយទាំងអស់ ក្នុងជំហានទី២ រួច ប្រសិនបើគ្មានអាសនៈនៅសល់ នោះចំនួនអាសនៈត្រូវកំណត់យកតែម្តង។

**<u>ជំហានទី៣</u> : ការកំណត់មធ្យមភាគខ្ពស់បំផុត**

៤.១.៥ ក្នុងករណីមានអាសនៈនៅសល់ គ.ជ.ប ត្រូវបន្តបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមការគណនាដូចខាងក្រោម៖

៤.១.៥.១ ត្រូវកំណត់ជាដំបូងនូវមធ្យមភាគរបស់គណបក្សនីមួយៗ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់គណបក្សនយោបាយ ចែកនឹងចំនួនអាសនៈបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួល បន្ទាប់ពីការគណនាក្នុងជំហានទី២ បូកនឹងលេខនិមិត្តចំនួន ១ តាមរូបមន្តដូចខាងក្រោម៖

$$ម_{ធ} = \frac{ស_{ប}}{អ_{ទូ} + ១}$$

លេខ១ ជាលេខនិមិត្ត

ក្នុងនោះ៖

- $ម_{ធ}$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត។
- $ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យគណបក្សនយោបាយមួយ។
- $អ_{ទូ}$ : តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យទៅគណបក្សនយោបាយមួយ។

៩.១.៥.២ ក្នុងការគណនារកមធ្យមភាគខ្ពស់បំផុតរបស់គណបក្សនយោបាយនីមួយៗ ប្រសិនបើលេខចែកមិនដាច់ ត្រូវគណនាដល់ចំនួនទសភាគ ២ ខ្ទង់ក្រោយក្បៀស ដើម្បីរកគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ។

៩.១.៥.៣ បន្ទាប់ពីកំណត់បានមធ្យមភាគខ្ពស់បំផុតរបស់គណបក្សនយោបាយនីមួយៗហើយ ត្រូវធ្វើការប្រៀបធៀបគ្នា។ គណបក្សនយោបាយណាមួយមានមធ្យមភាគខ្ពស់ជាងគេបំផុត ត្រូវទទួលបានអាសនៈ ១ (មួយ)។

**<u>ឧទាហរណ៍</u> : ការបែងអាសនៈលើកទី២**

នៅភូមិភាគ **A** ដដែល តាមការបែងចែកអាសនៈលើកទី១ យើងបាន៖

- គណបក្ស **ក** បានទទួលអាសនៈ ០
- គណបក្ស **ខ** បានទទួលអាសនៈ ១
- គណបក្ស **គ** បានទទួលអាសនៈ ០
- គណបក្ស **ឃ** បានទទួលអាសនៈ ២
- គណបក្ស **ង** បានទទួលអាសនៈ ១
- គណបក្ស **ច** បានទទួលអាសនៈ ០
- គណបក្ស **ឆ** បានទទួលអាសនៈ ១

អាសនៈដែលបានបែងចែកលើកទី១ មាន ៥ អាសនៈ

អាសនៈសរុបក្នុងភូមិភាគ **A** មាន ៨ អាសនៈ

អាសនៈនៅសល់ដែលត្រូវបន្តធ្វើការបែងចែកមាន ៣ អាសនៈ

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់ក្នុងជំហានទី៣ យើងបាន៖

គណបក្ស **ក** $ម_{ធ}ក = \frac{១៨៣}{០+១} = ១៨៣,០០$

គណបក្ស **ខ** $ម_{ធ}ខ = \frac{៣៣១}{១+១} = ១៦៥,៥០$

គណបក្ស **គ** $ម_{ធ}គ = \frac{៩៨}{០+១} = ៩៨,០០$

គណបក្ស **ឃ** $ម_{ធ}ឃ = \frac{៥១២}{២+១} = ១៧០,៦៦$

គណបក្ស **ង** $ម_{ធ}ង = \frac{២៨៥}{១+១} = ១៤២,៥០$

គណបក្ស **ច** $ម_{ធ}ច = \frac{១០៤}{០+១} = ១០៤,០០$

គណបក្ស **ឆ** $ម_{ធ}ឆ = \frac{២៥២}{១+១} = ១២៦,០០$

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំង ៧ (ប្រាំពីរ) ខាងលើ គណបក្ស **ក** មានមធ្យមភាគខ្ពស់ជាងគេ គឺ **១៨៣,០០** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះ គណបក្ស **ក** ត្រូវទទួលបានអាសនៈ ១ (មួយ)។

៤.១.៦ បន្ទាប់ពីអនុវត្តតាមរូបមន្តជំហានទី៣ អាសនៈចំនួន ១ (មួយ) ត្រូវបានបែងចែកជាលើកទី២ ទៅឱ្យគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត។

៤.១.៧ ក្នុងករណីមាននៅសល់អាសនៈ គ.ជ.ប ត្រូវបន្តបែងចែកទៀត តាមរូបមន្តជំហានទី៣ ដដែល។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈលើកទី៣**

នៅភូមិភាគ A ដដែល តាមការបែងចែកអាសនៈលើកទី២ យើងបាន៖

- គណបក្ស **ក** បានទទួលអាសនៈ ១ (ទើបបានទទួលក្នុងការបែងចែក)
- គណបក្ស **ខ** បានទទួលអាសនៈ ១ ដដែល
- គណបក្ស **គ** បានទទួលអាសនៈ ០ ដដែល
- គណបក្ស **ឃ** បានទទួលអាសនៈ ២ ដដែល
- គណបក្ស **ង** បានទទួលអាសនៈ ១ ដដែល
- គណបក្ស **ច** បានទទួលអាសនៈ ០ ដដែល
- គណបក្ស **ឆ** បានទទួលអាសនៈ ១ ដដែល

អាសនៈដែលបានបែងចែកលើកទី១ និងលើកទី២ មាន ៦ អាសនៈ

អាសនៈសរុបក្នុងភូមិភាគ A មាន ៨ អាសនៈ

ដូចនេះ អាសនៈនៅសល់ដែលត្រូវបន្តធ្វើការបែងចែកមាន ២ អាសនៈទៀត។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់ក្នុងជំហានទី៣ យើងបាន៖

គណបក្ស **ក** $ម_{ធ}ក = \frac{១៨៣}{១+១} = ៩១,៥០$

គណបក្ស **ខ** $ម_{ធ}ខ = \frac{៣៣១}{១+១} = ១៦៥,៥០$

| | | | | | |
|---|---|---|---|---|---|
| គណបក្ស | **គ** | មធគ | = ៩៨ / (០+១) | = | ៩៨,០០ |
| គណបក្ស | **ឃ** | មធឃ | = ៥១២ / (២+១) | = | ១៧០,៦៦ |
| គណបក្ស | **ង** | មធង | = ២៨៥ / (១+១) | = | ១៤២,៥០ |
| គណបក្ស | **ច** | មធច | = ១០៤ / (០+១) | = | ១០៤,០០ |
| គណបក្ស | **ឆ** | មធឆ | = ២៥២ / (១+១) | = | ១២៦,០០ |

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំង ៧ (ប្រាំពីរ) ខាងលើ គណបក្ស **ឃ** មានមធ្យមភាគខ្ពស់ជាងគេ គឺ **១៧០,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះ គណបក្ស **ឃ** ត្រូវទទួលបានអាសនៈ ១ (មួយ) នាំឱ្យ៖

- គណបក្ស **ក** បានទទួលអាសនៈ ១ ដដែល
- គណបក្ស **ខ** បានទទួលអាសនៈ ១ ដដែល
- គណបក្ស **គ** បានទទួលអាសនៈ ០ ដដែល
- គណបក្ស **ឃ** បានទទួលអាសនៈ ៣ (ទើបទទួលបន្ថែម ១ អាសនៈ)
- គណបក្ស **ង** បានទទួលអាសនៈ ១ ដដែល
- គណបក្ស **ច** បានទទួលអាសនៈ ០ ដដែល
- គណបក្ស **ឆ** បានទទួលអាសនៈ ១ ដដែល

សរុប **=** ៧ (ប្រាំពីរ) អាសនៈ

៤.១.៨ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀត ការគណនាត្រូវអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់ក្នុងជំហានទី៣ ហើយបន្តបែងចែកតាមរបៀបនេះម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈដែលនៅសល់។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈបន្ត**

នៅភូមិភាគ **A** ដដែល បន្ទាប់ពីការបែងចែកអាសនៈលើកទី៣ នៅមានសល់អាសនៈចំនួន ១ (មួយ) ទៀត ដែលត្រូវបន្តបែងចែក។



បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់ក្នុងជំហានទី៣ យើងបាន៖

| | | | | | | |
|---|---|---|---|---|---|---|
| គណបក្ស | **ក** | មធក | = | ១៨៣ / (១+១) | = | ៩១,៥០ |
| គណបក្ស | **ខ** | មធខ | = | ៣៣១ / (១+១) | = | ១៦៥,៥០ |
| គណបក្ស | **គ** | មធគ | = | ៩៨ / (០+១) | = | ៩៨,០០ |
| គណបក្ស | **ឃ** | មធឃ | = | ៥១២ / (៣+១) | = | ១២៨,០០ |
| គណបក្ស | **ង** | មធង | = | ២៨៥ / (១+១) | = | ១៤២,៥០ |
| គណបក្ស | **ច** | មធច | = | ១០៤ / (០+១) | = | ១០៤,០០ |
| គណបក្ស | **ឆ** | មធឆ | = | ២៥២ / (១+១) | = | ១២៦,០០ |

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំង ៧ (ប្រាំពីរ) ខាងលើ គណបក្ស **ខ** មានមធ្យមភាគខ្ពស់ជាងគេ គឺ **១៦៥,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះ គណបក្ស **ខ** ត្រូវទទួលបានអាសនៈ ១ (មួយ) នៅសល់ចុងក្រោយនេះ។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈក្នុងភូមិភាគ **A** យើងបាន៖

- គណបក្ស **ក** បានទទួលអាសនៈ ១
- គណបក្ស **ខ** បានទទួលអាសនៈ ២
- គណបក្ស **ឃ** បានទទួលអាសនៈ ៣
- គណបក្ស **ង** បានទទួលអាសនៈ ១
- គណបក្ស **ឆ** បានទទួលអាសនៈ ១
- គណបក្ស **គ** និង **ច** ពុំបានទទួលអាសនៈ

សរុប = ៨ (ប្រាំបី) អាសនៈ

៤.២ ក្នុងករណីការបែងចែកអាសនៈតាមជំហានទី២ ពុំមានគណបក្សនយោបាយណាមួយទទួលបានអាសនៈទេនោះ គ.ជ.ប ត្រូវបន្តបែងចែក ដោយអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទី៣ ម្តងមួយអាសនៈៗ រហូតដល់អស់អាសនៈ។

**<u>ឧទាហរណ៍</u> :**

នៅក្នុងមណ្ឌលបោះឆ្នោតភូមិភាគ **B** មានៈ

- គណបក្សនយោបាយមានចំនួន = ៥
- សន្លឹកឆ្នោតបានការសរុប $ស_{ស}$ = ៨៤៦ សន្លឹក
- អាសនៈសរុប $អ_{ស}$ = ៣ អាសនៈ
- កូតា $ក_{ត}$ = ២៨២

| គណបក្ស | $ស_{ប}$ | $អ_{ទូ}$១ លើកទី១ | $ម_{ធ}$១ | $អ_{ទូ}$ ២ លើកទី២ | $ម_{ធ}$២ | $អ_{ទូ}$៣ លើកទី៣ | $ម_{ធ}$៣ | $អ_{ទូ}$ ៤ លើកទី៤ |
|---|---|---|---|---|---|---|---|---|
| **ក** | ១៤៧ | ០ | ១៤៧<br>០+១ | ០ | ១៤៧<br>០+១ | ០ | ១៤៧<br>០+១ | ០ |
| **ខ** | ២០៣ | ០ | ២០៣<br>០+១ | ១ | ២០៣<br>១+១ | ០ | ២០៣<br>១+១ | ០ |
| **គ** | ១៨៤ | ០ | ១៨៤<br>០+១ | ០ | ១៨៤<br>០+១ | ០ | ១៨៤<br>០+១ | ១ |
| **ឃ** | ១៩៥ | ០ | ១៩៥<br>០+១ | ០ | ១៩៥<br>០+១ | ១ | ១៩៥<br>១+១ | ០ |
| **ង** | ១១៧ | ០ | ១១៧<br>០+១ | ០ | ១១៧<br>០+១ | ០ | ១១៧<br>០+១ | ០ |

ករណីនេះអាចកើតមានក្នុងភូមិភាគណាដែលគណបក្សនយោបាយឈរឈ្មោះមានចំនួនសន្លឹកឆ្នោតបានការប្រហាក់ប្រហែលគ្នា។

តាមតារាងឧទាហរណ៍ខាងលើៈ

- $ស_{ប}$ តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- $អ_{ទូ}$១ តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២ ដែលក្នុងនោះពុំមានគណបក្សនយោបាយណាមួយទទួលបានអាសនៈ និងត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣។
- $ម_{ធ}$១ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនីមួយៗដែលក្នុងនោះគណបក្ស **ខ** មានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត។
- $អ_{ទូ}$២ តាងឱ្យអាសនៈដែលគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី២ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅគណបក្ស **ខ**។

- $ម_{ធ}$២ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ របស់គណបក្សនីមួយៗដែលក្នុងនោះគណបក្ស **ឃ** មានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត។
- $អ_{ទ}$៣ តាងឱ្យអាសនៈ ដែលគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៣ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅគណបក្ស **ឃ**។
- $ម_{ធ}$៣ តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី៣ របស់គណបក្សនីមួយៗដែលក្នុងនោះគណបក្ស **គ** មានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត។
- $អ_{ទ}$៤ តាងឱ្យអាសនៈ ដែលគណបក្សនីមួយៗទទួលបាន ក្នុងការបែងចែកលើកទី៤ ក្នុងនោះអាសនៈចំនួន ១ (មួយ) ត្រូវបានទៅគណបក្ស **គ**។

ផ្អែកតាមលទ្ធផលនៃការបែងចែកអាសនៈក្នុងភូមិភាគ **B** យើងបាន៖

- គណបក្ស **ខ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **គ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ឃ** ទទួលបាន ១ (មួយ) អាសនៈ

សរុប = ៣ (បី) អាសនៈ។

## ករណីគណបក្សនយោបាយជាប់ឆ្នោតណាមួយបោះបង់ចោលអាសនៈ ឬអាសនៈនៅទំនេរ

៥- ក្នុងករណីដែលគណបក្សនយោបាយណាមួយបានទទួលអាសនៈមួយ ឬច្រើនក្នុងព្រឹទ្ធសភា ប៉ុន្តែបានប្រកាសបោះបង់ចោលអាសនៈដែលខ្លួនបានទទួល ឬត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយតាមច្បាប់ស្តីពីគណបក្សនយោបាយ គ.ជ.ប ត្រូវបែងចែកអាសនៈដែលបោះបង់ចោល ឬនៅទំនេរនោះទៅឱ្យគណបក្សនយោបាយផ្សេងទៀត ដែលមានអាសនៈនៅក្នុងភូមិភាគពាក់ព័ន្ធ ក្នុងអំឡុងពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីថ្ងៃទទួលបានលិខិតបោះបង់អាសនៈចោល ឬលិខិតលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយជាផ្លូវការ ឬបន្ទាប់ពីថ្ងៃត្រូវបានចាត់ទុកថា បោះបង់ចោលអាសនៈឱ្យនៅទំនេរ ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយដូចខាងក្រោម៖

### <u>ជំហានទី១</u> : ការកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ

៥.១ ដើម្បីកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ សម្រាប់ឱ្យគណបក្សនយោបាយឈ្នះឆ្នោតក្នុងភូមិភាគពាក់ព័ន្ធទទួលបាន ១ (មួយ) អាសនៈ ត្រូវយកសន្លឹកឆ្នោតបានការសរុបរបស់គណបក្សនយោបាយដែលបានទទួលអាសនៈក្នុងភូមិភាគនោះ ដកចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ រួចយកមកចែកនឹងចំនួនអាសនៈដែលបោះបង់ចោល ឬនៅទំនេរ តាមរូបមន្តដូចខាងក្រោម៖

$$ក'_{ត} = \frac{ស'_{ប}}{អ'_{ប}}$$

ក្នុងនោះ៖

- $ក'_{ត}$ : តាងឱ្យកូតានៃអាសនៈដែលបោះបង់ចោល ឬនៅទំនេរ ដែលជាផលចែកមិនគិតសំណល់ចែក។
- $ស'_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបរបស់គណបក្សនយោបាយទាំងអស់ដែលបានទទួលអាសនៈក្នុងមណ្ឌលភូមិភាគពាក់ព័ន្ធ ដកចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយណាដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជី។
- $អ'_{ប}$ : តាងឱ្យចំនួនអាសនៈដែលបោះបង់ចោល ឬនៅទំនេរ។

**<u>ឧទាហរណ៍</u> : ការកំណត់កូតានៃអាសនៈដែលបានបោះបង់ចោល**

នៅក្នុងមណ្ឌលភូមិភាគ **A** ដដែល៖

- គណបក្ស **ក** បានទទួលអាសនៈ ១
- គណបក្ស **ខ** បានទទួលអាសនៈ ២
- គណបក្ស **ឃ** បានទទួលអាសនៈ ៣
- គណបក្ស **ង** បានទទួលអាសនៈ ១
- គណបក្ស **ឆ** បានទទួលអាសនៈ ១
- គណបក្ស **គ** និង **ច** ពុំបានទទួលអាសនៈ

គណបក្សនយោបាយ **ខ** បានបោះបង់ចោលអាសនៈទាំង ២ (ពីរ)។

គណបក្សនយោបាយដែលបានទទួលអាសនៈក្នុងភូមិភាគ **A** មាន ៥ គឺគណបក្សនយោបាយ **ក ខ ឃ ង** និង **ឆ**។

នៅពេលដែលគណបក្សនយោបាយ **ខ** បានបោះបង់ចោលអាសនៈរបស់ខ្លួន អាសនៈដែលបោះបង់ចោលនោះត្រូវយកមកបែងចែកឱ្យគណបក្សនយោបាយ **ក ឃ ង** និង **ឆ** ដែលមានអាសនៈក្នុងភូមិភាគ **A** រីឯគណបក្ស **គ** និង **ច** ដែលពុំបានទទួលអាសនៈក្នុងភូមិភាគនោះ មិនត្រូវបានរាប់បញ្ចូលក្នុងការបែងចែកអាសនៈ ដែលគណបក្ស **ខ** បានបោះបង់ចោលឡើយ។

អនុវត្តតាមរូបមន្តក្នុងចំណុច ៥.១ យើងបាន៖

$ស'_{ប}$ = (១៨៣+៣៣១+៥១២+២៨៥+២៥២)-៣៣១ = ១.២៣២ សន្លឹក

$អ'_{ប}$ = ២ អាសនៈ

$$ក'_{ត} = \frac{ស'_{ប}}{អ'_{ប}} = \frac{១.២៣២}{២} = ៦១៦$$

កូតាស្មើនឹង ៦១៦ ($ក'_{ត}$ = ៦១៦)។

## ជំហានទី២ : ការកំណត់ចំនួនអាសនៈដែលបោះបង់ចោល ឬនៅទំនេរលើកទី១

៥.២ ដើម្បីកំណត់ចំនួនដំបូងនៃអាសនៈដែលត្រូវបានបោះបង់ចោល ឬនៅទំនេរឱ្យទៅគណបក្សដែលមានអាសនៈក្នុងភូមិភាគ ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលគណបក្សនីមួយៗបានទទួល មកចែកនឹងកូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ តាមរូបមន្តដូចខាងក្រោម៖

$$អ'_{ទូ} = \frac{ស_{ប}}{ក'_{គ}}$$

ក្នុងនោះ៖

- $អ'_{ទូ}$ : តាងឱ្យចំនួនអាសនៈដែលបោះបង់ចោល ឬនៅទំនេរ ដែលគណបក្សនីមួយៗបានទទួលក្នុងការបែងចែកលើកទី១ តាមរូបមន្តជំហានទី២។
- $ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- $ក'_{គ}$ : តាងឱ្យកូតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរដែលបានកំណត់ក្នុងជំហានទី១។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី១**

នៅក្នុងមណ្ឌលភូមិភាគ **A** ដដែល។

បន្ទាប់ពីអនុវត្តការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោល តាមរូបមន្តក្នុងជំហានទី២ យើងបាន៖

គណបក្ស **ក** $អ'_{ទូ}ក = \frac{១៨៣}{៦១៦} = ០,២៩$

គណបក្ស **ឃ** $អ'_{ទូ}ឃ = \frac{៥១២}{៦១៦} = ០,៨៣$

គណបក្ស **ង** $អ'_{ទូ}ង = \frac{២៨៥}{៦១៦} = ០,៤៦$

គណបក្ស **ឆ** $អ'_{ទូ}ឆ = \frac{២៥២}{៦១៦} = ០,៤០$

តាមការគណនាខាងលើ ពុំមានគណបក្សណាមួយទទួលបានអាសនៈ ដែលត្រូវបានបោះបង់ចោលនេះទេ។

៥.៣ ក្នុងករណីគ្មានអាសនៈនៅសល់សម្រាប់បែងចែកបន្ត បន្ទាប់ពីការបែងចែកលើកទី១ តាមរូបមន្តក្នុងជំហានទី២ ចំនួនអាសនៈដែលគណបក្សនយោបាយបានទទួលក្នុងភូមិភាគពាក់ព័ន្ធ ត្រូវកំណត់យកតែម្តង។

**<u>ជំហានទី៣</u> : ការកំណត់មធ្យមភាគខ្ពស់បំផុត**

៥.៤ ក្នុងករណី បន្ទាប់ពីការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោល ឬនៅទំនេរលើកទី១ តាមរូបមន្តជំហានទី២ ពុំមានគណបក្សណាមួយទទួលបានអាសនៈ ឬនៅមានសល់អាសនៈ អាសនៈដែលមាន ឬនៅសល់នោះ ត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ ខាងក្រោមនេះ។

៥.៤.១ ដើម្បីគណនារកមធ្យមភាគ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់គណបក្សនីមួយៗ ចែកនឹងចំនួនអាសនៈដែលគណបក្សពាក់ព័ន្ធបានទទួលបន្ទាប់ពីការបែងចែកលើកទី១ ក្នុងជំហានទី២ បូកនឹងលេខនិមិត្តចំនួនមួយតាមរូបមន្តខាងក្រោម៖

$$\text{ម’}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ’}_{\text{ទូ}}+\text{១}}$$

លេខ១ ជាលេខនិមិត្ត

ក្នុងនោះ៖

- $\text{ម’}_{\text{ធ}}$ : តាងឱ្យមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ។
- $\text{ស}_{\text{ប}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- $\text{អ’}_{\text{ទូ}}+\text{១}$ : តាងឱ្យចំនួនអាសនៈដែលបោះបង់ចោល ឬនៅទំនេរដែលគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ បូកនឹងលេខនិមិត្តចំនួនមួយ។

៥.៤.២ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗហើយ ត្រូវធ្វើការប្រៀបធៀបគ្នា។ គណបក្សនយោបាយណាមានមធ្យមភាគធំជាងគេដែលជាមធ្យមភាគខ្ពស់បំផុត នឹងត្រូវទទួលបានអាសនៈ ១ (មួយ)។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី២**

នៅក្នុងមណ្ឌលភូមិភាគ **A** ដដែល។

បន្ទាប់ពីការបែងចែកលើកទី១ តាមរូបមន្តក្នុងជំហានទី២ ពុំមានគណបក្សណាមួយបានទទួលអាសនៈដែលត្រូវបានបោះបង់ចោលទេ។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

| | | | | | |
|---|---|---|---|---|---|
| គណបក្ស **ក** | ម'ធក | = | ១៨៣ / ០+១ | = | ១៨៣,០០ |
| គណបក្ស **ឃ** | ម'ធឃ | = | ៥១២ / ០+១ | = | ៥១២,០០ |
| គណបក្ស **ង** | ម'ធង | = | ២៨៥ / ០+១ | = | ២៨៥,០០ |
| គណបក្ស **ឆ** | ម'ធឆ | = | ២៥២ / ០+១ | = | ២៥២,០០ |

តាមការប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំង ៤ (បួន) ខាងលើ គណបក្ស **ឃ** មានមធ្យមភាគធំជាងគេគឺ **៥១២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះ គណបក្ស **ឃ** ត្រូវទទួលបានអាសនៈដែលត្រូវបានបោះបង់ចោលចំនួន ១ (មួយ)។

៥.៤.៣ ប្រសិនបើនៅមានសល់អាសនៈ បន្ទាប់ពីការបែងចែកលើកទី២ អាសនៈដែលនៅសល់នោះត្រូវបន្តបែងចែកម្តងមួយអាសនៈៗរហូតដល់អស់អាសនៈ តាមរូបមន្តក្នុងជំហានទី៣ ដដែល។

**<u>ឧទាហរណ៍</u> : ការបែងចែកអាសនៈ ដែលត្រូវបានបោះបង់ចោលលើកទី៣**

នៅក្នុងមណ្ឌលភូមិភាគ **A** ដដែល។

បន្ទាប់ពីការបែងចែកលើកទី២ តាមរូបមន្តក្នុងជំហានទី៣ នៅមានសល់អាសនៈ ១ (មួយ) ទៀត ត្រូវបន្តបែងចែក។

បន្ទាប់ពីអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទី៣ យើងបាន៖

| | | | | | |
|---|---|---|---|---|---|
| គណបក្ស **ក** | ម'ធក | = | ១៨៣ / ០+១ | = | ១៨៣,០០ |
| គណបក្ស **ឃ** | ម'ធឃ | = | ៥១២ / ១+១ | = | ២៥៦,០០ |
| គណបក្ស **ង** | ម'ធង | = | ២៨៥ / ០+១ | = | ២៨៥,០០ |
| គណបក្ស **ឆ** | ម'ធឆ | = | ២៥២ / ០+១ | = | ២៥២,០០ |

តាមការប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងបួនខាងលើ គណបក្ស **ង** មានមធ្យមភាគធំជាងគេគឺ **២៨៥,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះគណបក្ស **ង** ត្រូវទទួលបានអាសនៈ ដែលត្រូវបានបោះបង់ចោល ចំនួន ១ (មួយ)។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលភូមិភាគ **A**៖

- គណបក្ស **ក** បានទទួលអាសនៈ ១
- គណបក្ស **ឃ** បានទទួលអាសនៈ ៤
- គណបក្ស **ង** បានទទួលអាសនៈ ២
- គណបក្ស **ឆ** បានទទួលអាសនៈ ១

សរុប = ៨ (ប្រាំបី) អាសនៈ។

## ករណីលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន

៦- ក្នុងករណីដែលការគណនាតាមរូបមន្តបែងចែកអាសនៈដូចមានចែងក្នុងចំណុច ៥.១.៥ និងចំណុច ៥.៤ នៃឧបសម្ព័ន្ធនេះ មានលទ្ធផលមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន នោះការបែងចែកអាសនៈត្រូវកំណត់ដូចខាងក្រោម៖

៦.១ ក្នុងករណីអាសនៈមាននៅសល់តែមួយគត់ ហើយគណបក្សនយោបាយមួយចំនួនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុត (ចែកដល់ចំនួនទសភាគ ២ ខ្ទង់ក្រោយក្បៀស) ស្មើគ្នា អាសនៈដែលនៅសល់នោះ ត្រូវផ្តល់ជូនទៅគណបក្សនយោបាយណាដែលមានចំនួនសន្លឹកឆ្នោតបានការច្រើនជាងគេ។

**<u>ឧទាហរណ៍</u>** :

នៅក្នុងមណ្ឌលភូមិភាគ **C** មាន៖

- គណបក្សនយោបាយចំនួន = ៦
- សន្លឹកឆ្នោតបានការសរុប ស$_{ស}$ = ៩៦៤ សន្លឹក
- អាសនៈសរុប អ$_{ស}$ = ៦ អាសនៈ
- កូតា ក$_{ត}$ = ១៦០

| គណបក្ស | ស$_{ប}$ | អ$_{ទ}$១ លើកទី១ | ម$_{ធ}$១ | អ$_{ទ}$២ លើកទី២ | ម$_{ធ}$២ | អ$_{ទ}$៣ លើកទី៣ |
|---|---|---|---|---|---|---|
| **ក** | ១៧២ | ១ | ១៧២ / (១+១) = ៨៦,០០ | ០ | ១៧២ / (១+១) = ៨៦,០០ | ០ |
| **ខ** | ៨៤ | ០ | ៨៤ / (០+១) = ៨៤,០០ | ០ | ៨៤ / (០+១) = ៨៤,០០ | ០ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **គ** | ៣៧៤ | ២ | ៣៧៤ / ២+១ | = | ១២៤,៦៦ | ១ | ៣៧៤ / ៣+១ | = | ៩៣,៥០ | ១ |
| **ឃ** | ៧១ | ០ | ៧១ / ០+១ | = | ៧១,០០ | ០ | ៧១ / ០+១ | = | ៧១,០០ | ០ |
| **ង** | ១៨៧ | ១ | ១៨៧ / ១+១ | = | ៩៣,៥០ | ០ | ១៨៧ / ១+១ | = | ៩៣,៥០ | ០ |
| **ច** | ៧៦ | ០ | ៧៦ / ០+១ | = | ៧៦,០០ | ០ | ៧៦ / ០+១ | = | ៧៦,០០ | ០ |

- $ស_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- $អ_{ទ}១$ : តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ ទទួលបានក្នុងការបែងចែកលើកទី១។
- $ម_{ធ}១$ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស **គ** មានមធ្យមភាគធំជាងគេគឺ **១២៤,៦៦** ដែលជាមធ្យមភាគខ្ពស់បំផុត។
- $អ_{ទ}២$ : តាងឱ្យចំនួនអាសនៈដែលគណបក្សនីមួយៗទទួលបាន បន្ទាប់ពីការបែងចែកលើកទី២ ដែលក្នុងនោះគណបក្ស គ ត្រូវបានទទួលអាសនៈ ១(មួយ) បន្ថែមទៀត។
- $ម_{ធ}២$ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ របស់គណបក្សនីមួយៗដែលក្នុងនោះគណបក្ស **គ** និង **ង** មានមធ្យមភាគធំជាងគេស្មើគ្នាគឺ **៩៣,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត ប៉ុន្តែដោយគណបក្ស **គ** មានសន្លឹកឆ្នោតបានការចំនួន ៣៧៤ សន្លឹក ច្រើនជាងគណបក្ស **ង** ដែលមានតែ ១៨៧ សន្លឹក ដូចនេះអាសនៈដែលនៅសល់ ១ (មួយ) ចុងក្រោយត្រូវផ្តល់ជូនទៅគណបក្ស **គ**។

លទ្ធផលសម្រេចគឺៈ

- គណបក្ស **ក** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **គ** ទទួលបាន ៤ (បួន) អាសនៈ
- គណបក្ស **ង** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ខ ឃ** និង **ច** ពុំបានទទួលអាសនៈ។

សរុប = ៦ (ប្រាំមួយ) អាសនៈ។

៦.២ ក្នុងករណីចំនួនអាសនៈនៅសល់ត្រូវបែងចែកបន្តមានចំនួនស្មើគ្នា ឬលើសបើប្រៀបធៀបទៅនឹងចំនួនគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុត

ស្មើគ្នានោះ គ.ជ.ប ត្រូវបែងចែកអាសនៈដែលនៅសល់ឱ្យទៅគណបក្សនយោបាយស្មើគ្នាទាំងនោះ ១ (មួយ) អាសនៈដូចគ្នា។ ហើយបើមាននៅសល់អាសនៈទៀត ត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដដែល។

<u>**ឧទាហរណ៍**</u> :

នៅក្នុងភូមិភាគ **D** មាន៖

- គណបក្សនយោបាយចំនួន = ៧
- សន្លឹកឆ្នោតបានការសរុប ស$_{ស}$ = ២.៣១៩ សន្លឹក
- អាសនៈសរុប អ$_{ស}$ = ៩ អាសនៈ
- កូតា ក$_{ត}$ = ២៥៧

| គណបក្ស | ស$_{ប}$ | អ$_{ទ}$១ លើកទី១ | ម$_{ធ}$១ | | អ$_{ទ}$២ លើកទី២ | ម$_{ធ}$២ | | អ$_{ទ}$៣ លើកទី៣ |
|---|---|---|---|---|---|---|---|---|
| **ក** | ៥០១ | ១ | ៥០១ / ១+១ = | ២៥០,៥០ | ១ | ៥០១ / ២+១ = | ១៦៧,០០ | ០ |
| **ខ** | ២៦១ | ១ | ២៦១ / ១+១ = | ១៣០,៥០ | ០ | ២៦១ / ១+១ = | ១៣០,៥០ | ០ |
| **គ** | ២០២ | ០ | ២០២ / ០+១ = | ២០២,០០ | ០ | ២០២ / ០+១ = | ២០២,០០ | ១ |
| **ឃ** | ២៥៩ | ១ | ២៥៩ / ១+១ = | ១២៩,៥០ | ០ | ២៥៩ / ១+១ = | ១២៩,៥០ | ០ |
| **ង** | ៥១ | ០ | ៥១ / ០+១ = | ៥១,០០ | ០ | ៥១ / ០+១ = | ៥១,០០ | ០ |
| **ច** | ១.០០២ | ៣ | ១.០០២ / ៣+១ = | ២៥០,៥០ | ១ | ១.០០២ / ៤+១ = | ២០០,៤០ | ០ |
| **ឆ** | ៤៣ | ០ | ៤៣ / ០+១ = | ៤៣,០០ | ០ | ៤៣ / ០+១ = | ៤៣,០០ | ០ |

- ស$_{ប}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- អ$_{ទ}$១ : តាងឱ្យចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១។
- ម$_{ធ}$១ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស **ក** និង **ច** មានមធ្យមភាគធំជាងគេ

ស្មើគ្នាគឺ **២៥០,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះអនុវត្តតាមចំណុច ៦.២ ខាងលើនេះ គ.ជ.ប ត្រូវបែងចែកអាសនៈឱ្យទៅគណបក្ស **ក** មួយ (១) អាសនៈ និងគណបក្ស **ច** ១ (មួយ) អាសនៈ។

- អ$_{ទ}$២ : តាងឱ្យចំនួនអាសនៈ ដែលគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះគណបក្សនយោបាយ **ក** និង **ច** ត្រូវទទួលបានអាសនៈ១ (មួយ) អាសនៈដូចគ្នា។
- ម$_{ធ}$២ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី២ របស់គណបក្សនីមួយៗដែលក្នុងនោះគណបក្ស **គ** មានមធ្យមភាគធំជាងគេគឺ **២០២,០០** ដែលជាមធ្យមភាគខ្ពស់បំផុត។
- អ$_{ទ}$៣ : តាងឱ្យចំនួនអាសនៈ ដែលគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី៣ ក្នុងនោះអាសនៈដែលនៅសល់មួយចុងក្រោយ ត្រូវផ្តល់ជូនទៅគណបក្ស **គ**។

លទ្ធផលសម្រេចក្នុងមណ្ឌលភូមិភាគ **D** គឺៈ

- គណបក្ស **ក** ទទួលបាន ២ (ពីរ) អាសនៈ
- គណបក្ស **ខ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **គ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ឃ** ទទួលបាន ១ (មួយ) អាសនៈ
- គណបក្ស **ច** ទទួលបាន ៤ (បួន) អាសនៈ
- គណបក្ស **ង** និង **ឆ** ពុំបានទទួលអាសនៈ

សរុប = ៩ (ប្រាំបួន) អាសនៈ។

**ករណីគណបក្សនយោបាយមួយចំនួនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងចំនួនសន្លឹកឆ្នោតបានការស្មើគ្នា ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ**

៧- ក្នុងករណីលទ្ធផលនៃការគណនារកមធ្យមភាគខ្ពស់បំផុតស្មើគ្នា ហើយចំនួនសន្លឹកឆ្នោតបានការក៏ស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន ដែលមិនអាចកំណត់ឱ្យគណបក្សនយោបាយណាមួយបានទទួលអាសនៈដែលត្រូវបែងចែក គ.ជ.ប ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់យកគណបក្សនយោបាយណាដែលត្រូវបានទទួលអាសនៈ ដែលនៅសល់តែមួយគត់ចុងក្រោយ។

៧.១ ករណីនេះ គ.ជ.ប ត្រូវប្រគល់ភារកិច្ចឱ្យនាយកដ្ឋានប្រតិបត្តិការចាត់ចែងរៀបចំពិធីចាប់ឆ្នោតជាសាធារណៈ។

៧.២ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើ នៅក្រោយពេលបញ្ចប់ការគណនាបែងចែកអាសនៈ តាមភូមិភាគទូទាំងប្រទេសនៅ គ.ជ.ប។ គ.ជ.ប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីចាប់ឆ្នោតជាសាធារណៈ ហើយត្រូវនិមន្ត និងអញ្ជើញៈ

- ព្រះសង្ឃ
- តំណាងផ្លូវការនៃគណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោត
- អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដើម្បីចូលរួមក្នុងពិធីចាប់ឆ្នោតនេះ។

៧.៣ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមជំហានដូចខាងក្រោមៈ

- អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវបោះពុម្ពនៅលើក្រដាសដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នានូវឈ្មោះនៃគណបក្សនយោបាយទាំងឡាយដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងមានសន្លឹកឆ្នោតបានការស្មើគ្នា។ ក្រដាសឆ្នោតមួយសន្លឹកត្រូវបោះពុម្ពឈ្មោះតែមួយគណបក្សនយោបាយប៉ុណ្ណោះ។ តួអក្សរឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទទំហំ និងពណ៌ដូចគ្នា។ ក្រដាសដែលបោះពុម្ពឈ្មោះគណបក្សនយោបាយរួចហើយ ត្រូវបត់ជាផ្នត់ដូចគ្នាដាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទ ពណ៌ និងទំហំដូចគ្នា រួចបិទភ្ជិត និងមូរចងនឹងកៅស៊ូកងពណ៌ដូចគ្នា។
- មន្ត្រីទទួលខុសត្រូវការចាប់ឆ្នោត ត្រូវបង្ហាញហិបឆ្នោតទទេជាសាធារណៈមុននឹងដាក់សំបុត្រសន្លឹកឆ្នោតទៅក្នុងហិបនោះ និងបិទគម្រប។
- មន្ត្រីទទួលខុសត្រូវការចាប់ឆ្នោតត្រូវក្រឡុកហិបឆ្នោត រួចហើយលើកហិបឆ្នោតនោះទៅដាក់លើតុមួយខ្ពស់។
- និមន្តព្រះសង្ឃចាប់យកសំបុត្រសន្លឹកឆ្នោតមួយពីក្នុងហិបឆ្នោត រួចប្រគល់ជូនទៅប្រធាន ឬតំណាង គ.ជ.ប។
- ប្រធាន ឬតំណាង គ.ជ.ប ដែលត្រូវបានចាត់តាំង ត្រូវបើកស្រោមសំបុត្រសន្លឹកឆ្នោតនោះជាសាធារណៈ រួចអានប្រកាសឈ្មោះគណបក្សនយោបាយដែលឈ្នះឆ្នោត និងលើកបង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ដែលបានចូលរួមក្នុងពិធីចាប់ឆ្នោតបានឃើញច្បាស់ថា ឈ្មោះគណបក្សនយោបាយដែលបានប្រកាសដូចគ្នានឹងឈ្មោះគណបក្សនយោបាយដែលបានបោះពុម្ពលើសន្លឹកឆ្នោតនោះប្រាកដមែន។

៧.៤ អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោតនេះ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង តំណាងចូលរួម (គ.ជ.ប តំណាងគណបក្សនយោបាយដែលបានចូលរួមបោះឆ្នោតក្នុងភូមិភាគ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ...) ដំណើរការចាប់ឆ្នោត និងលទ្ធផលនៃការចាប់ឆ្នោត។

៧.៤.១ កំណត់ហេតុត្រូវចុះហត្ថលេខាដោយៈ

- អ្នកធ្វើកំណត់ហេតុ
- ប្រធាន ឬតំណាង គ.ជ.ប
- តំណាងគណបក្សនយោបាយដែលមានលទ្ធផល គណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងមានសន្លឹកឆ្នោតបានការស្មើគ្នា។

៧.៤.២ កំណត់ហេតុត្រូវធ្វើជាច្រើនច្បាប់តាមតម្រូវការដូចខាងក្រោមដើម្បីៈ

- ផ្ញើជូនគ្រប់គណបក្សនយោបាយដែលបានចូលរួមបោះឆ្នោត
- រក្សាទុកជាឯកសារ។

**<u>ឧទាហរណ៍</u> : ការចាប់ឆ្នោតកំណត់យកគណបក្សណាមួយដែលត្រូវទទួលបានអាសនៈ**

នៅក្នុងភូមិភាគ **E** មានៈ

- គណបក្សនយោបាយ ចំនួន = ៥
- គណបក្ស **ក** មានសន្លឹកឆ្នោតបានការ $ស_{ប}ក$ = ៩១ សន្លឹក
- គណបក្ស **ខ** មានសន្លឹកឆ្នោតបានការ $ស_{ប}ខ$ = ២៧៩ សន្លឹក
- គណបក្ស **គ** មានសន្លឹកឆ្នោតបានការ $ស_{ប}គ$ = ១៤៨ សន្លឹក
- គណបក្ស **ឃ** មានសន្លឹកឆ្នោតបានការ $ស_{ប}ឃ$ = ២៥៣ សន្លឹក
- គណបក្ស **ង** មានសន្លឹកឆ្នោតបានការ $ស_{ប}ង$ = ២៧៩ សន្លឹក
- សន្លឹកឆ្នោតបានការសរុប $ស_{ស}$ = ១.០៥០ សន្លឹក
- អាសនៈសរុប $អ_{ស}$ = ៥ អាសនៈ
- កូតា $ក_{ត}$ = ២១០

| គណបក្ស | $ស_{ប}$ | $អ_{ទ១}$ លើកទី១ | $ម_{ធ១}$ | $អ_{ទ២}$ លើកទី២ | $ម_{ធ២}$ | $អ_{ទ៣}$ លើកទី៣ |
|---|---|---|---|---|---|---|
| ក | ៩១ | ០ | $\frac{៩១}{០+១}$ = ៩១,០០ | ០ | $\frac{៩១}{០+១}$ = ៩១,០០ | ០ |
| ខ | ២៧៩ | ១ | $\frac{២៧៩}{១+១}$ = ១៣៩,៥០ | ០ | $\frac{២៧៩}{១+១}$ = ១៣៩,៥០ | ១? |
| គ | ១៤៨ | ០ | $\frac{១៤៨}{០+១}$ = ១៤៨,០០ | ១ | $\frac{១៤៨}{១+១}$ = ៧៤,០០ | ០ |
| ឃ | ២៥៣ | ១ | $\frac{២៥៣}{១+១}$ = ១២៦,៥០ | ០ | $\frac{២៥៣}{១+១}$ = ១២៦,៥០ | ០ |
| ង | ២៧៩ | ១ | $\frac{២៧៩}{១+១}$ = ១៣៩,៥០ | ០ | $\frac{២៧៩}{១+១}$ = ១៣៩,៥០ | ១? |

- សប : តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- អទូ១ : តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗបានទទួលក្នុងការបែងចែកលើកទី១។
- មធ១ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនីមួយៗ ដែលក្នុងនោះគណបក្ស **គ** មានមធ្យមភាគធំជាងគេគឺ **១៤៨,០០** ដែលជាមធ្យមភាគខ្ពស់បំផុត។
- អទូ២ : តាងឱ្យចំនួនអាសនៈ ដែលគណបក្សនីមួយៗទទួលបានក្នុងការបែងចែកលើកទី២ ក្នុងនោះគណបក្ស **គ** ត្រូវទទួលបានអាសនៈ ១ (មួយ)។
- មធ២ : គណបក្សនយោបាយ **ខ** និង **ង** មានមធ្យមភាគធំជាងគេស្មើគ្នាគឺ **១៣៩,៥០** ដែលជាមធ្យមភាគខ្ពស់បំផុត និងមានចំនួនសន្លឹកឆ្នោតបានការសរុបស្មើគ្នា ដែលតម្រូវឱ្យធ្វើការចាប់ឆ្នោត។

## ការស្រង់បញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា

៨- បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ បានទទួលរួចហើយ គ.ជ.ប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភាក្នុងភូមិភាគនីមួយៗ តាមលក្ខខណ្ឌដូចខាងក្រោម៖

៨.១ ឈ្មោះបេក្ខជនជាប់ឆ្នោតទាំងអស់ ត្រូវស្រង់ចេញពីបញ្ជីបេក្ខជននៃគណបក្សដែលជាប់ឆ្នោតទៅតាមចំនួនអាសនៈដែលគណបក្សជាប់ឆ្នោតនីមួយៗបានទទួល។

៨.២ ឈ្មោះបេក្ខជនជាប់ឆ្នោត ត្រូវស្រង់តាមលំដាប់លេខរៀងពីខ្ពស់មកទាប តាមបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ។

៨.៣ ក្នុងករណីនៅភូមិភាគមួយមានគណបក្សនយោបាយតែមួយគត់ ដែលត្រូវបានអនុម័តយល់ព្រមឱ្យចុះបញ្ជី ឬមានគណបក្សនយោបាយតែមួយគត់ដែលជាប់ឆ្នោតនោះ ឈ្មោះបេក្ខជនជាប់ឆ្នោតត្រូវស្រង់ពីបញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយតែមួយនោះ តាមលំដាប់លេខរៀងពីខ្ពស់មកទាប រហូតដល់គ្រប់អាសនៈដែលមានក្នុងភូមិភាគនោះ។

៨.៤ ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយ មានអ្នកជាប់ឆ្នោតណាម្នាក់ទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកព្រឹទ្ធសភា បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយនោះ ត្រូវបានប្រកាសថា ជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភារបស់សាមីគណបក្សនយោបាយ។

៨.៥ ក្នុងករណីដែលគណបក្សនយោបាយណាមួយមានបេក្ខជនមិនគ្រប់គ្រាន់ ដោយមូលហេតុដូចមានចែងក្នុងចំណុច ៨.៤ ខាងលើនេះ គ.ជ.ប ត្រូវលើកសំណើជាលាយលក្ខណ៍អក្សរទៅគណបក្សនយោបាយពាក់ព័ន្ធ។ សាមីគណបក្សនយោបាយនោះ ត្រូវបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសំណើ។

៨.៥.១ បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា២៣ថ្មី (ប៉ុន្តែបេក្ខជនត្រូវមានអាយុយ៉ាងតិច ៤០ឆ្នាំ) មាត្រា២៤ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ និងមាត្រា៣៦ នៃ ច.ប.ត.រ។

៨.៥.២ ក្នុងករណីគណបក្សនយោបាយណាមួយមិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬមិនបានកែលម្អការខ្វះខាតដែលស្នើឡើងដោយ គ.ជ.ប ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈទំនេរបាននោះ គ.ជ.ប ត្រូវចាត់ទុកថាគណបក្សនយោបាយនោះបានបោះបង់ចោលអាសនៈឱ្យនៅទំនេរ។ ក្នុងករណីនេះ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះបង់ចោលអាសនៈឱ្យនៅទំនេរ ដោយអនុវត្តតាមវិធីគណនាដូចមានចែងក្នុងចំណុច ៥ ខាងលើនេះ។

៨.៦ ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ៤ ចំណុច ៥ និងចំណុច ៦ ខាងលើនេះ គ.ជ.ប អាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមភូមិភាគនីមួយៗជាបន្តបន្ទាប់។

៨.៧ មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គ.ជ.ប ត្រូវធ្វើរបាយការណ៍ជូនគ្រប់គណបក្សនយោបាយដែលចូលរួមបោះឆ្នោតនូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ព ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់។

# ឧបសម្ព័ន្ធទី២

# ក្រមសីលធម៌
# សម្រាប់មន្ត្រីបោះឆ្នោត

## ១- សេចក្ដីផ្ដើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្ដើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់មន្ត្រីបោះឆ្នោតទាំងអស់អនុវត្តក្នុងដំណើរការបោះឆ្នោត ដើម្បីធានាបានប្រសិទ្ធភាពការងារ អព្យាក្រឹតភាព និងជំនឿទុកចិត្តលើការបោះឆ្នោត។

## ២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធានសំខាន់ៗ ដើម្បីគ្រប់គ្រងសកម្មភាពមន្ត្រីបោះឆ្នោត ក្នុងការអនុវត្តសមត្ថកិច្ច ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ដើម្បី

ពង្រឹងអព្យាក្រឹតភាព ភាពមិនលម្អៀង សេចក្ដីថ្លៃថ្នូរ សីលធម៌បុគ្គល និងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដោយឈរលើគោលការណ៍គោរពច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដោយមិនត្រូវទទួលរងនូវឥទ្ធិពលផ្សេងៗ និងធានាឱ្យដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជាប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

ការគោរពបានល្អនូវក្រមសីលធម៌នេះរួមចំណែកផ្ដល់លទ្ធភាពឱ្យ គ.ជ.ប និងមន្ត្រីបោះឆ្នោតទាំងអស់សម្រេចបាននូវ៖

- ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតដែលធ្វើឡើងទៅតាមច្បាប់ស្ដីពីការបោះឆ្នោត
- ការបោះឆ្នោតដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលទទួលយកបានដោយប្រជាពលរដ្ឋកម្ពុជា ដោយគណបក្សនយោបាយចូលរួមបោះឆ្នោត និងដោយសហគមន៍អន្តរជាតិ
- ការបោះឆ្នោតដែលប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ឬការផ្ដាច់ផ្ដាល។

## ៣- វិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីបោះឆ្នោតដែលបំពេញការងាររៀបចំការបោះឆ្នោតក្នុងដំណើរការបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។ មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិក្រមសីលធម៌នេះ នៅពេលបំពេញភារកិច្ចរបស់ខ្លួនទាំងក្នុងម៉ោងធ្វើការ ទាំងក្រៅម៉ោងធ្វើការ។

## ៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះ មានន័យដូចតទៅ៖

៤.១- **មន្ត្រីបោះឆ្នោត** សំដៅដល់៖

- អ្នករាជការនៃ គ.ជ.ប
- សមាជិកគ្រប់រូបនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីជាប់កិច្ចសន្យាដែលត្រូវបានជ្រើសរើសឱ្យបំពេញការងារបោះឆ្នោតតាមដំណាក់កាល
- មន្ត្រីដែលត្រូវបានធ្វើប្រតិភូកម្មអំណាចឱ្យដោយ គ.ជ.ប តាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងស្ថិតក្នុងម៉ោងបំពេញការងារចុះឈ្មោះបោះឆ្នោត។

៤.២- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៣-**ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវជាក់លាក់ក្នុងការអនុវត្តសមត្ថកិច្ច ភារកិច្ចរបស់ខ្លួនក្នុងដំណើរការបោះឆ្នោត។

### ៥.១- សិទ្ធិរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានសិទ្ធិដូចខាងក្រោម៖

៥.១.១ អនុវត្តនូវគោលការណ៍ច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

៥.១.២ អនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដោយជំហរអព្យាក្រឹត ឥតលម្អៀង ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

៥.១.៣ ផ្ដល់ជំនួយតាមសំណូមពរ សម្រាប់ប្រជាពលរដ្ឋដែលមានពិការភាព ឬមិនចេះអក្សរ មានបំណងសុំចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោតដែលមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន។

៥.១.៤ ទទួលបានការការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន នៅក្នុងពេលដែលកំពុងបំពេញការងាររៀបចំការបោះឆ្នោត ក្នុងករណីចាំបាច់។

### ៥.២- ភារកិច្ចរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានភារកិច្ចដូចខាងក្រោម៖

**៥.២.១ ការអនុវត្តច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត**

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តប្រតិបត្តិតាមច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោតដែលនៅជាធរមាន។

### ៥.២.២ លក្ខខណ្ឌការងារ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តប្រតិបត្តិតាមអាណត្តិ និងលក្ខខណ្ឌការងាររបស់ខ្លួនដែលកំណត់ដោយ គ.ជ.ប ដោយរាប់បញ្ចូលទាំងក្រមសីលធម៌នេះផងដែរ។

### ៥.២.៣ ការអនុវត្តក្រមសីលធម៌

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តប្រតិបត្តិតាម គាំទ្រ និងអនុវត្តក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត។

### ៥.២.៤ ការគាំទ្រ និងការផ្សព្វផ្សាយ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តផ្ដល់ការគាំទ្រ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោតដែលនៅជាធរមាន និងក្រមសីលធម៌នេះ។

### ៥.២.៥ ការថ្កោលទោសចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យ

ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្ដេជ្ញាចិត្តថ្កោលទោស រារាំង និងទប់ស្កាត់នូវរាល់អំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យណាមួយទាក់ទងដល់ដំណើរការបោះឆ្នោត។

### ៥.២.៦ បរិយាកាសការងារ

**ក.** ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវបង្ក និងរក្សាភាពមិនលម្អៀងការបោះឆ្នោតជាសម្ងាត់ និងសេចក្ដីថ្លៃថ្នូរ។

**ខ.** មន្ត្រីបោះឆ្នោតគ្រប់រូប ត្រូវត្រៀមលក្ខណៈចាត់វិធានការសមស្របទៅតាមស្ថានភាពជាក់ស្ដែងដែលកើតមានឡើងក្នុងដំណើរការបោះឆ្នោត។ មន្ត្រីបោះឆ្នោតត្រូវៈ

- អនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ទោះក្នុងកាលៈទេសៈលំបាកយ៉ាងណាក៏ដោយ
- អនុវត្តកិច្ចការផ្សេងទៀតដែលត្រូវបានប្រគល់ជូន និងដែលសមស្របតាមសមត្ថភាពរបស់ខ្លួន ទោះបីកិច្ចការនោះមិនមែនជាភារកិច្ចរបស់ខ្លួនក៏ដោយ។

**គ.** ក្នុងករណីមានការជ្រៀតជ្រែក ឬការរំខាន មន្ត្រីបោះឆ្នោតត្រូវៈ

- បន្តអនុវត្តភារកិច្ចរបស់ខ្លួនដោយប្រុងប្រយ័ត្ន និងខ្ជាប់ខ្ជួន
- រក្សាសុវត្ថិភាពសម្ភារ បរិក្ខារបោះឆ្នោតទាំងអស់ដែលខ្លួនទទួលខុសត្រូវ
- រាយការណ៍ជាបន្ទាន់តាមឋានានុក្រម
- ធ្វើសកម្មភាពជាបន្ទាន់ទៅតាមសេចក្ដីណែនាំផ្សេងៗពីមន្ត្រីថ្នាក់លើរបស់ខ្លួន។

### ៥.២.៧ ជំនួយពិសេស

មន្ត្រីបោះឆ្នោតគ្រប់រូប ត្រូវផ្តល់ជំនួយពិសេសក្នុងសមត្ថកិច្ចរបស់ខ្លួនតាមសំណូមពរដល់បុគ្គលដែលៈ

- មិនចេះអក្សរ (ក្នុងពេលចុះឈ្មោះបោះឆ្នោត) ឬមានពិការភាព
- មិនដឹងថាខ្លួនត្រូវធ្វើអ្វី ឬមិនប្រាកដអំពីអ្វីដែលខ្លួនត្រូវធ្វើ ដើម្បីចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត
- មិនដឹងពីរបៀបដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់
- មិនមានឯកសារតាមលក្ខខណ្ឌតម្រូវសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត ឬឈ្មោះរបស់គាត់បានបាត់ចេញពីបញ្ជីបោះឆ្នោត ឬសិទ្ធិចុះឈ្មោះបោះឆ្នោត ឬសិទ្ធិបោះឆ្នោតរបស់គាត់ត្រូវបានបដិសេធ។

## ៥.៣- ការទទួលខុសត្រូវរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតត្រូវមានការទទួលខុសត្រូវចំពោះភារកិច្ចខ្លួន តាមទីកន្លែង និងករណីដូចខាងក្រោមៈ

### ៥.៣.១ នៅការិយាល័យចុះឈ្មោះបោះឆ្នោត

ក. មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាបានថា ប្រជាពលរដ្ឋគ្រប់រូប ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោតអាចអនុវត្តសិទ្ធិ និងភារកិច្ចរបស់ខ្លួនដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្របក្នុងការសុំចុះឈ្មោះបោះឆ្នោត។

ខ. មន្ត្រីបោះឆ្នោតត្រូវយកចិត្តទុកដាក់ ជាអាទិ៍ចំពោះប្រជាពលរដ្ឋខ្មែរដែលមានពិការភាពណាមួយ មិនមាំមួន មានជំងឺ ចាស់ជរា ឬស្ត្រីមានផ្ទៃពោះ ឬទើបឆ្លងទន្លេ ឬមិនចេះអក្សរមានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយ ឬកម្រិតណាមួយដែលខ្លួនត្រូវការ ដើម្បីជាជំនួយក្នុងការចុះឈ្មោះបោះឆ្នោត។ មន្ត្រីបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកចុះឈ្មោះនោះ ត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំតែប៉ុណ្ណោះ។

### ៥.៣.២ នៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ក. នៅការិយាល័យបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារបោះឆ្នោត ត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួន ដើម្បីអនុញ្ញាតឱ្យអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទាំងអស់ អាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតជាសម្ងាត់ ដោយសេចក្តីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្រប និងធានាថាសម្ភារ បរិក្ខារបោះឆ្នោតទាំងអស់ ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន។

ខ. មន្ត្រីបោះឆ្នោតត្រូវផ្តល់ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព មិនអាចបោះឆ្នោតដោយខ្លួនឯងបាន តាមសំណូមពរ ដោយត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំដោយអ្នកបោះឆ្នោតរូបនោះតែប៉ុណ្ណោះ និងទៅតាមការកំណត់នៃបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។ កិច្ចការនេះ តម្រូវឱ្យមន្ត្រីបោះឆ្នោតដែលត្រូវបានតែងតាំងនោះសួរទៅអ្នកបោះឆ្នោតអំពីគណបក្សនយោបាយណាមួយដែលគាត់ចង់បោះឆ្នោតឱ្យ និងត្រូវគូសលើសន្លឹកឆ្នោតក្នុងនាមអ្នកបោះឆ្នោតរូបនោះ ហើយត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតនេះ។

គ. មន្ត្រីបោះឆ្នោតត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប នូវសកម្មភាពរបស់បុគ្គលណាម្នាក់ដែលធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោត។

ឃ. នៅការិយាល័យរាប់សន្លឹកឆ្នោត មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយត្រូវអនុវត្តភារកិច្ចជាក់លាក់របស់ខ្លួនដែលបានកំណត់នៅក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដើម្បីធានាថាសន្លឹកឆ្នោតទាំងអស់ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន។

### ៥.៣.៣ ទំនាក់ទំនងជាមួយគណបក្សនយោបាយ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

ក. សកម្មភាព និងទំនាក់ទំនងរបស់មន្ត្រីបោះឆ្នោតជាមួយគណបក្សនយោបាយ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវបានកំណត់ដូចខាងក្រោម៖

- គ្រប់ពេលវេលា មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវមានទំនាក់ទំនងជិតស្និទ្ធ និងមិនលម្អៀងជាមួយបេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់។ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវទទួលស្គាល់តួនាទីត្រឹមត្រូវតាមច្បាប់របស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែល៖
    - មានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះ ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត
    - ធ្វើការតវ៉ា ឬជំទាស់ ឬធ្វើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់អំពីភាពមិនប្រក្រតីនៃការអនុវត្តច្បាប់ បទបញ្ជា និងនីតិវិធី ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច (សម្រាប់ភ្នាក់ងារគណបក្សនយោបាយតែប៉ុណ្ណោះ)។

- មន្ត្រីបោះឆ្នោតដែលមានភារកិច្ចទទួល និងដោះស្រាយពាក្យបណ្ដឹង ត្រូវយកចិត្តទុកដាក់អនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

ខ. មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវដឹងថា៖

- គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ មិនមានសិទ្ធិផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬរំខាន ឬជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោតឡើយ
- មិនត្រូវប្រតិបត្តិតាមការណែនាំណាមួយរបស់គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ។

## ៦- បម្រាមចំពោះមន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតត្រូវប្រតិបត្តិឱ្យបានម៉ឺងម៉ាត់នូវបម្រាមដូចខាងក្រោម លើកលែងតែការអនុវត្តភារកិច្ចរបស់ខ្លួន។

### ៦.១ ការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះ

មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវជៀសវាងសកម្មភាពពាក់ព័ន្ធទៅនឹង៖

- ការគំរាមកំហែង
- អំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យដល់បុគ្គលណាម្នាក់ ឬប្រឆាំងទៅនឹងបុគ្គលណាម្នាក់
- ការបដិសេធមិនចុះឈ្មោះបោះឆ្នោតឱ្យអ្នកដែលមានសិទ្ធិគ្រប់គ្រាន់ចុះឈ្មោះបោះឆ្នោត
- ការចុះឈ្មោះបោះឆ្នោតឱ្យអ្នកដែលគ្មានសិទ្ធិគ្រប់គ្រាន់ ឬបញ្ចូលឈ្មោះអ្នកដែលគ្មានសិទ្ធិពេញលេញចូលក្នុងបញ្ជីបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល
- ការអនុញ្ញាតឱ្យអ្នកគ្មានសិទ្ធិគ្រប់គ្រាន់ធ្វើការបោះឆ្នោត ឬអនុញ្ញាតឱ្យអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោតធ្វើការបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល
- ការធ្វើឱ្យខូចខាតដល់បរិវេណខាងក្នុង បរិវេណខាងក្រៅ និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ
- ការធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញសម្ភារ បរិក្ខារ ឬឯកសារបម្រើការបោះឆ្នោតណាមួយ
- ការបង្អាក់ ឬរារាំងអ្នកមានសិទ្ធិណាម្នាក់មិនឱ្យទៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការផ្សព្វផ្សាយព័ត៌មានសម្ងាត់ទាក់ទងនឹងការងាររបស់ខ្លួនទៅកាន់តតិយជនដោយគ្មានការអនុញ្ញាត។

## ៦.២ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវជៀសវាងៈ

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ឧប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

## ៦.៣ ការហូបចុក

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវបរិភោគអាហារនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឡើយ លើកលែងតែមានការអនុញ្ញាតពីមន្ត្រីថ្នាក់លើរបស់ខ្លួន។

## ៦.៤ ការប្រើប្រាស់គ្រឿងស្រវឹង និងសារធាតុញៀន

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវមានភេសជ្ជៈដែលមានផ្ទុកជាតិស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀនណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ ឬនៅក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យទាំងនេះឡើយ។

## ៦.៥ អាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវយកអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ឧប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឡើយ។

## ៦.៦ ល្បែង

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងកន្លែងធ្វើការឡើយ។

## ៦.៧ ភាពលម្អៀងចំពោះគណបក្សនយោបាយ

មន្ត្រីបោះឆ្នោតម្នាក់ៗៈ

**ក.** មិនត្រូវលម្អៀងជាដាច់ខាត និងមិនត្រូវធ្វើសកម្មភាពសម្តែងអាកប្បកិរិយា ឥរិយាបថ ឬពោលពាក្យសម្តី ឬថ្លែងសុន្ទរកថា ឬថ្លែងការណ៍អ្វីមួយដែលបង្ហាញឱ្យឃើញនូវភាពលម្អៀង ឬការចូលចិត្ត ឬមិនចូលចិត្តចំពោះគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយណាមួយ ក្នុងពេលអនុវត្តភារកិច្ចរបស់ខ្លួន។

ខ. មិនត្រូវធ្វើអ្វីមួយដែលជះឥទ្ធិពលទៅលើអ្នកបោះឆ្នោត ដែលអាចធ្វើឱ្យមានការបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

គ. មិនត្រូវពាក់ ឬបង្ហាញនូវផ្លាកសញ្ញាណាមួយ និមិត្តសញ្ញា ឬពាក្យស្លោកជាប់នឹងសម្លៀកបំពាក់ដែលមានជាប់ពាក់ព័ន្ធទៅនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយឡើយ។

ឃ. មិនត្រូវរើសអើងគ្រប់ទម្រង់ដូចជា ការរើសអើងពូជសាសន៍ ភេទ កុលសម្ព័ន្ធ ឋានៈ ឬសាសនា ដែលពាក់ព័ន្ធនឹងការបោះឆ្នោត និងសកម្មភាពនយោបាយផ្សេងៗ។

### ៦.៨ បម្រាមនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតត្រូវចងចាំបម្រាមចាំបាច់ពិសេសដូចខាងក្រោម៖

ក. ការប៉ះពាល់សម្ភារ ឯកសារបោះឆ្នោត

- មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមិនត្រូវប៉ះពាល់សៀវភៅសន្លឹកឆ្នោត សន្លឹកឆ្នោត បញ្ជីបោះឆ្នោត សោឃ្លុំ ត្រាសម្ងាត់ ត្រា គ.ក.ប ទម្រង់បែបបទ ឬសម្ភារបោះឆ្នោតផ្សេងទៀត ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ ទោះបីជាភារកិច្ចរបស់ខ្លួនក៏ដោយ
- ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មិនត្រូវ៖
    - ស្រាយចំណង ឬបើកសោឃ្លុំ សៀវភៅសន្លឹកឆ្នោត ហិបឆ្នោត កញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារបោះឆ្នោត
    - យកចេញនូវសៀវភៅសន្លឹកឆ្នោត ហិបឆ្នោត ឬកញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារបោះឆ្នោតនៅខាងក្នុង
    - យកសម្ភារបោះឆ្នោតណាមួយចេញពីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬជួយឱ្យអ្នកណាម្នាក់ផ្សេងទៀតឱ្យធ្វើដូច្នេះ
    - គូសសម្គាល់ ឬសរសេរលើសម្ភារបោះឆ្នោតណាមួយ ឬលុបគំនូស ឬលុបសំណេរណាមួយចេញពីសម្ភារបោះឆ្នោតណាមួយ។

ខ. ការប៉ះពាល់សន្លឹកឆ្នោត និងហិបឆ្នោត

- ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ មិនត្រូវ៖
    - ផ្តល់សន្លឹកឆ្នោតទៅជនណាម្នាក់
    - បោះត្រាសម្ងាត់ផ្លូវការនៅលើសន្លឹកឆ្នោតណាមួយ
    - ផ្លាស់ប្តូរ ឬបំផ្លាញត្រាសម្ងាត់ផ្លូវការនៅលើសន្លឹកឆ្នោត
    - ផ្លាស់ប្តូរ ឬបំផ្លាញសន្លឹកឆ្នោត

- គូសនៅលើសន្លឹកឆ្នោត
- ចាប់យក ឬប៉ះពាល់ហិបឆ្នោត
- ដាក់សន្លឹកឆ្នោត ឬរបស់ផ្សេងទៅក្នុងហិបឆ្នោត
- យកសន្លឹកឆ្នោតចេញពីហិបឆ្នោតឡើយ។

**គ.** ការរក្សាការសម្ងាត់នៃការបោះឆ្នោត

- មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោតមិនត្រូវព្យាយាមៈ
  - ចង់ដឹងពីបំណងដែលអ្នកបោះឆ្នោតចង់បោះឆ្នោត ឬបានបោះឆ្នោត
  - ធ្វើឱ្យអ្នកបោះឆ្នោតបង្ហាញ ឬប្រាប់ឱ្យដឹងអំពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោត
  - គូសសញ្ញាសម្គាល់ណាមួយនៅលើសន្លឹកឆ្នោត ដែលអាចធ្វើឱ្យគេស្គាល់ដល់អត្តសញ្ញាណនៃអ្នកបោះឆ្នោត
  - ប្រើឥទ្ធិពលទៅលើ ឬជួយអ្នកណាម្នាក់ដើម្បីបានបោះឆ្នោតដោយដឹងថាអ្នកនោះមិនមានសិទ្ធិបោះឆ្នោត
  - ដើរទៅជិតធ្វើជាសញ្ញា ឬនិយាយទៅកាន់អ្នកបោះឆ្នោតណាម្នាក់ដោយគ្មានភារកិច្ចអនុញ្ញាត ចាប់ពីពេលដែលអ្នកបោះឆ្នោតដើរចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត រហូតដល់អ្នកបោះឆ្នោតចាកចេញពីបរិវេណខាងក្នុងការិយាល័យបោះឆ្នោត
  - ដើរចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយគ្មានភារកិច្ច។
- មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោតដែលគ្មានភារកិច្ចអនុញ្ញាតឱ្យធ្វើ មិនត្រូវព្យាយាមលាតត្រដាងៈ
  - សន្លឹកឆ្នោតណាមួយដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ
  - លទ្ធផលនៃការត្រួតពិនិត្យ និងការគណនាណាមួយធ្វើឡើងដោយមន្ត្រីបោះឆ្នោត
  - ចំនួនសន្លឹកឆ្នោតមិនបានការដែលកំពុងមានវិវាទ
  - ចំនួនសំឡេងឆ្នោតដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ។

**ឃ.** ការទទួលសំណូក ឬរង្វាន់

- មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវទទួលយកទោះដោយផ្ទាល់ ឬដោយប្រយោលក្តីនូវចំនួនទឹកប្រាក់ រង្វាន់ ឬសម្ភារផ្សេងៗទៀត ឬការសន្យាណាមួយពីគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ។

ង. វិសមិតភាពការងារ

- មន្ត្រីបោះឆ្នោតម្នាក់ៗ នៅក្នុងអំឡុងពេលបោះឆ្នោត មិនត្រូវ៖
  - មានឈ្មោះជាបេក្ខជននៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ
  - ជាកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

## ៧- សំណូមពរ និងការអនុវត្ត

ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

### ៧.១- សំណូមពរ

- ក្នុងការងាររៀបចំការបោះឆ្នោត មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិតាមក្រមសីលធម៌នេះ នៅពេលដែលមន្ត្រីបុគ្គលិកទាំងនោះកំពុងស្ថិតនៅទីកន្លែងបំពេញការងាររបស់ខ្លួន ឬកំពុងបំពេញភារកិច្ចរបស់ខ្លួន

- មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវចូលរួមរៀនសូត្រគ្រប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាទាំងអស់ តាមការអញ្ជើញរបស់ គ.ជ.ប។

### ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

# សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

### មាត្រា១៤០.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់អាចបោះឆ្នោតបាន។

### មាត្រា១៤៥.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត។

### មាត្រា១៤៦.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោតដូចបានបញ្ញត្តក្នុងមាត្រា១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំ

ការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៥០.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្ខាប់ បញ្ឆោតលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៥១.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**មាត្រា១៦៩.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌ ផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់អាចបោះឆ្នោតបាន។

**មាត្រា១៧៤.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិច ដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត។

**មាត្រា១៧៥.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ។

**មាត្រា១៧៧.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោត បង្ខាប់ បញ្ជាលួងលោម បោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា ១៧៨.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿង សម្គាល់ សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូតលួចដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

# ឧបសម្ព័ន្ធទី៣

# ក្រមសីលធម៌
# សម្រាប់
# គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ
# ក្នុងដំណើរការបោះឆ្នោត

## ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អនុវត្តក្នុងដំណើរការបោះឆ្នោតតាមសិទ្ធិ និងភារកិច្ចរបស់ខ្លួនតាមការកំណត់នៃច្បាប់។

## ២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធានសំខាន់ៗសម្រាប់គណបក្សនយោបាយ បេក្ខជន ដែលឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយយកចិត្តទុកដាក់អនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនដើម្បីឱ្យ៖

- ការបោះឆ្នោតប្រព្រឹត្តទៅស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត

- ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ និងគ្មានការបំភិតបំភ័យ។

## ៣- វិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះគណបក្សនយោបាយ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយដែលបានចុះឈ្មោះ ហើយត្រូវបានទទួលស្គាល់ដោយ គ.ជ.ប។

## ៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **គណបក្សនយោបាយ** សំដៅដល់គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ហើយត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ។

៤.២- **គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត** សំដៅដល់គណបក្សនយោបាយដែលត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ និងបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតនៅ គ.ជ.ប ឬនៅគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ហើយត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៣- **បេក្ខជន** សំដៅដល់អ្នកដែលត្រូវបានគណបក្សនយោបាយតែងតាំងឱ្យឈរឈ្មោះជាបេក្ខជនក្នុងបញ្ជីបេក្ខជនតាមមណ្ឌលបោះឆ្នោត និងត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៤- **ភ្នាក់ងារគណបក្សនយោបាយ** សំដៅដល់ភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលជាតំណាងរបស់គណបក្សនយោបាយ ដើម្បីចូលរួមសង្កេតការណ៍មើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត និងត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៥- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៦- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត

- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយមានសិទ្ធិសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិពេញលេញ ស្មើភាពចូលរួមប្រកបដោយការទទួលខុសត្រូវក្នុងដំណើរការបោះឆ្នោត ជាអាទិ៍ ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ការប្តឹងជំទាស់ ឬប្តឹងតវ៉ា និងការទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។

បេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសង្កេតការណ៍មើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ។

### ៥.១- សិទ្ធិ និងភារកិច្ចរបស់គណបក្សនយោបាយ និងបេក្ខជន

គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

៥.១.១ គណបក្សនយោបាយមានសិទ្ធិ៖

- ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ តវ៉ាចំពោះការសម្រេចរបស់ គ.ជ.ប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ប្តឹងតវ៉ាទៅ គ.ជ.ប ចំពោះការសម្រេចរបស់ គធ.ខប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ប្តឹងតវ៉ាទៅ គធ.ខប និងប្តឹងបន្តទៅ គ.ជ.ប ចំពោះការសម្រេចរបស់ គឃ.សប បដិសេធការសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៥.១.២ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិលើកស្លាកគណបក្សនយោបាយនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។

៥.១.៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនមានសិទ្ធិសុំជួលរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ពីអ្នកគ្រប់គ្រងទីកន្លែងនោះ ដើម្បីប្រើប្រាស់សម្រាប់បម្រើការឃោសនាបោះឆ្នោត ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ។

៥.១.៤ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនមានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតនៅលើទីធ្លាឯកជន ឬសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងទៅគណៈកម្មការរៀបចំការបោះឆ្នោតពាក់ព័ន្ធ។

៥.១.៥ ក្នុងការឃោសនាបោះឆ្នោត គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោត។

៥.១.៦ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ ត្រូវទទួលខុសត្រូវផ្ទាល់លើខ្លឹមសារ និងសកម្មភាពឃោសនាបោះឆ្នោតរបស់ខ្លួន។

៥.១.៧ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ ត្រូវសហការយ៉ាងជិតស្និទ្ធ ជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៥.១.៨ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ ត្រូវយកចិត្តទុកដាក់គោរពឱ្យបានល្អនូវរាល់កម្មវិធីឃោសនាទាំងអស់ ដែលសម្របសម្រួលដោយអាជ្ញាធរដែនដី។

៥.១.៩ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ មានសិទ្ធិធ្វើសកម្មភាពឃោសនាបោះឆ្នោតដោយសេរី ក្នុងទីស្នាក់ការគណបក្សនយោបាយរបស់ខ្លួនទូទាំងប្រទេស។

៥.១.១០ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិសុំផ្លាស់ប្តូរភ្នាក់ងារពេញសិទ្ធិ ឬ/និងភ្នាក់ងារបម្រុងរបស់ខ្លួនទៅតាមកាលកំណត់ចុងក្រោយរបស់ គ.ជ.ប។

៥.១.១១ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ មានសិទ្ធិប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញ និងមានភស្តុតាង បញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការបោះឆ្នោត។

៥.១.១២ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្ដឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅ គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលបានធ្វើខុសពីកាលបរិច្ឆេទ ដែលធ្វើខុសពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្ដោះអាសន្នក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ។

៥.១.១៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ មានសិទ្ធិស្មើភាពគ្នាក្នុងការទទួលបានការការពារសន្តិសុខ សុវត្ថិភាព ក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុងដំណើរការបោះឆ្នោត។

៥.១.១៤ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវបណ្ណប្រកាស ឬបណ្ណបិទផ្សាយបដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។

## ៥.២- សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

៥.២.១ មានវត្តមាននៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនបានទទួលការអនុញ្ញាតតាមទីកន្លែង និងពេលវេលាដែលបានកំណត់ដោយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប និងត្រូវចុះបញ្ជីវត្តមាន។

៥.២.២ ចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ។ ភ្នាក់ងារបម្រុងត្រូវរង់ចាំនៅក្រៅការិយាល័យដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីមានការផ្លាស់ប្ដូរ។

៥.២.៣ តវ៉ា ឬ/និងជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធីដែលខ្លួនបានឃើញផ្ទាល់។ ការជំទាស់ត្រូវធ្វើឡើងទៅប្រធាន ក.ច.ប ប្រធាន គ.ក.ប ប្រធាន គ.ក.រ។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់អាចលើកឡើងដោយផ្ទាល់មាត់ ឬ/និងទៅតាមទម្រង់បែបបទរបស់ គ.ជ.ប។ នៅក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ប្រសិនបើភ្នាក់ងារគណបក្សនៅតែតវ៉ា ឬជំទាស់ ប្រធាន ក.ច.ប អាចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយនោះ កត់ត្រា ឬថតយកទិន្នន័យ ឬឯកសារដែលជាកម្មវត្ថុនៃពាក្យបណ្ដឹង។

៥.២.៤ ចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗដែលកំណត់ដោយ គ.ជ.ប។

៥.២.៥ ចុះហត្ថលេខា ឬផ្តិតមេដៃនៅលើកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

៥.២.៦ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិទទួលបានកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

៥.២.៧ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៥.២.៨ ប្តឹងជំទាស់ ឬប្តឹងតវ៉ាស្របតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញថា មានភស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការបោះឆ្នោត។

៥.២.៩ ទទួលបានដោយស្មើភាពគ្នា ក្នុងការការពារសន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានា ក្នុងដំណើរការបោះឆ្នោត។

៥.២.១០ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិកត់ត្រា និងថតយករូបភាពទូទៅនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដោយមិនត្រូវរំខាន ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការចុះឈ្មោះបោះឆ្នោត ឬ/និងរំលោភលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតឡើយ។

## ៥.៣- ការទទួលខុសត្រូវរបស់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះ។

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលបេក្ខជន និងភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួនឱ្យមានការយល់ដឹងត្រឹមត្រូវអំពីការបោះឆ្នោត អំពីតួនាទី និងភារកិច្ចរបស់ខ្លួនចូលរួមក្នុងការបោះឆ្នោត។

# ៦- បម្រាមចំពោះគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន ភ្នាក់ងារគណបក្សនយោបាយមិនត្រូវៈ

៦.១ ប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.២ ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀត។

៦.៣ និយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាមួយ។

៦.៤ រិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ។
៦.៥ ធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។
៦.៦ ផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ក្នុងរយៈពេលឃោសនាបោះឆ្នោត ថ្ងៃស និងថ្ងៃបោះឆ្នោត។
៦.៧ ធ្វើសកម្មភាពឃោសនាបោះឆ្នោត នៅចន្លោះពីម៉ោង ១០:០០ (ដប់) យប់ ដល់ម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក។
៦.៨ ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ចាប់ពីម៉ោង ១២:០០ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២:០០ (ពីរ) រសៀល។
៦.៩ ជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។
៦.១០ រារាំងដល់សកម្មភាពរបស់ភ្នាក់ងារគណបក្សនយោបាយដទៃទៀត។
៦.១១ ប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន។
៦.១២ រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប។
៦.១៣ ប្រើកម្លាំង អំពើហិង្សា អំពើរំលោភ បំភិតបំភ័យ ឬប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការភាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
៦.១៤ បង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន។
៦.១៥ បង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត។
៦.១៦ ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
៦.១៧ ទិញសន្លឹកឆ្នោត ដោយសម្ភារ ឬដោយប្រាក់កាស។
៦.១៨ បង្គាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត។
៦.១៩ ធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។
៦.២០ ទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោតបន្ថែមលើភ្នាក់ងារគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយ។
៦.២១ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត។

៦.២២ ជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោត។

៦.២៣ ញុះញង់ឱ្យមានការរើសអើងប្រកាន់បក្ខពួក ភេទ ឋានៈក្នុងសង្គម សមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ និងតាមគ្រប់រូបភាពទាំងអស់។

៦.២៤ រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាពលរដ្ឋមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀត។

៦.២៥ ប្រើប្រាស់ភាសា ពាក្យសំដីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយ។

៦.២៦ ដាក់តាំង ឬបង្ហាញ ឬចែកចាយខិត្តប័ណ្ណ ដែលពិពណ៌នាអំពីការវាយប្រហារដោយពាក្យសម្តី ឬដោយអាវុធ។

៦.២៧ ប្រើភាសា ឬរូបភាពរំលោភបំពាន ខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្កជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សាតាមរយៈសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តប័ណ្ណ រូបភាពបិទផ្សាយ និងសម្ភារឃោសនាបោះឆ្នោតផ្សេងទៀត។

៦.២៨ ចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗលុបលើសំឡេងឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.២៩ ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង នៅក្បែរមន្ទីរពេទ្យ ឬក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា។

៦.៣០ ប្រើប្រាស់ព្រះឆាយាល័ក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ថ និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រីព្រះវររាជមាតា ស្លាកសញ្ញា គ.ជ.ប ទៅប្រើប្រាស់ ដើម្បីរកសំឡេងឆ្នោត។

៦.៣១ ចម្លងយកសញ្ញាសម្គាល់របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់ បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន។

៦.៣២ បិទប័ណ្ណ ខិត្តប័ណ្ណ រូបភាពឃោសនា សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសារឃោសនាដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃ។

៦.៣៣ បក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវប័ណ្ណបិទផ្សាយ ខិត្តប័ណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសារឃោសនា ឬសេចក្តីណែនាំផ្សេងៗរបស់គណបក្សនយោបាយដទៃ ក្រសួង ស្ថាប័ននានា ឬអាជ្ញាធរដែនដី។

៦.៣៤ បិទប័ណ្ណផ្សព្វផ្សាយរូបភាពឃោសនា សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារឃោសនាបោះឆ្នោតដទៃទៀតក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង ១០០ (មួយរយ) ម៉ែត្រ លើកលែងតែទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៦.៣៥ ចងបដា ឬរូបសញ្ញាឃោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈ។

៦.៣៦ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៦.៣៧ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ផ្លាកសញ្ញារាជការ ឬរដ្ឋ រាជរដ្ឋាភិបាល នគរបាល ឬ ន.ប ខេមរភូមិន្ទ ឬ ខ.ម ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

៦.៣៨ ផ្ដល់វិភាគទាន ជូនសគុណ ឬផ្ដល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារដើម្បីទទួលបានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលឃោសនាបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត។

៦.៣៩ ប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបានការគាំទ្រ។

៦.៤០ ក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោត។

៦.៤១ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោត។

៦.៤២ នៅក្បែរបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោត។

៦.៤៣ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ត្រូវជៀសវាងៈ

- ការជក់បារីនៅក្នុងទីស្ដីការ គ.ជ.ប ទីស្នាក់ការ លធ.ឧប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.៤៤ ល្បែង

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្ដីការ គ.ជ.ប ទីស្នាក់ការ លធ.ឧប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

### ៧.១- សំណូមពរ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះឱ្យបានខ្ជាប់ខ្ជួន។

### ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

# សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

### មាត្រា១៤២.‒ ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

## មាត្រា១៤៣._ ថ្មី

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៤២ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសដូចបានចែងក្នុងមាត្រា១៤២ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## មាត្រា១៥០._

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្គាប់ បញ្ជាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោតបោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

## មាត្រា១៥១._

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៥២.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាក់លាក់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា១៥៣.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥២ ខាងលើនេះ។

**មាត្រា១៥៥.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា ៧២ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា១៥៦.–**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១៥៥ ខាងលើនេះ។

**មាត្រា១៥៧.–**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា ៧២ នៃច្បាប់នេះ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៦០.–**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្ដល់ការណែនាំ ឬស្ដីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា១៦២.–**

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ។

**ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**មាត្រា១៧១.– ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។

- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។

- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។

- រារាំងឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។

- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។

- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។

- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។

- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។

- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

## មាត្រា១៧២.‗ ថ្មី

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើនេះ។

បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសដូចបានចែងក្នុងមាត្រា១៧១ថ្មី ខាងលើ អាចត្រូវបានដកសិទ្ធិមិនឱ្យចូលរួមការបោះឆ្នោតសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា១៧៧.–**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្ខាប់ បញ្ឆោលួងលោម បោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោតបោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៧៨.–**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៨១.–**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាក់លាក់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា១៨២.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ១៨១ ខាងលើនេះ។

**មាត្រា១៨៤.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា ៧០ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

**មាត្រា១៨៥.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៨៤ ខាងលើនេះ។

**មាត្រា១៨៨.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា១៩០.-**

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ។

# ឧបសម្ព័ន្ធទី៤

# ក្រមសីលធម៌

# សម្រាប់

# អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត

## ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងតម្លាភាពនៃការបោះឆ្នោត។

## ២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធានសំខាន់ៗ សម្រាប់ឱ្យអង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកសង្កេតការណ៍បោះឆ្នោត អនុវត្តក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយជំហរអព្យាក្រឹត មិនលម្អៀង ដើម្បីធានាឱ្យ៖

- កិច្ចសង្កេតការណ៍បោះឆ្នោត ត្រូវធ្វើឡើងដោយសុចរិត និងតម្លាភាព
- អ្នកសង្កេតការណ៍បោះឆ្នោតបំពេញការងារដោយពុំមានការជ្រៀតជ្រែក។

## ៣- វិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងអង្គការអន្តរជាតិ និងអ្នកសង្កេតការណ៍ដែលត្រូវបាន គ.ជ.ប អនុញ្ញាតជាផ្លូវការឱ្យសង្កេតការណ៍បោះឆ្នោត។

## ៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **អ្នកសង្កេតការណ៍ជាតិ** គឺជាជនជាតិខ្មែរ ឬជនបរទេសដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងអនុញ្ញាតដោយ គ.ជ.ប។

៤.២- **អ្នកសង្កេតការណ៍អន្តរជាតិ** គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានាដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប។

៤.៣- **អ្នកសង្កេតការណ៍ជាតិចល័ត** សំដៅដល់ថ្នាក់ដឹកនាំ ឬមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលសាមីអង្គភាពស្នើសុំ និងត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស។

៤.៤- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៥- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត

បន្ទាប់ពី គ.ជ.ប បានទទួលស្គាល់ជាផ្លូវការហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍បោះឆ្នោត ដោយឯករាជ្យពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង គ.ជ.ប ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធរដែនដី គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍ មានដូចខាងក្រោមៈ

### ៥.១- សិទ្ធិរបស់អ្នកសង្កេតការណ៍បោះឆ្នោត

នៅពេលត្រូវបានទទួលស្គាល់ជាផ្លូវការ និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍រួចហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិដូចខាងក្រោមៈ

៥.១.១ អ្នកសង្កេតការណ៍ជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានី ខេត្ត ដែលអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប។

៥.១.២ អ្នកសង្កេតការណ៍អន្តរជាតិអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។

៥.១.៣ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោតនិងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជួយដោះស្រាយទាន់ពេលវេលា។

៥.១.៤ អមដំណើរជាមួយក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) គណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) គណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និង គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនសម្ភារបរិក្ខារចុះឈ្មោះបោះឆ្នោត ហិបឆ្នោត និងសម្ភារបោះឆ្នោត។

៥.១.៥ សង្កេតការណ៍នូវរាល់សកម្មភាពរបស់ លធ.ខប ក.ច.ប ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ឬ គ.ក.ប ឬ គឃ.សប ឬ គធ.ខប និង គ.ជ.ប នៅមុនពេល ក្នុងពេល និងក្រោយពេលចុះឈ្មោះបោះឆ្នោតឬបោះឆ្នោតតាមប្រតិទិនកំណត់ដោយគ.ជ.ប។

៥.១.៦ ចេញ ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយមិនត្រូវបង្កការរំខាន។

៥.១.៧ ជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោត នៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះ មិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

## ៥.២- ភារកិច្ចរបស់អ្នកសង្កេតការណ៍បោះឆ្នោត

អ្នកសង្កេតការណ៍ទាំងឡាយមានភារកិច្ចដូចខាងក្រោម៖

៥.២.១ ត្រូវគោរពច្បាប់ដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលស្គាល់ និងគោរពអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

៥.២.២ ត្រូវយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។ ក្នុងករណីមានការរំលោភច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី ត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន។

៥.២.៣ ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្ខពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀត ដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

៥.២.៤ រក្សាការសម្ងាត់នៃការបោះឆ្នោត។

៥.២.៥ ត្រូវបង្ហាញភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចដែលបានសាកសួរខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួន ដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយ លធ.ខប ឬ គធ.ខប ឬ គ.ជ.ប។

៥.២.៦ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធី ដែលបានកំណត់ដោយ គ.ជ.ប និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការបោះឆ្នោត ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ។

៥.២.៧ ធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន។

៥.២.៨ ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធី ដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងអាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ផង។

៥.២.៩ ត្រូវគោរពតាមការកំណត់របស់ប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ ដែលតម្រូវឱ្យផ្លាស់ប្តូរគ្នាចូលសង្កេតការណ៍ម្តង ៤ (បួន) នាក់ ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពី ៤ (បួន) នាក់ សម្រាប់ការិយាល័យមួយ។

### ៥.៣- ការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍បោះឆ្នោត

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬ/និងអ្នកសង្កេតការណ៍ត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន។

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬ/និងអ្នកសង្កេតការណ៍ត្រូវទទួលបន្ទុកចំណាយរបស់ខ្លួន នៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន។

## ៦- បម្រាមចំពោះអ្នកសង្កេតការណ៍បោះឆ្នោត

ក្នុងការសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោតអ្នកសង្កេតការណ៍មិនត្រូវ៖

៦.១ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។

៦.២ ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត។

៦.៣ យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួន។

៦.៤ បញ្ចុះបញ្ចូល ឬប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៥ ចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៦ ចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧ ចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៦.៨ ស្វែងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩ សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១០ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១១ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១២ ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៣ ផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៤ ផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៥ ផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៦ រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ នៅពេលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត កំពុងប្រព្រឹត្តទៅ។

៦.១៧ ប៉ះពាល់ឯកសារ ឬសម្ភារ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង។

៦.១៨ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗ នៅក្នុងការិយាល័យបោះឆ្នោត។

៦.១៩ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៦.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត និងបង្អាក់ដំណើរការបោះឆ្នោត។

៦.២១ រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៦.២២ ចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោត ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយពាក្យបណ្តឹងនេះបាន។

៦.២៣ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

អ្នកសង្កេតការណ៍បោះឆ្នោត ត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ឧប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.២៤ ល្បែង

អ្នកសង្កេតការណ៍បោះឆ្នោត មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

អង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកសង្កេតការណ៍ត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

### ៧.១- សំណូមពរ

បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ សាមីអង្គការសង្កេតការណ៍ទាំងឡាយត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងដំណើរការបោះឆ្នោត ផ្ញើជូន គ.ជ.ប។ គ.ជ.ប មានសិទ្ធិផ្តល់យោបល់លើរបាយការណ៍នេះ។ អង្គការសង្កេតការណ៍បោះឆ្នោតអាចធ្វើការកែតម្រូវ ឬមិនកែតម្រូវតាមយោបល់របស់ គ.ជ.ប។ ក្នុងករណីមិនធ្វើការកែតម្រូវតាមយោបល់របស់ គ.ជ.ប ត្រូវភ្ជាប់យោបល់នេះ នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍របស់ខ្លួនដែលត្រូវផ្សព្វផ្សាយ។

### ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

# សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

### មាត្រា១៤២.-ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬរុញច្រានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងឬរុញច្រានប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬរុញច្រានឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៤៨.–**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិ ដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោល បំពានលើបញ្ញត្តិនៃមាត្រា ៨៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៤៩.–**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា តាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

**មាត្រា១៥៩.–**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៣៧ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

**មាត្រា១៦០.–**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**ខ-សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់**

**មាត្រា១៧១.- ថ្មី**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៧៩.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិន

មែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិ ដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

## មាត្រា១៨០.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទ ដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

## មាត្រា១៨៧.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៥៩ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

## មាត្រា១៨៨.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ឧបសម្ព័ន្ធទី៥

## ក្រមសីលធម៌

## សម្រាប់

## ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត

### ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួនរួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអនុវត្តក្នុងដំណើរការបោះឆ្នោត ដើម្បីលើកកម្ពស់ថែមទៀតនូវប្រសិទ្ធភាពនៃការផ្សព្វផ្សាយអំពីការបោះឆ្នោតប្រកបដោយវិជ្ជាជីវៈ ត្រឹមត្រូវ និងតម្លាភាព។

### ២- គោលបំណង

ក្រមសីលធម៌នេះមានគោលបំណងកំណត់វិធានសំខាន់ៗ ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន អនុវត្តសេរីភាពសារព័ត៌មាន និងសេរីភាពខាងការផ្សព្វផ្សាយព័ត៌មាន ផ្តល់

ព័ត៌មានអំពីការបោះឆ្នោតបានត្រឹមត្រូវ ច្បាស់លាស់ ទាន់ពេលវេលា ចូលរួមធានាឱ្យដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

## ៣- វិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ដែលធ្វើការផ្សព្វផ្សាយព័ត៌មាន និងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត។

## ៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន** សំដៅដល់អង្គភាពទាំងឡាយដែលធ្វើសកម្មភាពនៃការផ្សព្វផ្សាយព័ត៌មាន ដែលត្រូវធ្វើឡើងជាទៀងទាត់ តាមរយៈការបោះពុម្ព ការផ្សព្វផ្សាយ រួមមានសារព័ត៌មាន ទស្សនាវដ្តី និងតាមរយៈវិទ្យុ ទូរទស្សន៍ និងតាមរយៈគេហទំព័រ។

៤.២- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៣-**ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់មានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវក្នុងការយកព័ត៌មាន និងផ្សព្វផ្សាយអំពីការងារបោះឆ្នោត។

### ៥.១- សិទ្ធិរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់មានសិទ្ធិដូចខាងក្រោម៖

៥.១.១ សមាគមអ្នកសារព័ត៌មាន ឬអង្គភាពអ្នកសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ្យដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានដោយផ្ទាល់ទៅ គ.ជ.ប។

៥.១.២ អាចទាញយកពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានពីគេហទំព័រ www.nec.gov.kh បានដោយឥតគិតថ្លៃ។

៥.១.៣ បំពេញបែបបទនៃការស្នើសុំចុះឈ្មោះជាអ្នកសារព័ត៌មាន ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតនីមួយៗ។

៥.១.៤ ថត និងយកព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥.១.៥ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិដែលមានបំណងថតយករូបភាពក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវជម្រាបជូនដំណឹងទៅប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ នោះជាមុន។

៥.១.៦ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីជួយដោះស្រាយឱ្យបានទាន់ពេលវេលា។

## ៥.២- ភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្សព្វផ្សាយព័ត៌មានដល់សាធារណជន អ្នកបោះឆ្នោតឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ ក្នុងន័យនេះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

៥.២.១ ចូលរួមក្នុងការអប់រំអ្នកបោះឆ្នោត ដើម្បីឱ្យអ្នកបោះឆ្នោតមានការយល់ដឹងត្រឹមត្រូវពីការបោះឆ្នោត។

៥.២.២ ផ្តល់ព័ត៌មាន និងការអប់រំអំពីការបោះឆ្នោតដែលងាយយល់សម្រាប់អ្នកបោះឆ្នោតរួមមានសិទ្ធិចុះឈ្មោះបោះឆ្នោត សិទ្ធិបោះឆ្នោត និងសិទ្ធិចូលរួមក្នុងសកម្មភាពផ្សេងៗទៀតនៃការបោះឆ្នោតតាមច្បាប់កំណត់។

៥.២.៣ ស្វែងរក និងផ្សព្វផ្សាយព័ត៌មានអំពីទស្សនៈ និងគំនិតផ្សេងៗគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបោះឆ្នោត។

៥.២.៤ ផ្សព្វផ្សាយព័ត៌មានអំពីសារៈសំខាន់នៃការចូលរួមរបស់ព្រះសង្ឃ យុវជន យុវនារី ស្ត្រី ជនជាតិភាគតិច និងជនមានពិការភាព ក្នុងជីវភាពសង្គម និងនយោបាយ ដើម្បីបង្កើនការយល់ដឹង។

៥.២.៥ ចូលរួមលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យអ្នកបោះឆ្នោតបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ។

៥.២.៦ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ ត្រូវមានអព្យាក្រឹតភាព យុត្តិធម៌ និងភាពត្រឹមត្រូវ ក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត។ ដោយឡែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ត្រូវចូលរួមសហការធ្វើការផ្សព្វផ្សាយព័ត៌មាន ប្រកបដោយអព្យាក្រឹត យុត្តិធម៌ និងត្រឹមត្រូវ។

៥.២.៧ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន គោរពច្បាប់ស្តីពីរបបសារព័ត៌មាន គោរពច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះ។

៥.២.៨ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ត្រូវខិតខំប្រឹងប្រែងឱ្យអស់សមត្ថភាពក្នុងការចូលរួមធ្វើឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

## ៥.៣- ការទទួលខុសត្រូវ និងភារកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន និងមានកាតព្វកិច្ចគោរពគោលការណ៍ចាំបាច់ដូចតទៅៈ

៥.៣.១ គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន។

៥.៣.២ គោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល។

៥.៣.៣ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវបានលើកទឹកចិត្តក្នុងលក្ខណៈជាដៃគូជាមួយ គ.ជ.ប ដើម្បីធ្វើការផ្តល់ព័ត៌មាន និងអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត។

៥.៣.៤ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ត្រូវបង្ហាញនូវកម្រិតគុណភាពខ្ពស់នៃវិជ្ជាជីវៈអ្នកសារព័ត៌មាន និងត្រូវផ្តល់ព័ត៌មាន និងហេតុការណ៍ថ្មីៗឱ្យបានសមរម្យពិតប្រាកដ និងឥតលម្អៀង ដើម្បីធានានូវយុត្តិធម៌ និងតុល្យភាពព័ត៌មានសម្រាប់គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោត។

៥.៣.៥ ពង្រឹង និងណែនាំអ្នកសារព័ត៌មាន មិនត្រូវបោះបង់គោលជំហរ ឬក្រមសីលធម៌របស់ខ្លួន ដោយសារតែអំណោយ ផលប្រយោជន៍ ឬចំណង់ចំណូលចិត្តពិសេសទេ។

៥.៣.៦ ត្រូវផ្ទៀងផ្ទាត់អំពីប្រភពព័ត៌មាន ភាពសុក្រឹត និងភាពច្បាស់លាស់នៃហេតុការណ៍ និងព្រឹត្តិការណ៍ដែលខ្លួនត្រូវរាយការណ៍។

៥.៣.៧ ត្រូវរាយការណ៍តែតាមហេតុការណ៍ ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬកែបន្លំឯកសារផ្សេងៗឡើយ។

៥.៣.៨ ប្រើវិធីសុចរិត ត្រឹមត្រូវ ដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ។

៥.៣.៩ ត្រូវផ្សាយដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឱ្យបានត្រឹមត្រូវ និងសមស្របតាមគោលការណ៍គតិយុត្តិធម៌ និងសីលធម៌។

៥.៣.១០ ថ្លឹងថ្លែងឱ្យបានត្រឹមត្រូវ មានប្រភពឯកសារច្បាស់លាស់ និងទទួលខុសត្រូវខ្ពស់ក្នុងការផ្សព្វផ្សាយលទ្ធផលនៃការបោះឆ្នោត។

៥.៣.១១ ត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ មិនលម្អៀង និងដោយមានការថ្លឹងថ្លែងឱ្យមានតុល្យភាព។

៥.៣.១២ ផ្តល់ឱកាសស្មើគ្នាដល់គណបក្សនយោបាយ ឬបេក្ខជនដែលចូលរួមក្នុងការបោះឆ្នោតឱ្យមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

៥.៣.១៣ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និងឯកជន ត្រូវបែងចែកឱ្យបានច្បាស់ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោត ដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រ។

៥.៣.១៤ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន ត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់រវាងហេតុការណ៍ជាក់ស្តែង និងទស្សនៈយោបល់។ ការផ្សព្វផ្សាយព័ត៌មានត្រូវឆ្លុះបញ្ចាំងពីហេតុការណ៍ជាក់ស្តែង។

៥.៣.១៥ ត្រូវចៀសវាងការផ្សព្វផ្សាយព័ត៌មាន ដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៥.៣.១៦ ត្រូវធ្វើការកែតម្រូវនូវព័ត៌មានណាដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់ និងនាំឱ្យមានការយល់ច្រឡំ។

## ៦- បម្រាមចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ត្រូវបានហាមឃាត់ ចំពោះសកម្មភាពដែលត្រូវបានចាត់ទុកថា ជាការរំលោភធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចខាងក្រោមៈ

៦.១ ការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យមានការភាន់ច្រឡំ នាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

៦.២ ការបន្លំឱ្យគេយល់ខុសដូចជា ការសរសេរបញ្ចិតបញ្ចៀង ដើម្បីឱ្យសាធារណជនមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុមបក្សណាមួយ។

៦.៣ ការផ្សព្វផ្សាយព័ត៌មានដោយសំអាងលើពាក្យចចាមអារ៉ាម ឬព័ត៌មានដែលពុំមានភស្តុតាងបញ្ជាក់។

៦.៤ ការផ្សព្វផ្សាយដែលមានលក្ខណៈមួលបង្កាច់ បរិហារកេរ្តិ៍ និងជេរប្រមាថដល់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ។

៦.៥ ការប្រើប្រាស់ភាសាញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្តាប់ធ្នាប់ ឬអាចឱ្យមានអំពើហិង្សា។

៦.៦ ការបោះពុម្ពផ្សាយ ឬចែកចាយព័ត៌មានណាដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ដែលបង្កឱ្យមានការភ័យខ្លាច ឬបង្កជាអំពើហិង្សាណាមួយកើតឡើង។

៦.៧ ការផ្សព្វផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៦.៨ ការបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែលបណ្ដាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ស្ថេរភាពនយោបាយ និងស្ថេរភាពសង្គម។

៦.៩ ការបោះពុម្ពផ្សាយ ឬផ្សាយបន្តហេតុការណ៍ ឬព្រឹត្តការណ៍មិនពិតដែលជាការជេរប្រមាថ ការមើលងាយដល់ស្ថាប័នជាតិ។

៦.១០ ការផ្សព្វផ្សាយមានលក្ខណៈរើសអើង ប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១១ ការសម្ដែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថ តាមរយៈកាយវិការ ឬឥរិយាបថជាក់ស្ដែងផ្សេងទៀត។

៦.១២ ការបញ្ចេញ បញ្ចូលនូវទស្សនៈផ្ទាល់ខ្លួន ឬក៏ធ្វើបុរេវិនិច្ឆ័យនៅក្នុងហេតុការណ៍កំពុងកើតមានដែលខ្លួនធ្វើសេចក្ដីរាយការណ៍។

៦.១៣ ការជ្រៀតជ្រែក ឬរំខានដល់ការងារចុះឈ្មោះបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៦.១៤ ការផ្សព្វផ្សាយមិនឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត។

៦.១៥ ការទទួលសំណូក អំណោយក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរនឹងការផ្សព្វផ្សាយ ឬមិនផ្សព្វផ្សាយនូវព័ត៌មានណាមួយ។

៦.១៦ ការធ្វើសម្ភាសន៍នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៦.១៧ ការប្រើប្រាស់តួនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើមន្ត្រីចុះឈ្មោះបោះឆ្នោត ឬសមាជិក គបយ.ស មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬគាបសង្កត់លើអ្នកសង្កេតការណ៍ ឬបេក្ខជន ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោត ឬអ្នកបោះឆ្នោតឡើយ។

៦.១៨ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

អ្នកសារព័ត៌មាន ត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្ដីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.១៩ ល្បែង

អ្នកសារព័ត៌មាន មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្ដីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោមៈ

### ៧.១- សំណូមពរ

ដើម្បីធានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ច្បាប់ស្ដីពីរបបសារព័ត៌មាន និងក្រមសីលធម៌នេះ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានអំពីដំណើរការបោះឆ្នោតឱ្យមានប្រសិទ្ធភាពប្រកបដោយវិជ្ជាជីវៈ ឯករាជ្យ ត្រឹមត្រូវ និងមិនលម្អៀង។

### ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

# សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

### មាត្រា១៤២.-ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និង ដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

## ខ- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

### មាត្រា១៧១._ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

# ឧបសម្ព័ន្ធទី៦
# ក្រមសីលធម៌
# សម្រាប់
# យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ
# និងភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដំណើរការបោះឆ្នោត

## ១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតចូលរួមក្នុងការបោះឆ្នោត ពិសេសក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល។

## ២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធាន និងគោលការណ៍សំខាន់ៗសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោតអនុវត្តនូវសិទ្ធិ តួនាទី និងភារកិច្ចរបស់ខ្លួនចូលរួមក្នុងដំណើរការបោះឆ្នោត ដើម្បី៖

- ធានាឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សាផ្សេងៗ និងសម្រេចបានជោគជ័យ
- ការពារសន្តិសុខ និងសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋអ្នកចុះឈ្មោះបោះឆ្នោត អ្នកបោះឆ្នោត បេក្ខជន ឃោសនិក និងភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងរក្សាស្ថិរភាពសម្រាប់សង្គមជាតិទាំងមូល
- ចាត់វិធានការបង្ការ រារាំង ទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើស អំពើវិទ្ធង្សនា និងអំពើភេរវកម្មផ្សេងៗ ដែលអាចបង្កឱ្យមានការរាំងស្ទះដល់ដំណើរការបោះឆ្នោត។

## ៣- វិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិក្នុងការចូលរួមក្នុងការបោះឆ្នោត ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល ទៅតាមមុខសញ្ញា និងទីតាំងជាក់លាក់។

## ៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **យោធិននៃកងយោធពលខេមរភូមិន្ទ** គឺជាពលទាហាន នាយទាហានរង និងនាយទាហានក្នុងនេះមានកងរាជអាវុធហត្ថ។

៤.២- **នគរបាលជាតិ** គឺជាមន្ត្រីនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា។

៤.៣- **ភ្នាក់ងារសន្តិសុខបោះឆ្នោត** គឺជាយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត។

៤.៤- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៥- **ដំណើរការបោះឆ្នោត** សំដៅដល់៖

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត

- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

## ៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវអនុវត្តសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

### ៥.១- សិទ្ធិរបស់យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ

យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានសិទ្ធិចូលរួមក្នុងការបោះឆ្នោតដូចជាប្រជាពលរដ្ឋទូទៅដែរ ហើយសិទ្ធិនេះ ត្រូវបានកំណត់ដោយច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធដែលនៅជាធរមាន។

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

### ៥.២- ភារកិច្ចរបស់មេបញ្ជាការ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

មេបញ្ជាការ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវអនុវត្តភារកិច្ចដូចខាងក្រោម៖

៥.២.១ មេបញ្ជាការ ឬតំណាងនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងនគរបាលជាតិមានភារកិច្ច៖

- ត្រូវចូលរួមប្រជុំជាមួយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីចាត់វិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល
- ត្រូវចេញសេចក្តីណែនាំ ឬបទបញ្ជាទៅដល់មន្ត្រីនៅក្រោមឱវាទ ដើម្បីពិនិត្យមើលសកម្មភាពរបស់មន្ត្រីនៃអង្គភាពរៀងៗខ្លួនពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោបាយ និងប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងកិច្ចការពារសិទ្ធិ សេរីភាពជាមូលដ្ឋានដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ត្រូវសហការ និងត្រៀមលក្ខណៈសហការជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ក្នុងការចាត់ចែងកម្លាំងសន្តិសុខបោះឆ្នោត ដើម្បីផ្តល់ការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោត។

៥.២.២ ភ្នាក់ងារសន្តិសុខបោះឆ្នោតមានភារកិច្ចៈ

- រក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈក្នុងពេលចុះឈ្មោះបោះឆ្នោត បិទផ្សាយបញ្ជីបោះឆ្នោតដំបូង បញ្ជីបោះឆ្នោតផ្លូវការ បញ្ជីទីតាំងការិយាល័យបោះឆ្នោត បញ្ជីបេក្ខជន ពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត
- នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣ (បី) នាក់ ការពារបរិវេណសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប
- ចូលរួមចំណែកការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ដែលជាបរិវេណរដ្ឋបាល និងសន្តិសុខ
- ស្ថិតនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីត្រៀមបំពេញភារកិច្ច ក្នុងករណីមានសំណូមពរពីប្រធាន គ.ក.ប/គ.ក.រ ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យណាមួយនោះ។

## ៥.៣- ការទទួលខុសត្រូវរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត

ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវមានការទទួលខុសត្រូវដូចខាងក្រោមៈ

៥.៣.១ ប្រកាន់ជំហរអព្យាក្រឹត មិនលម្អៀង និងមិនត្រូវបង្ហាញការគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងត្រូវដឹងថាៈ

- ប្រជាពលរដ្ឋ អ្នកសុំចុះឈ្មោះបោះឆ្នោត និងអ្នកបោះឆ្នោតគ្រប់រូបមានសិទ្ធិទទួលបានសន្តិសុខ សុវត្ថិភាព ដើម្បីឱ្យដំណើរការចុះឈ្មោះបោះឆ្នោត និងដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌
- បេក្ខជន វាគ្មិន ឬឃោសនិក តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងគ្រប់សកម្មភាពស្របច្បាប់។

៥.៣.២ ធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពនៅក្នុងសម័យបោះឆ្នោត។

៥.៣.៣ យាម និងត្រួតពិនិត្យគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតយ៉ាងតឹងរ៉ឹងបំផុត នៅក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៥.៣.៤ ហាមឃាត់ជនណាម្នាក់ដែលប្រដាប់ដោយអាវុធ ឬមានលាក់អាវុធជាតិផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូល ឬឈរក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត

ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែជននោះជាយោធិននៃកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ ដែលមានភារកិច្ច និងត្រូវបានស្នើសុំដើម្បីដោះស្រាយ បាតុភាព ដែលកើតមានក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬ/និងបរិវេណខាងក្នុង ឬ/និងបរិវេណខាងក្រៅ។

៥.៣.៥ ជួយការពារការដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយតាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ តាមការស្នើសុំ។

៥.៣.៦ ត្រូវមានស្មារតីប្រុងប្រយ័ត្ន ពង្រឹង និងកសាងសមត្ថភាព ស្វែងយល់ឱ្យបានច្បាស់អំពីគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត ផែនការអន្តរស្ថាប័នមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ក្រមសីលធម៌ រួមទាំងសេចក្ដីណែនាំផ្សេងៗ ស្ដីពីកិច្ចការពារសន្តិសុខបោះឆ្នោត សម្រាប់ធ្វើជាមូលដ្ឋាននៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។

## ៦- បម្រាមចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវបានៈ

៦.១ ហាមប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។ ការគំរាមកំហែង ការបំភិតបំភ័យ និងបំបាក់ទឹកចិត្តរួមមានៈ

- ការវាយតប់លើបុគ្គលណាម្នាក់
- ការរំលោភដោយពាក្យសម្ដីថា នឹងធ្វើទារុណកម្មដល់រាងកាយ
- ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដោយយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល មានជាអាទិ៍ឃាតកម្ម ការវាយដំ ឬការបង្ករបួសស្នាម ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់
- ការបាញ់ ការផ្ទុះអាវុធគំរាមបុគ្គលណាម្នាក់ ទោះតាមរូបភាពណាមួយក៏ដោយ
- ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ពួកគេ

- ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះ មានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់ពួកគេ
- ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង
- ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង និងផលប្រយោជន៍ផ្សេងទៀត។

៦.២ ហាមប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៣ ហាមចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ក្នុងពេលម៉ោងធ្វើការ ឬពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ។ ការចូលរួមសកម្មត្រូវបានកំណត់ដូចតទៅ៖

- ការចូលរួមជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ
- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការដាក់តាំងរូបភាពផ្សាយ ឬឯកសារផ្សេងៗ ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ និងតាមយានជំនិះផ្ទាល់របស់ខ្លួន ឬ/និងអង្គភាព
- ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោតដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចេញសេចក្តីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចូលរួមក្នុងសកម្មភាពឃោសនាជាសាធារណៈណាមួយ ក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ។

៦.៤ ហាមចូលរួមក្នុងសកម្មភាពឃោសនាណាមួយ ក្នុងពេលបំពេញភារកិច្ច។

៦.៥ ហាមដើរ ឬឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពឃោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

៦.៦ ហាមជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត។

៦.៧ ហាមយកអាវុធជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងការស្លៀកពាក់ឯកសណ្ឋាន ជាកងកម្លាំងប្រដាប់អាវុធ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត ព្រមទាំងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីចាំបាច់ និងមានការស្នើសុំអន្តរាគមន៍ពីប្រធាន គ.ជ.ប ប្រធាន លធ.ខប ឬប្រធាន គធ.ខប ប្រធាន គឃ.សប ឬ កបឃ.ស ឬប្រធាន ក.ច.ប ឬពីប្រធាន គ.ក.ប/គ.ក.រ។

៦.៨ ភ្នាក់ងារសន្តិសុខបោះឆ្នោតមិនត្រូវចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីចាំបាច់ និងមានការស្នើសុំអន្តរាគមន៍ពីប្រធាន គ.ជ.ប ប្រធាន លធ.ខប ឬប្រធាន គធ.ខប ប្រធាន គឃ.សប ឬពីប្រធាន គ.ក.ប/គ.ក.រ។

៦.៩ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.១០ ល្បែង

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

## ៧- សំណូមពរ និងការអនុវត្ត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត រួមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការងារសន្តិសុខ ត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម៖

## ៧.១- សំណូមពរ

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហការដល់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព ក្នុងរយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងសម្រាប់ដំណើរការបោះឆ្នោតនីមួយៗឱ្យទទួលបានជោគជ័យ។

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាព ការបង្ការទប់ស្កាត់ និងបង្រ្កាបបទល្មើសព្រហ្មទណ្ឌ ឬសកម្មភាពបំពារបំពានច្បាប់ផ្សេងៗទៀតដែលជាហេតុបង្កឱ្យមានការភ័យខ្លាច និងប៉ះពាល់ដល់បរិយាកាសនយោបាយ និងសន្តិសុខជាតិទាំងមូល។

តាមសំណើរបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវយកចិត្តទុកដាក់ការពារសុវត្ថិភាពសម្រាប់ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត ទីកន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងគ្រឿងសង្ហារិមចាំបាច់ផ្សេងៗដែលបម្រើការងារបោះឆ្នោត ការដឹកជញ្ជូនសន្លឹកឆ្នោត និងឯកសារបោះឆ្នោតនៅគ្រប់ដំណាក់កាល ប្រកបដោយប្រសិទ្ធភាពខ្ពស់ សុវត្ថិភាព និងគ្មានការរអាក់រអួល។

យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិទាំងមូល ជាពិសេសកងកម្លាំងដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត គឺភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវប្រមូលផ្តុំកម្លាំងសហការឱ្យបានល្អ និងប្រើប្រាស់តាមគ្រប់វិធានការជំនាញគ្រប់មធ្យោបាយ និងសម្ភារ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ក្នុងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសម្រាប់ការបោះឆ្នោត។

## ៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

# សម្រង់ទោសប្បញ្ញត្តិ

## ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

### មាត្រា១៤២._ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

**មាត្រា១៤៦.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍ អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា ៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោតដូចបានបញ្ញត្តក្នុងមាត្រា ១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិកឬជាសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៤៧.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលល្មើសនឹងមាត្រា ៨៧ នៃច្បាប់នេះ។

**មាត្រា១៤៨.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ខ-សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

### មាត្រា១៧១._ ថ្មី

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិតៈ

- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំង ឬញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬ/និងលុបបេក្ខភាពរបស់សាមីខ្លួន ឬ/និងដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរបស់សាមីខ្លួនសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងតិច ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

### មាត្រា១៧៥._

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការ

ជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិនៃមាត្រា ២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារនិងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា១៧៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលល្មើសនឹងមាត្រា ១០ នៃច្បាប់នេះ។

**មាត្រា១៨៦.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ឧបសម្ព័ន្ធទី៧

## សម្ភារៈ ឯកសារបោះឆ្នោតដែលត្រូវប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល

១- បណ្ណសម្គាល់សមាសភាព គ.ក.ប ចំនួន ៦ (ប្រាំមួយ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោត ក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុនបម្រុង)។

២- បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយចំនួន ១៦ (ដប់ប្រាំមួយ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុនបម្រុង)។

៣- បណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិ ចំនួន ២០ (ម្ភៃ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុន)។

៤- ទម្រង់បែបបទលេខ ១០០២ សម្រាប់បំពេញកិច្ចសន្យាបម្រើការងាររបស់សមាសភាព គ.ក.ប ចំនួន ១២ (ដប់ពីរ) សន្លឹក គុណនឹងការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុន)។

៥- ទម្រង់បែបបទលេខ ១០០៤ សម្រាប់បំពេញបញ្ជីវត្តមាន និងប្រាក់កម្រៃសមាសភាព គ.ក.ប ចំនួន ៣ (បី) ច្បាប់ (ត្រូវបញ្ជូនមុន)។

៦- កញ្ចប់សន្លឹកឆ្នោតបម្រុងចំនួន ១ (មួយ) កញ្ចប់។

៧- ទម្រង់បែបបទលេខ ១១០៦ ចំនួនបី (៣) ច្បាប់ សម្រាប់កត់ត្រាការត្រួតពិនិត្យការបែងចែក និងបញ្ជូនសន្លឹកឆ្នោត ។

៨- ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតចំនួន ៩ (ប្រាំបួន) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត។

៩- ទម្រង់បែបបទលេខ ១១១០ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ចំនួន ៣ (បី) ច្បាប់។

១០- ទម្រង់បែបបទលេខ ១១១១ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំនួន ៥ (ប្រាំ) ច្បាប់។

១១- ទម្រង់បែបបទលេខ ១១១៣ សម្រាប់បំពេញកំណត់ហេតុការវាយតម្លៃសមាសភាព គ.ក.ប ចំនួន ១២ (ដប់ពីរ) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត។

១២- ទម្រង់បែបបទលេខ ១១១៤ សម្រាប់បំពេញក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ចំនួន ៥ (ប្រាំ)ច្បាប់។

១៣- ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ចំនួន ៥ (ប្រាំ) ក្បាល ក្នុងមួយក្បាលមាន ២០ (ម្ភៃ) ច្បាប់។

១៤- ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសម្រង់សេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ចំនួន ៥ (ប្រាំ) ក្បាល ក្នុងមួយក្បាលមាន ២០ (ម្ភៃ) ច្បាប់។

១៥- ស្រោមសំបុត្រធំចំនួន ២ (ពីរ) គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត ស្រោមសំបុត្រមធ្យមចំនួន ៧ (ប្រាំពីរ) និងបន្ថែមស្រោមសំបុត្រមធ្យម ចំនួនគិតសមាមាត្រនឹង ស្បោង "ឃ" ដែលត្រូវប្រើនៅ គធ.ខប។

១៦- ម៉ាស៊ីនគិតលេខបែងចែកតាមរាជធានី ខេត្តតូច ឬធំ។

១៧- ប៊ិកហ្វឺតធំលុបមិនជ្រះ ចំនួន ២ (ពីរ) ដើម។

១៨- ប៊ិកហ្វឺតធំខៀវ ចំនួន ១ (មួយ) ដើម។

១៩- កញ្ចប់ "ឃ ពិសេស" បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

២០- ស្បោង "ឃ" បែងចែកតាមរាជធានី ខេត្តតូច ឬធំ។

២១- សោឃ្លុំជ័រធំមានលេខ សម្រាប់ឃ្លុំស្បោង "ឃ" ចំនួនស្មើនឹងស្បោង "ឃ"។

២២- បន្ទប់សម្ងាត់បម្រុង (បែងចែកតាម គធ.ខប តូច ឬ ធំ)។

២៣- ហិបឆ្នោតបម្រុង (បែងចែកតាម គធ.ខប តូច ឬធំ)។

## ឧបសម្ព័ន្ធទី៨

## សម្ភារ ឯកសារដែលត្រូវប្រគល់ជូន គ.ក.ប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត

១- លេខកូដការិយាល័យបោះឆ្នោតចំនួន ៣ (បី) ច្បាប់ សម្រាប់បិទនៅខាងមុខការិយាល័យបោះឆ្នោត ១ (មួយ) ច្បាប់ និងសម្រាប់បិទនៅជញ្ជាំងខាងមុខ និងក្រោយនៃហិបឆ្នោតចំនួន ១ (មួយ) ច្បាប់។

២- ស្លាកសម្គាល់ “ការិយាល័យបោះឆ្នោត” បោះពុម្ពលើកំណាត់ប្លាស្ទិកចំនួន ១ (មួយ)។

៣- បណ្ណប្រកាសហាមប្រើទូរសព្ទដៃ និងម៉ាស៊ីនថតចំនួន ២ (ពីរ) សន្លឹក។

៤- ទឹកខ្មៅលុបលាងមិនជ្រះចំនួន ២ (ពីរ) ដប។

៥- ត្រា គ.ក.ប ចំនួន ១ (មួយ)។

៦- ត្រាសម្ងាត់ចំនួន ១ (មួយ)។

៧- តាំប៉ុងពណ៌ក្រហមចំនួនមួយ (១) ប្រអប់ និងទឹកតាំប៉ុងក្រហម ចំនួនមួយ (១) ដប។

៨- ប៊ិកមានខ្សែចងសម្រាប់គូសសន្លឹកឆ្នោត និងប៊ិកធម្មតាសម្រាប់ គ.ក.ប សរុបទាំងពីរមុខចំនួន ៨ (ប្រាំបី) ដើម។

៩- ប៊ិកហ្វឺតធំលុបមិនជ្រះចំនួន ១ (មួយ) ដើម។

១០- ប៊ិកហ្វឺតធំចំនួន ១ (មួយ) ដើម។

១១- បន្ទាត់ជ័រចំនួន ១ (មួយ) ដើម។

១២- ប្រដាប់ចោះសន្លឹកឆ្នោតចំនួន ១ (មួយ)។

១៣- ជ័រការពារ ១ (មួយ) ដប។

១៤- ស្កុតថ្លាធំចំនួន ១ (មួយ) ដុំ។

១៥- កៅស៊ូកងមួយចំនួន សម្រាប់ចងសន្លឹកឆ្នោតតាមគណបក្ស។

១៦- ស្រោមសំបុត្រធំ ចំនួនមួយ (១) មធ្យម ចំនួនដប់ (១០) និងតូចចំនួនពីរ (២)។

១៧- ក្រដាសស្ទើងសម្រាប់បិទពាសសន្ទះបិទប្រឡោះស៊កសន្លឹកឆ្នោតចំនួន ៦ (ប្រាំមួយ) សន្លឹក។

១៨- ក្រដាសវ៉ាម សម្រាប់ប្រើប្រាស់ការងារផ្សេងៗ ចំនួន ២០ (ម្ភៃ) សន្លឹក។

១៩- ក្របក្រដាសពិសេសសម្រាប់អ្នកបោះឆ្នោតពិការភ្នែកទាំងសងខាងបោះឆ្នោតដោយខ្លួនឯងចំនួន ១ (មួយ)។

២០- ផ្ទាំងក្រដាស សម្រាប់ទ្រាប់គូសសន្លឹកឆ្នោតចំនួន ២ (ពីរ) ផ្ទាំង។

២១- ផ្ទាំងក្រដាសធំ សម្រាប់កត់ត្រាសំឡេងឆ្នោតចំនួន ១ (មួយ) សន្លឹក។

២២- ទម្រង់បែបបទលេខ ១១០១ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត។

២៣- ទម្រង់បែបបទលេខ ១១០២ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

២៤- ទម្រង់បែបបទលេខ ១១០៧ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត។

២៥- ទម្រង់បែបបទលេខ ១១០៨ ចំនួន ៤ (បួន) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោត។

២៦- ទម្រង់បែបបទលេខ ១១១២ ចំនួនបួន (៤) ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតដែល គ.ក.ប បានទទួល។

២៧- ទម្រង់បែបបទលេខ ១១១៥ ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ស្រង់វត្តមានភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលនៃការរាប់សន្លឹកឆ្នោត។

២៨- ទម្រង់បែបបទលេខ ១១២០ ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ស្រង់វត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

២៩- ទម្រង់បែបបទលេខ ១២០២ ចំនួន ២ (ពីរ) ក្បាល ក្នុងមួយក្បាលមានម្ភៃ (២០) ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់។

៣០- ស្បោងប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតដែលមិនទាន់ប្រើ និងគល់សន្លឹកឆ្នោតដែលប្រើហើយ ចំនួន ១ (មួយ)។

៣១- ស្បោងប្លាស្ទិកសម្រាប់ដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការចំនួន ១ (មួយ)។

៣២- កញ្ចប់សុវត្ថិភាព “ក” សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត និងសម្ភារ ឯកសារបោះឆ្នោត ចំនួន ១ (មួយ)។

៣៣- ស្បោង “ខ” សម្រាប់ដាក់កញ្ចប់សុវត្ថិភាព “ក” និងសម្ភារ ឯកសារបោះឆ្នោត ចំនួន ១ (មួយ)។

៣៤- សោឃ្លុំជ័រតូចមានលេខសម្រាប់បិទគម្របខាងក្នុង និងខាងក្រៅនៃហិបឆ្នោត ចំនួន ៣ (បី)។

៣៥- សោឃ្លុំជ័រមធ្យមមានលេខសម្រាប់ឃ្លុំបិទមាត់ស្បោង “ខ” ចំនួន ១ (មួយ)។

បោះពុម្ពដោយ
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ឆ្នាំ២០២៣